# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ឆក្កនិបាត

## ភាគ ៤២

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ឆក្កនិបាត មាន ២ បណ្ណាសកៈ

ចែកជា ១០ វគ្គ និងសុត្រមិនសង្គ្រោះក្នុងវគ្គ រួមមាន ១២៦ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ៩៨ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ឆក្កនិបាត

## ភាគ ៤៦

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ឆក្កនិបាត មាន ២ បណ្ណាសកៈ

ចែកជា ១០ វគ្គ និងសូត្រមិនសង្គ្រោះក្នុងវគ្គ រួមមាន ១២៦ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ៩៨ សូត្រ

# អង្គុត្តរនិកាយ ឆក្កនិបាត

## រួមមាន

២ បណ្ណាសកៈ មាន ១០ វគ្គ និងសូត្រមិនសង្គ្រោះក្នុងបណ្ណាសកៈ
និងសូត្រមិនសង្គ្រោះចូលក្នុងវគ្គ សរុបមាន ១២៦ សូត្រ
ព្រះអដ្ឋកថាកែសេចក្តី ៩៨ សូត្រ

### បឋមបណ្ណាសកៈ

១ អាហុនេយ្យវគ្គ មាន ១០ សូត្រ អដ្ឋកថាកែសេចក្តី ១០ សូត្រ
២ សារាណិយាធិវគ្គ មាន ១០ សូត្រ អដ្ឋកថាកែសេចក្តី ១០ សូត្រ
៣ អនុត្តរិយវគ្គ មាន ១០ សូត្រ អដ្ឋកថាកែសេចក្តី ១០ សូត្រ
៤ សេក្ខបរិ...វគ្គ មាន ១២ សូត្រ អដ្ឋកថាកែសេចក្តី ១២ សូត្រ
៥ ធម្មិកវគ្គ មាន ១២ សូត្រ អដ្ឋកថាកែសេចក្តី ១២ សូត្រ

### ទុតិយបណ្ណាសកៈ

១ មហាវគ្គ មាន ១០ សូត្រ អដ្ឋកថាកែសេចក្តី ១០ សូត្រ
២ ទេវតាវគ្គ មាន ១០ សូត្រ អដ្ឋកថាកែសេចក្តី ០៩ សូត្រ
៣ អរហត្តវគ្គ មាន ១០ សូត្រ អដ្ឋកថាកែសេចក្តី ០៨ សូត្រ
៤ សីតិវគ្គ មាន ១១ សូត្រ អដ្ឋកថាកែសេចក្តី ០៧ សូត្រ
៥ អានិសង្សវគ្គ មាន ១១ សូត្រ អដ្ឋកថាកែសេចក្តី ០៥ សូត្រ

### វគ្គមិនសង្គ្រោះក្នុងបណ្ណាសកៈ

១ តិកវគ្គ មាន ១០ សូត្រ អដ្ឋកថាកែសេចក្តី ០៤ សូត្រ

### សូត្រមិនសង្គ្រោះក្នុងវគ្គ

មាន ១០ សូត្រ អដ្ឋកថាកែសេចក្តីរួម

# ស្រៈនិងសៀ៉យ

## *Signes et accents:*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | ា | ិ | ី | ុ | ូ | េ | ោ | |
| រ៉ូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | า | ิ | ี | ุ | ู | เ | โ | |
| លាវ Laotien | າ | ິ | ີ | ຸ | ູ | ເ | ເາ | |
| សង្ហៈ Cinghalais | ා | ි | ී | ු, ු | ූ, ූ | ෙ | ො | |
| ភូមា Birman | ာ | ိ | ီ | ု | ူ | ေ | ော | |

# ស្រៈពេញតួ

## *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# *Consonnes.*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រ៉ូម<br>Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម<br>Siamois | ก | ข | ค | ฆ | ง |
| លាវ<br>Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា<br>Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា<br>Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | c | ch | j | jh | ñ |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | [illegible] | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | c | ch | j | jh | ñ |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | c | ch | j | jh | ñ |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

## ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី

រីកពាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទុន្នានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមក ហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះ ខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយ ខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្អក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

ក្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡ: សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធ: ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុឋៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡ: និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន
រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់
ព្រះសង្ឃលង្កាទទួលស្ដាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ
ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា
បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន
រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង
ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ
វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ
ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ
ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ
ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ
ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី
សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ
ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ
នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ
នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ
ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់
លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទិអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ឃ្លាត ហ៊ាង ឧបាសក ឆាក់ម៉ៅ

ឧបាសក ឌុំ ធួន ឧបាសក ហុកសីង់ហួត

ឧបាសក ជីម ជំនិត ឧបាសក កើត ធិត្យ

ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម វ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត

ឧបាសក សោម រតនៈ ឧបាសក សំ ឆាយ

ឧបាសក ម៉ៅ ផុន ឧបាសក ជា ស៊ីថាន

ឧបាសិកា ថាប់ លឿម ឧបាសិកា ហាយ សាក់ាត់

ឧបាសិកា ប៊ុត សុម៉ាលី ឧបាសិកា យស សម្បត្តិ

ឧបាសិកា ពូ ហ៊ាង ឧបាសិកា ប៊ុត សេដាដួង

ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ ប៉ូ | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ជុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ធាវ ធាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះស្វៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូនៈ

–ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

–ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**

## ឆក្កនិបាត បឋមបណ្ណាសកៈ

### អាហុនេយ្យវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា បឋមអាហុនេយ្យសូត្រ | ទី ១ | ១ |
| អដ្ឋកថា ទុតិយអាហុនេយ្យសូត្រ | ទី ២ | ៣ |
| អដ្ឋកថា ឥន្ទ្រិយសូត្រ | ទី ៣ | ៤ |
| អដ្ឋកថា ពលសូត្រ | ទី ៤ | ៥ |
| អដ្ឋកថា បឋមអាជានិយសូត្រ | ទី ៥ | ៦ |
| អដ្ឋកថា ទុតិយអាជានិយសូត្រ | ទី ៦ | ៧ |
| អដ្ឋកថា តតិយអាជានិយសូត្រ | ទី ៧ | ៨ |
| អដ្ឋកថា អនុត្តរិយសូត្រ | ទី ៨ | ៩ |
| អដ្ឋកថា អនុស្សតិសូត្រ | ទី ៩ | ១១ |
| អដ្ឋកថា មហានាមសូត្រ | ទី ១០ | ១២ |


### សារាណីយវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា បឋមសារាណិយសូត្រ | ទី ១ | ១៦ |
| អដ្ឋកថា ទុតិយសារាណិយសូត្រ | ទី ២ | ៣៥ |
| អដ្ឋកថា មេត្តាសូត្រ | ទី ៣ | ៣៦ |
| អដ្ឋកថា ភទ្ទកសូត្រ | ទី ៤ | ៤០ |
| អដ្ឋកថា អនុតប្បិយសូត្រ | ទី ៥ | ៤៣ |
| អដ្ឋកថា នកុលសូត្រ | ទី ៦ | ៤៤ |
| អដ្ឋកថា កុសលសូត្រ | ទី ៧ | ៤៨ |
| អដ្ឋកថា មច្ឆសូត្រ | ទី ៨ | ៥០ |
| អដ្ឋកថា បឋមមរណស្សតិសូត្រ | ទី ៩ | ៥២ |
| អដ្ឋកថា ទុតិយមរណស្សតិសូត្រ | ទី ១០ | ៥៤ |

**អនុត្តរិយវគ្គ ទី ៣**

| | | |
|---|---|---|
| អដ្ឋកថា សាមកសូត្រ | ទី ១ | ៥៦ |
| អដ្ឋកថា អបរិហានិយសូត្រ | ទី ២ | ៥៨ |
| អដ្ឋកថា ភយសូត្រ | ទី ៣ | ៥៩ |
| អដ្ឋកថា ហិមវន្តសូត្រ | ទី ៤ | ៦២ |
| អដ្ឋកថា អនុស្សតិដ្ឋានសូត្រ | ទី ៥ | ៦៤ |
| អដ្ឋកថា កច្ចានសូត្រ | ទី ៦ | ៦៥ |
| អដ្ឋកថា បឋមសមយសូត្រ | ទី ៧ | ៦៨ |
| អដ្ឋកថា ទុតិយសមយសូត្រ | ទី ៨ | ៧០ |
| អដ្ឋកថា ឧទាយិសូត្រ | ទី ៩ | ៧២ |
| អដ្ឋកថា អនុត្តរិយសូត្រ | ទី ១០ | ៧៩ |

**សេក្ខបរិហានិយវគ្គ ទី ៤**

| | | |
|---|---|---|
| អដ្ឋកថា សេក្ខសូត្រ | ទី ១ | ៨៣ |
| អដ្ឋកថា បឋមអបរិហានិយសូត្រ | ទី ២ | ៨៤ |
| អដ្ឋកថា ទុតិយ.....សូត្រ | ទី ៣ | ៨៦ |
| អដ្ឋកថា មោគ្គល្លានសូត្រ | ទី ៤ | ៨៧ |
| អដ្ឋកថា វិជ្ជាភាគិយសូត្រ | ទី ៥ | ៨៩ |
| អដ្ឋកថា វិវាទមូលសូត្រ | ទី ៦ | ៩០ |
| អដ្ឋកថា ទានសូត្រ | ទី ៧ | ៩៤ |
| អដ្ឋកថា អត្តការីសូត្រ | ទី ៨ | ៩៧ |
| អដ្ឋកថា និទានសូត្រ | ទី ៩ | ៩៩ |
| អដ្ឋកថា កិមិលសូត្រ | ទី ១០ | ១០០ |
| អដ្ឋកថា ទារុក្ខន្ធសូត្រ | ទី ១១ | ១០១ |
| អដ្ឋកថា នាគិតសូត្រ | ទី ១២ | ១០៣ |

**ធម្មិកវគ្គ ទី ៥**

| | | |
|---|---|---|
| អដ្ឋកថា នាគសូត្រ | ទី ១ | ១០៥ |
| អដ្ឋកថា មិគសាលាសូត្រ | ទី ២ | ១១៩ |
| អដ្ឋកថា ឥណសូត្រ | ទី ៣ | ១២៥ |

| | | |
|---|---|---|
| អដ្ឋកថា មហាចុន្ទសូត្រ | ទី ៤ | ១៣២ |
| អដ្ឋកថា បឋមសន្ទិដ្ឋិកសូត្រ | ទី ៥ | ១៣៥ |
| អដ្ឋកថា ទុតិយសន្ទិដ្ឋិកសូត្រ | ទី ៦ | ១៣៦ |
| អដ្ឋកថា ខេមសុមនសូត្រ | ទី ៧ | ១៣៧ |
| អដ្ឋកថា ឥន្ទ្រិយសំវរសូត្រ | ទី ៨ | ១៤១ |
| អដ្ឋកថា អានន្ទសូត្រ | ទី ៩ | ១៤២ |
| អដ្ឋកថា ខត្តិយសូត្រ | ទី ១០ | ១៤៥ |
| អដ្ឋកថា អប្បមាទសូត្រ | ទី ១១ | ១៤៩ |
| អដ្ឋកថា ធម្មិកសូត្រ | ទី ១២ | ១៥១ |


## ទុតិយបណ្ណាសកៈ

### មហាវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា សោណសូត្រ | ទី ១ | ១៥៩ |
| អដ្ឋកថា ផគ្គុណសូត្រ | ទី ២ | ១៧១ |
| អដ្ឋកថា ឆឡាភិជាតិសូត្រ | ទី ៣ | ១៧២ |
| អដ្ឋកថា អាសវសូត្រ | ទី ៤ | ១៧៤ |
| អដ្ឋកថា ទារុកម្មិកសូត្រ | ទី ៥ | ១៨៨ |
| អដ្ឋកថា ចិត្តហត្ថិសារីបុត្តសូត្រ | ទី ៦ | ១៩០ |
| អដ្ឋកថា ឆាឡាយនសូត្រ | ទី ៧ | ១៩៤ |
| អដ្ឋកថា ឧទកសូត្រ | ទី ៨ | ២០០ |
| អដ្ឋកថា និព្វេធិកសូត្រ | ទី ៩ | ២០៤ |
| អដ្ឋកថា ពលសូត្រ | ទី ១០ | ២១០ |


### ទេវតាវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា អនាគាមិសូត្រ | ទី ១ | ២១៤ |
| អដ្ឋកថា អរហត្តសូត្រ | ទី ២ | ២១៥ |
| អដ្ឋកថា មិត្តសូត្រ | ទី ៣ | ២១៦ |
| អដ្ឋកថា ឋានសូត្រ | ទី ៤ | ២១៧ |

| | | |
|---|---|---|
| អដ្ឋកថា ទេវតាសូត្រ | ទី ៥ | ២១៨ |
| អដ្ឋកថា សតិសូត្រ | ទី ៦ | ២១៩ |
| អដ្ឋកថា សក្ខិសូត្រ | ទី ៧ | ២២០ |
| អដ្ឋកថា ពលសូត្រ | ទី ៨ | ២២១ |
| អដ្ឋកថា បឋមឈានសូត្រ | ទី ៩ | ២២២ |
| អដ្ឋកថា ទុតិយឈានសូត្រ | ទី ១០ មិនមានអដ្ឋកថា | ២២៣ |

**អរហត្តវគ្គ ទី ៣**

| | | |
|---|---|---|
| អដ្ឋកថា ទុក្ខសូត្រ | ទី ១ | ២២៤ |
| អដ្ឋកថា អរហត្តសូត្រ | ទី ២ | ២២៥ |
| អដ្ឋកថា ឧត្តរិមនុស្សធម្មសូត្រ | ទី ៣ | ២២៦ |
| អដ្ឋកថា សុខសូត្រ | ទី ៤ | ២២៧ |
| អដ្ឋកថា អធិគមសូត្រ | ទី ៥ | ២២៩ |
| អដ្ឋកថា មហត្តសូត្រ | ទី ៦ | ២៣០ |
| អដ្ឋកថា បឋមនិរយសូត្រ | ទី ៧ មិនមានអដ្ឋកថា | ២៣១ |
| អដ្ឋកថា ទុតិយនិរយសូត្រ | ទី ៨ | ២៣២ |
| អដ្ឋកថា អគ្គធម្មសូត្រ | ទី ៩ មិនមានអដ្ឋកថា | ២៣៣ |
| អដ្ឋកថា រត្តិសូត្រ | ទី ១០ | ២៣៤ |

**សីតិវគ្គ ទី ៤**

| | | |
|---|---|---|
| អដ្ឋកថា សីតិសូត្រ | ទី ១ | ២៣៥ |
| អដ្ឋកថា ភព្វសូត្រ | ទី ២ | ២៣៦ |
| អដ្ឋកថា អាវរណាតាសូត្រ | ទី ៣ មិនមានអដ្ឋកថា | ២៣៧ |
| អដ្ឋកថា សុស្សូសាសូត្រ | ទី ៤ | ២៣៨ |
| អដ្ឋកថា បហាតព្វសូត្រ | ទី ៥ | ២៣៩ |
| អដ្ឋកថា បហីនសូត្រ | ទី ៦ មិនមានអដ្ឋកថា | ២៤០ |
| អដ្ឋកថា ឧប្បាទេតព្វសូត្រ | ទី ៧ មិនមានអដ្ឋកថា | ២៤១ |
| អដ្ឋកថា សត្ថិរសូត្រ | ទី ៨ | ២៤២ |
| អដ្ឋកថា កិញ្ចិសង្ខារសូត្រ | ទី ៩ | ២៤៣ |

អដ្ឋកថា មាតរិសូត្រ ទី ១០ មិនមានអដ្ឋកថា ២៤៤

អដ្ឋកថា សយន្តកសូត្រ ទី ១១ ២៤៥

**អានិសង្សវគ្គ ទី ៥**

អដ្ឋកថា ចាតុភាវសូត្រ ទី ១ ២៤៦

អដ្ឋកថា អានិសង្សសូត្រ ទី ២ ២៤៧

អដ្ឋកថា អនិច្ចសូត្រ ទី ៣ មិនមានអដ្ឋកថា ២៤៨

អដ្ឋកថា ទុក្ខសូត្រ ទី ៤ មិនមានអដ្ឋកថា ២៤៩

អដ្ឋកថា អនត្តសូត្រ ទី ៥ មិនមានអដ្ឋកថា ២៥០

អដ្ឋកថា និព្វានសូត្រ ទី ៦ មិនមានអដ្ឋកថា ២៥១

អដ្ឋកថា បឋមអនោធិសសូត្រ ទី ៧ ២៥២

អដ្ឋកថា ទុតិយអនោធិសសូត្រ ទី ៨ ២៥៣

អដ្ឋកថា តតិយអនោធិសសូត្រ ទី ៩ ២៥៤

អដ្ឋកថា ភវសូត្រ ទី ១០ មិនមានអដ្ឋកថា ២៥៥

អដ្ឋកថា តណ្ហាសូត្រ ទី ១១ មិនមានអដ្ឋកថា ២៥៦


## វគ្គមិនរួមចូលក្នុងបណ្ណាសកៈ


**តិកវគ្គ ទី ១**

អដ្ឋកថា រាគសូត្រ ទី ១ ២៥៧

អដ្ឋកថា ទុច្ចរិតសូត្រ ទី ២ មិនមានអដ្ឋកថា ២៥៨

អដ្ឋកថា វិតក្កសូត្រ ទី ៣ មិនមានអដ្ឋកថា ២៥៩

អដ្ឋកថា សញ្ញាសូត្រ ទី ៤ មិនមានអដ្ឋកថា ២៦០

អដ្ឋកថា ធាតុសូត្រ ទី ៥ មិនមានអដ្ឋកថា ២៦១

អដ្ឋកថា អស្សាទសូត្រ ទី ៦ ២៦២

អដ្ឋកថា អរតិសូត្រ ទី ៧ ២៦៣

អដ្ឋកថា តុដ្ឋិសូត្រ ទី ៨ មិនមានអដ្ឋកថា ២៦៤

អដ្ឋកថា សោវចស្សតាសូត្រ ទី ៩ មិនមានអដ្ឋកថា ២៦៥

អដ្ឋកថា ឧទ្ទុម្ពុរិកសូត្រ ទី ១០ ២៦៦

# ព្រះសូត្រមិនរាប់ចូលក្នុងវគ្គ

ព្រះអដ្ឋកថា កែសេចក្ដីរួម ២៦៧

# អង្គុត្តរនិកាយ ឆក្កនិបាត

# បឋមបណ្ណាសកៈ

# អាហុនេយ្យវគ្គវណ្ណនាទី ១

## អដ្ឋកថា បឋមអាហុនេយ្យសូត្រទី ១

*"គុណធម៌របស់ភិក្ខុដែលគួរដល់ការទទួល"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាហុនេយ្យសូត្រទី ១ ដូចតទៅនេះ ៖*

[១] *បទថា ឥធ ភិក្ខវេ ភិក្ខុ (ភិក្ខុក្នុងធម្មវិន័យនេះ) បានដល់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ។ បទថា នេវ សុមនោ ហោតិ ន ទុម្មនោ (មិនត្រេតអរ) សេចក្ដីថា រមែងជាអ្នកមិនត្រេកអរព្រោះឥដ្ឋា-រម្មណ៍ ដោយសោមនស្សដែលសហគតដោយរាគៈ ឬរមែងជាអ្នកមិនទាស់ចិត្តព្រោះអនិដ្ឋារម្មណ៍ ដោយទោមនស្សដែលសហគតដោយទោសៈ ។ បទថា ឧបេក្ខកោ វិហរតិ សតោ សម្បជានោ (មានឧបេក្ខា មានសតិ-សម្បជញ្ញៈ) សេចក្ដីថា មិនដល់ភាពជាអ្នកព្រងើយដោយឧបេក្ខា ដែលមិន*

មានញាណ ព្រោះមិនពិចារណាក្នុងមជ្ឈត្តារម្មណ៍ ជាអ្នកមានសតិសម្ប-ជញ្ញៈ មានចិត្តជាកណ្តាលក្នុងអារម្មណ៍ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ធម៌ជាគ្រឿងនៅជាប្រចាំរបស់ព្រះខីណាស្រពទុកហើយ ។

ចប់អដ្ឋកថា បឋមអាហុនេយ្យសូត្រទី ១

# អដ្ឋកថា ទុតិយអាហុនេយ្យសូត្រទី ២

## *“គុណធម៌របស់ភិក្ខុដែលគួរដល់ការទទួល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអាហុនេយ្យសូត្រទី ២ ដូចតទៅនេះ ៖*

[២] *បទថា* ***អនេកវិហិតំ ឥទ្ធិវិធំ*** *(សម្ដែងឫទ្ធិបានច្រើនប្រការ) ខ្ញុំពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា* ***អាសវានំ ខយា អនាសវំ*** *(ដែលរកអាសវៈមិនបាន ព្រោះអាសវៈទាំងឡាយអស់ទៅ) សេចក្ដីថា ឈ្មោះថា រកអាសវៈមិនបាន ព្រោះអាសវៈទាំងឡាយអស់ទៅ មិនមែនព្រោះដូចការមិនមាននៃចក្ខុវិញ្ញាណជាដើម ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ អភិញ្ញារបស់ព្រះខីណាស្រពតាមលំដាប់ ។*

ចប់អដ្ឋកថា ទុតិយអាហុនេយ្យសូត្រទី ២

# អដ្ឋកថា ឥន្ទ្រិយសូត្រទី ៣

*(ឥន្ទ្រិយជាហេតុឲ្យភិក្ខុជាស្រែបុណ្យ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥន្ទ្រិយសូត្រទី ៣ ដូចតទៅនេះ ៖*

[៣] *ព្រះមានព្រះភាគ ត្រាស់ចំពោះព្រះខីណាស្រពតែម្យ៉ាង ។*

ចប់អដ្ឋកថា ឥន្ទ្រិយសូត្រទី ៣

# អដ្ឋកថា ពលសូត្រទី ៤

*(កម្លាំងជាហេតុឲ្យភិក្ខុជាស្រែបុណ្យ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពលសូត្រទី ៤ ដូចតទៅនេះ ៖*

[៤] *ព្រះមានព្រះភាគ ត្រាស់ចំពោះព្រះទីណាស្រេពតែម្យ៉ាង ។*

ចប់អដ្ឋកថា ពលសូត្រទី៣

# អដ្ឋកថា បឋមអាជានិយសូត្រទី ៥

*(អង្គរបស់សេះអាជានេយ្យ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអាជានិយសូត្រទី ៥ ដូចតទៅនេះ ៖*

[៥] *បទថា* ***អង្គេហិ*** *(ដោយអង្គ) បានដល់ ដោយអង្គនៃគុណទាំងឡាយ ។ បទថា* ***ខមោ*** *(អត់ធន់) បានដល់ អត់ទ្រាំ ។ បទថា* ***រូបានំ*** *(ចំពោះរូប) បានដល់ ចំពោះរូបារម្មណ៍ទាំងឡាយ ។ បទថា* ***វណ្ណសម្បន្នោ*** *(បរិបូណ៌ដោយសម្បុរ) បានដល់ សម្បូរដោយវណ្ណៈនៃសរីរៈ ។*

ចប់អដ្ឋកថា បឋមអាជានិយសូត្រទី ៥

# អដ្ឋកថា ទុតិយអាជានិយសូត្រទី ៦

*(អង្គរបស់សេះអាជានេយ្យ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអាជានិយសូត្រទី ៦ ដូចតទៅនេះ ៖*

[៦] *បទថា ពលសម្បន្នោ (បរិបូណ៌ដោយកម្លាំង) បានដល់ ដល់ព្រមដោយកម្លាំងកាយ ។*

ចប់អដ្ឋកថា ទុតិយអាជានិយសូត្រទី ៦

# អដ្ឋកថា តតិយអាជានិយសូត្រទី ៧

*(អត្ថរបស់សេះអាជានេយ្យ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយអាជានិយសូត្រទី ៧ ដូចតទៅនេះ ៖*

[៧] *បទថា ជវសម្បន្នោ (បរិបូណ៌ដោយសន្ទុះ) បានដល់ បរិបូណ៌ដោយសន្ទុះជើង ។*

ចប់អដ្ឋកថា តតិយអាជានិយសូត្រទី ៧

# អដ្ឋកថា អនុត្តរិយសូត្រទី ៨

## *(ធម្មជាតដ៏ប្រសើរ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុត្តរិយសូត្រទី ៨ ដូចតទៅនេះ ៖*

*[៨] បទថា **អនុត្តរិយានិ (ធម្មជាតិប្រសើរ)** បានដល់ (ការឃើញជាដើម) វៀរចាកវត្ថុដទៃដែលក្រៃលែងជាង បានដល់ ប្រាសចាកវត្ថុដទៃដែលក្រៃលែងជាង ។ បទថា **ទស្សនានុត្តរិយំ (ការឃើញដ៏ប្រសើរ)** បានដល់ (ការឃើញព្រះពុទ្ធជាដើម) ជាការឃើញដ៏ប្រសើរក្រៃលែងជាងក្នុងការឃើញរូបទាំងឡាយ ។ ក្នុងបទទាំងពួង ក៏មានន័យនេះដូចគ្នា ។ អធិប្បាយថា ការឃើញដំរី សេះជាដើម មិនឈ្មោះថាជាទស្សនានុត្តរិយៈ ចំណែកការឃើញព្រះទសពលក្តី ភិក្ខុសង្ឃក្តី ដោយអំណាចសេចក្តីស្រឡាញ់យ៉ាងជូន់ ការឃើញនិមិត្តណាមួយ ក្នុងបណ្តាកសិណ និងអសុភនិមិត្តជាដើមក្តី របស់អ្នកមានសទ្ធាតាំងមាំហើយ ឈ្មោះថា **ទស្សនានុត្តរិយៈ** ។ ការស្តាប់គុណកថារបស់ក្សត្រិយ៍ជាដើមក្តី មិនឈ្មោះថា សវនានុត្តរិយៈ ចំណែកការស្តាប់គុណរបស់ព្រះរតនត្រ័យ ដោយអំណាចសេចក្តីស្រឡាញ់*

ដ៏ខ្ជាំងក្តី ការស្តាប់គុណរបស់ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដកក្តី របស់អ្នកមានសទ្ធាតាំងមាំហើយ ឈ្មោះថា **សវនានុត្តរិយៈ** ។ ការបានកែវមណីជាដើម មិនមែនជាលាភានុត្តរិយៈ ចំណែកការបានអរិយទ្រព្យ ៧ ឈ្មោះថា **លាភានុត្តរិយៈ** ។ ការសិក្សាសិល្បៈទាក់ទងជាមួយដំរីជាដើម មិនឈ្មោះថា សិក្ខានុត្តរិយៈ ចំណែកការបំពេញសិក្ខា ៣ ឈ្មោះថា **សិក្ខា-នុត្តរិយៈ** ។ ការបម្រើក្សត្រីយ៍ជាដើម មិនឈ្មោះថា បារិចរិយានុត្តរិយៈ ចំណែកការទំនុកបម្រុងព្រះរតនត្រ័យ ឈ្មោះថា **បារិចរិយានុត្តរិយៈ** ។ ការរលឹកដល់គុណរបស់ព្រះមហាក្សត្រីយ៍ជាដើម មិនឈ្មោះថា អនុស្ស-តានុត្តរិយៈ ចំណែកការរលឹកដល់គុណរបស់ព្រះរតនត្រ័យ ទើបឈ្មោះថា **អនុស្សតានុត្តរិយៈ** ។

អនុត្តរិយៈទាំង ៦ នេះ ព្រះមានព្រះភាគត្រាស់ទុកទាំងជាលោកិយៈនិងលោកុត្តរៈ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា អនុត្តរិយសូត្រទី ៨

# អដ្ឋកថា អនុស្សតិសូត្រទី ៩

## (អនុស្សតិ ៦)

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុស្សតិសូត្រទី ៩ ដូចតទៅនេះ ៖*

[៩] *បទថា* ពុទ្ធានុស្សតិ *(ពុទ្ធានុស្សតិ) បានដល់ អនុស្សតិមានព្រះពុទ្ធគុណជាអារម្មណ៍ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា អនុស្សតិសូត្រទី ៩

# អដ្ឋកថា មហានាមសូត្រទី ១០

## (អនុស្សតិ ៦ ត្រាស់ដល់ស្តេចមហានាម)

គប្បីជ្រាបវិនិច្ឆ័យក្នុង មហានាមសូត្រទី ១០ ដូចតទៅនេះ ៖

[១០] បទថា **មហានាមោ (មហានាម)** បានដល់ ជាឈ្មោះនៃព្រះរាជាមួយអង្គ ដែលជាព្រះរាជឱរសរបស់ព្រះរាជា ឱពុកមារបស់ព្រះទសពល ។ បទថា **យេន ភគវា តេនុបសង្កមិ (ស្តេចបានចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់)** បានដល់ ស្តេចសោយព្រះក្រយាហារពេលព្រឹកស្រេចហើយ ហែហមទៅដោយទាសៈ និងបរិវារជន ឲ្យមនុស្សកាន់គ្រឿងក្រអូប និងផ្កាកម្រងជាដើម ហើយស្តេចយាងទៅក្នុងទីដែលព្រះសាស្តាទ្រង់ប្រថាប់ ។ (ព្រះអរិយៈសាវក) ឈ្មោះថា **អាគតផលោ (អ្នកបានសម្រេចផល)** ព្រោះមានអរិយផលមកដល់ហើយ ។ បទថា **វិញ្ញាតសាសនោ (ដឹងច្បាស់នូវព្រះសាសនាហើយ)** ព្រោះពាក្យទូន្មាន គឺ សិក្ខា ៣ ដែលលោកដឹងច្បាស់ហើយ ។ ព្រះរាជាអង្គនេះ កាលនឹងទូលសួរថា ខ្ញុំព្រះអង្គទូលសួរដល់វិហារធម៌ ដែលជាទីអាស្រ័យរបស់ព្រះសោតាបន្ន ទើប

ក្រាបទូលយ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា **នេវស្ស រាគបរិយុដ្ឋិតំ (រមែងមិនត្រូវរាគៈរួបរិតចិត្ត)** បានដល់ មិនត្រូវរាគៈដែលកើតឡើង ផ្សាយឡើងហើយចាប់ទុក ។ បទថា **ឧជុគតំ (ប្រព្រឹត្តត្រង់)** បានដល់ ដំណើរត្រង់ទៅក្នុងពុទ្ធានុស្សតិកម្មដ្ឋាននោះឯង ។ បទថា **តថាគតំ អារព្ភ (ព្រោះប្រារព្ធនូវគុណព្រះតថាគត)** បានដល់ ប្រារព្ធព្រះគុណរបស់ព្រះតថាគត ។ បទថា **អត្ថវេទំ (ដឹងអត្ថ)** បានដល់ បីតិបាមោជ្ជៈដែលអាស្រ័យអដ្ឋកថាកើតឡើង ។ បទថា **ធម្មវេទំ (ដឹងធម៌)** បានដល់ បីតិបាមោជ្ជៈដែលអាស្រ័យព្រះបាលីកើតឡើង ។ បទថា **ធម្មូបសញ្ហិតំ (ប្រកបដោយធម៌)** បានដល់ ដែលអាស្រ័យទាំងបាលី និងអដ្ឋកថាកើតឡើង ។

បទថា **បមុទិតស្ស (កាលបើមានសេចក្ដីរីករាយហើយ)** បានដល់ បាមោជ្ជៈហើយ ដោយសេចក្ដីបាមោជ្ជៈ ២ យ៉ាង ។ បទថា **បីតិ ជាយតិ (បីតិក៏កើតឡើង)** បានដល់ បីតិ ៥ យ៉ាង រមែងកើតឡើង ។ បទថា **កាយោ បស្សម្ភតិ (កាយរមែងស្ងប់)** បានដល់ ទាំងនាមកាយ ទាំងករជ-កាយ រមែងស្ងប់រម្ងាប់ ដោយធម៌ជាគ្រឿងស្ងប់រម្ងាប់នូវសេចក្ដីខ្វល់ខ្វាយ ។

បទថា *សុខំ* (សុខ) បានដល់ សុខផ្លូវកាយ និងសុខផ្លូវចិត្ត ។ បទថា *សមាធិយតិ* (រមែងតាំងមាំ) បានដល់ រមែងតាំងមាំដោយល្អក្នុងអារម្មណ៍ ។ បទថា *វិសមគតាយ បជាយ* (ក្នុងកាលពពួកសត្វមិនស្ងប់) បានដល់ ក្នុងកាលដែលសត្វទាំងឡាយដល់នូវសេចក្ដីមិនស្ងប់ ព្រោះរាគៈ ទោសៈ មោហៈ ។ បទថា *សមប្បត្តោ* (ជាអ្នកដល់ការស្ងប់រម្ងាប់) បានដល់ ជាអ្នកដល់នូវសេចក្ដីស្ងប់រម្ងាប់ គឺ រៀបរយ ។ បទថា *សព្យាបជ្ឈាយ* (នៅមានព្យាបាទ) បានដល់ នូវមានទុក្ខ ។ បទថា *ធម្មសោតំ សមាបន្នោ* (ជាអ្នកចូលដល់ក្រសែធម៌) បានដល់ ជាអ្នកចូលដល់ក្រសែធម៌ ពោលគឺ វិបស្សនា ។ បទថា *ពុទ្ធានុស្សតិំ ភាវេតិ* (រមែងចម្រើនពុទ្ធានុស្សតិ) បានដល់ រមែងចម្រើន គឺ ចម្រើនពុទ្ធានុស្សតិកម្មដ្ឋាន ។ ក្នុងបទទាំងពួងគប្បីជ្រាបដោយន័យនេះ ។ ស្ដេចសក្យមហានាម ទូលសួរដល់វិហារធម៌ដែលជាទីអាស្រ័យរបស់ព្រះសោតាបន្ន ដោយប្រការដូច្នេះ ។ សូម្បីព្រះសាស្ដា ក៏ត្រាស់វិហារធម៌ ដែលជាទីអាស្រ័យរបស់ព្រះសោតាបន្នទុំះឯងដល់ស្ដេចមហានាម ។ ដោយប្រការនេះ ក្នុងសូត្រនេះ ព្រះមានព្រះភាគ

*ត្រាស់ដល់ព្រះសោតាបន្នតែម្យ៉ាងប៉ុណ្ណោះ ។*

ចប់អដ្ឋកថា មហានាមសូត្រទី ១០

## ចប់អាហុណេយ្យវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# សារាណិយវគ្គវណ្ណនាទី ២

## អដ្ឋកថា បឋមសារាណិយសូត្រទី ១

*(ធម៌ជាហេតុឲ្យរឭកដល់គ្នា)*

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសារាណីយសូត្រទី ១ ដូចតទៅនេះ ៖

[១១] បទថា *សារាណីយា (ជាហេតុឲ្យរឭកដល់គ្នា)* បានដល់ ដែលជាទីឲ្យរឭកដល់គ្នា ។ បទថា **មេត្តំ កាយកម្មំ** *(កាយកម្មប្រកបដោយមេត្តា)* បានដល់ កាយកម្មដែលគប្បីធ្វើដោយចិត្ត ប្រកបដោយមេត្តា ។ សូម្បីក្នុងវចីកម្ម និងមនោកម្ម ក៏មានន័យនេះដូចគ្នា ។

ឯមេត្តាកាយកម្មជាដើមទាំងនេះ ត្រាស់ទុកព្រោះសំដៅដល់ភិក្ខុទាំងឡាយ សូម្បីគ្រហស្ថទាំងឡាយក៏នាំទៅប្រើបាន ។ អធិប្បាយថា ចំពោះភិក្ខុទាំងឡាយ ការបំពេញធម៌ គឺ អភិសមាចារិកវត្ត ដោយមេត្តាចិត្ត ឈ្មោះថា កាយកម្មប្រកបដោយមេត្តា ចំណែកគ្រហស្ថទាំងឡាយ កម្មមានជាអាទិ៍យ៉ាងនេះថា ការដើរផ្លូវទៅដើម្បីសំពះព្រះចេតិយ៍ សំពះព្រះ-ពោធិព្រឹក្ស និមន្តព្រះសង្ឃ ការឃើញភិក្ខុទាំងឡាយដែលចូលទៅកាន់ស្រុក

ដើម្បីបិណ្ឌបាតហើយ ក្រោកឡើងទទួលរាក់ទាក់ ការទទួលបាត្រ ការក្រាលអាសនៈ និងការតាមបម្រើ ឈ្មោះថា កាយកម្មប្រកបដោយមេត្តា ។

ចំណែកភិក្ខុទាំងឡាយ ការធ្វើតាមអាចារបញ្ញត្តិ ការប្រាប់កម្មដ្ឋាន ការសម្ដែងធម៌ ការប្រាប់ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ដោយមេត្តាចិត្ត ឈ្មោះថា វចីកម្មប្រកបដោយមេត្តា ។ ចំពោះគ្រហស្ថទាំងឡាយ ក្នុងវេលាដែលពោលពាក្យជាដើមថា ពួកយើងនឹងទៅដើម្បីសំពះព្រះចេតិយ៍ ពួកយើងនឹងទៅដើម្បីសំពះព្រះពោធិព្រឹក្ស ពួកយើងនឹងធ្វើការស្ដាប់ធម៌ ពួកយើងនឹងធ្វើការបូជាប្រទីប ផ្កាកម្រង និងផ្កាឈើ ពួកយើងនឹងសមាទានប្រព្រឹត្តសុចរិត ៣ ពួកយើងនឹងថ្វាយសលាកភត្តជាដើម ពួកយើងនឹងថ្វាយសំពត់ចំណាំវស្សា ថ្ងៃនេះពួកយើងនឹងថ្វាយបច្ច័យ ៤ ដល់ព្រះសង្ឃ ពួកលោកចូរនិមន្តព្រះសង្ឃ ហើយចាត់ចែងរបស់ដែលគួរទាន់ជាដើម ពួកលោកចូរក្រាលអាសនៈ ពួកលោកចូរតាំងទឹកសម្រាប់ផឹក ពួកលោកចូរទទួលព្រះសង្ឃហើយនាំមក ពួកលោកចូរនិមន្តព្រះសង្ឃគង់លើអាសនៈដែលក្រាលហើយ ចូរកើតឧស្សាហៈ ធ្វើវេយ្យាវច្ចកិច្ចចុះ ឈ្មោះថា វចីកម្ម

ប្រកបដោយមេត្តា ។

សម្រាប់ភិក្ខុទាំងឡាយ ការក្រោកពីព្រឹកព្រលឹម ធ្វើការជម្រះកាយ និងធ្វើវត្តត្រង់ទីលានព្រះចេតិយជាដើម ហើយអង្គុយលើអាសនៈដ៏ស្ងាត់ គិតថា ភិក្ខុទាំងឡាយក្នុងវិហារនេះ ចូរមានសេចក្ដីសុខ កុំមានទុក្ខ ឈ្មោះថា មនោកម្មប្រកបដោយមេត្តា ។ ឯគ្រហស្ថទាំងឡាយ ការគិតថា សូមលោកម្ចាស់ទាំងឡាយ ចូរនៅជាសុខ កុំមានពៀរ កុំមានទុក្ខ ឈ្មោះថា មនោកម្មប្រកបដោយមេត្តា ។

បទថា **អាវិ ចេវ រហោ ច** (**ទាំងទីចំពោះមុខទាំងទីកំបាំងមុខ**) បានដល់ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ ។ ក្នុងពីរបទនោះ ការដល់ភាពជាមិត្ត (ការជួយគ្នាទៅវិញទៅមក) ក្នុងកម្មទាំងឡាយ មានវចីកម្មជាដើម របស់ភិក្ខុថ្មីជាដើម ឈ្មោះថា កាយកម្មប្រកបដោយមេត្តាក្នុងទីចំពោះមុខ ។ ចំណែកសាមីចិកម្មគ្រប់យ៉ាង សូម្បីការថ្វាយទឹកលាងជើងដល់ព្រះថេរៈជាដើម ឈ្មោះថា កាយកម្មប្រកបដោយមេត្តាក្នុងទីចំពោះមុខ ។ ការថែរក្សារបស់របរវត្ថុទាំងឡាយ មានឧសជាដើម ដែលភិក្ខុថ្មី

និងព្រះថេរៈទាំងឡាយទាំងពីរចំណែក រក្សាទុកមិនរៀបរយ ដូចថែរក្សារបស់របរដែលខ្លួនរក្សាទុក ឲ្យរៀបរយ ដោយមិនតិះដៀលជនទាំងនោះ ឈ្មោះថា កាយកម្មប្រកបដោយមេត្តាក្នុងទីកំបាំងមុខ ។ ការពោលលើកសរសើរយ៉ាងនេះថា លោកម្ចាស់ទេវត្ថេរៈ លោកម្ចាស់តិស្សត្ថេរៈ ឈ្មោះថា វចីកម្មប្រកបដោយមេត្តាក្នុងទីចំពោះមុខ ។ ក៏កាលសាកសួរដល់ព្រះថេរៈអ្នកមិននៅក្នុងវិហារ ការពោលពាក្យគួរស្រលាញ់យ៉ាងនេះថា លោកម្ចាស់ទេវត្ថេររបស់ពួកយើងទៅណា លោកម្ចាស់តិស្សត្ថេររបស់ពួកយើងទៅណា កាលណានឹងមកវិញហ្ន៎ ។ ឈ្មោះថា វចីកម្មប្រកបដោយមេត្តាក្នុងទីកំបាំងមុខ ។ ចំណែកការបើកភ្នែកដោយសេចក្ដីស្រឡាញ់ សម្លឹងមើលដោយទឹកមុខស្រស់ថ្លា ឈ្មោះថា មនោកម្មប្រកបដោយមេត្តាក្នុងទីចំពោះមុខ ។ ការបំណងល្អក្ដី (មានចិត្តជួយ) ថា សូមលោកម្ចាស់ទេវត្ថេរ សូមលោកម្ចាស់តិស្សត្ថេរ ចូរកុំមានរោគ កុំមានអាពាធ ឈ្មោះថា មនោកម្មប្រកបដោយមេត្តាក្នុងទីកំបាំងមុខ ។

បទថា លាភា (លាភ) បានដល់ បច្ច័យដែលបានមក មានចីវរ

ជាដើម ។ បទថា **ធម្មិកា (ប្រកបដោយធម៌)** បានដល់ ដែលកើតឡើង ដោយភិក្ខាចរិយវត្ត ដោយធម៌ដ៏ប្រពៃ វៀរមិច្ឆាអាជីវៈ មានដោយកុហក (បោកបញ្ឆោត) ជាដើម ។ បទថា **អន្តមសោ បត្តបរិយាបន្នមត្តម្បិ (សូម្បីដោយទីបំផុតត្រឹមបិណ្ឌបាត្រ)** បានដល់ ដោយហោចសូម្បីត្រឹមតែភិក្ខា ២-៣ វែក ដែលជាប់ក្នុងបាត្រ គឺ នៅជាប់ក្នុងបាត្រ ។

បទថា **អប្បដិវិភត្តភោគី (បរិភោគដោយមិនបែងចែក)** នេះ ការបែងចែកមាន ២ យ៉ាង គឺ ការបែងចែកដោយអាមិស ១ ការបែងចែកដោយបុគ្គល ១ ។ ក្នុងពីរយ៉ាងនោះ ការបែងចែកដោយគិតយ៉ាងនេះថា យើងនឹងឲ្យប៉ុណ្ណេះ មិនឲ្យប៉ុណ្ណេះ ឈ្មោះថា **បែងចែកដោយអាមិស** ។ ការបែងចែក ដោយគិតយ៉ាងនេះថា យើងនឹងឲ្យដល់ភិក្ខុរូបនោះ មិនឲ្យដល់ភិក្ខុរូបនោះ ឈ្មោះថា **បែងចែកបុគ្គល** ។ ភិក្ខុមិនធ្វើការបែងចែកទាំងពីរយ៉ាងនោះ បរិភោគដោយមិនបែងចែក ឈ្មោះថា **បរិភោគដោយមិនបានបែងចែក** ។

លក្ខណៈរបស់អ្នកបរិភោគរួមគ្នា ក្នុងបទថា **សីលវន្តេហិ សព្រហ្ម-**

ចារីហិ សាធារណភោគី (រមែងបរិភោគរួមគ្នាជាមួយសព្រហ្មចារីទាំងឡាយ ដែលមានសីល) នេះ មានដូច្នេះ ភិក្ខុបានលាភណាៗ ដែលប្រណីត មិនឲ្យលាភនោះៗ ដល់គ្រហស្ថទាំងឡាយ ដោយបំណងយកលាភទាក់លាភ ទាំងខ្លួនឯងមិនបរិភោគ ហើយកាលនឹងទទួល ក៏ទទួលដោយគិតថា លាភនេះ ចូរជារបស់សាធារណៈដោយពួកសង្ឃ រមែងឃើញដូចជារបស់សង្ឃ ដែលនឹងវាយរគាំងឲ្យមកបរិភោគរួមគ្នា ។

ក៏នរណាបំពេញសារាណីយធម៌នេះ ឲ្យបរិបូណ៌បាន នរណាបំពេញឲ្យបរិបូណ៌មិនបាន? ។ បុគ្គលទ្រុស្តសីល រមែងបំពេញឲ្យបរិបូណ៌មិនបាន ព្រោះថា ភិក្ខុអ្នកមានសីលទាំងឡាយ នឹងមិនទទួលវត្ថុរបស់ភិក្ខុទ្រុស្ត-សីលនោះ ។ ចំណែកភិក្ខុអ្នកមានសីលបរិសុទ្ធ មិនព្រមឲ្យវត្តសៅហ្មង រមែងបំពេញឲ្យបរិបូណ៌បាន ។ ក្នុងការបំពេញសារាណីយធម៌ឲ្យបរិបូណ៌បាននោះ មានធម្មទំនៀមដូច្នេះ ក៏ភិក្ខុណាតាំងចិត្តឲ្យរបស់ដល់មាតាក្តី ដល់បិតាក្តី ដល់អាចារ្យ និងឧបជ្ឈាយ៍ជាដើមក្តី ភិក្ខុនោះឈ្មោះថា រមែងឲ្យវត្ថុដែលគួរឲ្យ (ដល់អ្នកដែលគួរឲ្យ) តែមិនឈ្មោះថា មានសារាណីយធម៌

មានត្រឹមតែការបដិបត្តិដល់អ្នកដែលគួរកន្ទល់ ។ ព្រោះថា សារាណីយធម៌ រមែងសមគួរដល់បុគ្គលដែលផុតចាកបលិពោធ (សេចក្តីកន្ទល់) ហើយ ។ ក៏បុគ្គលដែលបំពេញសារាណីយធម៌នោះ កាលនឹងឲ្យដោយចំពោះ គួរឲ្យដល់ភិក្ខុឈឺ អ្នកព្យាបាលភិក្ខុឈឺ ភិក្ខុអាគន្តុកៈ នឹងភិក្ខុអ្នកត្រៀមខ្លួននឹងដើរផ្លូវ និងភិក្ខុបួសថ្មី អ្នកដែលមិនចេះគ្រងចីវរ និងបីបាត្រ កាលឲ្យដល់ភិក្ខុទាំងនេះហើយ នៅមានរបស់សល់ គួរឲ្យតាំងពីថេរាសនៈចុះទៅ ភិក្ខុណានឹងទទួលប៉ុនណា គួរឲ្យដល់ភិក្ខុនោះប៉ុណ្ណោះ ។ បើមិនមានរបស់សល់ ចេញទៅបិណ្ឌបាតទៀត គួរឲ្យចំណែកដែលប្រណីតតាំងពីថេរាសនៈចុះទៅ ហើយគប្បីបរិភោគចំណែកដែលសល់ ។ ព្រោះមានព្រះបាលីថា **សីលវន្តេហិ (អ្នកមានសីល)** សូម្បីមិនឲ្យដល់ភិក្ខុទ្រុស្តសីលក៏គួរ ។

ក៏សារាណីយធម៌នេះ បំពេញបានងាយក្នុងបរិស័ទដែលសិក្សាល្អហើយ ព្រោះថា ក្នុងបរិស័ទដែលសិក្សាល្អហើយ ភិក្ខុណាបាន (អាហារ) មកពីទីដទៃ ភិក្ខុនោះនឹងមិនព្រមទទួល សូម្បីនឹងមិនបានមកពីដទៃ ក៏នឹង

ទទួលត្រឹមល្មមប្រមាណប៉ុណ្ណោះ មិនទទួលហួសប្រមាណ ។ ក៏សារាណី-យធម៌នេះ កាលភិក្ខុឲ្យរបស់ដែលខ្លួនទៅបិណ្ឌបាតរឿយៗ យ៉ាងនេះ បានមកនឹងបំពេញឲ្យបរិបូណ៌បាន ត្រូវប្រើវេលា ១២ ឆ្នាំ តិចជាងនោះឲ្យបរិបូណ៌មិនបាន ។ បើលោកបំពេញសារាណីយធម៌ក្នុងឆ្នាំទី ១២ ដាក់បាត្រដែលពេញដោយអាហារទុកត្រង់រោងឆាន់ ហើយទៅងូតទឹក ព្រះសង្ឃ-ថេរៈសួរថា នោះបាត្ររបស់អ្នកណា កាលពួកភិក្ខុឆ្លើយថា របស់ភិក្ខុអ្នកបំពេញសារាណីយធម៌ លោកពោលថា ចូរនាំយកបាត្រនោះមក ហើយពិចារណាឆាន់បិណ្ឌបាតនោះមិនមានសេសសល់ ហើយដាក់បាត្រទទេទុក ។ កាលភិក្ខុនោះមកឃើញបាត្រទទេ កើតទោមនស្សថា ភិក្ខុទាំងឡាយឆាន់មិនសេសសល់ទុកឲ្យយើងឡើយ ។ សារាណីយធម៌រមែងបែកធ្លាយ ត្រូវបំពេញថ្មីទៀត ១២ ឆ្នាំ ស្រដៀងនឹងតិត្ថិយបរិវាស ។ បើសារាណីយធម៌ដាច់មួង ភិក្ខុនោះត្រូវបំពេញថ្មីទៀត ។ ចំណែកភិក្ខុណា កើតសោមនស្សថា ជាលាភរបស់យើងហ្ន៎ យើងបានល្អហើយហ្ន៎ ដល់មិត្តសព្រហ្មចារីមិនប្រាប់ ហើយឆាន់អាហារដែលនៅក្នុងបាត្រ ។ សារាណីយធម៌ភិក្ខុនោះ

ឈ្មោះថា បំពេញសារាណីយធម៌បរិបូណ៌ ។

ភិក្ខុមានសារាណីយធម៌បរិបូណ៌យ៉ាងនេះ រមែងមិនមានឥស្សា មិនមានសេចក្តីកំណាញ់ រមែងជាទីស្រឡាញ់របស់មនុស្សទាំងឡាយ រកបច្ច័យបានងាយ សូម្បីរបស់ក្នុងបាត្រដែលទាយកថ្វាយដល់លោកអ្នកមានសារាណីយធម៌បរិបូណ៌ រមែងមិនអស់ទៅ ។ លោករមែងបានវត្ថុដ៏ប្រណីតក្នុងទីដែលគេចែកវត្ថុ ការជួបភ័យ ឬសេចក្តីអន្តរាយ ទេវតាទាំងឡាយរមែងជួយ ។ ក្នុងសេចក្តីនោះ មានរឿងដូចតទៅនេះជាឧបមា ។

## រឿងព្រះតិស្សត្ថេរៈ

បានឮមកថា ព្រះតិស្សត្ថេរៈ អ្នកស្រុកលេណគិរីវិហារ អាស្រ័យនៅក្នុងស្រុកឈ្មោះថា មហាគីរៈ ។ ព្រះមហាថេរៈ ៥០ រូប ដើរផ្លូវទៅថ្វាយបង្គំនាគទីបចេតិយ ត្រាច់បិណ្ឌបាតក្នុងគីរគ្រាម មិនបានអ្វីឡើយ ទើបនាំគ្នាចេញទៅ ។ ព្រះតិស្សត្ថេរកាលចូលទៅ ឃើញព្រះថេរៈទាំងនោះ ទើបសួរថា លោកម្ចាស់ទទួលបាន (អាហារ) ហើយឬ? ព្រះថេរៈទាំងនោះឆ្លើយថា លោកម្ចាស់ ពួកយើងទៅហើយ មកវិញហើយ ។ លោក

ដឹងថា ព្រះថេរៈទាំងនោះមិនបានអាហារ ទើបពោលថា លោកម្ចាស់ សូមពួកលោករង់ចាំនៅក្នុងទីនេះ រហូតខ្ញុំករុណានឹងត្រឡប់មក ។ ព្រះថេរៈទាំងនោះពោលថា ករុណាលោកម្ចាស់ ពួកយើងមានដល់ ៥០ រូប មិនបានសូម្បីត្រឹមតែទឹកលាងបាត្រ ។ ព្រះតិស្សត្ថេរៈពោលថា លោកម្ចាស់ ដែលឈ្មោះថា ភិក្ខុជាម្ចាស់ទីលំនៅ រមែងជាអ្នកអាច សូម្បីកាលមិនបានភិក្ខា ក៏រមែងដឹងផ្លូវភិក្ខាចារ ។ ព្រះថេរៈទាំងឡាយក៏បានរង់ចាំ ។ ព្រះតិស្សត្ថេរ ចូលទៅកាន់ស្រុក ។ មហាឧបាសិកានៅផ្ទះជិតៗ ទីនោះឯង ចាត់ចែងខីរភត្ត ឈរចាំព្រះថេរៈ ពេលព្រះថេរៈមកដល់ទ្វារប៉ុណ្ណោះ ក៏ថ្វាយអាហារពេញបាត្រ ។ លោកកាន់យកបាត្រនោះ សំដៅទៅកាន់សម្នាក់របស់ព្រះថេរៈទាំងឡាយ ហើយពោលជាមួយនឹងព្រះសង្ឃត្ថេរៈថា និមន្តទទួលចុះលោកម្ចាស់ ព្រះថេរគិតថា ពួកយើងចំនួនប៉ុណ្ណេះ នៅមិនទាន់បានអ្វីឡើយ ភិក្ខុរូបនេះកាន់យកបាត្រទៅ ត្រឡប់មកមួយរំពេចវិញ មានអ្វីកើតឡើងហ្ន៎ ហើយសម្លឹងមើលមុខព្រះថេរៈដ៏សេសទាំងឡាយ ។ ព្រះតិស្សត្ថេរដឹងដោយអាការដែលសម្លឹងមើលមុខនុ៎ះឯង ទើបផ្ដើមថា សូមលោក

ម្ចាស់ទទួលបិណ្ឌបាត ខ្ញុំបានមកដោយធម៌ សូមលោកម្ចាស់ទាំងឡាយកុំរង្កៀសឡើយ និមន្តទទួលចុះ ហើយថ្វាយបិណ្ឌបាតដល់ព្រះថេរៈទាំងអស់តាំងពីដើមរហូតល្មមដល់សេចក្តីត្រូវការ ចំណែកខ្លួនឯងក៏ឆាន់ឆ្អែតដែរ ។

កាលភត្តកិច្ចស្រេចហើយ ព្រះថេរៈទាំងឡាយសួរលោកថា អាវុសោ លោកសម្រេចលោកុត្តរកាលណា ។ លោកឆ្លើយថា លោកម្ចាស់ ខ្ញុំមិនទាន់បានសម្រេចលោកុត្តរធម៌នៅឡើយទេ ។ ព្រះថេរៈទាំងឡាយសួរថា អាវុសោ លោកបានឈានឬ ។ លោកឆ្លើយថា លោកម្ចាស់ ឈានក៏ខ្ញុំមិនទាន់បានដែរ ។ ព្រះថេរៈទាំងឡាយសួរថា ឬលោកមានបាដិហារ្យ ។ លោកឆ្លើយថា ខ្ញុំករុណាបំពេញសារាណីយធម៌ តាំងពីវេលាដែលខ្ញុំបំពេញសារាណីយធម៌បរិបូណ៌ហើយ ប្រសិនបើមានភិក្ខុ ១០០.០០០ រូប អាហារដែលនៅក្នុងបាត្រក៏មិនអស់ ។ ព្រះថេរៈទាំងនោះពោលថា សាធុ សាធុ លោកសប្បុរស វត្តនេះសមគួរដល់លោកហើយ ។ នេះជាគ្រឿងឧបមាក្នុងប្រការនេះថា អាហារដែលនៅក្នុងបាត្រមិនចេះអស់ជាមុន ។

ក៏ព្រះតិស្សត្ថេរមួយអង្គនេះឯង ចូលទៅកាន់ទីថ្វាយទាន ដើម្បីមហា

បូជាក្នុងចេតិយបពិត ឈ្មោះថា គិរីកណ្ណៈ ហើយសួរថា ក្នុងការឲ្យទាននេះ មានអ្វីជារបស់ប្រសើរបំផុត ។ មនុស្សទាំងឡាយឆ្លើយថា មានសំពត់សាដក ២ ផ្ទាំងលោកម្ចាស់ ។ ព្រះថេរៈពោលថា សំពត់សាដកគូនេះ នឹងបានមកអាត្មា ។ អាមាត្យបានឮពាក្យនោះហើយ ទៅក្រាបទូលព្រះរាជាថា ភិក្ខុកំលោះមួយរូបពោលយ៉ាងនេះ ព្រះរាជាត្រាស់ថា ភិក្ខុកំលោះមានការគិតយ៉ាងនេះ តែសំពត់សាដកសាច់ល្អិតសមគួរដល់ព្រះមហាថេរៈទាំងឡាយ ដូច្នេះហើយ ទ្រង់ក៏ទុកដោយព្រះតម្រិះថា យើងនឹងថ្វាយដល់ព្រះមហាថេរៈទាំងឡាយ កាលព្រះរាជាថ្វាយសំពត់ដល់ភិក្ខុសង្ឃដែលគង់ឈរនៅតាមលំដាប់ សំពត់សាដកដែលទ្រង់ដាក់ខាងលើក៏មិនជាប់ព្រះហត្ថ ផែនសំពត់ដទៃត្រឡប់ជាជាប់ព្រះហត្ថវិញ តែក្នុងវេលាទ្រង់ថ្វាយដល់ភិក្ខុកំលោះ សំពត់សាដកទាំង ២ ផ្ទាំងនោះ បែរជាជាប់ព្រះហត្ថវិញ ព្រះអង្គទ្រង់ដាក់លើដៃរបស់ភិក្ខុកំលោះ ហើយទ្រង់សម្លឹងមើលមុខអាមាត្យនិមន្តភិក្ខុកំលោះឲ្យគង់ ថ្វាយទាន ទ្រង់អង្គៀសភិក្ខុសង្ឃហើយ ប្រថាប់ក្នុងទីដ៏សមគួរមួយជិតភិក្ខុកំលោះ ត្រាស់ថា លោកដ៏ចម្រើន លោកម្ចាស់

សម្រេចគុណធម៌នេះកាលណា ។ លោកមិនទូលគុណធម៌ ដែលមិនមាន ដោយបញ្ចិតបញ្ចៀង តែបានទូលថា សូមថ្វាយព្រះពរមហាបពិត្រ លោកុត្តរធម៌របស់អាត្មាភាពមិនមានទេ ។ ព្រះរាជាត្រាស់សួរថា លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានពោលមុនហើយមិនមែន ។ ភិក្ខុកំលោះឆ្លើយថា សូមថ្វាយព្រះពរមហាបពិត្រ ត្រូវហើយ អាត្មាភាពបំពេញសារាណីយធម៌ចាប់តាំងពីវេលាដែលអាត្មាភាពបំពេញសារាណីយធម៌បរិបូណ៌ហើយ ក្នុងស្ថានទីដែលគេចែកទាន (គ្រប់កន្លែង) របស់ដែលប្រសើររមែងមានដល់អាត្មាភាព ។ ព្រះរាជាត្រាស់ថា សាធុ សាធុ លោកម្ចាស់ សំពត់សាដកមួយគូនេះ សមគួរដល់លោកម្ចាស់ហើយ ហើយស្តេចក៏ចេញទៅ ។ នេះជាឧបមាក្នុងសេចក្តីនេះថា ក្នុងស្ថានទីដែលគេចែករបស់របរប្រើប្រាស់ដ៏ប្រសើររមែងមានដល់ (ដល់អ្នកបំពេញសារាណីយធម៌) ។

ក៏អ្នកស្រុកដែលអាស្រ័យនៅក្នុងកាតគ្រាម មិនទាន់បានពោលដល់ព្រះនាគថេរ ប្រញាប់ចៀសចេញទៅ ព្រោះព្រហ្មតិស្សភ័យ[១] ។ ក្នុង

---

(១) ដីកា = ចោរភ័យ ។

ពេលព្រឹក ព្រះថេរីពោលជាមួយភិក្ខុនីក្រមុំ អ្នកស្រុកចណ្ឌាលតិស្សៈថា ពួកអ្នកស្រុកស្ងប់ស្ងាត់ណាស់ នាងទាំងឡាយចូលទៅពិនិត្យមើលមើល៍ ។ ភិក្ខុនីក្រមុំទាំងនោះទៅហើយ ដឹងថា មនុស្សទាំងឡាយ គេចចេញអស់ហើយ ទើបត្រឡប់មកប្រាប់ដល់ព្រះថេរី ព្រះថេរីស្តាប់ហើយ ទើបពោលថា ពួកនាងកុំគិតដល់ការដែលមនុស្សទាំងនោះមិនមានឡើយ ចូរធ្វើសេចក្តីព្យាយាមក្នុងឧទ្ទេស ការសាកសួរ និងយោនិសោមនសិការរបស់ខ្លួនទុកចុះ ក្នុងវេលាភិក្ខាចារ យុំចីវរហើយ (រូម) ១២ រូប ទាំងខ្លួនឯង បាននាំគ្នាទៅឈរនៅត្រង់គល់ដើមជ្រៃជិតទ្វារស្រុក ទេវតាដែលរស់នៅនឹងដើមឈើបានថ្វាយបិណ្ឌបាតដល់ភិក្ខុនីទាំងឡាយ ១២ រូប ហើយពោលថា បពិត្រអ្នកម៉ែជាម្ចាស់ សូមកុំទៅក្នុងទីដទៃឡើយ និមិន្តមកកាន់ទីនេះប៉ុណ្ណោះជាប្រចាំ ។ ព្រះថេរីមានប្អូនប្រុស នាមថា នាគថេរៈ ព្រះថេរៈនោះគិតថា ភ័យធំ យើងមិនអាចមានជីវិតនៅបាន យើងនឹងទៅត្រើយខាងណោះ រូមជា ១២ រូប ទាំងខ្លួនលោក ចេញអំពីទីនៅរបស់ខ្លួន មកកាន់កាតគ្រាមដោយគិតថា យើងនឹងទៅសួរសុខទុក្ខព្រះថេរី ។ ព្រះថេរីបានជ្រាបថា ព្រះ

ថេរៈទាំងឡាយមក ទើបចូលទៅកាន់សម្នាក់របស់ព្រះថេរៈទាំងនោះ ហើយសួរថា មានរឿងអ្វីឬ លោកម្ចាស់ ។ ព្រះថេរៈ ប្រាប់រឿងរ៉ាវនោះហើយ ។ ព្រះថេរីពោលថា ថ្ងៃនេះ និមន្តពួកលោកម្ចាស់នៅក្នុងវិហារនេះ ចាំថ្ងៃស្អែកសូមទៅ ព្រះថេរៈទាំងឡាយបានចូលទៅកាន់វិហារហើយ ។

ពេលព្រឹកឡើង ព្រះថេរីបានទៅបិណ្ឌបាតត្រង់គល់ឈើ ហើយចូលទៅរកព្រះថេរៈ ពោលថា និមិន្តពួកលោកឆាន់បិណ្ឌបាតនេះ ។ ព្រះថេរៈមិនពោលថា "របស់នេះគួរឬ" ក៏ឈរនៅស្ងៀម ។ ព្រះថេរីពោលថា លោកម្ចាស់ បិណ្ឌបាតនេះបានមកដោយធម៌ សូមលោកទាំងឡាយកុំរង្កៀសឡើយ ចូរឆាន់ចុះ ។ ព្រះថេរៈពោលថា របស់នេះគួរឬព្រះថេរី ។ ព្រះថេរីនោះចាប់បាត្រ ហើយបោះទៅក្នុងអាកាស បាត្របានអណ្តែតនៅក្នុងអាកាស ។ ព្រះថេរៈពោលថា ព្រះថេរី កត្តដែលអណ្តែតនៅលើអាកាសកម្ពស់ ៧ ជួរត្នោត ជាកត្តាហារសម្រាប់ភិក្ខុនីប៉ុណ្ណោះ ។ ហើយពោលតទៅទៀតថា ដែលឈ្មោះថា ភ័យ នឹងមិនមានគ្រប់កាល កាលភ័យស្ងប់ហើយ យើងដែលជាអ្នកពោលអរិយវង្ស ត្រូវចិត្តដាស់តឿនរឿយៗ ថា

លោកដែលកាន់បិណ្ឌបាត្រជាវត្ត លោកទាំងឡាយឆាន់កត្តាហាររបស់ភិក្ខុទី ទើបរួចជីវិតមកបាន នឹងមិនអាចទៅមុខបាន ។ ព្រះថេរីទាំងឡាយពោលថា សូមលោកម្ចាស់ទាំងឡាយចូរជាអ្នកមិនប្រមាទចុះ ហើយចៀសចេញទៅ ។

ចំណែករុក្ខទេវតាគិតថា បើព្រះថេរៈនឹងឆាន់បិណ្ឌបាតអំពីដៃរបស់ព្រះថេរី យើងនឹងមិនឲ្យលោកត្រឡប់ទៅវិញ បើមិនឆាន់ យើងនឹងឲ្យលោកត្រឡប់ ដូច្នេះ ឃើញព្រះថេរៈដើរទៅ ក៏ចុះអំពីដើមឈើហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ចូរឲ្យបាត្រដល់ខ្ញុំម្ចាស់ចុះ ហើយទទួលបាត្រនាំព្រះថេរៈទៅក្រោមដើមឈើនុ៎ះឯង ក្រាលអាសនៈ ថ្វាយបិណ្ឌបាត និមន្តព្រះថេរៈដែលសម្រេចកត្តកិច្ចហើយទទួលពាក្យ ទំនុកបម្រុងទាំងភិក្ខុនី ១២ រូប ទាំងភិក្ខុ ១២ រូប រហូតដល់អស់វេលា ៧ ឆ្នាំ ។ នេះជាឧបមាក្នុងសេចក្តីនេះថា ទេវតាទាំងឡាយ រមែងជួយសង្គ្រោះ ។ នេះជារឿងដែលព្រះថេរីបំពេញសារាណីយធម៌ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា **អខណ្ឌានិ (មិនដាច់)** ជាដើម

ដូចតទៅនេះ បណ្ដាលអាបត្តិទាំង ៧ កង ភិក្ខុណាមានសិក្ខាបទដាច់ក្នុងខាងចុង ឬខាងដើម សីលរបស់ភិក្ខុនោះឈ្មោះថា ដាច់ ដូចសំពត់ដាច់ត្រង់ជាយ ។ ចំណែកភិក្ខុណាមានសិក្ខាបទដាច់ត្រង់កណ្ដាល សីលរបស់ភិក្ខុនោះឈ្មោះថា ធ្លុះ ដូចសំពត់ដែលធ្លុះ (ត្រង់កណ្ដាល) ភិក្ខុមានសិក្ខាបទ ២-៣ សិក្ខាបទដាច់តាមលំដាប់ សីលរបស់អ្នកនោះឈ្មោះថា ពពាល ដូចមេគោមានសម្បុរខ្មៅ សម្បុរក្រហមជាដើម ពណ៌ណាមួយ ដោយមានពណ៌កាត់គ្នា ប្រាកដត្រង់ខ្នង ឬត្រង់ពោះ ។ ភិក្ខុមានសិក្ខាបទដាច់ត្រង់ចន្លោះៗ សីលរបស់ភិក្ខុនោះឈ្មោះថា ពព្រុស ដូចមេគោដែលមានស្នាមអុជពព្រុស ឆ្លាស់គ្នាក្នុងចន្លោះៗ ។ ចំណែកភិក្ខុមានសិក្ខាបទទាំងអស់មិនដាច់ ភិក្ខុនោះឈ្មោះថា មានសីល មិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស (អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ) ។ ក៏សិក្ខាបទទាំងអស់នោះ ត្រាស់ថា ភុជិស្សានិ (ជាធំ) ព្រោះធ្វើភាពជាធំ ធ្វើឲ្យផុតអំពីភាពជាទាសៈរបស់តណ្ហា វិញ្ញុប្បសដ្ឋានិ (ដែលវិញ្ញូជនសរសើរ) ព្រោះវិញ្ញូជនទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរ អបរាមដ្ឋានិ (ដែលតណ្ហា

និងទិដ្ឋិមិនស្ទាបអង្អែល) ព្រោះតណ្ហា និងទិដ្ឋិមិនស្ទាបអង្អែល និងព្រោះនរណាៗ មិនអាចនឹងចោទបានថា លោកធ្លាប់ត្រូវអាបត្តិឈ្មោះនេះមក **សមាធិសំវត្តនិកានិ (ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ)** ព្រោះអត្ថថា ធ្វើឧបចារសមាធិ ឬអប្បនាសមាធិឲ្យប្រព្រឹត្តទៅ ។

បទថា **សីលសាមញ្ញគតោ វិហរតិ (ភិក្ខុអ្នកមានសីលស្មើគ្នា)** សេចក្តីថា ជាភិក្ខុមានសីលស្មើគ្នា ជាមួយនឹងភិក្ខុទាំងឡាយក្នុងទិសាភាគនោះៗ ។ សីលរបស់ព្រះសោតាបន្នជាដើម រមែងជាសីលស្មើគ្នាជាមួយសីលរបស់ព្រះសោតាបន្នដទៃជាដើម ដែលនៅក្នុងរវាងនៃមហាសមុទ្រខ្លះ ក្នុងទេវលោកខ្លះ ព្រោះហេតុនោះ ក្នុងមគ្គសីល (សីលក្នុងអរិយមគ្គ) ទើបមិនមានសេចក្តីផ្សេងគ្នា ។ ព្រះមានព្រះភាគត្រាស់ថា **ជាអ្នកមានសីលស្មើគ្នា** នេះទុក ដោយទ្រង់ត្រាស់សំដៅយកសីលរបស់ព្រះសោតាបន្នជាដើមនោះឯង ។

បទថា **យាយំ ទិដ្ឋិ (ទិដ្ឋិដ៏ប្រសើរ)** បានដល់ សម្មាទិដ្ឋិ ដែលសម្បយុត្តជាមួយមគ្គ ។ បទថា **អរិយា (ព្រះអរិយៈ)** បានដល់ មិនមាន

*ទោស ។ ទិដ្ឋិ ឈ្មោះថា និយ្យានិកា (ជាគ្រឿងនាំចេញ) ព្រោះនាំសត្វចេញអំពីកព ។ បទថា តក្ករស្ស (ដល់អ្នកធ្វើតាម) បានដល់ អ្នកដែលធ្វើយ៉ាងនោះ ។ បទថា ទុក្ខក្ខយាយ (ដើម្បីការអស់ទុក្ខ) បានដល់ ដើម្បីអស់ទុក្ខទាំងពួង ។ បទថា ទិដ្ឋិសាមញ្ញគតោ (មានទិដ្ឋិស្មើគ្នា) បានដល់ជាអ្នកចូលដល់ភាពជាអ្នកមានទិដ្ឋិស្មើគ្នា ។*

ចប់អដ្ឋកថា បឋមសារាណីយសូត្រទី ១

# អដ្ឋកថា ទុតិយសារាណីយសូត្រទី ២

*(ធម៌ជាហេតុឲ្យរឭកដល់គ្នា)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសារាណីយសូត្រទី ២ ដូចតទៅនេះ ៖*

[១២] *បទថា* ***បិយករណា*** *(ធ្វើឲ្យជាទីស្រឡាញ់) ព្រោះអត្ថថា ធ្វើបុគ្គលអ្នកបំពេញធម៌ទាំងនោះ ឲ្យជាទីស្រឡាញ់របស់មិត្រសព្រហ្មចារីទាំងឡាយ ។ បទថា* ***គរុករណា*** *(ជាទីគោរព) ព្រោះអត្ថថា ធ្វើឲ្យជាអ្នកគួរគោរព ។ បទថា* ***សង្គហាយ*** *(ដើម្បីសេចក្ដីសង្គ្រោះ) បានដល់ ដើម្បីប្រយោជន៍ដល់ការសង្គ្រោះ ។ បទថា* ***អវិវាទាយ*** *(ដើម្បីការមិនវិវាទ) បានដល់ ដើម្បីប្រយោជន៍ដល់ការមិនវិវាទគ្នា ។ បទថា* ***សាមគ្គិយា*** *(ដើម្បីសេចក្ដីព្រមព្រៀងគ្នា) បានដល់ ដើម្បីប្រយោជន៍ដល់ការសាមគ្គី ។ បទថា* ***ឯកីភាវាយ*** *(ដើម្បីមូលមិត្រគ្នា) បានដល់ ដើម្បីប្រយោជន៍ដល់ការមូលមិត្រគ្នា គឺ ដើម្បីប្រយោជន៍ធ្វើឲ្យជាអ្នកមិនផ្សេងគ្នា ។ បទថា* ***សំវត្តន្តិ*** *(រមែងប្រព្រឹត្តទៅ) បានដល់ រមែងប្រព្រឹត្តទូទៅ ។*

ចប់អដ្ឋកថា ទុតិយសារាណិយសូត្រទី២

# អដ្ឋកថា មេត្តាសូត្រទី ៣

## (មេត្តាជាធាតុគ្រឿងរលាស់ចេញ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង មេត្តាសូត្រទី ៣ ដូចតទៅនេះ ៖*

*[១៣] បទថា **និស្សារណីយា ធាតុយោ** (និស្សារណីយធាតុ) បាន ដល់ ធាតុ (សភាវៈដែលទ្រទ្រង់ទុក) ដែលជាគ្រឿងរលាស់ចេញ ។ ក្នុង បទថា **មេត្តា ហិ ខោ មេ ចេតោវិមុត្តិ** (ចេតោវិមុត្តិប្រកបដោយមេត្តា) នេះ មានអធិប្បាយថា មេត្តានុ៎ះឯង ដែលប្រព្រឹត្តទៅក្នុងឈានពួក ៣ ឬពួក ៤ ឈ្មោះថា មេត្តាចេតោវិមុត្តិ ព្រោះរួចផុតចាកធម៌ដែលជាសត្រូវ ទាំងឡាយ ។ បទថា **ភាវិតា** (ចម្រើនហើយ) គឺ ឲ្យចម្រើនហើយ ។ បទថា **ពហុលីកតា** (ធ្វើឲ្យច្រើនហើយ) គឺ ធ្វើហើយរឿយៗ ។ បទថា **យានីកតា** (បានធ្វើឲ្យដូចជាយាន) គឺ ធ្វើឲ្យដូចជាយានដែលទឹមហើយ ។ បទថា **វត្ថុកតា** (ធ្វើឲ្យជាទីតាំង) គឺ ធ្វើឲ្យជាទីតាំងអាស្រ័យ ។ បទថា **អនុដ្ឋិតា** (តាំងមាំហើយ) គឺ ដំកល់ស៊ប់ហើយ ។ បទថា **បរិចិតា** (អប់រំហើយ) បានដល់ ផ្ដើមឡើង គឺ សន្សំ បានដល់ អប់រំហើយដោយជុំវិញ ។ បទថា*

សុសមារទ្ធា (ប្រារព្ធល្អហើយ) បានដល់ ប្រារព្ធដោយល្អ ដោយធ្វើឲ្យជំនាញយ៉ាងល្អ ។

បទថា **បរិយាទាយ តិដ្ឋតិ** (គង់គ្របសង្កត់...ហើយ) បានដល់ គ្របសង្កត់ទុកយ៉ាងមាំ ។ បទថា **មា ហេវន្តិស្ស វចនីយោ** (ដែលភិក្ខុទាំងឡាយពោលជាស់តឿនថា មិនមែនយ៉ាងនោះឡើយ) សេចក្តីថា ព្រោះហេតុដែលភិក្ខុនោះនិយាយបង្អាច់រឿងដែលមិនពិត ដូច្នោះ លោកគប្បីត្រូវភិក្ខុទាំងឡាយពោលថា អ្នកកុំនិយាយយ៉ាងនេះឡើយ ។ បទថា **យទិទំ មេត្តាចេតោវិមុត្តិ** (មេត្តាចេតោវិមុត្តិនេះ) បានដល់ មេត្តាចេតោវិមុត្តិនេះឯង ។ អធិប្បាយថា ពាក្យថា មេត្តាចេតោវិមុត្តិ ជាគ្រឿងរលាស់ចេញចាកព្យាបាទ គឺ រលាស់ចេញផុតពីព្យាបាទ ។ ក៏បុគ្គលណាចម្រើនមេត្តាចេញចាកឈានពួក ៣ ឬពួក ៤ ហើយ ពិចារណា សង្ខារទាំងឡាយសម្រេចមគ្គទី ៣ ដឹងថា ព្យាបាទនឹងមិនមានទៀតទេ រមែងឃើញព្រះនិព្វានដោយតតិយផលចិត្តរបស់បុគ្គលនោះ ដែលជាគ្រឿងរលាស់ចេញនូវព្យាបាទដោយអស់ជើង ។ ក្នុងគ្រប់ៗ បទ គប្បីជ្រាបអធិប្បាយដោយឧបមានេះ ។

បទថា **អនិមិត្តាចេតោវិមុត្តិ** (ជាធម៌សម្រាប់រលាស់ចោលនូវនិមិត្តទាំងអស់) បានដល់ វិបស្សនាដ៏មានកម្លាំង ចំណែកអាចារ្យអ្នកពោលគម្ពីរទីឃនិកាយពោលថា បានដល់ សមាបត្តិដែលសម្បយុត្តដោយអរហត្តផល ។ ក៏អរហត្តផលសមាបត្តិនោះ លោកពោលថា រកនិមិត្ត ព្រោះមិនមាននិមិត្តទាំងឡាយ មានរាគនិមិត្តជាដើម រូបនិមិត្តជាដើម និងនិច្ចនិមិត្តជាដើម ។ បទថា **និមិត្តានុសារិ** (នៅស្វែងរកនិមិត្ត) បានដល់ មានសភាវៈតាមព្រួកដល់និមិត្ត មានប្រភេទដូចពោលមកហើយ ។ បទថា **អស្មិ** បានដល់ **អស្មិមានះ** ។ បទថា **អយមហមស្មិ** (នេះជាយើង) បានដល់ ឈ្មោះថាវត្ថុនេះក្នុងខន្ធ ៥ ជាយើង ព្រោះហេតុនោះ ដោយពាក្យត្រឹមប៉ុណ្ណេះ ឈ្មោះថា ជាការព្យាករណ៍អរហត្តផលហើយ ។ បទថា **វិចិកិច្ឆាកថំកថាសល្លំ** (សរ គឺ សេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់) បានដល់ កូនសរ គឺសេចក្តីងឿងឆ្ងល់ដែលគួរសង្ស័យ ។ បទថា **មា ហេវន្តិស្ស វចនីយោ** (ដែលភិក្ខុទាំងឡាយគប្បីពោលជាស់តឿនថា មិនមែនយ៉ាងនោះ) សេចក្តីថា ប្រសិនបើ វិចិកិច្ឆាដែលបឋមមគ្គនឹងគប្បីសម្លាប់ កើតឡើងដល់លោក

សោត ការព្យាករណ៍អរហត្តផលរមែងខុស ព្រោះដូច្នោះ លោកទើបគួរហាមថា កុំពោលរឿងដែលមិនពិត ។ បទថា **អស្មីតិ មានសមុគ្ឃាតោ (ការដកអស្មិមានះ)** បានដល់ អរហត្តមគ្គ ។ ក៏កាលឃើញនិព្វាន ដោយអំណាចអរហត្តមគ្គ និងអរហត្តផលហើយ អស្មិមានះរមែងមិនមានតទៅទៀត ព្រោះហេតុនោះ អរហត្តមគ្គ ព្រះមានព្រះភាគទើបត្រាស់ថា ការដកអស្មិមានះ ។ ក្នុងព្រះសូត្រនេះ ត្រាស់ឲ្យឈ្មោះថា **អភូតព្យាករណ៍ (ព្យាករណ៍រឿងមិនពិត)** ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា មេត្តាសូត្រទី ៣

# អដ្ឋកថា ភទ្ទកសូត្រទី ៤

## (ការនៅដែលចម្រើន និងមិនចម្រើន)

គប្បីជ្រាបវិនិច្ឆ័យក្នុង ភទ្ទកសូត្រទី ៤ ដូចតទៅនេះ ៖

[១៤] បទថា **ន ភទ្ទកំ** (ដែលមិនចម្រើន) បានដល់ ដែលមិនបានចម្រើន ។ ក្នុងបទនោះ បុគ្គលណាកិតក័យច្រើនហើយស្លាប់ បុគ្គលនោះឈ្មោះថា ស្លាប់មិនចម្រើន ។ (ចំណែក) បុគ្គលណាបដិសន្ធិក្នុងអបាយ បុគ្គលនោះ (ឈ្មោះថា) ស្លាប់ហើយមិនចម្រើន ។ ក្នុងបទមានជាអាទិ៍ថា **កម្មារាមោ** (អ្នករីករាយក្នុងការងារ) មានអធិប្បាយដូច្នេះ វត្ថុដែលគួរត្រេកអរ ឈ្មោះថា **អារាមៈ** អធិប្បាយថា រីករាយដ៏ក្រៃលែង ។ ឈ្មោះថា **អ្នកពេញចិត្តក្នុងការងារ** ព្រោះអត្ថថា មានសេចក្តីត្រេកអរក្នុងនវកម្ម មានការសាងវិហារជាដើម ។ បទថា **កម្មរតោ** (ត្រេកអរក្នុងការងារ) ព្រោះអត្ថថា ត្រេកអរក្នុងការងារនោះឯង ។ បទថា **អនុយុត្តោ** (ខ្វល់ខ្វាយ) ព្រោះអត្ថថា ប្រកបសេចក្តីត្រេកអរក្នុងការងារនោះឯងរឿយៗ ។ ក្នុងបទទាំងពួង ក៏ន័យនេះដូចគ្នា ។

ក៏ក្នុងទីនេះការពោលចរចាគ្នា ឈ្មោះថា **ភស្សំ** (ការចរចា) ។ ការដេកលក់ ឈ្មោះថា **និទ្ទា** (ការលក់) ។ ការស្និទ្ធស្នាលដោយពួកគណៈនោះ គប្បីជ្រាបដោយន័យមានជាអាទិ៍ថា កាលមានមនុស្សម្នាក់ក៏បន្ថែមឲ្យជាពីរនាក់ កាលមានពីរនាក់ ក៏មានបីនាក់ ។ ពាក្យថា ភាពជាអ្នកស្និទ្ធ-ស្នាលគ្នា ដែលប្រព្រឹត្តទៅហើយដោយអំណាចនៃការទាក់ទងគ្នា ដោយការស្តាប់ ការឃើញ ការចរចា ការនៅរួមគ្នា និងការទាក់ទងគ្នាផ្លូវកាយ ឈ្មោះថា **សំសគ្គោ** (ការស្និទ្ធស្នាល) ។ ធម៌ជាគ្រឿងយឺតយូរ គឺ កិលេសដែលប្រព្រឹត្តទៅហើយដោយអំណាចនៃតណ្ហា ទិដ្ឋិ និងមានះ ដែលតាំងនៅដោយការប្រកាន់មាំ ឈ្មោះថា **បបញ្ចោ** (ធម៌ដែលជាហេតុឲ្យយឺតយូរ) ។ បទថា **សក្កាយំ** (សក្កាយៈ) បានដល់ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **សម្មា ទុក្ខស្ស អន្តកិរិយាយ** (ដើម្បីធ្វើទីបំផុតនៃទុក្ខដោយប្រពៃ) បានដល់ ដើម្បីធ្វើការកាត់ផ្តាច់ផ្លូវនៃវដ្តទុក្ខទាំងអស់ ដោយហេតុ ដោយន័យ ។

បទថា **មគោ** (ម្រឹគ) បានដល់ ដូចជាម្រឹគ ។ បទថា **និប្បបញ្ច-**

*បទេ* (ក្នុងបទ គឺ ធម៌ដែលមិនមែនជាហេតុឲ្យយឺតយូរ) បានដល់ ក្នុងបទ គឺ ព្រះនិព្វាន ។ បទថា *អារាធយតិ* (រមែងបានការសរសើរ) បានដល់ ឲ្យបរិបូណ៌ គឺ ធ្វើព្រះនិព្វាននោះឲ្យដល់ព្រម ។

ចប់អដ្ឋកថា ភទ្ទកសូត្រទី ៤

# អដ្ឋកថា អនុតប្បិយសូត្រទី ៥

## (ការនៅដែលធ្វើឲ្យក្តៅក្រហាយ និងមិនក្តៅក្រហាយ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុតប្បិយសូត្រទី ៥ ដូចតទៅនេះ ៖*

*[១៥] បទថា **អនុតប្បា** (ក្តៅក្រហាយ) បានដល់ ត្រូវសោកសៅក្នុងខាងក្រោយ គឺ ធ្វើសេចក្តីក្តៅក្រហាយឲ្យកើតឡើងក្នុងខាងក្រោយ ។ ក្នុងសូត្រទាំង ២ នេះ និងក្នុងគាថាទាំងឡាយ ព្រះសារីបុត្តពោលទុកទាំងចំណែកសេចក្តីវិនាស និងសេចក្តីចម្រើន ។*

ចប់អដ្ឋកថា អនុតប្បិយសូត្រទី ៥

# អដ្ឋកថា នកុលសូត្រទី ៦

## (ពាក្យជាស់តឿនរបស់នកុលមាតាគហបតានី)

គប្បីជ្រាបវិនិច្ឆ័យក្នុង នកុលសូត្រទី ៦ ដូចតទៅនេះ ៖

[១៦] បទថា **ពាឡ្ហគិលានោ (ឈឺធ្ងន់)** បានដល់ ជាជំងឺធ្ងន់ ។ បទថា **ឯតទវោច (បានពោលជាស់តឿន)** សេចក្តីថា នកុលមាតាគហបតានី កាលមិនអាចចាត់ចែងថ្នាំរម្ងាប់ព្យាធិរបស់ស្វាមីបាន ឥឡូវនេះ ដើម្បីនឹងបន្ទឺសីហនាទរម្ងាប់ព្យាធិ ដោយការធ្វើសច្ចកិរិយា ទើបអង្គុយជិតស្វាមី ហើយពោលពាក្យមានជាអាទិ៍ថា **មា ខោ ត្វំ (អ្នកកុំ)** ។ បទថា **សាបេក្ខោ (ជាអ្នកមានសេចក្តីអាល័យ)** បានដល់ នៅមានសេចក្តីអាឡោះអាល័យដ៏យ៉ាងក្រៃលែង ។ **ន** អក្សរ ក្នុងបទថា **ន នកុលមាតា** នេះ ត្រូវប្រកបចូលជាមួយបទក្រោយយ៉ាងនេះថា **ន បហោតិ** ។ បទថា **សណ្ឋាតុំ (តាំងនៅ)** បានដល់ ដើម្បីធ្វើមិនឲ្យមានចន្លោះ (មិនធ្វេសប្រហែស) ។ អធិប្បាយថា គ្រប់គ្រងទុកដោយល្អ ។ បទថា **វេណី ឱលិខិតុំ (ធ្វើរោមសត្វ)** បានដល់ ដើម្បីត្រៀមរោមកេះ យកមកសាងហើយធ្វើឲ្យជាចន្លោះ ។

បទថា អញ្ញំ ភត្តារំ គមិស្សតិ (នឹងបានបុគ្គលដទៃជាស្វាមី) បានដល់ នឹងមានស្វាមីថ្មី ។ បទថា សោឡសវស្សានិ គហដ្ឋព្រហ្មចរិយំ សមាចិណ្ណំ (ព្រហ្មចរិយធម៌របស់គ្រហស្ថ យើងធ្លាប់សន្សំមកអស់ ១៦ ឆ្នាំហើយ) បានដល់ រាប់ថយអំពីនេះទៅ ១៦ ឆ្នាំ ខ្ញុំបានប្រព្រឹត្តព្រហ្មចារ្យ របស់គ្រហស្ថយ៉ាងល្អ ។ បទថា ទស្សនកាមតរា (ត្រូវការឃើញ... យ៉ាង ខ្លាំង) បានដល់ ប្រាថ្នានឹងគាល់ (ព្រះពុទ្ធ) ក្រៃលែងៗ ឡើង ។ នាង បានបន្លឺសីហនាទដោយអង្គ ៣ ប៉ុណ្ណេះហើយ បានធ្វើសច្ចកិរិយាថា ដោយ ពាក្យសច្ចៈនេះ សូមព្យាធិក្នុងកាយរបស់លោក (ចូរវិនាសទៅ) ចូរបាន ជាសុខចុះ ។

ឥឡូវនេះ ដើម្បីនឹងអាងព្រះមានព្រះភាគជាសាក្សី ធ្វើសច្ចកិរិយា សូម្បីដោយគុណ មានសីលជាដើមរបស់ខ្លួន នាងទើបបានពោលពាក្យជា អាទិ៍ថា សិយា ខោ បន តេ (ក៏លោកកុំគប្បីមានសេចក្តីអាល័យ) ។ បណ្តាលបទទាំងនោះ បទថា បរិបូរិការិនី (បុគ្គលធ្វើឲ្យបរិបូរ) បានដល់ អ្នកធ្វើបានបរិបូណ៌ ។ បទថា ចេតោសមថស្ស (សេចក្តីស្ងប់ចិត្ត) បាន

ដល់ សមាធិកម្មដ្ឋាន ។ បទថា **ឱគាធប្បត្តា** (ដល់នូវការឈានចុះ) បានដល់ ដល់នូវការឈានចុះ គឺ ការតាមចូលទៅ ។ បទថា **បដិគាធប្បត្តា** (ដល់នូវទីពឹង) បានដល់ ដល់នូវការឈានចុះចំពោះ គឺ ទីតាំង ។ បទថា **អស្សាសប្បត្តា** (ដល់នូវការធូរស្រាលចិត្ត) បានដល់ ដល់នូវកាពកក់ក្តៅ គឺ ទីពឹង ។ បទថា **វេសារជ្ជប្បត្តា** (ដល់នូវសេចក្តីក្លៀវក្លា) បានដល់ ដល់សោមនស្សញាណ ។ បទថា **អបរប្បច្ចយា** (មិនមានអ្នកដទៃជាបច្ច័យ) មានវិនិច្ឆ័យថា សទ្ធាជាប់ដោយអ្នកដទៃ គឺ ធ្វើដំណើរតាមបដិបទារបស់អ្នកដទៃ ហៅថា មានអ្នកដទៃជាបច្ច័យ (អបរប្បច្ចយៈ) អធិប្បាយថា វៀរចាកសទ្ធាដែលជាប់ដោយអ្នកដទៃនោះ ។ គហបតានី បានធ្វើសច្ចកិរិយាប្រារព្ធគុណ គឺ សេចក្តីល្អរបស់ខ្លួនដោយអង្គទាំង ៣ នេះ ។ បទថា **គិលានា វុដ្ឋិតោ** (ស្បើយចាកជម្ងឺ) បានដល់ ជាសះស្បើយហើយ ។ បទថា **យាវតា** (ទាំងប៉ុន្មាន) បានដល់ មានប្រមាណប៉ុនណា ។ បទថា **តាសំ អញ្ញតរា** (ជាបុគ្គលម្នាក់ក្នុងចំនួនសាវិកាទាំងនោះ) បានដល់ ជាសាវិកាក្នុងចំណោមសាវិកាទាំងនោះ ។ បទថា **អនុកម្បិកា** (ជាអ្នកអនុគ្រោះ)

បានដល់ ជាអ្នកអនុគ្រោះដោយប្រយោជន៍ដ៏ច្រើន ។ បទថា **ឱវាទិកា** (ពោលដាស់តឿន) បានដល់ អ្នកឲ្យពាក្យទូន្មាន ។ បទថា **អនុសាសិកា** (ប្រៀនប្រដៅ) បានដល់ អ្នកឲ្យការប្រៀនប្រដៅ ។

ចប់អដ្ឋកថា នកុលសូត្រទី ៦

# អដ្ឋកថា កុសលសូត្រទី ៧

*(ទ្រង់ទូន្មានឲ្យឃើញច្បាស់ក្នុងកុសលធម៌)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុសលសូត្រទី ៧ ដូចតទៅនេះ ៖*

[១៧] *បទថា* ***បដិសល្លានា វុដ្ឋិតោ*** *(ទ្រង់ចេញចាកទីសម្ងំ) បានដល់ ស្ដេចចេញចាកពីទីសម្ងំនៅមួយអង្គឯង គឺ ចាកការសម្ងំធម៌ដោយឈាន បានដល់ ចាកវិហារធម៌ គឺ ផលសមាបត្តិ ។ បទថា* ***យថាវិហារំ*** *(ទៅកាន់វិហាររៀងៗ ខ្លួន) បានដល់ វិហារដែលជាទីនៅរៀងៗ ខ្លួន ។ បទថា* ***នវា*** *(ថ្មី) បានដល់ ភិក្ខុបួសថ្មី ។ ភិក្ខុទាំងនោះមានប្រមាណ ៥០០ រូប ។ បទថា* ***កាកច្ឆមានា*** *(សិងស្រមុក) បានដល់ ការធ្វើសំឡេងដូចក្អែក និងសង្កៀតធ្មេញ ។ បទថា* ***ថេរា*** *(ព្រះថេរៈ) បានដល់ ភិក្ខុជាអ្នកដល់នូវភាពមាំមួន ។ បទថា* ***តេន នោ*** *កែជា* ***តេន នុ*** *ប្រែថា ព្រោះហេតុនោះឬហ្ន៎ ។ បទថា* ***សេយ្យសុខំ*** *(ការដេកជាសុខ) ជាដើម មានអត្ថតាមដែលធ្លាប់បានពោលហើយ ។ បទថា* ***រដ្ឋិកោ*** *(អ្នកជំក្នុងដែន) អ្នកគ្រប់គ្រងរដ្ឋ ។ អ្នកគ្រប់គ្រងត្រកូលតអំពីបិតា ឈ្មោះថា* ***បេត្តនិកោ*** *(អ្នក*

ជាទាយាទនៃត្រកូល) ។ អ្នកជាប្រមុខនៃសេនា (មេទ័ព) ឈ្មោះថា សេនាបតិកោ (អ្នកដែលជាសេនាបតី) ។ អ្នកគ្រប់គ្រងស្រុក ឈ្មោះថា គាមគាមណិកោ (អ្នកគ្រប់គ្រងស្រុក) ។ អ្នកជាធំក្នុងពួកគណៈ ឈ្មោះថា បូគគាមណិកោ (អ្នកគ្រប់គ្រងពួកគណៈ) ។ បទថា អវិបស្សកោ កុសលានំ ធម្មានំ (មិនឃើញច្បាស់នូវកុសលធម៌ទាំងឡាយ) បានដល់ ជាអ្នកមិនស្វែងរក គឺ មិនស្វែងរកកុសលធម៌ទាំងឡាយ ។ បទថា ពោធិបក្ខិយានំ ធម្មានំ (ពោធិបក្ខិយធម៌) បានដល់ ពោធិបក្ខិយធម៌ ៣៧ ប្រការ ។

ចប់អដ្ឋកថា កុសលសូត្រទី ៧

# អដ្ឋកថា មច្ឆសូត្រទី ៨

## (ទោសនៃការសម្លាប់ត្រីជាដើម)

គប្បីជ្រាបវិនិច្ឆ័យក្នុង មច្ឆសូត្រទី ៨ ដូចតទៅនេះ ៖

[១៨] បទថា **មច្ឆិកំ** (ព្រានប្រមង់) បានដល់ អ្នកសម្លាប់ត្រី ។ បទថា **ហត្ថិយាយី** (ជិះដំរី) ព្រោះទៅដោយដំរី ។ សូម្បីស័ព្ទតទៅខាងមុខ ក៏មានន័យនេះដូចគ្នា ។ បទថា **វជ្ឈេ** (ដែលគប្បីសម្លាប់) បានដល់ ដែលគួរសម្លាប់ ។ បទថា **វធាយានីតេ** (នាំមកដើម្បីសម្លាប់) បានដល់ ដែលគេនាំទៅដើម្បីសម្លាប់ ។ បទថា **បាបកេន មនសា** (ដោយចិត្តដែលជាបាប) បានដល់ ដោយចិត្តគិតនឹងសម្លាប់ដ៏លាមក ។ តែក្នុងព្រះបាលីសរសេរទុកថា **វធាយុបនីតេ** (នាំចូលមកដើម្បីនឹងសម្លាប់) ។ បទថា **មាគវិកោ** (ព្រានម្រឹគ) បានដល់ អ្នកសម្លាប់ម្រឹគ ។ បទថា **កោ បន វាទោ មនុស្សភូតំ**[១] (ចាំបាច់និយាយថ្វីដល់បុគ្គលដែលសម្លឹងមើលមនុស្ស) សេចក្តីថា ចំពោះបុគ្គលដែលមានចិត្តលាមក សម្លឹងមើលមនុស្ស ចាំបាច់

(១) បិដក = កោ បន វាទោ យំ មនុស្សភូតំ ។

និយាយថា ក្នុងការមិនមានសម្បត្តិ ។ សេចក្តីនេះ ព្រះមានព្រះភាគត្រាស់ទុកដើម្បីទ្រង់សំដែងថា បាបកម្មមានផលមិនគួរប្រាថ្នា ។ តែបើសូម្បីបុគ្គលណាធ្វើបាបកម្មដូច្នោះ ត្រឡប់បានយស សេចក្តីនោះគប្បីយល់ថា កុសលឲ្យផលដល់គេប៉ុណ្ណោះ ព្រោះអាស្រ័យកុសលនោះ ។ តែវិបាកមិនទៀងទាត់អស់កាលយូរទេ ព្រោះវិបាកនោះ នឹងត្រូវអកុសលកម្មនោះកាត់ផ្តាច់ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ធម៌ដែលជាចំណែកអកុសលទុកតែម្យ៉ាង ។

ចប់អដ្ឋកថា មច្ឆសូត្រទី ៨

# អដ្ឋកថា បឋមមរណស្សតិសូត្រទី ៩

## (ការចម្រើនមរណស្សតិមានផលច្រើន)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមមរណស្សតិសូត្រទី ៩ ដូចតទៅនេះ ៖

[១៩] បទថា **នាទិកេ** (ទៀបនាទិកគ្រាម) បានដល់ ក្នុងស្រុកដែលមានឈ្មោះយ៉ាងនេះ ។ បទថា **គិញ្ជកាវសថេ** (ទ្រង់គង់នៅក្នុងប្រសាទឥដ្ឋ) បានដល់ ក្នុងប្រាសាទដែលធ្វើដោយឥដ្ឋ ។ បទថា **អមតោគធា** (ឈានចុះកាន់អមតៈ) បានដល់ ឈានចុះកាន់ព្រះនិព្វាន អធិប្បាយថា ចូលកាន់ព្រះនិព្វាន ។ បទថា **ភាវេថ នោ** កែជា **ភាវេថ នុ** ប្រែថា រមែងចម្រើនឬ ។ បទថា **មរណស្សតឹ** (មរណស្សតិ) បានដល់ មរណស្សតិកម្មដ្ឋាន ។ បទថា **អហោ វត** (ឱហ្ន៎) ជានិបាត ចុះក្នុងអត្ថថា ប្រាថ្នា ។ បទថា **ពហុ វត មេ កតំ អស្ស** (យើងគប្បីធ្វើនូវកិច្ចឲ្យបានច្រើន) សេចក្តីថា ខ្ញុំព្រះអង្គគប្បីធ្វើកិច្ចក្នុងសាសនារបស់ព្រះអង្គឲ្យច្រើន ។ បទថា **តទន្តរំ** (ជួរខណៈ) បានដល់ ក្នុងរវាង គឺ ខណៈ បានដល់ ឱកាសនោះ ។ បទថា **អស្សសិត្វា វា បស្សសាមិ** (ដកដង្ហើមចូល ហើយដកដង្ហើមចេញ

វិញ) នេះ មានវិនិច្ឆ័យដូចតទៅនេះ ខ្យល់ដែលចូលទៅខាងក្នុង លោកហៅថា ខ្យល់អស្សាសៈ , ខ្យល់ដែលចេញមកខាងក្រៅ លោកហៅថា ខ្យល់បស្សាសៈ ។ ភិក្ខុនេះប្រារព្ធការរស់នៅតែក្នុងខណៈពេលដែលខ្យល់ចូលទៅខាងក្នុង ហើយចេញមកខាងក្រៅ , ខ្យល់ដែលចេញទៅខាងក្រៅ ហើយចូលមកខាងក្នុងវិញ ទើបបានទូលយ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា **ទន្ធំ (ទន់ខ្សោយ)** បានដល់ ប្រព្រឹត្តទៅទន់ខ្សោយៗ យឺតយូរ គឺ មិនរហ័ស ។ បទថា **អាសវានំ ខយាយ (ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ)** បានដល់ ដើម្បីព្រះអរហត្តផល ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់មរណស្សតិរហូតដល់អរហត្តផល ។

ចប់អដ្ឋកថា បឋមមរណស្សតិសូត្រទី ៩

# អដ្ឋកថា ទុតិយមរណស្សតិសូត្រទី ១០

*(វិធីចម្រើនមរណស្សតិឲ្យមានផលច្រើន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយមរណស្សតិសូត្រទី ១០ ដូចតទៅនេះ ៖*

*[២០] បទថា **បដិហិតាយ** (យាងចូលមក) បានដល់ ដំណើរទៅ ។ បទថា **ឥតិ បដិសញ្ចិក្ខតិ** (រមែងពិចារណាឃើញដូច្នេះ) បានដល់ រមែងពិចារណាយ៉ាងនេះ ។ បទថា **សោ មមស្ស អន្តរាយោ** (អន្តរាយនោះគប្បីមានដល់យើង) បានដល់ អន្តរាយ ៣ យ៉ាង គឺ អន្តរាយនៃជីវិត ១ អន្តរាយនៃសមណធម៌ ១ អន្តរាយសួគ៌ និងអន្តរាយនៃមគ្គសម្រាប់អ្នកធ្វើកាលកិរិយាទាំងនៅជាបុថុជ្ជន ១ ។ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ទ្រង់សំដៅដល់អន្តរាយសូម្បីទាំងអស់នោះ ។ បទថា **ព្យាបជ្ជេយ្យ** (គប្បីជាទោស) បានដល់ គប្បីវិនាសទៅដោយអំណាចនៃការមិនរលាយអាហារជាដើម ។ បទថា **អធិមត្តោ** (ឲ្យមានប្រមាណក្រៃលែង) បានដល់ ឲ្យមានកម្លាំង ។ ការពេញចិត្ត គឺ ភាពជាអ្នកប្រាថ្នានឹងធ្វើ ឈ្មោះថា **ឆន្ទោ** (ឆន្ទៈ) ។ សេចក្ដីព្យាយាមក្នុងការប្រកបកិច្ចការងារ ឈ្មោះថា **វាយាមោ***

(សេចក្ដីព្យាយាម) ។ សេចក្ដីព្យាយាមដែលជាហេតុនៃការខ្មីឃ្មាត ឈ្មោះថា **ឧស្សាហោ** (សេចក្ដីខ្មីឃ្មាត) ។ សេចក្ដីព្យាយាមដែលជាហេតុឲ្យដល់ព្រម (សម្រេច) ឈ្មោះថា **ឧស្សោឡ្ហី** (សេចក្ដីប្រឹងប្រែង) ។ ការមិនរាថយ គឺ ការមិនថយក្រោយ ឈ្មោះថា **អប្បដិវានី** (ការប្រព្រឹត្តមិនថយក្រោយ) ។ បទដ៏សេសក្នុងទីទាំងពួង មានន័យងាយយល់ហើយ ។

ចប់អដ្ឋកថា ឧតិយមរណស្សតិសូត្រទី ១០

## ចប់សារាណីយាទិវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# អនុត្តរិយវគ្គវណ្ណនាទី ៣

## អដ្ឋកថា សាមកសូត្រទី ១

*(ធម៌ធ្វើឲ្យវិនាស ដែលទ្រង់ត្រាស់ទុកនៅក្នុងសាមគ្រាម)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាមកសូត្រទី ១ ដូចតទៅនេះ ៖*

[២១] *បទថា* ***សាមគាមកេ*** *(ជិតសាមគ្រាម) បានដល់ ក្នុងស្រុកដែលមានឈ្មោះយ៉ាងនេះ ព្រោះមានវត្ថុខ្មៅៗ ច្រើន ។ បទថា* ***បោក្ខរណិយាយំ*** *(បោក្ខរណីយវិហារ) បានដល់ ក្នុងវិហារដែលមានឈ្មោះថា បោក្ខរណីយ៍ ។ បទថា* ***អភិក្កន្តាយ រត្តិយា*** *(កាលរាត្រីកន្លងហើយ) បានដល់ កាលកន្លងបឋមយាមនៃរាត្រីកាល ជិតចូលមជ្ឈិមយាម ។ បទថា* ***អភិក្កន្តវណ្ណា*** *(មានរស្មីរុងរឿង) បានដល់ មានសម្បុរស្រស់ស្អាត គួរពេញចិត្ត ។ បទថា* ***កេវលកប្បំ*** *(ទាំងអស់) បានដល់ ទូទៅទាំងអស់ ។ បទថា* ***បោក្ខរណិយំ ឱភាសេត្វា*** *(ញុំាងបោក្ខរណីវិហារ... ឲ្យភ្លឺស្វាង) បានដល់ ផ្សាយរស្មី (ឱភាស) របស់ខ្លួនទៅ រហូតដល់មហាវិហារឈ្មោះថា បោក្ខរណីយ៍ ។ បទថា* ***សមនុញ្ញោ*** *(ទ្រង់ពេញព្រះទ័យ) បានដល់ ទ្រង់*

ពេញព្រះទ័យ គឺ ទ្រង់មានចិត្តស្មើ ។ បទថា **ទោវចស្សតា** (ជាអ្នកប្រដៅដោយក្រ) បានដល់ ភាពជាអ្នកពោលប្រដៅបានដោយលំបាក ។ បទថា **បាបមិត្តតា** (ជាអ្នកមានមិត្រអាក្រក់) បានដល់ ជាអ្នកមានមនុស្សអាក្រក់ជាមិត្រ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ធម៌ដែលប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសតែម្យ៉ាង ។

ចប់អដ្ឋកថា សាមកសូត្រទី ១

# អដ្ឋកថា អបរិហានិយសូត្រទី ២

*(ធម៌មិនមែនជាទីតាំងនៃសេចក្តីវិនាស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អបហានិយសូត្រទី ២ ដូចតទៅនេះ ៖*

*[២២] ក្នុងអបរិហានិយសូត្រទី ២ ព្រះមានព្រះភាគត្រាស់ធម៌មិនមែនជាទីតាំងនៃសេចក្តីវិនាស ដែលលាយដោយលោកុត្តរទុកហើយ ។*

*ចប់អដ្ឋកថា អបរិហានិយសូត្រទី ២*

# អដ្ឋកថា ភយសូត្រទី ៣

*(ភ័យជាឈ្មោះរបស់កាម)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភយសូត្រទី ៣ ដូចតទៅនេះ ៖*

*[២៣] បទថា **កាមរាគរត្តាយំ** កាត់បទជា **កាមរាគរត្តា អយំ** ប្រែថា សត្វលោកដែលត្រូវសេចក្តីប្រាថ្នាក្នុងកាមដុតរោលហើយ ។ បទថា **ឆន្ទរាគវិនិពន្ធា** (ត្រូវសេចក្តីប្រាថ្នា ព្រោះសេចក្តីពេញចិត្តចងទុក) បានដល់ ត្រូវឆន្ទរាគចងជាប់ហើយ ។ បទថា **ភយា** (អំពីភ័យ) បានដល់ អំពីភ័យ គឺ សេចក្តីតក់ស្លុតនៃចិត្ត ។ បទថា **បង្កា** (អំពីភក់) បានដល់ បាកពីភក់ គឺ កិលេស ។*

*បទថា **សង្គោ បង្កោ ច ឧភយំ** (និងវត្ថុទាំង ២ គឺ គ្រឿងជាប់ជំពាក់ផង ភក់ផង) បានដល់ ទាំងពីរយ៉ាងនេះ គឺ គ្រឿងជាប់ជំពាក់ និងភក់ ។ ពីរបាទក្នុងព្រះគាថាថា **ឯតេ កាមា បវុច្ចន្តិ យត្ថ សត្តោ បុថុជ្ជនោ** (តថាគតហៅ... ដែលជាទីជាប់នៅរបស់បុថុជ្ជនថា ជាកាម) បានដល់ បុថុជ្ជន ជាប់ ជាប់ជំពាក់ ទាក់ទង ពាក់ព័ន្ធ ក្នុងគ្រឿងជាប់ និង*

ភក់ណា ។

បទថា **ឧបាទានេ (ក្នុងឧបាទាន)** បានដល់ ក្នុងឧបាទាន ៤ យ៉ាង ។ បទថា **ជាតិមរណសម្ភវេ (ជាដែនកើតនៃជាតិ និងមរណៈ)** បានដល់ ជាទីកើត គឺ ជាបច្ច័យនៃជាតិ និងមរណៈ ។ បទថា **អនុបាទា វិមុច្ចន្តិ (រមែងរួចផុត ព្រោះមិនប្រកាន់)** បានដល់ មិនប្រកាន់ហើយ រមែងរួចផុត ។ បទថា **ជាតិមរណសង្ខយេ (ព្រោះការអស់ជាតិ និងមរណៈ)** បានដល់ ក្នុងព្រះនិព្វាន ពោលគឺ ការអស់ទៅនៃជាតិ និងមរណៈ អធិប្បាយថា រមែងរួចផុតដោយវិមុត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ។ ភិក្ខុនេះមិនវិលមកក្នុងឋានៈនេះ ហើយសម្រេចព្រះអរហត្តនោះឯង ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់លើកសរសើរព្រះខីណាស្រពនោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **តេ ខេមប្បត្តា (ដល់នូវសេចក្តីក្សេមក្សាន្ត)** ។ បណ្តាបទទាំងនោះ បទថា **ខេមប្បត្តា** បានដល់ ដល់នូវសេចក្តីក្សេម ។ បទថា **សុខិនោ (មានសុខ)** បានដល់ សេចក្តីសុខ ដោយលោកុត្តរសុខ ។ បទថា **ទិដ្ឋធម្មាភិនិព្វុតា (រលត់ក្នុងបច្ចុប្បន្ន)** បានដល់ រលត់កិលេសហើយ

ក្នុងបច្ចុប្បន្ននេះឯង ព្រោះមិនមានកិលេសក្នុងខាងក្នុង ។ ព្រះមានព្រះភាគ ត្រាស់ចំពោះតែសេចក្តីវិនាសប៉ុណ្ណោះក្នុងសូត្រ តែទ្រង់ត្រាស់ទាំងចំណែក សេចក្តីវិនាស និងសេចក្តីចម្រើនក្នុងគាថា ។

ចប់អដ្ឋកថា ភយសូត្រទី ៣

# អដ្ឋកថា ហិមវន្តសូត្រទី ៤

## (ធម៌ដែលទម្លាយភ្នំហិមវន្តបាន)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ហិមវន្តសូត្រទី ៤ ដូចតទៅនេះ ៖*

*[២៤] បទថា* ***បទាលេយ្យ (គប្បីទម្លាយ)*** *បានដល់ គប្បីទម្លាយ ។ បទថា* ***ឆវាយ (ដ៏លាមក)*** *បានដល់ ថោកទាប ។ បទថា* ***សមាធិស្ស សមាបត្តិកុសលោ ហោតិ (ជាអ្នកឈ្លាសក្នុងការចូលសមាធិ)*** *សេចក្តីថា ជាអ្នកឈ្លាស វាងវៃ អាច អង់អាច ដើម្បីកំណត់យកអាហារដែលជាទីសប្បាយ និងរដូវជាទីសប្បាយ ហើយចូលសមាធិ ។ បទថា* ***សមាធិស្ស ឋិតិកុសលោ (ឈ្លាសក្នុងការធ្វើសមាធិឲ្យតាំងនូវតាមកំណត់)*** *សេចក្តីថា ជាអ្នកឈ្លាសក្នុងការបញ្ឈប់សមាធិបាន អធិប្បាយថា រមែងអាចបញ្ឈប់សមាធិទុកបាន ។ បទថា* ***សមាធិស្ស វុដ្ឋានកុសលោ (ឈ្លាសក្នុងការចេញចាកសមាធិ)*** *សេចក្តីថា ជាអ្នកឈ្លាសក្នុងការចេញចាកសមាធិ អធិ-ប្បាយថា រមែងចេញបានតាមកំណត់ ។ បទថា* ***សមាធិស្ស កល្លតាកុ-សលោ (ឈ្លាសក្នុងការបែងចែកសមាធិ)*** *សេចក្តីថា ជាអ្នកឈ្លាសក្នុង*

ការបែងចែកសមាធិ អធិប្បាយថា រមែងធ្វើសមាធិចិត្តឲ្យរីករាយ គឺ ធ្វើសមាធិចិត្តឲ្យដល់ព្រម ។ បទថា **សមាធិស្ស គោចរកុសលោ** (ឈ្លាសក្នុងអារម្មណ៍របស់សមាធិ) សេចក្តីថា ភិក្ខុកាលវៀរចាកធម៌ដែលជាអសប្បាយ គឺ មិនមានឧបការៈដល់សមាធិហើយ សេពធម៌ដែលជាទីសប្បាយ គឺ មានឧបការៈដល់សមាធិក្តី កាលដឹងថា សមាធិនេះមាននិមិត្តជាអារម្មណ៍ សមាធិនេះមានលក្ខណៈជាអារម្មណ៍ក្តី ឈ្មោះថា ជាអ្នកឈ្លាសក្នុងអារម្មណ៍សមាធិ ។ បទថា **សមាធិស្ស អភិនិហារកុសលោ** (ឈ្លាសក្នុងការសន្សំនូវសមាធិ) សេចក្តីថា ភិក្ខុកាលនាំសមាធិ មានបឋមជាដើមឲ្យឈានទៅមុខ ដើម្បីប្រយោជន៍ដល់ការចូលសមាធិជាន់ខ្ពស់ៗ ឡើងទៅ ឈ្មោះថា ជាអ្នកឈ្លាសក្នុងការសន្សំសមាធិ គឺ លោកចេញចាកបឋមឈាន ហើយចូលទុតិយឈាន ចេញចាកទុតិយឈានហើយ ។ល។ ចេញចាកតតិយឈាន ហើយចូលចតុត្ថឈាន ដូច្នេះឯង ។

ចប់អដ្ឋកថា ហិមវន្តសូត្រទី ៤

# អដ្ឋកថា អនុស្សតិដ្ឋានសូត្រទី ៥

## (ធម៌ជាទីតាំងអនុស្សតិ)

គប្បីជ្រាបវិនិច្ឆ័យក្នុង អនុស្សតិដ្ឋានសូត្រទី ៥ ដូចតទៅនេះ ៖

[២៥] បទថា *អនុស្សតិដ្ឋានានិ (ទីតាំងនៃសេចក្ដីរឭក)* បានដល់ហេតុនៃអនុស្សតិ ។ បទថា *ឥតិបិ សោ ភគវា (សូម្បីព្រោះហេតុនេះៗ ព្រះមានព្រះភាគព្រះអង្គនោះ)* ជាដើម ខ្ញុំបានឲ្យពិស្ដារក្នុងគម្ពីរវិសុទ្ធិមគ្គនោះហើយ ។ បទថា *ឥទម្បិ ខោ ភិក្ខវេ អារម្មណំ ករិត្វា (ធ្វើពុទ្ធានុស្សតិសូម្បីនេះឲ្យជាអារម្មណ៍)* បានដល់ ធ្វើពុទ្ធានុស្សតិកម្មដ្ឋាននេះឲ្យជាអារម្មណ៍ ។ បទថា *វិសុជ្ឈន្តិ (រមែងបរិសុទ្ធបាន)* បានដល់ ដល់ព្រះនិព្វានដ៏បរិសុទ្ធដ៏ក្រៃលែង ។ បទដ៏សេសក្នុងបទទាំងពួង មានសេចក្ដីងាយយល់ហើយ ។ ក៏ក្នុងសូត្រនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទីតាំងនៃអនុស្សតិ ៦ យ៉ាង លាយគ្នា (ទាំងលោកិយៈ និងលោកុត្តរៈ ។

ចប់អដ្ឋកថា អនុស្សតិដ្ឋានសូត្រទី ៥

# អដ្ឋកថា កច្ចានសូត្រទី ៦

## (ព្រះកច្ចានៈពោលទីតាំងអនុស្សតិ)

គប្បីជ្រាបវិនិច្ឆ័យក្នុង កច្ចានសូត្រទី ៦ ដូចតទៅនេះ ៖

[២៦] បទថា **សម្ពាធេ (ក្នុងទីដ៏ចង្អៀត)** បានដល់ ក្នុងទីដែលចង្អៀតដោយកាមគុណ ៥ ។ ទីតាំងនៃអនុស្សតិ ៦ ហៅថា ឱកាស ក្នុងបទថា **ឱកាសាធិគមោ (ការបានឱកាស)** នេះ បានដល់ ការសម្រេចហេតុនៃអនុស្សតិទាំង ៦ នោះ ។ បទថា **វិសុទ្ធិយា (ដើម្បីសេចក្ដីបរិសុទ្ធ)** បានដល់ ដើម្បីប្រយោជន៍ដល់សេចក្ដីបរិសុទ្ធ ។ បទថា **សោកបរិទេវានំ សមតិក្កមាយ (ដើម្បីឈានកន្លងសេចក្ដីសោកខ្សឹកខ្សួល)** បានដល់ ដើម្បីប្រយោជន៍ដល់កន្លងបង់នូវសេចក្ដីសោក និងខ្សឹកខ្សួល ។ បទថា **អត្ថង្គមាយ (ដើម្បីរលត់)** បានដល់ ដើម្បីប្រយោជន៍ដល់ការតាំងនៅមិនបាន ។ បទថា **ញាយស្ស អធិគមាយ (ដើម្បីលុះញេយ្យធម៌)** បានដល់ ដើម្បីប្រយោជន៍ដល់ការសម្រេចមគ្គព្រមដោយវិបស្សនា ។ បទថា **និព្វានស្ស សច្ឆិកិរិយាយ (ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិព្វាន)** បានដល់ ដើម្បី

ប្រយោជន៍ដល់ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលរកបច្ច័យមិនបាន ។

បទថា **សព្វសោ** (ដោយប្រការទាំងពួង) បានដល់ ដោយអាការទាំងពួង ។ បទថា **អាកាសសមេន** (ស្មើដោយអាកាស) បានដល់ ដូចជាអាកាស ព្រោះអត្ថថា មិនជាប់ និងព្រោះអត្ថថា មិនមានកន្លង់ ។ បទថា **វិបុលេន** (ធំទូលាយ) បានដល់ មិនមែនតិចតួច ។ បទថា **មហគ្គតេន** (ធំ) បានដល់ ដល់ភាពជាធំ ឬដែលព្រះអរិយសាវកអ្នកជាធំ គឺ ដំណើរទៅហើយ ។ បទថា **អប្បមាណេន** (មិនមានប្រមាណ) បានដល់ ឈ្មោះថា មិនមានប្រមាណ ព្រោះមិនមានប្រមាណនៃការផ្សាយទៅ ។ បទថា **អវេរេន** (មិនមានពៀរ) បានដល់ វៀរចាកអកុសលធម៌ដែលជាពៀរ និងបុគ្គលអ្នកមានពៀរ ។ បទថា **អព្យាបជ្ជេន** (មិនមានព្យាបាទ) បានដល់ វៀរអំពីទុក្ខដែលកើតអំពីសេចក្ដីក្រោធ ។ បទទាំងអស់នេះ ព្រះមហាកច្ចានៈពោលសំដៅដល់ចិត្ត ដែលមានពុទ្ធានុស្សតិជាអារម្មណ៍ប៉ុណ្ណោះ ។ សូម្បីសេចក្ដីតទៅ ក៏មានន័យនេះដូចគ្នា ។ បទថា **វិសុទ្ធិធម្មា** (មានសេចក្ដីបរិសុទ្ធជាធម្មតា) បានដល់ មានសេចក្ដីបរិសុទ្ធជាសភាវៈ ។ សូម្បីក្នុង

សូត្រនេះ ព្រះមហាកច្ចានៈក៏ពោលដល់ទីតាំងនៃអនុស្សតិ ៦ លាយគ្នា ដោយប្រការដូច្នោះឯង ។

ចប់អដ្ឋកថា កច្ចានសូត្រទី ៦

# អដ្ឋកថា បឋមសមយសូត្រទី ៧

## (សម័យដែលគួរចូលទៅជួបអ្នកចម្រើនភាវនា)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសមយសូត្រទី ៧ ដូចតទៅនេះ ៖

[២៧] បទថា *មនោភាវនិយស្ស (អ្នកចម្រើនភាវនាផ្លូវចិត្ត)* នេះ មានវិគ្រោះថា ភិក្ខុឈ្មោះថា *អ្នកចម្រើនភាវនាផ្លូវចិត្ត* ព្រោះអត្ថថា អប់រំចិត្ត គឺ ញុំាងចិត្តឲ្យចម្រើន ។ បទថា *ទស្សនាយ (ជួប)* បានដល់ ដើម្បីឃើញ ។ បទថា *និស្សរណំ (នូវឧបាយជាគ្រឿងរលាស់ចេញ)* បានដល់ ផ្លូវចេញ គឺ សេចក្តីស្ងប់រំងាប់ ។ *ធម្មំ ទេសេតិ (រមែងសម្តែងធម៌)* ប្រាប់អសុភកម្មដ្ឋាន ដើម្បីត្រូវការលះបង់កាមរាគៈ ។ ក្នុងវារៈទី ២ ជាដើមគប្បីជ្រាបថា ប្រាប់មេត្តាកម្មដ្ឋានដើម្បីលះព្យាបាទ ប្រាប់កម្មដ្ឋានដែលជាហេតុបន្ទោបង់ថីនមិទ្ធៈ គឺ អាលោកសញ្ញា ឬកម្មដ្ឋានដែលជាទីតាំងនៃវិរិយារម្ភៈជាដើមយ៉ាងណាមួយ ដើម្បីលះថីនមិទ្ធៈ ប្រាប់សមថកម្មដ្ឋានដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ប្រាប់កថាប្រារព្ធគុណរបស់ព្រះរតនត្រ័យដើម្បីលះវិចិកិច្ឆា ឈ្មោះថា *សម្តែងធម៌* ។ បទថា *អាគម្ម (អាស្រ័យ)* បានដល់

ប្រារព្ធ ។ បទថា **មនសិករោតោ** (ធ្វើទុកក្នុងចិត្ត) បានដល់ ធ្វើទុកក្នុងចិត្តឲ្យជាអារម្មណ៍ ។ បទថា **អនន្តរា អាសវានំ ខយោ ហោតិ** (**អាសវៈទាំងឡាយរមែងអស់ទៅដោយឥតមានចន្លោះ**) បានដល់ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដោយប្រាសចាកអន្តរាយ ។

ចប់អដ្ឋកថា បឋមសមយសូត្រទី ៧

# អដ្ឋកថា ទុតិយសមយសូត្រទី ៨

## (សម័យដែលគួរចូលទៅជួបអ្នកចម្រើនភាវនា)

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសមយសូត្រទី ៨ ដូចតទៅនេះ ៖

[២៨] បទថា **មណ្ឌលមាឡេ (ក្នុងរោងឆាន់)** បានដល់ ត្រង់សាលាឆាន់ ។ បទថា **ចារិត្តកិលមថោ (សេចក្តីលំបាកព្រោះការត្រាច់ទៅដើម្បីបិណ្ឌបាត)** បានដល់ សេចក្តីលំបាកដែលកើតឡើងពីការត្រាច់បិណ្ឌបាត ។ បទថា **ភត្តកិលមថោ (សេចក្តីលំបាកព្រោះឆាន់អាហារ)** បានដល់ សេចក្តីខ្វល់ខ្វាយដែលកើតអំពីភត្ត ។ បទថា **វិហារបច្ឆាយាយំ (ត្រង់ម្លប់ខាងក្រោយវិហារ)** បានដល់ ត្រង់ម្លប់ក្រោយវិហារ ។ បទថា **យទេវស្ស ទិវា សមាធិនិមិត្តំ មនសិកតំ ហោតិ (សមាធិនិមិត្តណា ដែលភិក្ខុចម្រើនភាវនាផ្លូវចិត្តនោះ បានធ្វើទុកក្នុងចិត្តក្នុងវេលាថ្ងៃ)** បានដល់ សមថនិមិត្តណានុ៎ះឯង ដែលភិក្ខុចម្រើនផ្លូវចិត្តនោះ ធ្វើទុកក្នុងចិត្តក្នុងចំណែកនៃថ្ងៃមុន (ដែលអង្គុយត្រង់ម្លប់វិហារ) នោះ ។ បទថា **តទេវស្ស តស្មឹ សមយេ សមុទាចរតិ (សម័យនោះ... សមាធិនិមិត្តនោះ ក៏នៅប្រាកដ)** បានដល់

ក្នុងសម័យនោះ សមថនិមិត្តនោះឯង នៅប្រព្រឹត្តទៅក្នុងមនោទ្វាររបស់ភិក្ខុនោះដែលអង្គុយនៅក្នុងទីសម្រាកពេលថ្ងៃត្រង់ ។ បទថា **ឱជដ្ឋាយិស្ស (នៅមានឱជាតាំងនៅ)** បានដល់ តាំងនៅ គឺ តាំងនៅបានដោយឱជារស ។ បទថា **ផាសុកស្ស ហោតិ (សេចក្តីសប្បាយរមែងមានដល់ភិក្ខុអ្នកចម្រើនការនាផ្លូវចិត្តនោះ)** បានដល់ សេចក្តីសប្បាយរមែងមានដល់លោក ។ បទថា **សម្មុខា (ចំពោះព្រះភក្ត្រ)** បានដល់ ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគដែលទ្រង់ត្រាស់ដឹងហើយ ។ បទថា **សុតំ (បានស្តាប់)** បានដល់ បានស្តាប់ដោយសោតធាតុ ។ បទថា **បដិគ្គហិតំ (ទទួលមក)** បានដល់ ទទួលមកដោយចិត្ត ។

ចប់អដ្ឋកថា ទុតិយសមយសូត្រទី ៨

# អដ្ឋកថា ឧទាយិសូត្រទី ៩

## (ត្រាស់សួរព្រះឧទាយីអំពីទីតាំងអនុស្សតិ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧទាយីសូត្រទី ៩ ដូចតទៅនេះ ៖*

*[២៩] បទថា **ឧទាយិ** បានដល់ ព្រះលោឡុទាយិត្ថេរៈ ។ បទថា **សុណាមហំ អាវុសោ (ម្នាលអាវុសោអានន្ទ ខ្ញុំបានឮហើយ)** បានដល់ អាវុសោ ខ្ញុំមិនមែនជាមនុស្សថ្លង់ ខ្ញុំបានឮព្រះតម្រាស់របស់ព្រះមានព្រះភាគ តែខ្ញុំនៅតែគិតពិចារណាបញ្ហា ។ បទថា **អធិចិត្តំ (អធិចិត្ត)** បានដល់ សមាធិចិត្ត និងវិបស្សនាចិត្ត ។ បទថា **ឥទំ ភន្តេ អនុស្សតិដ្ឋានំ (បពិត្រព្រះអង្គដ៏ចម្រើន នេះជាទីតាំងនៃអនុស្សតិ)** បានដល់ នេះជាហេតុនៃអនុស្សតិ ពោលគឺ ឈានទាំង ៣ ។ បទថា **ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ (រមែងប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន)** បានដល់ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ការនៅជាសុខក្នុងអត្តភាពនេះប៉ុណ្ណោះ ។*

*បទថា **អាលោកសញ្ញំ (សំគាល់នូវពន្លឺ)** បានដល់ សញ្ញាដែលកើតឡើងក្នុងអាលោកនិមិត្ត ។ បទថា **ទិវាសញ្ញំ អធិដ្ឋាតិ (រមែងតាំង***

សញ្ញាថា ជាវេលាថ្ងៃ) បានដល់ តាំងសញ្ញាទុកថា ពេលថ្ងៃ ។ បទថា យថា ទិវា តថា រត្តឹ (លោកធ្វើអាលោកសញ្ញាថា វេលាថ្ងៃទុកក្នុងចិត្ត យ៉ាងណា ក្នុងវេលាយប់ក៏ដូច្នោះ) សេចក្តីថា ក្នុងវេលាថ្ងៃ លោកមនសិការអាលោកសញ្ញាដោយប្រការណា សូម្បីក្នុងវេលាយប់ ក៏មនសិការអាលោកសញ្ញានោះ ដោយប្រការនោះដូចគ្នា ។ បទថា វិវដេន (ត្រចះត្រចង់) បានដល់ ប្រាកដច្បាស់ ។ បទថា អបរិយោនទ្ធេន (ដែលនីវរណៈរួបរឹតមិនបាន) បានដល់ មិនត្រូវនីវរណៈទាំងឡាយរួបរឹត ។

បទថា សប្បភាសំ ចិត្តំ ភាវេតិ (រមែងចម្រើនចិត្តប្រកបដោយពន្លឺ) បានដល់ តែងចម្រើនចិត្តព្រមដោយពន្លឺ គឺ ញុំាងចិត្តនោះឲ្យចម្រើន ដើម្បីប្រយោជន៍ដល់ទិព្វចក្ខុញាណ ។ ក៏ពាក្យណាដែលព្រះអានន្ទក្រាបទូលថា អាលោកសញ្ញំ មនសិករោតិ (រមែងធ្វើអាលោកសញ្ញាទុកក្នុងចិត្ត) បទនោះគប្បីយល់ថា លោកពោលសំដៅយកអាលោកសញ្ញា ដែលកំចាត់ថីនមិទ្ធៈចេញ មិនពោលសំដៅយកអាលោកសញ្ញា គឺ ទិព្វចក្ខុ ។ បទថា ញាណទស្សនប្បដិលាភាយ (ដើម្បីបានញាណទស្សនៈ) បានដល់

ដើម្បីការបានចំពោះនូវញាណទស្សនៈ ពោលគឺ ទិព្វចក្ខុ ។ បណ្ដាបទមានជាអាទិថា **ឥមមេវ កាយំ** (កាយនេះ) បទណាដែលគប្បីពោល បទទាំងអស់នោះ ខ្ញុំបានពោលទុកហើយដោយពិស្ដារ ដោយអាការគ្រប់យ៉ាងក្នុងវិសុទ្ធិមគ្គ ក្នុងផ្នែកពោលដោយកាយគតាសតិកម្មដ្ឋាន ។ បទថា **កាមរាគស្ស បហានាយ** (ដើម្បីលះកាមរាគ) បានដល់ ដើម្បីលះបង់រាគៈដែលកើតឡើងពីបញ្ចកាមគុណ ។

បទថា **សេយ្យថាបិ បស្សេយ្យ** (គប្បីឃើញ "សរីរៈ" ដូច) បានដល់ សរីរៈរបស់អ្នកស្លាប់ហើយ ។ បទថា **សីវថិកាយ ឆឌ្ឌិតំ** (ដែលគេចោលក្នុងព្រៃខ្មោច) បានដល់ ដែលគេចោលក្នុងព្រៃខ្មោច ។ ដែលឈ្មោះថា **ឯកាហមតំ** (ទោះស្លាប់ ១ ថ្ងៃ) ព្រោះអត្ថថា សាកសពរបស់សត្វដែលស្លាប់ហើយ ១ ថ្ងៃ ។ ដែលឈ្មោះថា **ទ្វីហមតំ** (ស្លាប់ ២ ថ្ងៃ) ព្រោះអត្ថថា ស្លាប់ហើយ ២ ថ្ងៃ ។ ដែលឈ្មោះថា **តីហមតំ** (ស្លាប់ ៣ ថ្ងៃ) ព្រោះអត្ថថា ស្លាប់ហើយ ៣ ថ្ងៃ ។ សរីរៈ ឈ្មោះថា **ឧទ្ធុមាតៈ** ព្រោះក្រោយពីអស់ជីវិតហើយ នឹងប៉ោងឡើង ដោយហើមប៉ោងទៅតាម

លំដាប់ ដូចថង់ដែលផ្ទុំដោយខ្យល់ ។ ឧទ្ធុមាតៈនោះឯង ឈ្មោះថា ឧទ្ធុ-មាតកៈ ។ មា៉្យងទៀត ឈ្មោះថា **ឧទ្ធុមាតកំ (ប៉ោងឡើង)** ព្រោះអត្ថថា សរីរៈប៉ោងឡើង គួរខ្ពើម ព្រោះជារបស់បដិកូល ។ សរីរៈដែលមានពណ៌ប្រែប្រួលទៅ ហៅថា វិនីលៈ ។ វិនីលៈនោះឯង ឈ្មោះថា វិនីលកៈ ។ មា៉្យងទៀត ដែលឈ្មោះថា **វិនីលកំ (មានពណ៌ខៀវ)** ព្រោះអត្ថថា មានពណ៌ខៀវដែលគួរឲ្យខ្ពើម ព្រោះជារបស់បដិកូល ។ បទថា **មានពណ៌ខៀវ** នេះ ជាឈ្មោះរបស់សាកសពដែលមានពណ៌ក្រហមក្នុងទីដែលមានសាច់ប្រេះបែក មានពណ៌ខៀវក្នុងទីដែលមានខ្ទុះហូរចេញ និងដោយច្រើនក៏មានពណ៌ខៀវ ដូចគ្របដោយសំពត់ពណ៌ខៀវ ត្រង់កន្លែងខៀវ ។ សរីរៈដែលមានខ្ទុះហូរចេញមកអំពីកន្លែងដែលមានស្នាមប្រេះ ឬអំពីមុខដំបៅទាំង ៩ កន្លែង ឈ្មោះថា វិបុព្វៈ ។ វិបុព្វៈនោះឯង ឈ្មោះថា វិបុព្វកៈ ។ មា៉្យងទៀត ឈ្មោះថា វិបុព្វកៈ ព្រោះអត្ថថា មានខ្ទុះហូរចេញមក គួរឲ្យខ្ពើម ព្រោះជារបស់បដិកូល ។ ដែលឈ្មោះថា **វិបុព្វកជាតំ (មានខ្ទុះចេញ)** ព្រោះអត្ថថា សាកសពមានខ្ទុះហូរចេញ គឺ មានសភាពយ៉ាងនោះ ។

បទថា *សោ ឥមមេវ កាយំ* (ភិក្ខុនោះប្រៀបធៀបនឹងកាយនេះ) បានដល់ ភិក្ខុនោះបង្អោន គឺ ធ្វើកាយរបស់ខ្លួននេះចូលទៅប្រៀបធៀបជាមួយកាយនោះដោយញាណ ។ ប្រៀបធៀបយ៉ាងណា ។ ប្រៀបធៀបថា កាយសូម្បីនេះឯង រមែងមានយ៉ាងនោះជាធម្មតា រមែងជាយ៉ាងនោះ មិនកន្លងផុតសេចក្តីនោះទៅបានឡើយ ។ មានពាក្យអធិប្បាយថា ព្រោះធម៌ទាំង ៣ យ៉ាងនេះ គឺ អាយុ ភ្លើងធាតុ និងវិញ្ញាណនៅមាន កាយនេះ ទើបគួរដល់ឥរិយាបថ មានការឈរបាន ដើរទៅបានជាដើម ។ តែព្រោះប្រាសចាកធម៌ទាំង ៣ យ៉ាងនេះ សូម្បីកាយនេះ ក៏នឹងមានសភាពយ៉ាងនេះជាធម្មតា គឺ មានសភាពប្រែក្លាយយ៉ាងនេះដូចគ្នា ។ បទថា **ឯវំភាវី (រមែងជាយ៉ាងនោះ)** បានដល់ នឹងមានប្រភេទជាសាកសពដែលប៉ោងឡើងជាដើមយ៉ាងនេះដូចគ្នា ។ បទថា **ឯវំអនតីតោ (កន្លងមិនផុតសភាពយ៉ាងនោះទៅបាន)** បានដល់ នឹងមិនកន្លងផុតសភាពជាសាកសពហើមប៉ោងយ៉ាងនេះទៅបានឡើយ ។

បទថា **ខជ្ជមានំ (ជញ្ជែងស៊ី)** បានដល់ សត្វទាំងឡាយ មានក្អែក

ជាដើម ចោះត្រង់ពោះជាដើម ហើយចឹកស៊ីសាច់ពោះ បបូរមាត់ ត្របកភ្នែកជាដើម ។ បទថា **សមំសលោហិតំ (មានសាច់ និងឈាម)** បានដល់ប្រកបដោយសាច់ និងឈាមដែលនៅសេសសល់ ។ បទថា **និម្មំសលោហិតមក្ខិតំ (មិនមានសាច់គ្រាន់តែប្រឡាក់ដោយឈាម)** បានដល់ សាច់អស់ទៅហើយ តែឈាមនៅមិនទាន់ស្ងួត ។ លោកពោលពាក្យថា **ប្រឡាក់ដោយឈាម** សំដៅដល់សាកសពនោះ ។ បទថា **អញ្ញេន (ផ្លូវមួយ)** បានដល់ ដោយទិសដទៃ ។ បទថា **ហត្ថដ្ឋិកំ (ឆ្អឹងដៃ)** បានដល់ ឆ្អឹងដៃសូម្បីមាន ៦៤ កំណាត់ ក៏ខ្ចាត់ខ្ចាយទៅទិសផ្សេងៗ ។ បទថា **បាទដ្ឋិកំ (ឆ្អឹងជើង)** ជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **តេរោវស្សិកានិ (កន្លងហួស ១ ឆ្នាំ)** បានដល់ កន្លងហួស ១ ឆ្នាំទៅហើយ ។ បទថា **បូតីនិ (ពុកផុយ)** បានដល់ ឆ្អឹងដែលតាំងនៅកណ្តាលវាលកន្លងហួស ១ ឆ្នាំនោះឯង នឹងពុកផុយព្រោះត្រូវខ្យល់ កំដៅថ្ងៃ និងភ្លៀង តែឆ្អឹងដែលកប់នៅក្នុងផែនដីនឹងនៅបានយូរជាង ។ បទថា **ចុណ្ណកជាតានិ (ជាកំទេច)** បានដល់ ខ្ចាត់ខ្ចាយខ្ទេចខ្ទីទៅ ។ ក្នុងគ្រប់ៗ បទ គប្បីជ្រាបដោយអំណាចនៃសាកសពដែល

ត្រូវសត្វកកេរស៊ីជាដើម ដោយន័យដែលពោលទុកហើយថា *សោ ឥមមេវ (ភិក្ខុ... នេះ)* ។

បទថា *អស្មិមានសមុគ្ឃាតាយ (ដើម្បីដកនូវអស្មិមានះ)* បានដល់ ដើម្បីដកចោលមានះ ៩ យ៉ាង ដែលប្រព្រឹត្តទៅហើយ ថាយើង ជាដើម ដូច្នេះ ។ បទថា *អនេកធាតុប្បដិវេធាយ (ដើម្បីត្រាស់ដឹងនូវធាតុច្រើនប្រការ)* បានដល់ ដើម្បីត្រាស់ដឹងនូវធាតុច្រើនយ៉ាង ។ បទថា *សតោវ អភិក្កមតិ (មានសតិឈានទៅមុខ)* បានដល់ កាលនឹងដើរ ក៏ជាអ្នកប្រកបដោយសតិ និងបញ្ញាដើរទៅ ។ បទថា *សតោវ បដិក្កមតិ (មានសតិថយត្រឡប់)* បានដល់ សូម្បីកាលនឹងថយត្រឡប់ ក៏ប្រកបដោយសតិ និងបញ្ញា ថយត្រឡប់ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា *សតិសម្បជញ្ញាយ (ដើម្បីបានសតិសម្បជញ្ញៈ)* បានដល់ ដើម្បីប្រយោជន៍ដល់ការរឭកបាន និងការដឹង ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់សតិ និងបញ្ញាលាយគ្នា ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា ឧទាយិសូត្រទី ៩

# អដ្ឋកថា អនុត្តរិយសូត្រទី ១០

## (វត្ថុដ៏ប្រសើរ ៦ យ៉ាង)

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុត្តរិយសូត្រទី ១០ ដូចតទៅនេះ ៖*

*[៣០] បទថា **ឧច្ចាវចំ** (របស់ធំតូច) បានដល់ របស់ធំរបស់តូច ឬរបស់ខ្ពស់របស់ទាប ណាមួយ ។ បទថា **ហីនំ** (ជារបស់អាក្រក់) បានដល់ ជារបស់ថោកទាប ។ បទថា **គម្មំ** (ជារបស់អ្នកស្រុក) បានដល់ ជាការឃើញរបស់ពួកអ្នកស្រុក ។ បទថា **បោថុជ្ជនិកំ** (ជារបស់បុថុជ្ជន) បានដល់ ជារបស់នៃបុថុជ្ជន ។ បទថា **អនរិយំ** (មិនប្រសើរ) បានដល់ មិនប្រសើរ គឺ មិនខ្ពង់ខ្ពស់ បានដល់ មិនបរិសុទ្ធ ។ បទថា **អនត្ថសញ្ហិតំ** (មិនប្រកបដោយប្រយោជន៍) បានដល់ មិនអាស្រ័យប្រយោជន៍ ។*

*បទថា **ន និព្វិទាយ** (មិន... ដើម្បីសេចក្តីនឿយណាយ) បានដល់ មិនមែនដើម្បីប្រយោជន៍ដល់ការនឿយណាយក្នុងវដ្តៈ ។ បទថា **ន វិរាគាយ** (មិន... ដើម្បីប្រាសចាកតម្រេក) បានដល់ មិនមែនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ការប្រាសចាករាគៈជាដើម ។ បទថា **ន និរោធាយ** (មិន...*

ដើម្បីការរលត់) បានដល់ មិនមែនប្រព្រឹត្តទៅដើម្បីរលត់ គឺ ការមិនប្រព្រឹត្តទៅនៃកិលេស មានរាគៈជាដើម ។ បទថា **ន ឧបសមាយ** (មិន... ដើម្បីសេចក្តីស្ងប់រម្ងាប់) បានដល់ មិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់កិលេស មានរាគៈជាដើម ។ បទថា **ន អភិញ្ញាយ** (មិន... ដើម្បីដឹងដ៏ក្រៃលែង) បានដល់ មិនមែនប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ការដឹងដ៏ក្រៃលែង ។ បទថា **ន សម្ពោធាយ** (មិន... ដើម្បីត្រាស់ដឹង) បានដល់ មិនមែនដើម្បីប្រយោជន៍ដល់ការចាក់ធ្លុះមគ្គញ្ញាណទាំង ៤ ពោលគឺ សម្ពោធិញ្ញាណ ។ បទថា **ន និព្វានាយ** (មិន... ដើម្បីនិព្វាន) សេចក្តីថា មិនមែនប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

បទថា **និវិដ្ឋសទ្ធោ** (មានសទ្ធាតាំងមាំ) បានដល់ មានសទ្ធាតាំងមាំ ។ បទថា **និវិដ្ឋបេមោ** (មានចិត្តស្រឡាញ់តាំងមាំ) បានដល់ មានសេចក្តីស្រឡាញ់មាំមួន ។ បទថា **ឯកន្តគតោ** (មានសទ្ធាមិនញាប់ញ័រ) បានដល់ ដល់នូវទីបំផុតតែម្យ៉ាង អធិប្បាយថា មានសទ្ធាមិនយោលយោង ។ បទថា **អភិប្បសន្នោ** (ជ្រះថ្លាខ្លាំង) បានដល់ ជ្រះថ្លាដ៏ក្រៃលែង ។

បទថា **ឯតទានុត្តរិយំ** (ការឃើញនេះប្រសើរបំផុត) បានដល់ ការឃើញនេះជាការឃើញដែលមិនមានការឃើញដទៃក្រៃលែងជាង ។ បទថា **ហត្ថិស្មិំ សិក្ខតិ** (សិក្សាវិជ្ជាដំរី) បានដល់ សិក្សានិមិត្តទាក់ទងជាមួយដំរី គឺសិល្បៈទាក់ទងជាមួយដំរីដែលគួរសិក្សា ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **ឧច្ចាវចំ** (សិល្បៈខ្ពស់ទាប) បានដល់ សិក្សាសិល្បៈធំតូច ។

បទថា **ឧបដ្ឋិតា បារិចរិយេ** (ចូលទៅតាំងការទំនុកបម្រុង) បានដល់ ទំនុកបម្រុងដោយការប្រណិបត្តិ ។ បទថា **ភាវយន្តិ អនុស្សតី** (ចម្រើនអនុស្សតិ) បានដល់ ចម្រើនអនុស្សតិដ៏ប្រសើរ ។ បទថា **វិវេកបដិសំយុត្តំ**[1] (ដែលប្រកបដោយវិវេក) បានដល់ ធ្វើឲ្យអាស្រ័យព្រះនិព្វាន ។ បទថា **ខេមំ** (ជាដែនក្សេម) បានដល់ ប្រាសចាកឧបទ្រវន្តរាយ ។ បទថា **អមតគាមិនី** (ឲ្យដល់អមតធម៌) បានដល់ ឲ្យដល់ព្រះនិព្វាន អធិប្បាយថា បំពេញអរិយមគ្គ ។ បទថា **អប្បមាទេ បមោទិតា** (អ្នករីករាយក្នុងសេចក្ដីមិន

---

(១) បិដក = វិវេកបដិសញ្ញុត្តំ ។

*ប្រមាទ) បានដល់ ជាអ្នករីករាយទូទៅក្នុងសេចក្ដីមិនប្រមាទ ពោលគឺ ការនៅមិនប្រាសចាកសតិ ។ បទថា* **និបកា** *(មានបញ្ញារក្សាខ្លួន) បានដល់ ប្រកបដោយបញ្ញាជាគ្រឿងរក្សាខ្លួន ។ បទថា* **សីលសំវុតា** *(សង្រួមក្នុងសីល) បានដល់ សង្រួម រវាំង គឺ ការពារទុកដោយសីល ។ បទថា* **តេ វេ កាលេន បច្ចេន្តិ** *(ភិក្ខុទាំងនោះរមែងដឹងច្បាស់... តាមកាលដ៏សមគួរ) បានដល់ ភិក្ខុនោះឯង រមែងដឹង (ហេតុដែលរលត់ទុក្ខ) តាមកាលដ៏សមគួរ ។ បទថា* **យត្ថ ទុក្ខំ និរុជ្ឈតិ** *(នូវទីរលត់ទុក្ខ) សេចក្ដីថា ភិក្ខុនោះ រមែងដឹងឋានៈដែលជាទីរលត់វដ្ដទុក្ខទាំងអស់ គឺ អមតៈនិព្វាន ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់អនុត្តរិយៈ ៦ លាយគ្នា (ទាំងលោកិយៈ និងលោកុត្តរៈ) ដោយប្រការដូច្នេះឯង ។*

ចប់អដ្ឋកថា អនុត្តរិយសូត្រទី ១០

## ចប់អនុត្តរិយវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# សេក្ខបរិហានិយវគ្គវណ្ណនាទី ៤

## អដ្ឋកថា សេក្ខសូត្រទី ១

*(ធម៌ធ្វើឲ្យព្រះសេក្ខៈវិនាស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សេក្ខសូត្រទី ១ ដូចតទៅនេះ ៖*

[៣១] *បទថា* **សេក្ខស្ស** *(ជាសេក្ខៈ) បានដល់ ព្រះសេក្ខបុគ្គល ៧ ពួក ។ ឯបុថុជ្ជន មិនមានអ្វីដែលនឹងត្រូវពោលដល់ឡើយ ។ បទថា* **បរិហានាយ** *(ដើម្បីសេចក្តីវិនាស) បានដល់ ដើម្បីវិនាសចាកគុណ គឺសេចក្តីល្អជាន់ខ្ពស់ ។*

ចប់អដ្ឋកថា សេក្ខសូត្រទី ១

# អដ្ឋកថា បឋមអបរិហានិយសូត្រទី ២

*(ធម៌ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីមិនវិនាស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអបរិហានិយសូត្រទី ២ ដូចតទៅនេះ ៖*

*[៣២] បទថា **សត្ថុគារវតា** (ភាពជាអ្នកគោរពក្នុងព្រះសាស្ដា) ភាពជាអ្នកធ្ងន់ក្នុងព្រះសាស្ដា ។ ភាពជាអ្នកធ្ងន់ក្នុងលោកុត្តរធម៌ ៩ ឈ្មោះថា **ធម្មគារវតា** (ភាពជាអ្នកគោរពក្នុងព្រះធម៌) ។ ភាពជាអ្នកធ្ងន់ក្នុងព្រះសង្ឃ ឈ្មោះថា **សង្ឃគារវតា** (ភាពជាអ្នកគោរពក្នុងព្រះសង្ឃ) ។ ការធ្វើសេចក្ដីគោរពក្នុងសិក្ខា ៣ ឈ្មោះថា **សិក្ខាគារវតា** (ភាពជាអ្នកគោរពក្នុងសិក្ខា) ។ ភាពជាអ្នកធ្ងន់ក្នុងសេចក្ដីមិនប្រមាទ ឈ្មោះថា **អប្បមាទគារវតា** (ភាពជាអ្នកគោរពក្នុងសេចក្ដីមិនប្រមាទ) ។ ភាពជាអ្នកធ្ងន់ក្នុងបដិសន្ថារៈ ២ យ៉ាង ធម្មប្បដិសន្ថារៈ និងអាមិសប្បដិសន្ថារៈ ឈ្មោះថា **បដិសន្ថាគារវតា** (ភាពជាអ្នកគោរពក្នុងបដិសន្ថារៈ) ។*

*ភិក្ខុឈ្មោះថា **សត្ថុគរុ** (អ្នកគោរពក្នុងព្រះសាស្ដា) ព្រោះអត្ថថាមានសេចក្ដីគោរពក្នុងព្រះសាស្ដា ។ ឈ្មោះថា **ធម្មគរុ** (គោរពក្នុងធម៌)*

*ព្រោះអត្ថថា មានសេចក្តីគោរពក្នុងព្រះធម៌ ។ អ្នកគោរពយ៉ាងធ្ងន់ ឈ្មោះថា* **តិព្វគារវោ** *(គោរពដ៏ខ្លាំងក្លា) ។ ឈ្មោះថា* **បដិសន្ថារគារវោ** *(គោរពក្នុងបដិសន្ថារៈ) ព្រោះអត្ថថា មានសេចក្តីគោរពក្នុងបដិសន្ថារៈ ។*

ចប់អដ្ឋកថា បឋមអបរិហានិយសូត្រទី ២

# អដ្ឋកថា ទុតិយអបរិហានិយសូត្រទី ៣

*(ធម៌ប្រព្រឹត្តទៅដើម្បីសេចក្ដីមិនវិនាស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអបរិហានិយសូត្រទី ៣ ដូចតទៅនេះ ៖*

*[៣៣] បទថា* សប្បតិស្សា *(មានសេចក្ដីកោតក្រែង) បានដល់ មានអ្នកដឹកនាំ (ដឹងថានរណាជាអ្នកធំជាង) មានសេចក្ដីគោរព ។ ក៏ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ហិរិ និងឱត្តប្បៈលាយគ្នា ។*

ចប់អដ្ឋកថា ទុតិយអបរិហានិយសូត្រទី ៣

# អដ្ឋកថា មោគ្គល្លានសូត្រទី ៤

## (ព្រះមោគ្គល្លានសន្ទនាជាមួយតិស្សព្រហ្ម)

*គប្បីជ្រាបវិនិច្ឆ័យក្នុង មោគ្គល្លានសូត្រទី ៤ ដូចតទៅនេះ ៖*

[៣៤] *បទថា* **តិស្សោ នាម ភិក្ខុ** *(ភិក្ខុឈ្មោះតិស្សៈ) បានដល់ភិក្ខុដែលជាសទ្ធិវិហារិករបស់ព្រះថេរៈនោះឯង ។ បទថា* **មហិទ្ធិកោ មហានុភាវោ** *(ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន) មានវិគ្រោះថា ឈ្មោះថា អ្នកមានឫទ្ធិច្រើន ព្រោះមានឫទ្ធិច្រើន ដោយអត្ថថា ឲ្យសម្រេចបាន (តាមសេចក្ដីប្រាថ្នា) ។ ឈ្មោះថា មានអានុភាពច្រើន ព្រោះមានអានុភាពច្រើន ដោយអត្ថថា ផ្សាយទៅមិនដាច់ ។*

*បទថា* **ចិរស្សំ ខោ មារិស មោគ្គល្លាន ឥមំ បរិយាយមកាសិ** *(លោកបានធ្វើបរិយាយក្នុងការមកទីនេះ អស់កាលយូរណាស់ហើយ) នេះជាពាក្យរាក់ទាក់ដែលគួរស្រឡាញ់តាមប្រក្រតីរបស់មនុស្សលោក ។ ពិតហើយ មនុស្សលោកឃើញអ្នកដែលពេញចិត្តមកហើយ អស់កាលយូរៗទើបមកក្ដី មិនធ្លាប់មកក្ដី រមែងពោលពាក្យមានជាអាទិ៍ថា លោកដ៏ចម្រើន*

និមិត្តមកអំពីណា លោកដ៏ចម្រើន យូរណាស់ហើយ ទើបនឹងមក លោកដ៏ចម្រើន ដឹងផ្លូវមកទីនេះបានយ៉ាងណា លោកដ៏ចម្រើន វង្វេងផ្លូវមកឬអ្វី ។ តែតិស្សព្រហ្មនេះ ពោលយ៉ាងនេះ ព្រោះព្រះថេរៈធ្លាប់មកហើយនោះឯង ។ តាមពិត ព្រះថេរៈទៅព្រហ្មលោកតាមកាលដែលសមគួរនោះឯង ។ បណ្ដាបទទាំងនោះ បទថា ***បរិយាយមកាសិ (បានធ្វើបរិយាយ)*** បានដល់ បានធ្វើទៅតាមវារៈ ។ បទថា ***យទិទំ ឥធាគមនាយ (ក្នុងការមកកាន់ទីនេះ)*** បានដល់ មានពាក្យអធិប្បាយថា យូរណាស់ហើយ លោកទើបបានធ្វើវារៈដើម្បីនឹងមកកាន់ព្រហ្មលោកនេះ ។ បទថា ***ឥទមាសនំ បញ្ញត្តំ (នេះជាអាសនៈក្រាលទុកហើយ)*** អធិប្បាយថា តិស្សព្រហ្ម ក្រាលព្រហ្មបល្ល័ង្កដែលមានតម្លៃច្រើនហើយ ទើបពោលយ៉ាងនេះ ។ បទថា ***អវេច្ចប្បសាទេន (ដោយសេចក្ដីជ្រះថ្លាដែលមិនញាប់ញ័រ)*** បានដល់ ដោយសេចក្ដីជ្រះថ្លាដែលសម្បយុត្តដោយមគ្គ មិនយ្រើងឃ្រោង ដែលខ្លួនបានសម្រេចហើយ ។ ក្នុងសូត្រនេះ លោកពោលសោតាបត្តិមគ្គញាណ ។

ចប់អដ្ឋកថា មោគ្គល្លានសូត្រទី ៤

# អដ្ឋកថា វិជ្ជាភាគិយសូត្រទី ៥

*(ធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិជ្ជាភាគិយសូត្រទី ៥ ដូចតទៅនេះ ៖*

[៣៥] *បទថា* ***វិជ្ជាភាគិយា*** *(ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា) បាន ដល់ ជាធម៌ដែលប្រព្រឹត្តទៅក្នុងចំណែករបស់វិជ្ជា ។ សញ្ញាដែលកើតឡើង ក្នុងអនិច្ចានុបស្សនាញាណ ឈ្មោះថា* ***អនិច្ចសញ្ញា*** *។ សញ្ញាដែលកើត ឡើងក្នុងទុក្ខានុបស្សនាញាណ ឈ្មោះថា* ***អនិច្ចេទុក្ខសញ្ញា*** *។ សញ្ញាដែល កើតឡើងក្នុងអនត្តានុបស្សនាញាណ ឈ្មោះថា* ***ទុក្ខេអនត្តសញ្ញា*** *។ សញ្ញា ដែលកើតឡើងក្នុងបហានានុបស្សនាញាណ ឈ្មោះថា* ***បហានសញ្ញា*** *។ សញ្ញាដែលកើតឡើងក្នុងវិរាគានុបស្សនាញាណ ឈ្មោះថា* ***វិរាគសញ្ញា*** *។ សញ្ញាដែលកើតឡើងក្នុងនិរោធានុបស្សនាញាណ ឈ្មោះថា* ***និរោធសញ្ញា*** *។*

ចប់អដ្ឋកថា វិជ្ជាភាគិយសូត្រទី ៥

# អដ្ឋកថា វិវាទមូលសូត្រទី ៦

## (មូលហេតុនៃការវិវាទ)

គប្បីជ្រាបវិនិច្ឆ័យក្នុង វិវាទមូលសូត្រទី ៦ ដូចតទៅនេះ ៖

[៣៦] បទថា **វិវាទមូលានិ** (មូលហេតុនៃសេចក្តីវិវាទ) ។ បទថា **កោធនោ** (អ្នកក្រោធ) បានដល់ អ្នកប្រកបដោយសេចក្តី ក្រោធមានសេចក្តីអន់ចិត្តជាលក្ខណៈ ។ បទថា **ឧបនាហី** (ចងសេចក្តីក្រោធទុក) បានដល់ អ្នកប្រកបដោយការចងសេចក្តីក្រោធ មានការមិនលះបង់ពៀរជាលក្ខណៈ ។

បទថា **អហិតាយ ទុក្ខាយ ទេវមនុស្សានំ** (ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ) បានដល់ ការវិវាទរបស់ភិក្ខុ ២ រូប រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។ ប្រព្រឹត្តទៅបានយ៉ាងណា ។ (ប្រព្រឹត្តទៅបានយ៉ាងនេះគឺ) ដូចក្នុងគម្ពីរកោសម្ពីខន្ធកៈ កាលភិក្ខុ ២ រូប វិវាទគ្នា អន្តេវាសិករបស់លោកទាំងពីរនោះ ក្នុងវត្តនោះក៏នឹងវិវាទគ្នា ភិក្ខុនីសង្ឃដែលទទួលឱវាទរបស់ភិក្ខុទាំងនេះ ក៏វិវាទគ្នា តពីនោះ ឧបដ្ឋាករបស់លោកទាំងនោះ

ក៏វិវាទគ្នា តមកពួកទេវតាអ្នករក្សាមនុស្សទាំងឡាយ ក៏នឹងបែកគ្នាជា ២ ចំណែក ពួកទេវតាអ្នករក្សាមនុស្សចំណែកធម្មវាទី ក៏ដូច្នោះ គឺ ជាចំណែកធម្មវាទី , ពួកទេវតាដែលរក្សាមនុស្សចំណែកខាងអធម្មវាទី ក៏ដូច្នោះ គឺ ជាចំណែកអធម្មវាទី តអំពីនោះ ពួកភូមិទេវតាជាមិត្ររបស់អារក្ខទេវតាទាំងឡាយ ក៏បែកគ្នា វៀរពួកអរិយសាវកចេញ , ពួកទេវតា និងមនុស្សទាំងឡាយរមែងបែកគ្នាជា ២ ចំណែក តៗ គ្នាយ៉ាងនេះ រហូតដល់ព្រហ្មលោក តែចំណែកអធម្មវាទីមានចំនួនច្រើនជាងធម្មវាទី តអំពីនោះ ទេវតា និងមនុស្សទាំងឡាយ ក៏នឹងកាន់យកវត្ថុដែលមនុស្សចំនួនច្រើនជាងកាន់យកចំណែកចំនួនមនុស្សជាងនោះឯង លះបង់ធម៌ កាន់យកអធម៌ ។ ទេវតា និងមនុស្សទាំងនោះ កាលកាន់យកអធម៌ជាប្រធាន ក៏ទៅកើតក្នុងអបាយ ។ ការវិវាទរបស់ភិក្ខុទាំងពីររូប រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ដល់ត្រកូល ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការដូច្នេះ ។

បទថា អជ្ឈត្តំ វា (ក្នុងខាងក្នុង) បានដល់ ក្នុងបរិស័ទខាងក្នុង

របស់អ្នកទាំងឡាយ ។ បទថា **ពហិទ្ធា វា (ចំណែកខាងក្រៅ)** បានដល់ក្នុងបរិស័ទរបស់អ្នកពួកដទៃ ។ បទថា **មក្ខី (លុបគុណ)** បានដល់ អ្នកប្រកបដោយការលុបគុណ ដែលមានការលុបគុណអ្នកដទៃជាលក្ខណៈ ។ បទថា **បឡាសី (វាយឫកស្មើ)** បានដល់ អ្នកប្រកបដោយការវាយឫកស្មើ មានការចាប់គូជាលក្ខណៈ ។ បទថា **ឥស្សុកី (អ្នកឫស្យា)** បានដល់ អ្នកប្រកបដោយសេចក្តីឫស្យា ដែលមានសេចក្តីឫស្យាក្នុងសក្ការៈជាដើមរបស់អ្នកដទៃជាលក្ខណៈ ។ បទថា **មច្ឆរី (មានសេចក្តីកំណាញ់)** បានដល់ អ្នកប្រកបដោយសេចក្តីកំណាញ់ មានសេចក្តីកំណាញ់ជាដើមជាលក្ខណៈ ។ បទថា **សឋោ (ជាអ្នកអួតអាង)** បានដល់ អ្នកបោកបញ្ឆោត ។ បទថា **មាយាវី (មានពុតត្បុត)** បានដល់ អ្នកបិទបាំងវត្ថុដែលធ្វើទុកហើយ ។ បទថា **បាបិច្ឆោ (ជាអ្នកមានសេចក្តីប្រាថ្នាលាមក)** បានដល់ បុគ្គលទ្រុស្តសីលជាអ្នកប្រាថ្នាការសរសើរគុណដែលខ្លួនមិនមាន ។ បទថា **មិច្ឆាទិដ្ឋិ (មានការឃើញខុស)** បានដល់ នត្ថិកវាទីបុគ្គល (មានវាទថា មិនមាន) អហេតុកវាទីបុគ្គល (មានវាទថា មិនមានហេតុ) និងអកិរិយវាទីបុគ្គល (មានវាទ

ថា បាបមិនជាការធ្វើ) ។ បទថា **សន្ទិដ្ឋិបរាមាសី** (ជាអ្នកស្ទាបអង្អែលសេចក្តីយល់ឃើញរបស់ខ្លួន) បានដល់ រមែងប្រកាន់ក្នុងវត្ថុដែលខ្លួនឃើញនោះឯង ។ បទថា **អាទានគ្គាហី** (ប្រកាន់មាំ) បានដល់ អ្នករឹងរូស ។ បទថា **ទុប្បដិនិស្សគ្គី** (លះបង់ការឃើញរបស់ខ្លួនបានដោយក្រ) បានដល់ នរណាៗ មិនអាចឲ្យគេលះបង់វត្ថុដែលប្រកាន់មាំបាន ។ ក្នុងសូត្រនេះ ព្រះភាគព្រះមានព្រះភាគត្រាស់ចំណែកវិនាសតែប៉ុណ្ណោះឯង ។

ចប់អដ្ឋកថា វិវាទមូលសូត្រទី ៦

# អដ្ឋកថា ទានសូត្រទី ៧

## (អង្គនៃទក្ខិណាទាន)

គប្បីជ្រាបវិនិច្ឆ័យក្នុង ទានសូត្រទី ៧ ដូចតទៅនេះ ៖

[៣៧] បទថា **វេឡុកណ្ឌកី** (ក្នុងក្រុងវេឡុកណ្ឌកៈ) បានដល់ អ្នកនៅក្នុងក្រុងវេឡុកណ្ឌកៈ ។ បទថា **ឆឡង្គសមន្នាគតំ** (ដែលប្រកបដោយអង្គ ៦) បានដល់ ប្រកបដោយអង្គគុណ ៦ ប្រការ ។ បទថា **ទក្ខិណំ បតិដ្ឋាបេតិ** (តម្កល់ទក្ខិណាទាន) បានដល់ ថ្វាយទាន។ បទថា **បុព្វេ ទានា សុមនោ** (មុនឲ្យទានជាអ្នករីករាយ) សេចក្ដីថា ជាអ្នករីករាយតាំងអំពីខាងដើមថា យើងនឹងឲ្យទាន ។ ក្នុងបទថា **មុនឲ្យទានជាអ្នករីករាយ** នេះ មានអធិប្បាយថា **បុព្វចេតនា** រមែងមានដល់អ្នកដែលផ្ដើមធ្វើស្រែដោយគិតថា យើងនឹងថ្វាយទានដោយស្រូវដែលកើតអំពីស្រែនេះ ផ្ដើមពីកាលដែលកើតសេចក្ដីគិតឡើងថា យើងនឹងថ្វាយទាន ។ ចំណែក **មុញ្ចនចេតនា** (ការតាំងចិត្តលះ) ដែលត្រាស់ទុកយ៉ាងនេះថា **ទទំ ចិត្តំ បសាទេតិ** (កំពុងតែឲ្យ រមែងធ្វើចិត្តឲ្យជ្រះថ្លា) រមែងមានក្នុងវេលាឲ្យទានប៉ុណ្ណោះ

តែ អបរចេតនា នេះថា ទត្វា អត្តមនោ ហោតិ (លុះឲ្យទានហើយ រមែង រីករាយ) រមែងមានដល់អ្នកព្រួកក្នុងពេលក្រោយតៗ មក ។

បទថា វីតរាគា (ប្រាសចាករាគៈ) បានដល់ អ្នកមានរាគៈទៅប្រាស ហើយ គឺ អ្នកមានអាសវៈអស់ហើយ ។ បទថា រាគវិនយាយ វា បដិ-បន្នា (ឬបដិបត្តិដើម្បីកម្ចាត់រាគៈ) បានដល់ បដិបត្តិបដិបទាដែលជាហេតុ កម្ចាត់រាគៈឲ្យអស់ទៅ ។ ទេសនានេះ ជាទេសនាយ៉ាងឧក្រិដ្ឋ ។ មិនមែន សម្រាប់ព្រះខីណាស្រពតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីព្រះអនាគាមី ព្រះសក-ទាគាមី ព្រះសោតបន្ន ដោយទីបំផុតសូម្បីសាមណេរអ្នកយកកណ្ឌៈបួស ក្នុងថ្ងៃនោះ ទក្ខិណាដែលថ្វាយហើយ រមែងឈ្មោះថា ប្រកបដោយអង្គ ៦ នោះឯង ។ ព្រោះថា សូម្បីសាមណេរនោះ ក៏បួសដើម្បីសោតាបត្តិមគ្គ ដូចគ្នា ។

សេចក្តីបរិបូណ៌នៃទាន ឈ្មោះថា យញ្ញស្ស សម្បទា (ការដល់ ព្រមនៃយញ្ញ) ។ បទថា សញ្ញតា (អ្នកសង្រួម) បានដល់ អ្នកសង្រួម ហើយដោយសេចក្តីសង្រួម គឺ សីល ។ បទថា សយំ អាចមយិត្វាន[១]

(ក្រោកទទួលបដិគ្គាហកៈដោយខ្លួនឯង) បានដល់ ខ្លួនឯងនោះឯង លាងដៃ លាងជើង (របស់ព្រះទីណាស្រព) ហើយលាងមុខ ។ បទថា **សកេហិ បាណិភិ** (ដោយដៃរបស់ឯង) បានដល់ ដោយដៃរបស់ខ្លួន ។ បាឋៈថា **សយេហិ** ក៏មាន ។ បទថា **សទ្ធោ** (មានសទ្ធា) បានដល់ ជឿក្នុងគុណព្រះរតនត្រ័យ ។ បទថា **មុត្តេន ចេតសា** (មានចិត្តផុតស្រឡះចាកសេចក្ដីកំណាញ់) បានដល់ មានចិត្តរួចផុតពីសេចក្ដីកំណាញ់ក្នុងលោកជាដើម ។ បទថា **អព្យាបជ្ឈំ សុខំ លោកំ** (លោកជាសុខ មិនមានការបៀតបៀន) បានដល់ ទេវលោកដែលប្រាសចាកទុក្ខ មានតែសុខ និងសោមនស្សដ៏ឱឡារិក ។

ចប់អដ្ឋកថា ទានសូត្រទី ៧

---

(១) បិដក = សយំ អាចរយិត្វាន ។

# អដ្ឋកថា អត្តការីសូត្រទី ៨

## *(ការធ្វើដើម្បីខ្លួន និងដើម្បីអ្នកដទៃ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អត្តការីសូត្រទី ៨ ដូចតទៅនេះ ៖*

[៣៨] *បទថា* ***អទ្ទសំ វា អស្សោសី វា (“យើងកុំ” បានឃើញ ឬបានស្តាប់ពាក្យ)*** *សេចក្តីថា យើងបើកភ្នែកហើយ កុំបានឃើញ កុំបានឮថា គេនៅក្នុងទីឈ្មោះនោះ ឬកុំបានឮពាក្យដែលគេនិយាយ ។ បទថា* ***កថំ ហិ នាម (ហេតុអ្វី)*** *បានដល់ ព្រោះហេតុអ្វីហ្ន៎ ។ សេចក្តីព្យាយាម ដែលប្រព្រឹត្តទៅហើយដោយអំណាចនៃសេចក្តីផ្តួចផ្តើម ឈ្មោះថា* ***អារព្ភធាតុ (ការផ្គងនូវសេចក្តីព្យាយាម)*** *។ សេចក្តីព្យាយាម ដែលមានសភាពកន្លងពីការខ្ជិលច្រអូស ឈ្មោះថា* ***និក្កមធាតុ (ចាកការខ្ជិលច្រអូស)*** *។ សភាវៈនៃការឈានមុខ ឈ្មោះថា* ***បរក្កមធាតុ (សេចក្តីប្រឹងប្រែង)*** *។ សភាវៈនៃកម្លាំង ឈ្មោះថា* ***ថាមធាតុ (សេចក្តីរឹងប៉ឹង)*** *។ សភាវៈនៃការតាំងទុក ឈ្មោះថា* ***ធិតិធាតុ (សេចក្តីមាំមួន)*** *។ សភាវៈនៃសេចក្តីព្យាយាម ឈ្មោះថា* ***ឧបក្កមធាតុ (សេចក្តីខ្វល់ខ្វាយ)*** *។ ក៏ពាក្យទាំងអស់នេះ ជាឈ្មោះនៃ*

*សេចក្ដីព្យាយាម ដែលប្រព្រឹត្តទៅហើយដោយអាការនោះៗ ឯង ។*

ចប់អដ្ឋកថា អត្តការីសូត្រទី ៨

# អដ្ឋកថា និទានសូត្រទី ៩

## (ហេតុកើតអកុសលកម្ម និងកុសលកម្ម)

គប្បីជ្រាបវិនិច្ឆ័យក្នុង និទានសូត្រទី ៩ ដូចតទៅនេះ ៖

[៣៩] បទថា **កម្មានំ** (កម្ម) បានដល់ កម្មដែលឲ្យដល់វដ្តៈ ។ បទថា **សមុទយាយ** (ដុចផ្តើមឲ្យកើត) បានដល់ ដើម្បីប្រយោជន៍ដល់ការប្រមូល (កម្មមក) ។ បទថា **និទានំ** (ហេតុ) បានដល់ បច្ច័យ ។ បទថា **លោកជេន** (ដែលកើតពីលោភៈ) បានដល់ ដែលកើតពីលោភៈ ។ បទថា **ន បញ្ញាយន្តិ** (រមែងមិនប្រាកដ) សេចក្តីថា រមែងមិនប្រាកដជាកើតហើយព្រោះកម្មបែបនេះ ។ ក្នុងធម៌ចំណែកស បទថា **កម្មានំ** (កម្ម) បានដល់ កម្មដែលឲ្យដល់វិវដ្តៈ ។ ដូច្នេះ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ទុកទាំងចំណែកវដ្តៈ និងវិវដ្តៈ។

ចប់អដ្ឋកថា និទានសូត្រទី ៩

# អដ្ឋកថា កិមិលសូត្រទី ១០

## (ត្រាស់ហេតុធ្វើឲ្យសាសនាវិនាសដល់ព្រះកមិលៈ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង កិមិលសូត្រទី ១០ ដូចតទៅនេះ ៖*

[៤០] *បទថា* ***វេឡុវនេ*** *(ក្នុងវត្តវេឡុវន) បានដល់ ក្នុងព្រៃមហាមុចលិន្ទ ។ បទថា* ***សទ្ធម្មោ*** *(ព្រះសទ្ធម្ម) បានដល់ ព្រះសទ្ធម្ម គឺ ព្រះសាសនា ។*

ចប់អដ្ឋកថា កិមិលសូត្រទី ១០

# អដ្ឋកថា ទារុក្ខន្ធសូត្រទី ១១

*(អ្នកមានឫទ្ធិធ្វើគំនរឈើឲ្យក្លាយជាដីបាន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទារុក្ខន្ធសូត្រទី ១១ ដូចតទៅនេះ ៖*

[៤១] *បទថា* ***ចេតោវសិប្បត្តោ*** *(ដល់សេចក្តីជំនាញផ្លូវចិត្ត) បាន ដល់ អ្នកដល់កាលជាអ្នកមានអំណាចផ្លូវចិត្ត ។ បទថា* ***បថវីត្វេវ អធិ-មុច្ចេយ្យ (គប្បីបង្អោនចិត្តដល់... ឲ្យជាដីបាន)*** *សេចក្តីថា គប្បីកំណត់ អាការដែលរឹងថា ជាធាតុដី ។ បទថា* ***យំ និស្សាយ (ដែល... អាស្រ័យ)*** *សេចក្តីថា អាស្រ័យបថវីធាតុដែលមានអាការរឹង មានទៅត្រង់ណាហើយ គប្បីបង្អោនចិត្តទៅកាន់កំណាត់ឈើនោះឲ្យជាដីថា បថវីធាតុនោះ មានទៅ ក្នុងកំណាត់ឈើនេះ ។ សូម្បីពាក្យដ៏សេស គប្បីជ្រាបដោយន័យនេះ ។ អធិប្បាយថា ក្នុងកំណាត់ឈើនោះ មានបថវីធាតុ ដែលមានអាការរឹង យ៉ាងណា អាបោធាតុដែលមានអាការកកខន់ តេជោធាតុដែលមានអាការ អប់អ៊ុន វាយោធាតុដែលមានអាការកម្រើកញ័រ ក៏មានទៅក្នុងកំណាត់ឈើ នោះ ដូច្នេះ ។ សុភធាតុណា ដែលមានពណ៌ដូចផ្កាឈូក មានទៅក្នុងខ្លឹម*

ឈើដែលមានពណ៌ក្រហម (ភិក្ខុគប្បីបង្អោនចិត្តទៅ គឺ កំណត់កំណាត់ឈើនោះ ដោយអាស្រ័យសុភធាតុនោះ ថាស្អាត) អសុភធាតុណា ដែលមានពណ៌មិនគួរពេញចិត្ត មាននៅក្នុងសាច់ដែលស្អុយ និងក្នុងសាច់ស្រោយនិងក្រមរទាំងឡាយ (របស់ដើមឈើ) ភិក្ខុបង្អោនចិត្តទៅ គឺ កំណត់កំណាត់ឈើនោះ ដោយអាស្រ័យអសុភធាតុនោះៗ ឯងថា មិនស្អាត ។ ក្នុងសូត្រនេះ ព្រះសារីបុត្តឲ្យឈ្មោះថា មិស្សកវិហារ ។

ចប់អដ្ឋកថា ទារុក្ខន្ធសូត្រទី ១១

# អដ្ឋកថា នាគិតសូត្រទី ១២

*(ត្រាស់ការមិនជាប់ជំពាក់យសដល់ព្រះនាគិតៈ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង នាគិតសូត្រទី ១២ ដូចតទៅនេះ ៖*

[៤២] *បទថា* ***គាមន្តវិហារំ*** *(អ្នកនៅជិតស្រុក) បានដល់ អ្នកនៅក្នុងសេនាសនៈចុងស្រុកនោះ ។ បទថា* ***សមាហិតំ និសន្នំ*** *(កំពង់អង្គុយពត់ភ្នែន) បានដល់ អ្នកអង្គុយចូលសមាធិក្នុងសេនាសនៈចុងស្រុកនោះ ។ បទថា* ***ឥទានិមំ*** *កាត់បទជា* ***ឥទានិ ឥមំ*** *។ បទថា* ***សមាធិម្ហា ចាវេស្សតិ***[១] *(នឹងញាំង... ឲ្យឃ្លាតចាកសមាធិ) បានដល់ ចេញចាកសមាធិ ។ បទថា* ***ន អត្តមនោ ហោមិ*** *(ទើបមិនពេញចិត្ត) បានដល់ រមែងមិនមានចិត្តជារបស់ខ្លួន (មិនត្រេកអរ) ។ បទថា* ***បចលាយមានំ***[២] *(ងោកងក់) បានដល់ លក់ហើយ ។ បទថា* ***ឯកគ្គំ*** *(ជាឯកគ្គតា) បានដល់ មានសភាពតែមួយ អធិប្បាយថា ធ្វើអារញ្ញសញ្ញានោះឯងទុកក្នុងចិត្ត ឲ្យជាចិត្តមានអារម្មណ៍តែមួយ ។ បទថា* ***អនុរក្ខិស្សតិ*** *(តាមរក្សា) បានដល់ នឹង*

---

(១) បិដក = សមាធិម្ហា តំ ចាវេស្សតីតិ ។ (២) បិដក = ចបលាយមានំ ។

អនុគ្រោះ ។ បទថា **អវិមុត្តំ វា ចិត្តំ វិមោចេស្សតិ** (នឹងលើកចិត្តដែលមិនទាន់រួចផុត ឲ្យរួចផុត) សេចក្ដីថា នឹងលើកចិត្តដែលមិនទាន់រួចផុត ក្នុងវេលាដទៃ ដោយវិមុត្តិទាំង ៥ ក្នុងបច្ចុប្បន្ន ។ បទថា **វិញ្ចតិ** (លះបង់) បានដល់ វៀរ គឺ រលាស់ចោល ។ បទថា **បដិប្បណាមេត្វា** (លះ) បានដល់ បន្ទោបង់ គឺ រលាស់ចេញ ។ បទថា **ឧច្ចារប្បស្សាវកម្មាយ** (ដោយការបន្ទោបង់ឧច្ចារៈបស្សាវៈ) បានដល់ ត្រូវការបន្ទោបង់ឧច្ចារៈបស្សាវៈ ។ ព្រោះហេតុនេះ គឺ ដោយឋានៈត្រឹមប៉ុណ្ណោះ ព្រះបរមសាស្ដាបានត្រាស់សរសើរសេនាសនៈព្រៃ ។ ក៏ពាក្យណាដែលនឹងពោលក្នុងចំណែកខាងដើមនៃព្រះសូត្រ ខ្ញុំបានពោលទុកហើយនោះឯង ។

ចប់អដ្ឋកថា នាគិតសូត្រទី ១២

## ចប់សេក្ខបរិហានិយវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១២ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១២ សូត្រ

# ធម្មិកវគ្គវណ្ណនាទី ៥

## អដ្ឋកថា នាគសូត្រទី ១

*(បុគ្គលប្រសើរ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង នាគសូត្រទី ១ ដូចតទៅនេះ ៖*

[៤៣] *បទថា* ***អាយស្មតា អានន្ទេន សទ្ធឹ*** *(ជាមួយនឹងព្រះអានន្ទដ៏មានអាយុ) នេះ ព្រះសង្គីតិកាចារ្យពោលទុក ព្រោះព្រះមានព្រះភាគត្រាស់ហៅព្រះថេរៈថា អានន្ទមកចុះ ហើយស្តេចទៅ ។ ក៏បណ្ឌិតគប្បីជ្រាបថា ព្រះសាស្តាដែលភិក្ខុចំនួន ៥០០ រូប ហែហមហើយ ស្តេចបានចូលទៅបុព្វារាមនោះ ។ បទថា* ***តេនុបសង្កមិ*** *(ទ្រង់ចូលទៅ) សេចក្តីថា ព្រះសាស្តាដែលភិក្ខុទាំង ៥០០ រូបនោះហែហមហើយ ស្តេចចូលទៅ ។ បទថា* ***បរិសិញ្ចិត្វា*** *(ទ្រង់ស្រង់ហើយ) នេះ ត្រឹមតែជាវោហារ អធិប្បាយថា ទ្រង់ស្រង់ទឹកហើយ ។*

*បទថា* ***បុព្វសទិសានិ កុរុមានោ*** *(គប្បី... ឲ្យឃើញ) សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ស្លៀកដណ្តប់សំពត់ពីរជាន់ដែលជ្រលក់ហើយ ទ្រង់*

កាន់យកសំពត់ឧត្តរាសង្គៈដោយព្រះហស្តទាំងពីរ ហើយប្រថាប់ឈរបែរព្រះបិដ្ឋៈ (ខ្នង) ឲ្យលោកធាតុទិសខាងលិច បែរព្រះភក្ត្រឲ្យលោកធាតុទិសខាងកើត ធ្វើព្រះវរកាយឲ្យស្ងួតទឹក ។ ចំណែកភិក្ខុសង្ឃចុះតាមទាំងនោះស្រង់ទឹកហើយ បានឡើងមកឈរហែហមព្រះសាស្តា យ៉ាងនោះឯង ។ ដូច្នោះ សម័យនោះ ព្រះអាទិត្យគោចរជ្រេទៅកាន់លោកធាតុទិសខាងលិច ស្រដៀងក្រវិលពណ៌ក្រហមលាយពណ៌មាស កំពុងនឹងលិចចុះចាកអាកាស ។ លោកធាតុទិសខាងកើត ព្រះចន្ទដ៏បរិសុទ្ធដូចដុំប្រាក់ ក៏រះឡើងក្នុងកណ្តាលលោកធាតុ ព្រះសម្មាសម្ពុទ្ធមានភិក្ខុ ៥០០ រូប ជាបរិវារ បានប្រថាប់ឈរបញ្ចេញឆព្វណ្ណរង្សីត្រចះត្រចង់ត្រង់មាត់ប្រាំងទន្លេបុព្វកោដ្ឋកៈ[១] ។

បទថា **តេន ខោ បន សមយេ ។បេ។ សេតោ នាម នាគោ (ក៏សម័យនោះ ព្រះស្វេតកុញ្ជរ)** បានដល់ នាគ គឺ ដំរី ដែលបានឈ្មោះយ៉ាងនោះ ព្រោះមានពណ៌ស ។ បទថា **មហាតុរិយតាឡិតវាទិតេន (ព្រោះសំឡេងតន្ត្រីធំដែលគេប្រគំ)** បានដល់ ដោយការប្រគំតន្ត្រីយ៉ាងឱឡារិក ។

---

(១) បិដក = ស្រះធំ ។

ក្នុងបទថា *ព្រោះសំឡេងតន្ត្រីធំដែលគេប្រគំ* នោះ មានអធិប្បាយថា ការខ្ទប់គ្នាគ្រាដំបូង ឈ្មោះថា **តាឡិតៈ (ដំ)** តអំពីនោះទៅ ឈ្មោះថា **វាទិតៈ (ប្រគំ)** ។ បទថា **ជនោ (មហាជន)** បានដល់ មហាជនដែលប្រជុំគ្នាដើម្បីមើលដំរី ។ បទថា **ទិស្វា ឯវមាហ (ឃើញ... ហើយនិយាយយ៉ាងនេះ)** សេចក្ដីថា មហាជនឃើញដំរីធំនោះ ដែលម៉ដំរីឲ្យងូតទឹក លាបពណ៌អវយវៈតូចធំហើយ ឲ្យឡើងមកសម្រាកលើប្រាំង ធ្វើខ្លួនឲ្យស្ងួតទឹក ហើយយកគ្រឿងប្រដាប់ដំរីមកពាក់ឲ្យ ទើបពោលពាក្យសរសើរថា អ្នកដ៏ចម្រើន ដំរីនេះស្អាតណាស់ហ្ន៎ ។ បទថា **កាយូបបន្នំ (មានអាវយវៈសមរម្យ)** បានដល់ ចូលដល់ភាពសម្បូរនៃរាងកាយ អធិប្បាយថា មានអវយវៈតូចធំបរិបូណ៌ ។

បទថា **អាយស្មា ឧទាយិ (ឧទាយិដ៏មានអាយុ)** បានដល់ ព្រះកាឡុទាយិអ្នកសម្រេចបដិសម្ភិទា ។ បទថា **ឯតទវោច (បានទូលសួរ)** សេចក្ដីថា ព្រះកាឡុទាយិ ឃើញមហាជននោះពោលសរសើរគុណរបស់ដំរី ទើបគិតថា មហាជននេះ ពោលសរសើរគុណរបស់ដំរីដែលកើតដោយអហេតុ-

កបដិសន្ធិ មិនពោលសរសើរព្រះគុណរបស់ដំរី គឺ ព្រះពុទ្ធ ឥឡូវនេះ យើងនឹងពោលសរសើរព្រះគុណរបស់ដំរី គឺ ព្រះពុទ្ធ ប្រៀបដូចជាដំរីដ៏ប្រសើរនេះ ហើយបានពោលពាក្យមានជាអាទិ៍ថា **ហត្ថិមេវ នុ ខោ ភន្តេ** (បពិត្រព្រះអង្គដ៏ចម្រើន... ដំរីស... ប៉ុណ្ណោះឬហ្ន៎) ។ បណ្តាបទទាំងនោះ បទថា **មហន្តំ** (ធំ) បានដល់ ដល់ព្រមដោយរូបរាងធំ ។ បទថា **ព្រហន្តំ** (ខ្ពស់) បានដល់ ដល់ព្រមដោយកម្ពស់ ។ បទថា **ឯវមាហ** (ទើបបានពោលយ៉ាងនេះ) បានដល់ រមែងពោលយ៉ាងនេះ ។

លំដាប់នោះ ព្រះមានព្រះភាគ ព្រោះនាគសព្ទ ប្រព្រឹត្តទៅក្នុងដំរីខ្លះ សេះខ្លះ គោខ្លះ ពស់ខ្លះ ដើមឈើខ្លះ មនុស្សខ្លះ ដូច្នោះ ទើបត្រាស់ថា **ហត្ថិម្បិ ខោ** (ដំរី...ខ្លះ) ជាដើម ។ បទថា **អាគុំ** (អំពីអាក្រក់) បានដល់ អកុសលធម៌ដ៏អាក្រក់លាមក ។ បទថា **តមហំ នាគោតិ ព្រូមិ** (តថាគតហៅបុគ្គលនោះថា បុគ្គលប្រសើរ) សេចក្តីថា តថាគតហៅបុគ្គលនោះថា ជាបុគ្គលប្រសើរ (នាគ) ព្រោះមិនធ្វើអកុសលកម្មបថ ១០ និងអកុសលចិត្ត ១២ ដោយទ្វារ ៣ នេះ ។ ក៏បុគ្គលនោះឈ្មោះថា ជាបុគ្គល

ដ៏ប្រសើរ ដោយន័យនេះ គឺ មិនធ្វើអំពីអាក្រក់ ។ បទថា **ឥមាហិ គាថាហិ អនុមោទាមិ** (ខ្ញុំព្រះអង្គសូមអនុមោទនា... ដោយគាថាទាំងនេះ) សេចក្ដីថា ខ្ញុំព្រះអង្គសូមអនុមោទនា គឺ សូមសរសើរដោយគាថា ១៦ គាថា (ចែកជាបទ) បាន ៦៤ បទ ។

បទថា **មនុស្សភូតំ** (ជាមនុស្សជាតិ) គឺ ជាមនុស្សពិតៗ មិនបានចូលដល់ភាពជាទេវតាជាដើម ។ បទថា **អត្តទន្តំ** (ទ្រង់ទូន្មានព្រះអង្គហើយ) បានដល់ ទ្រង់ទូន្មានហើយដោយព្រះអង្គឯងនោះឯង គឺ មិនត្រូវបានបុគ្គលដទៃនាំទៅកាន់ការទូន្មាន ។ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ទូន្មានហើយក្នុងឋានៈ ៦ ទាំងនេះ គឺ ទ្រង់ទូន្មានទាំងផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ និងផ្លូវចិត្ត ដោយគ្រឿងទូន្មាន គឺ មគ្គ ដែលព្រះអង្គឲ្យកើតឡើងឯង គឺ ទ្រង់ស្ងប់ហើយ រលត់ហើយ បានដល់ រលត់ស្និទ្ធ ព្រោះហេតុនោះ ព្រះកាឡុទាយិទើបពោលថា **ទ្រង់ទូន្មានព្រះអង្គហើយ** ។ បទថា **សមាហិតំ** (មានព្រះទ័យតំកល់មាំ) បានដល់ មានចិត្តតាំងមាំហើយដោយសមាធិទាំងពីរយ៉ាង ។ បទថា **ឥរិយមានំ** (ប្រព្រឹត្តហើយ) បានដល់ តាំង

នៅហើយ ។

បទថា ព្រហ្មបថេ (ក្នុងផ្លូវដ៏ប្រសើរ) បានដល់ ក្នុងផ្លូវដ៏ប្រសើរបំផុត គឺ ក្នុងផ្លូវ គឺ អមតនិព្វាន ។ បទថា **ចិត្តស្សូបសមេ រតំ (ទ្រង់ត្រេកអរក្នុងធម៌ដែលធ្វើចិត្តឲ្យស្ងប់រម្ងាប់)** បានដល់ ទ្រង់រម្ងាប់នីវរណៈ ៥ ដោយបឋមឈាន រម្ងាប់វិតក្កៈវិចារៈដោយទុតិយឈាន រម្ងាប់បីតិដោយតតិយឈាន រម្ងាប់សុខ និងទុក្ខដោយចតុត្ថឈាន ហើយត្រេកអរ គឺ ទ្រង់ត្រេកអរក្រៃលែងក្នុងសេចក្ដីស្ងប់របស់ចិត្តនោះ ។ បទថា **នមស្សន្តិ (រមែងនមស្ការ)** បានដល់ នមស្ការដោយកាយ នមស្ការដោយវាចា នមស្ការដោយចិត្ត នមស្ការ គឺ ធ្វើសក្ការៈដោយការបដិបត្តិធម៌សមគួរដល់ធម៌ ។ បទថា **សព្វធម្មានបារគុំ (ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង)** បានដល់ ទ្រង់ដល់ត្រើយ គឺ សម្រេច ដល់នូវការសម្រេច បានដល់ ដល់ទីបំផុតនៃធម៌ គឺ ខន្ធ អាយតនៈ ធាតុទាំងអស់ ដោយការដល់ត្រើយ ៦ យ៉ាង គឺ ទ្រង់ដល់នូវត្រើយនៃអភិញ្ញា ទ្រង់ដល់នូវត្រើយនៃបរិញ្ញា ទ្រង់ដល់នូវត្រើយនៃបហានៈ ទ្រង់ដល់នូវត្រើយនៃភាវនា ទ្រង់ដល់នូវត្រើយនៃការធ្វើឲ្យជាក់

ច្បាស់ ទ្រង់ដល់នូវត្រើយនៃសមាបត្តិ ។

បទថា **ទេវាបិ តំ នមស្សន្តិ** (សូម្បីពួកទេវតា ក៏រមែងនមស្ការព្រះសម្ពុទ្ធអង្គនោះ) សេចក្តីថា ទេវតាទាំងឡាយដែលប្រសព្វទុក្ខ មានសុព្រហ្មទេវបុត្រជាដើម និងសូម្បីទេវតាទាំងឡាយដែលប្រសព្វសុខ ដែលស្ថិតនៅក្នុងម៉ឺនចក្រវាឡ ក៏នាំគ្នានមស្ការព្រះអង្គ ។ ដោយបទថា **ឥតិ មេ អរហតោ សុតំ** (ខ្ញុំព្រះអង្គបានស្តាប់ពីព្រះអង្គ ដែលជាព្រះអរហន្តដូច្នេះ) ព្រះកាឡុទាយិសម្តែងថា ខ្ញុំព្រះអង្គបានស្តាប់ក្នុងសម្នាក់របស់ព្រះអង្គនោះឯង បុគ្គលបានវោហារថា ជាព្រះអរហន្ត ដោយហេតុ ៤ យ៉ាងដូចពណ៌នាមកដូច្នេះ ។ បទថា **សព្វសញ្ញោជនាតីតំ** (ទ្រង់ឈានកន្លងសញ្ញោជនៈទាំងពួង) បានដល់ ទ្រង់រួចផុតអំពីសញ្ញោជនៈទាំង ១០ ។ បទថា **វនា និព្វានមាគតំ** (ទ្រង់លុះនិព្វានជាទីចេញចាកកិលេសដែលជាគ្រឿងជោតក្រង) បានដល់ មកដល់ គឺ សម្រេចដល់ព្រះនិព្វាន ដែលមិនមានព្រៃ ចេញចាកព្រៃ គឺ កិលេស គឺ វៀរចាកព្រៃ គឺ កិលេស ។ បទថា **កាមេហិ នេក្ខម្មរតំ** (ទ្រង់ត្រេកអរក្នុងធម៌ដែលជាទីចេញចាកកាម

**ទាំងឡាយ)** សេចក្ដីថា ការបព្វជ្ជា ១ សមាបត្តិប្រាំបី ១ អរិយមគ្គបួន ១ ឈ្មោះថា ការចេញចាកកាមទាំងឡាយ ព្រោះចេញទៅហើយចាកកាមទាំង ២ យ៉ាង ទ្រង់ត្រេកអរ គឺ ទ្រង់ត្រេកអរយ៉ាងក្រៃលែងក្នុងនេក្ខម្មៈនោះ ។ បទថា **មុត្តំ សេលាវ កញ្ចនំ (ដូចមាសដែលស្រូវចេញអំពីថ្ម)** បានដល់ ដូចមាសដែលស្រូវចេញពីជាតុ គឺ សិលា ។ បទថា **សព្វេ អច្ចរុចិ (រុងរឿងកន្លងបង់នូវសត្វទាំងពួង)** មានសេចក្ដីរុងរឿងប្រព្រឹត្តទៅលើសសព្វសត្វ អធិប្បាយថា ព្រះសោតបន្ន (សោតាបត្តិផលបុគ្គល) ឈ្មោះថា មានសេចក្ដីរុងរឿងក្រៃលែងជាង ព្រោះមានសេចក្ដីរុងរឿងប្រព្រឹត្តកន្លងបុគ្គលទី ៨ (សោតាបត្តិមគ្គបុគ្គល) ព្រះសកទាគាមិ ឈ្មោះថា មានសេចក្ដីរុងរឿងក្រៃលែងជាង ព្រោះមានសេចក្ដីរុងរឿងប្រព្រឹត្តទៅកន្លងព្រះសោតាបន្ន ។ល។ ព្រះបច្ចេកពុទ្ធ ឈ្មោះថា មានសេចក្ដីរុងរឿងក្រៃលែងជាង ព្រោះមានសេចក្ដីរុងរឿងប្រព្រឹត្តទៅកន្លងព្រះខីណាស្រព ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា មានសេចក្ដីរុងរឿងក្រៃលែងជាង ព្រោះមានសេចក្ដីរុងរឿងប្រព្រឹត្តទៅកន្លងព្រះបច្ចេកពុទ្ធ ។

បទថា ហិមវាញ្ញ សិលុច្ចយោ (ដូចភ្នំហិមពាន្តដែលរុងរឿងជាង ភ្នំដទៃ) សេចក្ដីថា ព្រះមានព្រះភាគរមែងរុងរឿងក្រៃលែងជាង (បុគ្គល ដទៃទាំងទេវតា និងមនុស្ស) ប្រៀបដូចភ្នំហិមពាន្តប្រសើរជាងភ្នំដទៃៗ ។ បទថា សច្ចនាមោ (ព្រះអង្គទ្រង់មានព្រះនាមថានាគដោយពិត) បានដល់ ទ្រង់មានព្រះនាមពិត គឺ មានព្រះនាមតាមសេចក្ដីពិត បានដល់ មានព្រះ នាមពិតយ៉ាងនេះថា នាគៈ ព្រោះទ្រង់មិនធ្វើអំពីអាក្រក់នោះឯង ។ បទថា សោរច្ចំ (សេចក្ដីស្ងប់) បានដល់ មានសីលដែលស្អាត ។ បទថា អវិហឹសា (មិនបៀតបៀន) បានដល់ ករុណា (អប្បនា) និងធម៌ដែលជាចំណែកខាង ដើមនៃករុណា (ឧបចារៈ) ។ បទថា បាទា នាគស្ស តេ ទុវេ (ជាជើង មុខទាំងពីររបស់ព្រះអង្គដូចដំរីដ៏ប្រសើរ) សេចក្ដីថា ជាព្រះបាទខាងមុខ របស់ព្រះអង្គដែលជានាគ គឺ ព្រះពុទ្ធជាម្ចាស់ ។ បទថា តបោ (តបៈ) បានដល់ ការសមាទានវត្ត ។ បទថា ព្រហ្មចរិយំ (ព្រហ្មចរិយៈ) បានដល់ សីលក្នុងអរិយមគ្គ ។ បទថា ចរណា នាគស្ស ត្យាបរេ (ជាជើងក្រោយ ទាំងពីររបស់ព្រះអង្គដូចដំរីដ៏ប្រសើរ) សេចក្ដីថា ជាព្រះបាទក្រោនេះ គឺ

ជាព្រះបាទខាងក្រោយរបស់ព្រះអង្គដែលជានាគៈ គឺ ព្រះពុទ្ធជាម្ចាស់ ។

បទថា **សទ្ធាហត្ថោ** (មានសទ្ធាជាប្រមោយ) បានដល់ ប្រកបដោយប្រមោយដែលសម្រេចដោយសទ្ធា ។ បទថា **ឧបេក្ខាសេតទន្តវា** (មានឧបេក្ខាជាភ្លុកស) បានដល់ ប្រកបដោយភ្លុកស ដែលសម្រេចដោយឧបេក្ខាមានអង្គ ៦ ។ បទថា **សតិ គីវា** (មានសតិជា.ក) សេចក្តីថា ក.ជាទីតាំងនៃសំណុំសរសៃលោហិតក្នុងអវយវៈតូចធំរបស់ដំរី យ៉ាងណា សតិក៏ជាទីតាំងនៃធម៌ មានសោរច្ចៈជាដើមរបស់នាគ គឺ ព្រះពុទ្ធ ក៏យ៉ាងនោះ ព្រោះហេតុនោះ ព្រះកាឡុទាយិត្ថេរៈទើបពោលថា **សតិជា.ក** ។ បទថា **សិរោ បញ្ញា** (មានបញ្ញាជាសីសៈ) សេចក្តីថា សីសៈជាអវយវៈដ៏ខ្ពង់ខ្ពស់របស់ដំរី យ៉ាងណា ព្រះសព្វញ្ញុតញ្ញាណជាវត្ថុដ៏ឧត្តមរបស់នាគ គឺ ព្រះពុទ្ធជាម្ចាស់ ក៏យ៉ាងនោះ ព្រោះថា ព្រះពុទ្ធអង្គនោះ ទ្រង់រមែងជ្រាបធម៌ទាំងពួងដោយព្រះសព្វញ្ញុតញ្ញាណនោះ ព្រោះហេតុនោះ ព្រះកាឡុទាយិត្ថេរទើបពោលថា **មានបញ្ញាជាសីសៈ** ។ បទថា **វិមំសា ធម្មចិន្តនា** (ការពិចារណាធម៌ជាចុងប្រមោយ) សេចក្តីថា នាគ គឺ ដំរី ឈ្មោះថា មានចុងប្រមោយជាគ្រឿង

ពិចារណា ដំរីនោះ រមែងពិចារណាដល់វត្ថុដែលរឹង និងទន់ និងវត្ថុដែលគួរទំពារស៊ី និងមិនគួរទំពារស៊ី ដោយចុងប្រមោយនោះ តអំពីនោះ ក៏លះបង់វត្ថុដែលគួរលះ ស្រវាចាប់យកវត្ថុដែលគួរស្រវាចាប់យក យ៉ាងណា ការគិតដល់ធម៌ ពោលគឺ ញាណជាគ្រឿងកំណត់ចំណែកនៃធម៌ ឈ្មោះថា ជា **វិមំសា (បញ្ញាជាគ្រឿងពិចារណា)** របស់នាគ: គឺ ព្រះពុទ្ធជាម្ចាស់ ក៏ដូច្នោះដូចគ្នា ព្រោះថា ព្រះពុទ្ធអង្គនោះ ទ្រង់ដឹងបុគ្គលដែលមានភ័ព្វ និងបុគ្គលដែលមិនមានភ័ព្វដោយញាណនោះ ព្រោះហេតុនោះ ព្រះកាឡុទាយិត្ថេរៈទើបពោលថា **ការពិចារណាធម៌ជាចុងប្រមោយ** ។ បទថា **ធម្មកុច្ឆិសមាតបោ (មានធម៌ជាគ្រឿងដុតកិលេសជាផ្ទៃ)** មានវិគ្រោះថា ចតុត្ថជ្ឈានសមាធិ លោកហៅថា ធម៌ ការដុតបំផ្លាញកិលេស គឺ **កុច្ឆិ** ឈ្មោះថា **កុច្ឆិសមាតប:** បានដល់ ដែសសម្រាប់ដុតបំផ្លាញ (កិលេស) ធម៌ដែលដុតបំផ្លាញ (កិលេស) គឺ ពោះរបស់បុគ្គលនោះ ហេតុនោះ បុគ្គលនោះទើបឈ្មោះថា មានធម៌ជាគ្រឿងដុតបំផ្លាញកិលេស គឺ ពោះ ។ ព្រោះថា ធម៌ មានឥទ្ធិវិធីជាដើមនោះឯង រមែងសម្រេចដល់បុគ្គលដែលតាំងនៅក្នុង

ចតុត្ថជ្ឈានសមាធិ ព្រោះហេតុនោះ ចតុត្ថជ្ឈានសមាធិនោះ ទើបហៅថា ធម៌ជាគ្រឿងដុតបំផ្លាញ គឺ ពោះ ។ បទថា *វិវេកោ (មានសេចក្តីស្ងប់)* បានដល់ កាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។ ពោមកន្ទុយរបស់ដំរី រមែងការពារសត្វរុយ យ៉ាងណា វិវេករបស់ព្រះតថាគតរមែងបក់គ្រហស្ថ និងបុព្វជិត[១] ក៏យ៉ាងនោះ ព្រោះហេតុនោះ វិវេកនោះ ព្រះកាឡុទាយី ទើបពោលថា *វាលធិ (ជាកន្ទុយ)* ។ បទថា *ឈាយី (ទ្រង់មានឈាន)* បានដល់ ទ្រង់មានប្រក្រតីសម្លឹងដោយឈាន ២ យ៉ាង (គឺលក្ខណូបនិជ្ឈាន និងអារម្មណូបនិជ្ឈាន) ។ បទថា *អស្សាសរតោ (ទ្រង់ត្រេកអរក្នុងផល-សមាបត្តិជាការដកដង្ហើម)* សេចក្តីថា ក៏ផលសមាបត្តិរបស់នាគៈ គឺ ព្រះពុទ្ធ ប្រៀបដូចខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញរបស់ដំរី ព្រះពុទ្ធ ទ្រង់ត្រេកអរក្នុងផលសមាបត្តិនោះ អធិប្បាយថា វៀរចាកផលសមាបត្តិនោះ ដែលប្រៀបដូចខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ក៏ប្រព្រឹត្តទៅ មិនបាន ។

---

(១) គឺ ការពារមិនឱ្យមកស្និទ្ធស្នាលជាមួយព្រះអង្គ ។

បទថា *សព្វត្ថ សំវុតោ* (ទ្រង់សង្រួមហើយក្នុងទ្វារទាំងពួង) បានដល់ សង្រួមហើយគ្រប់ៗ ទ្វារ ។ បទថា *អនវជ្ជានិ* (វត្ថុដែលមិនមានទោស) បានដល់ ភោជនដែលកើតឡើងអំពីសម្មាអាជីវៈ ។ បទថា *សាវជ្ជានិ* (វត្ថុដែលមានទោស) បានដល់ ភោជនដែលកើតឡើងព្រោះមិច្ឆាជីវៈ ៥ យ៉ាង ។ បទថា *អណុំ ថូលំ* (តូចធំ) បានដល់ តិច និងច្រើន ។ បទថា *សព្វំ ឆេត្វាន ពន្ធនំ* (ទ្រង់កាត់... ដែលជាគ្រឿងចងទាំងពួង) បានដល់ កាត់សញ្ញោជនៈទាំង ១០ យ៉ាង ។ បទថា *ន ឧបលិម្បតិ លោកេន* (ដែលតណ្ហា មានះ ទិដ្ឋិ មិនលាបព្រះអង្គឲ្យជាប់ជាមួយលោក) សេចក្តីថា ទ្រង់មិនជាប់ជាមួយលោក ដោយគ្រឿងធ្វើឲ្យជាប់ គឺ តណ្ហា មានះ និងទិដ្ឋិ ។ បទថា *មហាគ្គិនិ* (គំនរភ្លើងធំ) បានដល់ គំនរភ្លើងធំ ។ បទថា *វិញ្ញូហិ ទេសិតា* (ដែលវិញ្ញូជនទាំងឡាយសម្តែងទុកហើយ) សេចក្តីថា ព្រះកាឡុទាយិត្ថេរៈ សម្រេចបដិសម្ភិទាក្នុងធម្មវិន័យនោះឯង ជាវិញ្ញូជនជាបណ្ឌិត (ឧបមាទាំងឡាយ) ដែលព្រះកាឡុទាយិត្ថេរៈនោះសម្តែងទុកហើយ ។ បទថា *វិញ្ញាយន្តិ មហានាគា នាគំ នាគេន ទេសិតំ* (ព្រះអរហន្ត

ជាដំរីដ៏ប្រសើរ ដ៏ឧត្តមទាំងឡាយ រមែងដឹងច្បាស់ចំពោះព្រះអង្គដែលជានាគដ៏ប្រសើរ ដែលព្រះកាឡុទាយីជាដំរីដ៏ប្រសើរ បានសម្តែងទុកហើយ) សេចក្តីថា នាគ គឺ ព្រះខីណាស្រពក្រៅអំពីនេះ ក៏ដឹងច្បាស់នូវនាគ គឺព្រះពុទ្ធ ដែលនាគ គឺ ព្រះឧទាយិត្ថេរៈសម្តែងទុកហើយ ។ បទថា *សរីរំ វិជហំ នាគោ បរិនិព្វិស្សតិ* (កាលទ្រង់លះបង់សរីរៈក៏នឹង... ស្តេចបរិនិព្វាន) សេចក្តីថា នាគ គឺ ព្រះពុទ្ធទ្រង់រលត់ស្និទ្ធដោយការរលត់កិលេសត្រង់ពោធិបល្ល័ង្ក និងស្តេចរលត់ខន្ធបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុត្រង់ចន្លោះដើមរាំងទាំងគូ ។ ព្រះឧទាយីអ្នកសម្រេចបដិសម្ភិទា ពោលសរសើរគុណព្រះទសពល បញ្ចប់ព្រះទេសនាដោយគាថា ១៦ គាថា ដោយបាទ ៦៤ បាទ ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគទ្រង់អនុមោទនា ។ វេលាចប់ទេសនា សត្វ ៨៤.០០០ បានផឹកទឹកអម្រឹត (សម្រេចធម៌) នោះឯង ។

ចប់អដ្ឋកថា នាគសូត្រទី ១

# អដ្ឋកថា មិគសាលាសូត្រទី ២

## (ព្រោះពាក្យសួររបស់មិគសាលាឧបាសិកា)

គប្បីជ្រាបវិនិច្ឆ័យក្នុង មិគសាលាសូត្រទី ២ ដូចតទៅនេះ ៖

[៤៤] បទថា **កថំ កថំ នាម (បានយ៉ាងណា)** បានដល់ ព្រោះហេតុអ្វីៗ ។ បទថា **អញ្ញេយ្យោ (ដែលវិញ្ញូជនគប្បីដឹងបាន)** បានដល់ (ធម៌) ដែលបុគ្គលគប្បីដឹងទូទៅ ។ បទថា **យត្រ ហិ នាម (ដែលជាហេតុឲ្យ)** បានដល់ ក្នុងធម៌ឈ្មោះអ្វី ។ បទថា **សមសមគតិកា (ជាអ្នកមានគតិស្មើ)** បានដល់ ជាអ្នកមានគតិស្មើគ្នា ដោយការៈដែលស្មើគ្នានោះឯង ។ បទថា **ភវិស្សន្តិ (មាន... ហើយ)** បានដល់ កើតហើយ ។ បទថា **សកទាគាមិ សត្តោ តុសិតំ កាយំ ឧបបន្នោ (ជាសកទាគាមិបុគ្គលចូលដល់ពួកទេវតាជាន់តុសិត)** សេចក្តីថា ជាសកទាគាមិបុគ្គលកើតក្នុងភពតុសិតនោះឯង ។ បទថា **កថំ កថំ នាម (បានយ៉ាងណា)** សេចក្តីថា (មិគសាលាឧបាសិកាសួរថា ព្រះមានព្រះភាគទ្រង់សម្តែងព្រហ្មចារីបុគ្គល និងអព្រហ្មចារីបុគ្គល) ដោយហេតុយ៉ាងណាហ្ន៎ គឺ ព្រះអង្គទ្រង់ដឹងហើយ ទើប

សំដែងទុក ឬទ្រង់មិនដឹង ។ ព្រះថេរៈ (អានន្ទ) មិនជ្រាបហេតុ ទើបពោលថា បទថា អម្ពកា អម្ពកសញ្ញា (ប្អូនស្រី ក៏សេចក្តីនេះព្រះមានព្រះភាគទ្រង់ព្យាករណ៍ទុកយ៉ាងនោះឯង) បានដល់ ជាស្ត្រីប្រកបដោយការសំគាល់ខ្លួនជាស្ត្រីនោះឯង ។

ក្នុងបទថា កេ ច បុរិសបុគ្គលបរោបរិយញ្ញាណេ (ក្នុងញាណជាគ្រឿងកំណត់ដឹងភាពចាស់ក្លា និងភាពទន់ខ្ចីនៃឥន្ទ្រិយរបស់បុគ្គល... និងព្រះសម្មាសម្ពុទ្ធជានរណា) នេះ មានវិនិច្ឆ័យដូចតទៅនេះ ញាណជាគ្រឿងកំណត់ដឹងឥន្ទ្រិយចាស់ក្លា និងទន់ខ្ចីរបស់បុគ្គលទាំងឡាយ ហៅថា បុរិសបុគ្គលបរោបរិយញ្ញាណ (ញាណជាគ្រឿងកំណត់ដឹងភាពចាស់ក្លា និងទន់ខ្ចីនៃឥន្ទ្រិយរបស់បុគ្គល) ព្រោះហេតុនោះ មិគសាលាឧបាសិកាស្ត្រីល្ងង់ជានរណា និងព្រះសម្មាសម្ពុទ្ធ ដែលទ្រង់មានអារម្មណ៍មិនត្រូវជំទាស់ក្នុងញាណជាគ្រឿងកំណត់ដឹងភាពចាស់ក្លា និងទន់ខ្ចីនៃឥន្ទ្រីយរបស់បុគ្គលទាំងឡាយ ជានរណា ក្នុងបទនេះ មានសេចក្តីសង្ខេបដូចតទៅនេះ ទាំង ២ ចំណែកនោះ ឃ្លាតឆ្ងាយពីគ្នា គឺ ឆ្ងាយពីគ្នាក្រៃលែងណាស់ ។

ឥឡូវនេះ កាលនឹងទ្រង់សម្តែងថា មិគសាលាឧបាសិកាជាមួយនឹងព្រះអង្គឃ្លាតឆ្ងាយពីគ្នាច្រើន ទើបត្រាស់ពាក្យថា **ឆ យិមេ អានន្ទ** (ម្នាលអានន្ទ... ៦ ពួកនេះ) ជាដើម ។ បទថា **សោរតោ ហោតិ** (ជាអ្នកវៀរចាកបាប) បានដល់ (បុគ្គលពួកខ្លះ) ជាអ្នកវៀរ គឺ វៀរចាកបាបដោយល្អ ។ បាឋៈថា **សូរតោ** ដូច្នេះក៏មាន ។ បទថា **អភិនន្ទតិ សព្រហ្មចារី ឯកត្តវាសេន** (ពួកបុគ្គលដែលប្រព្រឹត្តព្រហ្មចារីរួមគ្នា រមែងត្រេកអរដោយការនៅរួមគ្នា) សេចក្តីថា ព្រហ្មចារីបុគ្គលទាំងឡាយនាំគ្នារីករាយ គឺ ត្រេកអរដោយការនៅរួមគ្នាជាមួយបុគ្គលនោះ ។ បាឋៈថា **ឯកន្តវាសេន** ដូច្នេះក៏មាន ។ អធិប្បាយថា ដោយការនៅតជាប់គ្នា ។ បទថា **សវនេនបិ អកតំ ហោតិ** (គេមិនបានធ្វើកិច្ចសូម្បីដោយការស្តាប់) បានដល់ យើងមិនបានស្តាប់វត្ថុដែលគួរស្តាប់ ។ ក្នុងបទថា **ពាហុសច្ចេនបិ អកតំ ហោតិ** (មិនបានធ្វើសូម្បីដោយភាពជាពហុសូត) នេះ វិរិយៈ ហៅថា ពាហុសច្ចៈ អធិប្បាយថា មិនបានធ្វើវត្ថុដែលគួរធ្វើដោយវិរិយៈ ។ បទថា **ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ** (មិនចាក់ធ្លុះសូម្បីដោយទិដ្ឋិ) បានដល់ មិនបានចាក់ធ្លុះវត្ថុ

ដែលគួរចាក់ធ្លុះដោយទិដ្ឋិ ។

បទថា **សាមាយិកម្បិ វិមុត្តឹ ន លភតិ** (មិនបានទូវវិមុត្តិសូម្បីដែលកើតក្នុងសម័យ) បានដល់ អាស្រ័យការស្តាប់ធម៌តាមកាលដ៏សមគួរហើយក៏មិនបានបីតិ និងបាមោជ្ជៈ ។ បទថា **ហានគាមីយេវ ហោតិ** (ជាអ្នកដល់នូវការវិនាសតែម្យ៉ាង) បានដល់ រមែងដល់នូវភាពសាបសូន្យតែម្យ៉ាង ។ បទថា **បមាណិកា** (ពួកបុគ្គលអ្នកកាន់យកប្រមាណ)) គឺ ពួកបុគ្គលអ្នកប្រមាណ (ការប្រៀបធៀប) ក្នុងបុគ្គលទាំងឡាយ ។ បទថា **បមិណន្តិ** (រមែងប្រមាណ) បានដល់ ផ្តើមនឹងប្រៀបធៀប គឺ ស្ទាបស្ទង់ ។ បទថា **ឯកោ ហីនោ** (បុគ្គលថោកទាបម្នាក់) បានដល់ មនុស្សម្នាក់ថោកទាបដោយគុណ ។ បទថា **ឯកោ បណីតោ** (បុគ្គលឧត្តមម្នាក់) បានដល់ មនុស្សម្នាក់ប្រណីតជាងដោយគុណ ។ បទថា **តញ្ហិ** (ក៏ការប្រមាណ) បានដល់ ការធ្វើការប្រមាណនោះ ។ បទថា **អភិក្កន្តតរោ** (ល្អជាង) គឺ ប្រសើរជាង ។ បទថា **បណីតតរោ** (ឧត្តមជាង) គឺ ឧត្តមជាង ។ បទថា **ធម្មសោតោ និព្វហតិ** (ព្រោះក្រសែនៃធម៌រមែងពាល់ត្រូវ) បានដល់ វិប-

សម្បន្នាញាណប្រព្រឹត្តទៅយ៉ាងក្លៀវក្លា រមែងពាល់ត្រូវ គឺ ឲ្យដល់អរិយ-ភូមិ ។ បទថា **តទនន្តរំ កោ ជានេយ្យ (នរណាហ្ន៎... នឹងគប្បីដឹងហេតុនោះ)** សេចក្ដីថា វាងការជាប់តគ្នានោះ គឺ ហេតុនោះ ក្រៅពីព្រះតថាគតហើយ នរណាហ្ន៎នឹងដឹង ។ បទថា **កោធមានោ (មានសេចក្ដីក្រោធ និងការប្រកាន់ខ្លួន)** បានដល់ មានសេចក្ដីក្រោធ និងមានមានះ ។ បទថា **លោភធម្មា (លោភធម៌)** បានដល់ សេចក្ដីលោភនោះឯង ។ បទថា **វចី-សង្ខារា (វចីសង្ខារ)** បានដល់ ការពោលដោយអំណាចការសន្ទនាប្រាស្រ័យនោះឯង ។ បទថា **យោ វា បនស្ស មាទិសោ (ឬបុគ្គលប្រហែលនឹងយើង)** សេចក្ដីថា ឬក៏បុគ្គលសូម្បីដទៃណា គប្បីជាព្រះសម្មាសម្ពុទ្ធ ដូចជាតថាគត បុគ្គលនោះ ក៏គប្បីកាន់យកជាប្រមាណ (ការប្រៀបធៀប) ក្នុងបុគ្គលទាំងឡាយបាន ។ បទថា **ខញ្ញតិ (រមែងទម្លាយ)** បានដល់ រមែងដល់នូវការជីករំលើងនូវគុណ ។

បទថា **ឥមេ ខោ អានន្ទ ឆ បុគ្គលា (ម្នាលអានន្ទ បុគ្គល ៦ ពួកនេះឯង)** បានដល់ បុគ្គល ៦ ពួកទាំងនេះ គឺ បុគ្គលអ្នកវៀរចាកបាប ២

ពួក បុគ្គលអ្នកមានសេចក្ដីក្រោធ និងការប្រកាន់ខ្លួន និងមានលោកធម៌ ២ ពួក បុគ្គលដែលមានសេចក្ដីក្រោធ និងការប្រកាន់ខ្លួន និងមានវចីសង្ខារ ២ ពួក ។ បទថា **គតឹ (គតិ)** បានដល់ ញាណគតិ ។ បទថា **ឯកង្គហីនា (ថោកទាបជាងគ្នាដោយអង្គនៃបុគ្គលម្យ៉ាង)** បានដល់ ថោកទាបជាងគ្នាដោយអង្គគុណនៃបុគ្គលម្យ៉ាង ។ បូរណៈ ជាបុគ្គលវិសេសដោយសីល (ខ្ពស់ជាងដោយសីល) ឥសិទត្តៈជាបុគ្គលវិសេសដោយបញ្ញា (ខ្ពស់ជាងដោយបញ្ញា) សីលរបស់បូរណៈ តាំងនៅក្នុងឋានៈនៃបញ្ញារបស់ឥសិទត្តៈ បញ្ញារបស់ឥសិទត្តៈ តាំងនៅក្នុងឋានៈនៃសីលរបស់បូរណៈ ។

ចប់អដ្ឋកថា មិគសាលាសូត្រទី ២

# អដ្ឋកថា ឥណសូត្រទី ៣

## (ផ្លូវលោក និងផ្លូវធម៌)

គប្បីជ្រាបវិនិច្ឆ័យក្នុង ឥណសូត្រទី ៣ ដូចតទៅនេះ ៖

[៤៥] បទថា **ទលិទ្ទិយំ** (ជាអ្នកទ័លក្រ) បានដល់ ភាពជាអ្នកទ័លក្រ ។ បទថា **កាមភោគិនោ** (របស់បុគ្គលអ្នកបរិភោគកាម) បានដល់សត្វដែលបរិភោគកាម ។ បទថា **អស្សកោ** (មិនមានវត្ថុជារបស់ខ្លួន) បានដល់ ប្រាសចាកទ្រព្យដែលជារបស់ខ្លួន ។ បទថា **អនឡ្ហិកោ** (ក្រលំបាក) បានដល់ មិនស្តុកស្តម្ភ ។ បទថា **ឥណំ អាទិយតិ** (រមែងខ្ចីបំណុល) បានដល់ កាលមិនអាចនឹងរស់នៅបានក៏ខ្ចីបំណុល ។ បទថា **វឌ្ឍឹ បដិស្សុណាតិ** (ត្រូវឲ្យការប្រាក់) បានដល់ កាលមិនអាចនឹងសង ក៏ឲ្យសញ្ញាថា នឹងឲ្យការប្រាក់ ។ បទថា **អនុចរន្តិបិ នំ** (រមែងដេញតាមគេ) សេចក្តីថា (ម្ចាស់បំណុលទាំងឡាយ) ដេញតាមក្រោយៗ កូនបំណុល ធ្វើឲ្យគេបានទទួលអាការដែលចម្លែក ដោយការចាប់ឲ្យនៅកណ្តាលថ្ងៃ និងការរោយធូលីលើជាដើម ក្នុងកណ្តាលបរិស័ទ និងកណ្តាលគណៈជាដើម ។

បទថា **សទ្ធា នត្ថិ (មិនមានសទ្ធា)** បានដល់ មិនមានសូម្បីត្រឹមតែសទ្ធា គឺ ការជាក់ចិត្តជឿ ។ បទថា **ហិរិ នត្ថិ (មិនមានហិរិ)** បានដល់ មិនមានសូម្បីត្រឹមតែអាការដែលអៀនខ្មាស ។ បទថា **ឱត្តប្បំ នត្ថិ (មិនមានឱត្តប្បៈ)** បានដល់ មិនមានត្រឹមតែអាការភ័យខ្លាច ។ បទថា **វីរិយំ នត្ថិ (មិនមានវីរិយៈ)** បានដល់ មិនមានសូម្បីត្រឹមតែសេចក្តីព្យាយាមដែលប្រព្រឹត្តទៅតាមផ្លូវកាយ ។ បទថា **បញ្ញា នត្ថិ (មិនមានបញ្ញា)** បានដល់ មិនមានសូម្បីត្រឹមតែកម្មស្សកតាបញ្ញា ។ បទថា **ឥណាទានស្មឹ វទាមិ**[1] **(តថាគតពោល "ការប្រព្រឹត្តទុច្ចរិតរបស់គេនេះ" ថា ជាការជំពាក់បំណុល)** បានដល់ តថាគតពោលថា ជាកូនបំណុល ។ បទថា **មា មំ ជញ្ញុ (ជនដទៃណាកុំស្គាល់យើង)** បានដល់ សូមម្ចាស់បំណុលទាំងឡាយកុំជួបជាមួយយើង ។

បទថា **ទលិទ្ទិយំ ទុក្ខំ (ជាអ្នកទ័លក្រ... ជាទុក្ខ)** បានដល់ ភាពជាអ្នកទ័លក្រនូវទ្រព្យ ជាហេតុឲ្យកើតទុក្ខ ។ បទថា **កាមលាភាភិជប្បិនំ**

---

(១) បិដក = ឥណាទានស្មិំ វទាមិ ។

(អ្នកប្រាថ្នាការបាននូវកាម) បានដល់ អ្នកប្រាថ្នាការបានកាម ។ បទថា ***បាបកម្មំ វិនិព្វយោ***[១] (កពូនបាបកម្ម) បានដល់ អ្នកកពូននូវបាបកម្ម ។ បទថា ***សំសប្បតិ*** (ត្រដាបត្រដួស) បានដល់ ត្រដរ ។ បទថា ***ជានំ*** (ជ្រាប) បានដល់ ដឹងហើយ ។ បទថា ***យស្ស វិប្បដិសារជា*** (ដែលកើតពីសេចក្ដីក្ដៅក្រហាយចិត្តរបស់បុគ្គល) សេចក្ដីត្រិះរិះណាកើតអំពីសេចក្ដីក្ដៅក្រហាយក្នុងចិត្តរបស់គេ ។ បទថា ***យោនិមញ្ញតរំ*** (កំណើតតិរច្ឆានខ្វះ) បានដល់ កំណើតសត្វតិរច្ឆាន កំណើតណាមួយ ។ បទថា ***ទទំ ចិត្តំ បសាទយំ*** (បុគ្គលញ៉ាំងចិត្តឲ្យជ្រះថ្លា ហើយឲ្យទាន) បានដល់ អ្នកញ៉ាំងចិត្តឲ្យជ្រះថ្លាហើយថ្វាយទាន ។ បទថា ***កដគ្គាហោ*** (រមែងជាអ្នកកាន់យកជ័យជំនះបាន) បានដល់ ជាអ្នកបានជ័យជំនះ គឺ ជាអ្នកបានមិនខុស ។ បទថា ***ឃរមេសិនោ*** (នៅគ្រប់គ្រងផ្ទះ) បានដល់ អ្នកស្វែងរកការនៅគ្រប់គ្រងផ្ទះ ។ បទថា ***ចាគោ បុញ្ញំ បវឌ្ឍតិ***[១] (បុណ្យ គឺ ការបរិច្ចាគ... រមែងចម្រើន) បានដល់ បុណ្យដែលប្រព្រឹត្តទៅក្នុងសន្ដាន គឺ ចាគៈរមែងចម្រើន ។

---

(១) ឱរុប = វិឆិច្ចយោ , (២) បិដក = បវត្តតិ ។

ម្យ៉ាងទៀត បាលីថា ចាគំ បុញ្ញំ ដូច្នេះក៏មាន ។ បទថា បតិដ្ឋិតា (ដំកល់មាំ) បានដល់ សទ្ធារបស់ព្រះសោតាបន្ន ឈ្មោះថា សទ្ធាដែលតាំងមាំ ។ បទថា ហិរិមនោ (មានចិត្តប្រកបដោយហិរិ) បានដល់ ចិត្តសម្បយុត្តដោយហិរិ ។ បទថា និរាមិសំ សុខំ (សេចក្តីសុខប្រាសចាកអាមិស) បានដល់ សុខដែលអាស្រ័យឈាន ៣ កើតឡើង ។ បទថា ឧបេក្ខំ (ឧបេក្ខា) បានដល់ ឧបេក្ខាក្នុងចតុត្ថជ្ឈាន ។ បទថា អារទ្ធវីរិយោ (ជាអ្នកប្រារព្ធសេចក្តីព្យាយាម) បានដល់ មានសេចក្តីព្យាយាមផ្គងទុកយ៉ាងបរិបូណ៌ ។ បទថា ឈានានិ ឧបសម្បជ្ជ (លុះនូវឈានទាំងឡាយ) បានដល់ សម្រេចឈាន ៤ ។ បទថា ឯកោទិ និបកោ សតោ (មានឯកគ្គតាចិត្ត មានបញ្ញាជាគ្រឿងរក្សាខ្លួន) បានដល់ មានចិត្តជាឯកគ្គតា និងប្រកបដោយកម្មស្សកតាញាណ និងសតិ ។

បទថា ឯតំ ញត្វា យថាភូតំ (ព្រោះដឹងហេតុ... តាមសេចក្តីពិត) បានដល់ ដឹងហេតុនេះថា មានប៉ុណ្ណេះ តាមសភាវៈដែលពិត ។ បទថា សព្វសញ្ញោជនក្ខយេ (ក្នុងធម៌ជាទីអស់ទៅនៃសំយោជនៈទាំងពួង) បានដល់

ក្នុងនិព្វាន ។ បទថា **សព្វសោ** (ដោយប្រការទាំងពួង) បានដល់ ដោយអាការគ្រប់យ៉ាង ។ បទថា **អនុបាទាយ** (ព្រោះមិនបានកាន់យក) បានដល់ ព្រោះប្រកាន់ ។ បទថា **សម្មា ចិត្តំ វិមុច្ចតិ** (ចិត្តក៏ផុតស្រឡះដោយប្រពៃ) មានពាក្យអធិប្បាយដូច្នេះថា មគ្គចិត្តរមែងរួចផុតដោយប្រពៃ គឺ ដោយហេតុ ដោយន័យ ព្រោះមិនប្រកាន់មាំដោយប្រការទាំងពួង ក្នុងនិព្វាន ពោលគឺ ធម៌ដែលជាទីអស់ទៅនៃសញ្ញោជនៈទាំងពួង ។ អាចារ្យពួកខ្លះសរសេរបាលីជា **ឯវំ ញត្វា យថាភូតំ សព្វសញ្ញោជនក្ខយំ** (ព្រោះដឹងធម៌ជាទីអស់ទៅនៃសញ្ញោជនៈទាំងពួងតាមសេចក្ដីពិតយ៉ាងនេះ) ដូច្នេះក៏មាន ។ បាលីនោះមានអធិប្បាយថា ដឹងនិព្វាន ពោលគឺ ធម៌ជាទីអស់ទៅនៃសញ្ញោជនៈទាំងអស់នោះតាមពិត ។ តែថា អត្ថព្រះបាលីបទមុខ និងបទក្រោយមិនជាប់តគ្នាឡើយ ។ បទថា **តស្ស សម្មាវិមុត្តស្ស** (គេមានចិត្តរួចផុតដោយប្រពៃ) បានដល់ គេជាអ្នកមានចិត្តរួចផុតដោយប្រពៃ គឺមានអាសវៈអស់ហើយ ។ បទថា **ញាណំ ចេ ហោតិ** (ប្រសិនបើ... រមែងមានញាណដឹង) បានដល់ មានបច្ចវេក្ខណញ្ញាណ ។ បទថា **តាទិនោ**

*(អ្នកស្ថិតនៅ)* បានដល់ អ្នកតាំងមាំយ៉ាងនោះ ។ បទថា **អកុប្បា** *(មិនកម្រើក)* បានដល់ ឈ្មោះថាមិនកម្រើក ព្រោះមានធម៌មិនកម្រើកជាអារម្មណ៍ និងព្រោះមិនមានកិលេសជាគ្រឿងធ្វើឲ្យកម្រើក ។ បទថា **វិមុត្តិ** *(ការរួចផុត)* បានដល់ ទាំងមគ្គវិមុត្តិ ទាំងផលវិមុត្តិ ។ បទថា **ភវសញ្ញោជនក្ខយេ** *(ក្នុងធម៌ជាទីអស់ទៅនៃភវសំយោជនៈ)* បានដល់ ក្នុងនិព្វាន ពោលគឺ ធម៌ជាទីអស់ទៅនៃកិលេសជាគ្រឿងចងសត្វទុកក្នុងភព និងព្រោះវិមុត្តិកើតឡើងក្នុងបំផុតនៃការអស់ទៅនៃកិលេសជាគ្រឿងចងសត្វទុកក្នុងភព ។ បទថា **ឯតំ ខោ បរមំ ញាណំ** *(ញាណនុ៎ះឯង ជាញាណដ៏ឧត្តម)* បានដល់ មគ្គញាណ និងផលញាណនោះ ឈ្មោះថា បរមញាណ (ញាណដ៏ឧត្តម) ។ បទថា **សុខមនុត្តរំ** *(ជាសុខរកសេចក្តីសុខដទៃក្រៃលែងជាងគ្មាន)* បានដល់ សុខដែលកើតអំពីមគ្គ និងផលនុ៎ះឯង ឈ្មោះថា ជាសុខដ៏កំពូល ។ បទថា **អានណ្យា មុត្តមំ** *(ខ្ពស់បំផុតជាងការមិនមានបំណុល)* សេចក្តីថា បណ្តាបុគ្គលដែលមិនមានបំណុលទាំងអស់ ព្រះខីណាស្រពជាបុគ្គលមិនមានបំណុលដ៏ខ្ពង់ខ្ពស់ជាង ព្រោះដូច្នោះ ព្រះមាន-

ព្រះភាគទើបរួមអត្ថដ៏សំខាន់នៃទេសនា ដោយអរហត្តផលថា អរហត្តផល ជាញាណ មិនមានបំណុលឧត្តមជាង ។ ក៏ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ចំណែកវដ្ដៈទុកមុន ហើយត្រាស់ទាំងចំណែកវដ្ដៈ និងវិវដ្ដៈទុកក្នុង គាថាទាំងឡាយ ។

ចប់អដ្ឋកថា ឥណសូត្រទី ៣

# អដ្ឋកថា មហាចុន្ទសូត្រទី ៤

## (ព្រះមហាចុន្ទៈទូន្មានឲ្យភិក្ខុសម្លឹងឈាន)

*គប្បីជ្រាបវិនិច្ឆ័យក្នុង មហាចុន្ទសូត្រទី ៤ ដូចតទៅនេះ ៖*

[៤៦] *បទថា* ***ចេតីសុ*** *(ក្នុងដែនចេតិ) បានដល់ ក្នុងចេតរដ្ឋ ។ បទថា* ***សញ្ជាតិយំ*** *(នៅក្នុងនិគមឈ្មោះសញ្ជាតិ) បានដល់ ក្នុងនិគមដែលមានឈ្មោះយ៉ាងនេះ ។ បទថា* ***មហាចុន្ទោ*** *(ព្រះមហាចុន្ទៈ) បានដល់ ប្អូនប្រុសពៅរបស់ព្រះធម្មសេនាបតី ។ ឈ្មោះថា* ***ធម្មយោគា*** *(អ្នកប្រកបក្នុងធម៌) ព្រោះអត្ថថា មានការប្រកប គឺ ការធ្វើរឿយៗ ក្នុងធម៌ ។ បទថា* ***អ្នកប្រកបក្នុងធម៌*** *នោះ ជាឈ្មោះរបស់ព្រះធម្មកថិកទាំងឡាយ ។ បទថា* ***ឈាយី*** *(អ្នកសម្លឹងឈាន) ព្រោះអត្ថថា សម្លឹង ។ បទថា* ***អបសាទេន្តិ*** *(រមែងរុករាន) បានដល់ រមែងខ្ទាំងខ្ទប់ គឺ រមែងចោមវាយ ។ បទថា* ***ឈាយន្តិ*** *(សម្លឹងឈាន) បានដល់ រមែងគិត ។ បទថា* ***បជ្ឈាយន្តិ*** *(ប្រកាន់ឈាន) ជាដើម លោកផ្សាយ (រូប) ចេញទៅដោយអំណាចឧបសគ្គ ។*

បទថា **កិញ្ចិមេ ឈាយន្តិ** (ក៏ភិក្ខុទាំងនេះ សម្លឹងឈានអ្វី) បាន ដល់ ភិក្ខុអ្នកសម្លឹងឈានទាំងនេះ រមែងសម្លឹងឈានអ្វី ។ បទថា **កិន្តិមេ ឈាយន្តិ** (សម្លឹងឈានដើម្បីអ្វី) បានដល់ ភិក្ខុអ្នកសម្លឹងឈានទាំងនេះ សម្លឹងឈានដើម្បីអ្វី ។ បទថា **កថញ្ចិមេ ឈាយន្តិ** (សម្លឹងឈានព្រោះ ហេតុអ្វី) បានដល់ ភិក្ខុអ្នកសម្លឹងឈានទាំងនេះ សម្លឹងឈានព្រោះហេតុ អ្វី ។ បទថា **អមតំ ធាតុំ កាយេន ផុសិត្វា វិហរន្តិ** (លោកពាល់ត្រូវ អមតធាតុដោយកាយហើយ) ជាដើម មានសេចក្តីថា ភិក្ខុទាំងឡាយកំណត់ កម្មដ្ឋានសំដៅដល់និព្វានធាតុដែលវៀរចាកមរណៈ គឺ ពាល់ត្រូវនិព្វាន-ធាតុនោះដោយនាមកាយតាមលំដាប់ ។ បទថា **គម្ភីរអត្ថបទំ** (ចំណែកនៃ អត្ថដ៏ជ្រាលជ្រៅ) បានដល់ អត្ថរបស់ខន្ធ ធាតុ អាយតនៈជាដើម ដែល កំបាំង គឺ ត្រូវ (អវិជ្ជា) បិទបាំងទុក ។ បទថា **បញ្ញាយ អតិវិជ្ឈបស្សន្តិ** (ចាក់ធ្លុះ ឃើញ... ដោយបញ្ញា) បានដល់ ចាក់ធ្លុះ ឃើញ ដោយមគ្គ-បញ្ញាព្រមទាំងវិបស្សនា ។ តែក្នុងអត្ថនេះ រមែងគួរទាំងបញ្ញាជាគ្រឿង ចាក់ធ្លុះដោយការពិចារណា ទាំងបញ្ញាក្នុងការរៀន និងការសាកសួរនោះ

ឯង ៗ

ចប់អដ្ឋកថា មហាចុន្ទសូត្រទី ៤

# អដ្ឋកថា បឋមសន្ទិដ្ឋិកសូត្រទី ៥

*(ធម៌ដែលបុគ្គលចាក់ធ្លុះគប្បីឃើញឯង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសន្ទិដ្ឋិកសូត្រទី ៥ ដូចតទៅនេះ ៖*

[៤៧] *បទថា* ***សន្តំ វា អជ្ឈត្តំ*** *(មានក្នុងខាងក្នុង) បានដល់ មាននៅខាងក្នុងខ្លួន ។ ព្រះមានព្រះភាគទ្រង់សម្តែងអកុសលមូល ៣ ដោយពាក្យថា* ***លោភះ*** *ជាដើម ។ ទ្រង់សម្តែងធម៌ដែលសម្បយុត្តដោយអកុសលមូល ៣ នោះ ដោយបទថា* ***លោភធម្មា*** *(ធម៌ដែលប្រកបដោយលោភះ) ជាដើម ។*

ចប់អដ្ឋកថា បឋមសន្ទិដ្ឋិកសូត្រទី ៥

# អដ្ឋកថា ទុតិយសន្ទិដ្ឋិកសូត្រទី ៦

*(ធម៌ដែលបុគ្គលចាក់ដោះគប្បីឃើញឯង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសន្ទិដ្ឋិកសូត្រទី ៦ ដូចតទៅនេះ ៖*

*[៤៨] បទថា **កាយសំទោសំ**(១) (ហេតុជាគ្រឿងប្រទូស្តកាយ) បាន ដល់ ហេតុនៃការប្រទូសរ៉ាយផ្លូវកាយទ្វារ ។ សូម្បីក្នុងពីរបទដ៏សេស ក៏ មានន័យនេះដូចគ្នា ។ ព្រះមានព្រះភាគត្រាស់បច្ចវេក្ខណញាណទុក ក្នុង សូត្រទាំងពីរ (សន្ទិដ្ឋិកសូត្រទី ៥-៦) នេះ ដូច្នេះ ។*

ចប់អដ្ឋកថា ទុតិយសន្ទិដ្ឋិកសូត្រទី ៦

---

(១) បិដក = កាយសន្ទោសំ ។

# អដ្ឋកថា ខេមសុមនសូត្រទី ៧

## (ព្រះខេមៈ និងព្រះសុមនៈព្យាករណ៍អរហត្តផល)

គប្បីជ្រាបវិនិច្ឆ័យក្នុង ខេមសុមនសូត្រទី ៧ ដូចតទៅនេះ ៖

[៤៩] បទថា **វុសិតវា** (នៅចប់ព្រហ្មចរិយៈ) បានដល់ អ្នកនៅចប់ព្រហ្មចរិយៈហើយ ។ បទថា **កតករណីយោ** (មានកិច្ចដែលគួរធ្វើធ្វើស្រេចហើយ) បានដល់ អ្នកធ្វើកិច្ចដែលគួរធ្វើដោយមគ្គ ៤ ហើយតាំងនៅ ។ បទថា **ឱហិតភារោ** (មានភារៈដាក់ចុះហើយ) បានដល់ អ្នកមានខន្ធភារៈដាក់ចុះ និងអភិសង្ខារភារៈដាក់ចុះហើយ ។

បទថា **អនុប្បត្តសទត្ថោ** (មានប្រយោជន៍របស់ខ្លួនសម្រេចហើយ) សេចក្តីថា បុគ្គលសម្រេចព្រះអរហត្ត ដែលហៅថា ប្រយោជន៍របស់ខ្លួន ។ បទថា **បរិក្ខីណភវសញ្ញោជនោ** (អស់សំយោជនៈក្នុងភពហើយ) បានដល់ អ្នកមានកិលេសជាគ្រឿងចងទុកក្នុងភពអស់ហើយ ។ បទថា **សម្មទញ្ញាវិមុត្តោ** (រួចផុតហើយព្រោះដឹងដោយជុំវិញ) បានដល់ រួចផុតហើយព្រោះដឹងដោយជុំវិញ គឺ ដោយហេតុ ដោយការណៈ ។ ព្រះខេមបដិសេធមានះ

៣ មានមានៈរបស់អ្នកដែលប្រសើរជាងគេថា យើងប្រសើរជាងគេជាដើម សូម្បីបទថា តស្ស ន ឯវំ ហោតិ អត្ថិ មេ សេយ្យោតិ វា (ភិក្ខុនោះមិនមានការគិតយ៉ាងនេះថា បុគ្គលដទៃប្រសើរជាងយើងមាន) ជាដើម ។ ព្រោះថា ព្រះខីណាស្រពមិនមានមានៈថា បុគ្គលដែលប្រសើរជាងយើងមាន បុគ្គលដែលនៅស្មើនឹងយើងមាន បុគ្គលដែលថោកទាបជាងយើងមាន ។ ព្រះសុមនៈបដិសេធមានៈ ៣ ទាំងនោះឯង សូម្បីបទថា នត្ថិ មេ សេយ្យោ (បុគ្គលប្រសើរជាងយើងមិនមាន) ជាដើម ព្រោះថា ព្រះខីណាស្រពមិនមានមានៈយ៉ាងនេះថា យើងនេះឯងប្រសើរជាងគេ យើងស្មើនឹងគេ យើងថោកទាបជាងគេ មិនមានបុគ្គលដទៃប្រសើរជាង ជាដើម ។

បទថា អចិរបក្កន្តេសុ (ចៀសចេញទៅមិនយូរប៉ុន្មាន) បានដល់កាលព្រះខេមៈ និងព្រះសុមនៈព្យាករណ៍អរហត្តផលហើយ មិនយូរប៉ុន្មានក៏ចៀសចេញទៅ ។ បទថា អញ្ញំ ព្យាករោន្តិ (រមែងព្យាករណ៍អរហត្តផល) បានដល់ ពោលដល់អរហត្តផល ។ បទថា ហសមានកា មញ្ញេ អញ្ញំ ព្យាករោន្តិ (ហាក់ដូចជារីករាយព្យាករណ៍នូវអរហត្តផល) បានដល់

ពោលដូចជារីកកាយ ។ បទថា វិឃាតំ អាបជ្ជតិ (រមែងដល់សេចក្តីទុក្ខ) បានដល់ ប្រសព្វទុក្ខ ។

បទថា ឧស្សា[១] (បុគ្គលដែលប្រសើរជាង) ក្នុងបទថា ន ឧស្សេសុ ន ឱមេសុ សមត្ត នោបនិយ្យរេ (មិនបានបង្អោនខ្លួនទៅប្រៀបនឹងបុគ្គលដែលប្រសើរជាង មិនបានបង្អោនខ្លួនទៅប្រៀបនឹងបុគ្គលដែលថោកទាបជាង មិនបង្អោនខ្លួនទៅប្រៀបនឹងបុគ្គលដែលស្មើគ្នា) នេះ បានដល់ បុគ្គលដែលគេលើកតម្កើង គឺ បុគ្គលដែលប្រសើរជាងគេ ។ បទថា ឱមា (បុគ្គលដែលថោកទាបជាង) បានដល់ បុគ្គលដែលថោកទាបជាងគេ ។ បទថា សមត្តា (បុគ្គលដែលស្មើគ្នា) បានដល់ បុគ្គលដែលស្មើនឹងខ្លួន ។ ព្រះខីណាស្រព ដែលមានះរមែងនាំចូលទៅមិនបាន គឺ មិនចូលជិត អធិប្បាយថា មិនចូលដល់មានះក្នុងបុគ្គលដែលប្រសើរជាងគេ ថោកទាបជាងគេ និងស្មើនឹងគេ ទាំង ៣ ជំពូកនេះ ។ បទថា ខីណា សញ្ញាតិ (មានជាតិអស់ហើយ) បានដល់ ជាតិរបស់ព្រះខីណាស្រពទាំងនោះអស់ហើយ ។ បទថា

(១) បិដក = ឧស្សេសុ ។

វុសិតំ ព្រហ្មចរិយំ (នៅចប់ព្រហ្មចរិយៈហើយ) បានដល់ មគ្គព្រហ្មចរិយៈ ដែលព្រះខីណាស្រពទាំងឡាយជាអ្នករួចផុតចាកសំយោជនៈទាំងពួង ហើយ ត្រាច់ទៅ ។ ព្រះមានព្រះភាគត្រាស់ដល់ព្រះខីណាស្រព ទាំងក្នុងព្រះសូត្រ ទាំងក្នុងគាថា ។

ចប់អដ្ឋកថា ខេមសុមនសូត្រទី ៧

# អដ្ឋកថា ឥន្ទ្រិយសំវរសូត្រទី ៨

*(ការសង្រួមឥន្ទ្រិយ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥន្ទ្រិយសំវរសូត្រទី ៨ ដូចតទៅនេះ ៖*

*[៥០] បទថា **ហតូបនិសំ ហោតិ** (មានឧបនិស្ស័យត្រូវកម្ចាត់) បានដល់ សីល រមែងមានឧបនិស្ស័យត្រូវកម្ចាត់ ។ បទថា **សីលវិបន្នស្ស** (របស់ភិក្ខុអ្នកមានសីលវិបត្តិ) បានដល់ អ្នកមានសីលដែលវិបត្តិហើយ ។ បទថា **យថាភូតំ ញាណទស្សនំ** (យថាភូតញ្ញាណទស្សនៈ) បានដល់ វិបស្សនាញាណទន់ខ្ចី ។ វិបស្សនាញាណដែលមានកម្លាំង ឈ្មោះថា **និព្វិទា** អរិយមគ្គ ឈ្មោះថា **វិរាគៈ** ក្នុងបទថា **និព្វិទា វិរាគោ** នេះ ។ អរហត្តផល ឈ្មោះថា **វិមុត្តិ** , បច្ចវេក្ខណញ្ញាណ ឈ្មោះថា **ញាណទស្សនៈ** ក្នុងបទថា **វិមុត្តិញាណទស្សនៈ** នេះ ។ បទថា **ឧបនិស្សយសម្បន្នំ ហោតិ** (រមែងមានឧបនិស្ស័យសម្បូរ) បានដល់ សីលដែលដល់ព្រមហើយ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់ឥន្ទ្រិយដែលជាគ្រឿងរក្សាសីល ។*

ចប់អដ្ឋកថា ឥន្ទ្រិយសំវរសូត្រទី ៨

# អដ្ឋកថា អានន្ទសូត្រទី ៩

*(គុណរបស់ព្រះអានន្ទ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានន្ទសូត្រទី ៩ ដូចតទៅនេះ ៖*

[៥១] *បទថា* ***កិត្តាវតា*** *(តើដោយហេតុប៉ុន្មាន) បានដល់ ដោយហេតុមានប្រមាណប៉ុន្មាន ។ បទថា* ***អសុតញ្ចេវ*** *(នៅមិនធ្លាប់បានស្តាប់) បានដល់ ធម៌ដែលមិនធ្លាប់ស្តាប់មកក្នុងកាលដទៃ ។ បទថា* ***ន សម្មោសំ គច្ឆន្តិ*** *(មិនដល់នូវសេចក្តីភ្លេចភ្លាំងទៅវិញ) បានដល់ រមែងមិនដល់នូវភាពសាបសូន្យទៅ ។ បទថា* ***ចេតសា សម្ផុដ្ឋបុព្វា*** *(ដែលលោកធ្លាប់ពាល់ត្រូវដោយចិត្ត) បានដល់ ដែលលោកធ្លាប់សម្ផ័ស្សដោយចិត្ត ។ បទថា* ***សមុទាចរន្តិ*** *(ក៏ផុសផុលឡើង) បានដល់ រមែងប្រព្រឹត្តទៅក្នុងមនោទ្វារ ។ បទថា* ***អវិញ្ញាតញ្ច វិជានាតិ*** *(និងលោករមែងជ្រាបច្បាស់នូវធម៌ដែលមិនទាន់ជ្រាបច្បាស់) បានដល់ រមែងដឹងហេតុដែលនៅមិនទាន់ដឹងច្បាស់មកក្នុងកាលដទៃ ។ បទថា* ***បរិយាបុណាតិ*** *(រមែងរៀន) បានដល់ សិក្សា គឺ ស្វាធ្យាយ ។ បទថា* ***ទេសេតិ*** *(រមែងសម្តែង) គឺ រមែងប្រកាស ។*

*បទថា **បរំ វាចេតិ**[1] (រមែងបង្រៀន... ដល់បុគ្គលដទៃ) បានដល់ ឲ្យបុគ្គលដទៃរៀន ។*

*បទថា **អាគតាគមា** (ជំនាញគម្ពីរ) មានវិគ្រោះថា ឈ្មោះថា **ជំនាញគម្ពីរ** ព្រោះអត្ថថា ជំនាញក្នុងគម្ពីរណាមួយក្នុងគម្ពីរទាំងឡាយ មានគម្ពីរទីឃនិកាយជាដើម ។ បទថា **ធម្មធរា** (ទ្រទ្រង់ធម៌) បានដល់ ទ្រទ្រង់ព្រះសុត្តន្តបិដក ។ បទថា **វិនយធរា** (ទ្រទ្រង់វិន័យ) បានដល់ ទ្រទ្រង់វិន័យបិដក ។ បទថា **មាតិកាធរា** (ទ្រទ្រង់មាតិកា) បានដល់ ទ្រទ្រង់ចាំបាតិមោក្ខទាំង ២ ចំណែក ។ បទថា **បរិបុច្ឆតិ** (សាកសួរ) បានដល់ សួរដល់ខាងដើម និងខាងចុងរបស់អនុសន្ធិ ។ បទថា **បរិបញ្ហតិ** (ជញ្ជោល) បានដល់ ពិចារណា គឺ កំណត់ថា យើងនឹងសួរវត្ថុនេះ និងវត្ថុនេះ ។ បទថា **ឥទំ ភន្តេ កថំ** (លោកម្ចាស់ ភាសិតនេះដូចម្តេច) សេចក្តីថា ភិក្ខុរមែងសួរថា លោកម្ចាស់ បទខាងដើម និងខាងចុងរបស់អនុសន្ធិនេះដូចម្តេច ។ បទថា **ឥមស្ស ក្វត្ថោ** (អត្ថរបស់ភាសិតនេះដូចម្តេច)*

---

(១) បិដក = បរេសំ វាចេតិ ។

*សេចក្តីថា ភិក្ខុរមែងសួរថា ភាសិតនេះ មានសេចក្តីយ៉ាងណា ។ បទថា **អវិវដំ** (ដែលនៅមិនទាន់ជាក់ច្បាស់) បានដល់ ដែលមិនទាន់បើកផ្សាវ ។ បទថា **វិវរន្តិ** (រមែងបើកបង្ហាញ) បានដល់ ធ្វើឲ្យប្រាកដ ។ បទថា **កង្ខាដ្ឋានិយេសុ** (ជាទីតាំងនៃសេចក្តីសង្ស័យ) បានដល់ ដែលជាហេតុនៃសេចក្តីសង្ស័យ ។ ក្នុងបទថា **ដែលជាទីតាំងនៃសេចក្តីសង្ស័យ** នោះ គប្បីជ្រាបសេចក្តីសង្ស័យកើតឡើងក្នុងធម៌ណា ធម៌នោះឯង ឈ្មោះថាជាទីតាំងនៃសេចក្តីសង្ស័យ ។*

ចប់អដ្ឋកថា អានន្ទសូត្រទី ៩

# អដ្ឋកថា ខត្តិយសូត្រទី ១០

## (សេចក្តីបំណងរបស់ក្សត្រិយជាដើម)

គប្បីជ្រាបវិនិច្ឆ័យក្នុង ខត្តិយសូត្រទី ១០ ដូចតទៅនេះ ៖

[៥២] បទថា *ភោគាធិប្បាយា (បំណងភោគទ្រព្យ)* បានដល់ ទ្រង់តាំងព្រះបំណងទុក គឺ ទ្រង់មានអធ្យាស្រ័យប្រព្រឹត្តទៅដើម្បីប្រមូលភោគៈ ។ បទថា *បញ្ញូបវិចារា (និយមបញ្ញា)* សេចក្តីថា មានការពិចារណាដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់បញ្ញា យ៉ាងនេះថា សូមយើងទាំងឡាយគប្បីជាអ្នកមានបញ្ញា ។ ការពិចារណានេះឯងរបស់ក្សត្រិយទាំងនោះ រមែងមានក្នុងព្រះហឫទ័យជានិច្ច ។ បទថា *ពលាធិដ្ឋានា (ទុកចិត្តដល់កម្លាំងទាហាន)* សេចក្តីថា មានសេចក្តីទុកចិត្តក្នុងកម្លាំងកងទ័ព ។ សេចក្តីពិតក្សត្រិយទាំងនោះ បានកងទ័ពហើយ ក៏ឈ្មោះថា បាននូវទីពឹង ។ បទថា *បឋវីអភិនិវេសា (ត្រូវការដើម្បីបានផែនដី)* សេចក្តីថា ធ្វើការតាំងព្រះទ័យមាំ ដើម្បីត្រូវការផែនដីយ៉ាងនេះ យើងនឹងជាម្ចាស់របស់ផែនដី ។ បទថា *ឥស្សរិយបរិយោសានា (មានឥស្សរិយៈជាទីបំផុត)* សេចក្តីថា មានភាជា-

ភិសេក (ការអភិសេកជាព្រះរាជា) ជាទីបំផុត ។ ពិតណាស់ ក្សត្រិយទាំងនោះ បានទទួលការអភិសេកហើយ ឈ្មោះថា ដល់ទីបំផុត ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួងដោយន័យនេះ ។

ចំណែកក្នុងពាក្យដ៏សេសក្នុងសូត្រនេះ មានអធិប្បាយដូចតទៅនេះ ជាដំបូង ព្រាហ្មណ៍ទាំងឡាយបានមន្តហើយ ឈ្មោះថា បានទីពឹង , គហបតីទាំងឡាយបានសិល្បៈណាមួយហើយ ឈ្មោះថា បានទីពឹង , ស្ត្រីទាំងឡាយបានបុត្រដែលជាអ្នកស្នងមត៌កក្នុងត្រកូល ឈ្មោះថា បានទីពឹង , ចោរទាំងឡាយបានសាស្ត្រាវុធប្រភេទណាមួយហើយ ឈ្មោះថា បានទីពឹង , សមណព្រាហ្មណ៍មានសីលបរិបូណ៌ ឈ្មោះថា បានទីពឹង ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យទាំងឡាយ មានបទថា ទុកចិត្តក្នុងមន្ត ជាដើម ។ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយ រមែងមានចិត្តប្រកាន់ថា យើងទាំងឡាយនឹងបូជាយ័ញ្ញ កាលចូលដល់ព្រហ្មលោកហើយ ឈ្មោះថា ដល់ទីបំផុត ព្រោះដូច្នោះ ព្រាហ្មណ៍ទាំងនោះ ព្រះមានព្រះភាគទើបត្រាស់ថា យញ្ញាភិនិវេសា ព្រហ្មលោកបរិយោសាន (ត្រូវការបូជាយ័ញ្ញ មានព្រហ្មលោក

ជាទីបំផុត) ។ ឈ្មោះថា **កម្មន្តាភិនិវេសា** (ត្រូវការការងារ) ព្រោះអត្ថថា ដែលមានចិត្តប្រកាន់ដើម្បីត្រូវការនឹងធ្វើការងារ ។ កាលការងារស្រេចហើយ គហបតីទាំងឡាយ ឈ្មោះថា ដល់ទីបំផុត ព្រោះដូច្នោះ គហបតីទាំងឡាយទើបឈ្មោះថា **និដ្ឋិតកម្មន្តបរិយោសានា** (មានការងារដែលសម្រេចហើយជាទីបំផុត) ។ បទថា **បុរិសាធិប្បាយា** (បំណងបុរស) បានដល់មានអធ្យាស្រ័យប្រព្រឹត្តទៅក្នុងបុរសទាំងឡាយ ។ បទថា **អលង្ការូបវិចារា** (និយមគ្រឿងតែងខ្លួន) ព្រោះអត្ថថា មានចិត្តនិយមត្រូវការគ្រឿងប្រដាប់ ។ បទថា **អសបតិអភិនិវេសា** (ត្រូវការមិនឲ្យមានស្ត្រីដទៃរួមស្វាមី) ព្រោះអត្ថថា មានចិត្តប្រកាន់យ៉ាងនេះថា យើងកុំគប្បីមានស្រីរួមស្វាមី (ជាមួយស្ត្រីដទៃ) សូមនៅ (ជាធំ) តែម្នាក់ឯងប៉ុណ្ណោះក្នុងផ្ទះ ។ បទថា **ឥស្សរិយបរិយោសានា** (មានភាពជាធំជាទីបំផុត) ព្រោះអត្ថថា កាលបានភាពជាធំក្នុងការគ្រប់គ្រងផ្ទះ ក៏រាប់ថា ដល់ទីបំផុតហើយ ។ បទថា **អាទានាធិប្បាយា** (បំណងលួចទ្រព្យអ្នកដទៃ) ព្រោះអត្ថថា មានបំណងក្នុងការលួចយករបស់របរបុគ្គលដទៃ ។ បទថា **គហណូបវិចារា** (និយមទីស្ងាត់)

ព្រោះអត្ថថា មានការពេញចិត្តក្នុងព្រៃខ្មោច គឺ ក្នុងទីសម្រាប់គេចខ្លួន ។ ឈ្មោះថា *អន្ធកាភកិនិវេសា* (ត្រូវការទីងងឹត) ព្រោះអត្ថថា មានចិត្តប្រកាន់ដើម្បីត្រូវការសេចក្តីងងឹត ។ បទថា *អទស្សនបរិយោសានា* (មានការត្រូវការជល់អ្នកដទៃមិនឃើញគេជាទីបំផុត) ព្រោះអត្ថថា ដល់ភាវៈដែលមិនមាននរណាឃើញ ក៏រាប់ថា ដល់ទីបំផុតហើយ ។ បទថា *ខន្តិសោរច្ចាធិប្បាយា* (បំណងខន្តិសោរច្ចៈ) ព្រោះអត្ថថា មានបំណងក្នុងអធិវាសនខន្តិ និងក្នុងសីល ដែលមានសេចក្តីស្អាតជាសភាវៈ ។ បទថា *អកិញ្ចនាភិនិវេសា* (ត្រូវការការមិនកង្វល់) ព្រោះអត្ថថា មានចិត្តប្រកាន់ក្នុងភាពមិនមានអ្វីៗ គឺ ក្នុងភាវៈដែលមិនមានការប្រកាន់ ។ បទថា *និព្វានបរិយោសានា* (មានព្រះនិព្វានជាទីបំផុត) ព្រោះអត្ថថា សម្រេចនិព្វាន គឺ រាប់ថា ដល់ទីបំផុតហើយ ។

ចប់អដ្ឋកថា ខត្តិយសូត្រទី ១០

# អដ្ឋកថា អប្បមាទសូត្រទី ១១

*(ការមិនប្រមាទ រមែងឲ្យសម្រេចប្រយោជន៍ទាំងពីរ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អប្បមាទសូត្រទី ១១ ដូចតទៅនេះ ៖*

*[៤៣] បទថា **សមធិគ្គយ្ហ** (កាន់យក) បានដល់ កាន់យកទុកដោយល្អ ។ បទថា **ជង្គលានំ បាណានំ** (នៃសត្វទាំងឡាយដែលសញ្ចរលើផែនដី) បានដល់ សត្វមានជើង ដែលមានប្រក្រតីត្រាច់លើផែនដី ។ បទថា **បទជាតានិ** (ស្នាមជើង) បានដល់ ស្នាមជើង (បទានិ) ។ បទថា **សមោធានំ គច្ឆន្តិ** (រមែងរួមចុះ) បានដល់ ដល់នូវការប្រជុំចុះ គឺ ដាក់ចុះ ។ បទថា **អគ្គមក្ខាយតិ** (ពោលថាប្រសើរជាង) បានដល់ ដែលមនុស្សលោកពោលថា ប្រសើរបំផុត ។ បទថា **បព្វជលាយកោ** (អ្នកប្រូតស្មៅ) បានដល់ អ្នកប្រូតស្មៅជំណោកទន្សាយ ។ បទថា **ឱធុនាតិ** (ចាប់ត្រង់ចុង) បានដល់ ដាក់មុខឲ្យចុះ ។ បទថា **និធុនាតិ** (រលាស់) បានដល់ រលាស់ទៅទាំងពីរខាង ។ បទថា **និច្ឆាទេតិ** (បោក) បានដល់ បោកនឹងដៃ ឬដើមឈើ ។ បទថា **អម្ពបិណ្ឌិយា** (ចង្កោមស្វាយ) បាន*

*ដល់ ចង្អោមផ្ទៃស្វាយ ។ បទថា* ***វណ្ណាបនិព្ពនានិ***[១] *(ដែលជាប់នឹងទង) បានដល់ ជាប់នៅត្រង់ទង ឬព្យួរត្រង់ទង ។ បទថា* ***តទនុយានិ ភវន្តិ*** *(រមែងប្រព្រឹត្តទៅតាមនូវទងនោះ) បានដល់ រមែងទៅតាមទង អធិប្បាយថា រមែងទៅតាមចង្អោមផ្ទៃស្វាយ ។ បទថា* ***កុឌ្ឌករាជានោ***[២] *(ព្រះរាជគ្រប់គ្រងប្រទេសតូចៗ) បានដល់ ព្រះរាជាតូច (ស័ក្តិតូច) ឬព្រះរាជាធម្មតា ។*

ចប់អដ្ឋកថា អប្បមាទសូត្រទី ១១

(១) បិដក = វណ្ណាបនិពន្ធានិ , (២) បិដក = ខុទ្ទករាជានោ ។

# អដ្ឋកថា ធម្មិកសូត្រទី ១២

## (ព្រះធម្មិកៈថេរសព្រហ្មចារី)

គប្បីជ្រាបវិនិច្ឆ័យក្នុង ធម្មិកសូត្រទី ១២ ដូចតទៅនេះ ៖

[៥៤] បទថា *សព្វសោ* (ទាំងអស់) កែជា *សព្វេសុ* គឺ ទាំងពួង ។ បទថា *សត្តសុ អាវាសេសុ* (ក្នុងអាវាសទាំង ៧) បានដល់ ក្នុងបរិវេណ ៧ កន្លែង ។ បទថា *បរិភាសតិ* (ជេរប្រទេច) បានដល់ សំឡុតគំរាម គឺ បង្កឲ្យកើតសេចក្ដីភ័យខ្លាច ។ បទថា *វិហឹសតិ* (បៀតបៀន) បានដល់ ធ្វើឲ្យលំបាក ។ បទថា *វិតុទតិ* បានដល់ ចាក់ដោត ។ បទថា *រោសេតិ វាចាយ* (គោសរុសនូវពួកភិក្ខុជាអាគន្តុកៈដោយវាចា) បានដល់ ខ្ទាំងខ្ទប់ដោយវាចា ។ បទថា *បក្កមន្តិ* (ចៀសចេញទៅ) បានដល់ ចៀសចេញទៅកាន់ទិសទាំងឡាយ ។ បទថា *ន សណ្ឋហន្តិ*[១] (មិននៅ) បានដល់ មិនឋិតនៅ ។ បទថា *រិញ្ចន្តិ* (លះបង់... ទៅ) បានដល់ បោល គឺ លះបង់ ។ បទថា *បព្វាជេយ្យាម* (ត្រូវបណ្ដេញ) បានដល់ គប្បីបណ្ដេញ

(១) បិដក = ន សណ្ឋន្តិ ។

ឲ្យចេញទៅ ។ បទថា **ហន្ទ (អើ)** ជានិបាត ប្រើក្នុងអត្ថផ្តើមសន្ទនា ។ បទថា **អលំ (សមគួរហើយ)** សេចក្តីថា កាលឧបាសកទាំងឡាយ គប្បីបណ្តេញលោកចេញ (ព្រះធម្មិកៈ) នោះ ចេញទៅជាការសមគួរហើយ ។ បទថា **កិន្តេ ឥមិនា (មានប្រយោជន៍អ្វីដល់លោក ដោយការនៅក្នុងជាតិភូមិជនបទនេះ)** បានដល់ ប្រយោជន៍អ្វីរបស់លោកហ្ន៎ ដោយការអាស្រ័យនៅក្នុងជាតិភូមិជនបទនេះ ។

បទថា **តីរទស្សឹ សកុណំ (បក្សីស្វែងរកត្រើយ)** បានដល់ ការប្រាប់ទិស ។ បទថា **មុញ្ចន្តិ (លែង)** បានដល់ លែងទៅដើម្បីប្រាប់ទិស ។ បទថា **សាមន្តា (នៅជិត)** បានដល់ ក្នុងទីមិនឆ្ងាយ ។ បាឋៈថា **សមន្តា** ដូច្នេះក៏មាន សេចក្តីថា ដោយជុំវិញ ។

បទថា **អភិនិវេសោ (គ្របដណ្តប់)** បានដល់ បរិវេណមែកឈើផ្សាយចេញទៅគ្របដណ្តប់ ។ បទថា **មូលសន្តានកានំ (មានបណ្តាញឬស)** បានដល់ បរិវេណរបស់ឬសឈើ ។ បទថា **អាឡ្ហកថាលិកា (ភាជនៈដាំបាយបានមួយអាឡ្ហកៈ)** បានដល់ ឆ្នាំងដាំបាយ (ដាក់) អង្ករបាន ១

អាឡ្ហកៈ ។ បទថា **ខុទ្ទមធុំ (ឃ្មុំផ្អិត)** បានដល់ ទឹកឃ្មុំត្រង់ដើមឈើដែលពួកឃ្មុំខ្លួនតូចៗ ធ្វើទុក ។ បទថា **អនេឡកំ (មិនមានទោស)** បានដល់ប្រាសចាកទោស ។ បទថា **ន ច សុទំ អញ្ញមញ្ញស្ស ផលានិ ហឹសន្តិ (មិនមាននរណាៗ ធ្វើអន្តរាយនូវផ្លែរបស់គ្នានឹងគ្នាឡើយ)** សេចក្តីថា នរណាៗ រមែងមិនបៀតបៀនផ្លែទាំងឡាយក្នុងចំណែករបស់គ្នានឹងគ្នា ដែលឈ្មោះថានរណាៗ ដែលនឹងកាត់ឬស សំបក ឬស្លឹក ពីចំណែករបស់ខ្លួនមិនមាន ។ ព្រះរាជាជាដើម រមែងបរិភោគចំពោះតែផ្លែជ្រុះទៅខាងក្រោមមែករបស់ខ្លួនប៉ុណ្ណោះ ។ សូម្បីផ្លែអំពីចំណែករបស់មែកមួយ រមៀលទៅកាន់ចំណែករបស់មែកមួយទៀត ព្រះរាជាជាដើមទ្រង់ជ្រាបថា មិនមែនជាផ្លែរបស់មែកពួកយើង ក៏មិនបរិភោគ ។

បទថា **យាវទត្ថំ ផលានិ ភក្ខិត្វា (បរិភោគ... ដរាបដល់ឆ្អែត)** បានដល់ បរិភោគប្រមាណដល់ក (ទាល់តែពេញពោះ) ។ បទថា **សាខំ ភញ្ជិត្វា (កាច់មែក)** បានដល់ កាច់ស្លឹកឈើប្រមាណប៉ុនម្ជុល ប៉ាំងជាម្ជុល ហើយចៀសចេញទៅ ។ បទថា **យត្រ ហិ នាម** បានដល់ **យោ ហិ នាម**

(បុរសនេះ) ។ បទថា **បក្កមិស្សតិ** (ចៀសចេញទៅ) បានដល់ ចៀសចេញទៅហើយ ។ បទថា **នាទាសិ** (មិនបាន) បានដល់ មិនចេញផ្លែទៀតដោយអានុភាពរបស់ទេវតា ។ ព្រោះថា ទេវតានោះបានអធិដ្ឋានយ៉ាងនេះ ។ បទថា **តេនុបសង្កមិ** (ស្តេចចូលទៅគាល់... ដល់ទីប្រថាប់) សេចក្តីថា កាលពួកអ្នកជនបទទៅក្រាបទូលថា បពិត្រព្រះមហារាជ ដើមឈើមិនចេញផ្លែឡើយ ជាកំហុសរបស់ពួកខ្ញុំឬរបស់ព្រះអង្គ ព្រះបាទកោរព្យៈត្រិះរិះថា មិនមែនកំហុសរបស់យើង មិនមែនកំហុសរបស់ពួកអ្នកជនបទ អធម៌មែងមិនប្រព្រឹត្តទៅក្នុងដែនរបស់យើង ដើមឈើមិនចេញផ្លែព្រោះហេតុអ្វីហ្ន៎ យើងនឹងចូលទៅទូលសួរសក្កទេវរាជ ដូច្នេះ ហើយចូលទៅគាល់សក្កទេវរាជចមទេពដល់ទីប្រថាប់ ។ បទថា **បវត្តេសិ** បានដល់ បក់បោក ។ បទថា **ឧម្មូលមកាសិ** (ធ្វើឲ្យមានឫសឡើងលើ) បានដល់ ធ្វើឲ្យមានឫសឡើងខាងលើ ។ បទថា **អបិ នុ ត្វំ** (លោក... បានអ្វី) ស្មើនឹង អបិ នុ ត្វ ។ បទថា **អដ្ឋិតាយេវ** (មិនបានឋិតនៅ... ជាប្រាកដ) កែជា **អដ្ឋិតាយេវ** ។ បទថា **សច្ឆវិនី** (មានសភាពដូចដើម) បានដល់ ត្រឡប់មាន

ពណ៌ដូចដើម គឺ តាំងនៅក្នុងកន្លែងតាមប្រក្រតី ។ បទថា **ន បច្ចក្កោសតិ** (មិនជេរតប) បានដល់ រមែងមិនជេរតប ។ បទថា **អក្កោសន្តំ** (កោសរូស) បានដល់ អ្នកខ្ញាំងខ្ញប់ហើយ ។ បទថា **ភណ្ឌន្តំ** (ប្រហារ) បានដល់ ជាបុគ្គលកាច ។

ក្នុងបទថា **សុនេត្តោ** (ឈ្មោះសុនេត្តៈ) កែវភ្នែក ហៅថា នេត្តៈ ព្រោះភ្នែកទាំងគូនោះស្អាត ទើបឈ្មោះថា **សុនេត្តៈ** ។ បទថា **តិត្ថករោ** (ម្ចាស់លទ្ធិ) បានដល់ អ្នកសាងកំពង់ (លទ្ធិ) ជាទីចូលទៅកាន់សុគតិ ។ បទថា **វីតរាគោ** (អ្នកប្រាសចាកតម្រេក) បានដល់ អ្នកប្រាសចាកតម្រេកដោយអំណាចការគ្របសង្កត់ទុក ។ បទថា **បសវតិ** (រមែងប្រសព្វ) បានដល់ រមែងបាន ។ បទថា **ទិដ្ឋិសម្បន្នំ** (អ្នកមានទិដ្ឋិបរិបូណ៌) បានដល់បុគ្គលអ្នកបរិបូណ៌ដោយទស្សនៈ អធិប្បាយថា ព្រះសោតាបន្ន ។ បទថា **ខន្តិំ** (ការជីករំលើងគុណ គឺ សេចក្ដីល្អរបស់ខ្លួន) បានដល់ ការជីករំលើងគុណរបស់ខ្លួន ។ បទថា **យថាមំ សព្រហ្មចារីសុ** (ដូចការជេរសព្រហ្មចារីបុគ្គលទាំងឡាយ) បានដល់ យើងមិនពោលការជីករំលើងគុណបែបនេះ

យ៉ាងដទៃ ថាដូចការជេរបរិភាសក្នុងអ្នកប្រព្រឹត្តព្រហ្មចរិយៈរួមគ្នានេះ ។ មនុស្សរបស់ខ្លួនហៅថា **អាមជន** ក្នុងបទថា **ន នោ អាមសព្រហ្មចារីសុ** (របស់យើងទាំងមិន... ក្នុងលោកដែលប្រព្រឹត្តព្រហ្មចរិយៈរួមគ្នាជាមួយខ្លួន) នេះ ព្រោះដូច្នោះ ក្នុងទីនេះទើបមានន័យដូច្នេះថា យើងទាំងឡាយមិនមានចិត្តប្រទុស្តរ៉ាយក្នុងសព្រហ្មចារីជាអ្នកស្មើនឹងខ្លួន ។ បទថា **ជោតិបាលោ ច គោវិន្ទោ** (ឈ្មោះជោតិបាលគោវិន្ទៈ) បានដល់ ពោលដោយឈ្មោះ មានឈ្មោះថា ជោតិបាលៈ ពោលដោយតំណែង មានឈ្មោះថា មហា-គោវិន្ទៈ ។ បទថា **សត្តបុរោហិតោ** (ជាបុរោហិតរបស់ព្រះរាជា ៧ ព្រះអង្គ) បានដល់ អ្នកជាបុរោហិតរបស់ព្រះរាជា ៧ ព្រះអង្គ មានព្រះបាទរេណុជាដើម ។ បទថា **អភិសេកា អតីតំសេ** (ជាអ្នកបានទទួលការសរសើរថា ជាមេលទ្ធិក្នុងអតីត) បានដល់ សាស្តាទាំង ៦ នេះ បានទទួលការបានទទួលការរាប់អានមកហើយក្នុងអតីត ។ បទថា **និរាមគន្ធា** (ជាអ្នកអស់ក្លិនស្អុះស្អាប) បានដល់ មិនមានក្លិនស្អាបដោយ ក្លិនស្អាប គឺ សេចក្តីក្រោធ ។ បទថា **ករុណេ វិមុត្តា** (បំណងក្នុងករុណា) បានដល់ បំណង

ហើយក្នុងករុណាឈាន គឺ តាំងនៅក្នុងករុណា (អប្បនា) និងក្នុងធម៌ដែលជាចំណែកខាងដើមនៃករុណា (ឧបចារៈ) ។ បទថា **យេ តេ** (ទាំងនោះ) កែជា **ឯតេ** ។ ម្យ៉ាងទៀត បាឋៈជា **ឯតេ** នេះ ក៏មាន ។ បទថា **ន សាធុរូបំ អាសិទេ** (នរជនមិនគប្បីកោសរូសបុគ្គលល្អ) បានដល់ មិនគប្បីខ្ទាំងខ្ទប់ដល់មនុស្សល្អ ។ បទថា **ទិដ្ឋិដ្ឋានប្បហាយិនំ** (អ្នកលះបង់ទិដ្ឋិ) បានដល់ អ្នកលះទិដ្ឋិ ៦២ ប្រការ ។ បទថា **សត្តមោ** (ទី ៧) បានដល់ជាបុគ្គលទី ៧ រាប់ពីព្រះអរហន្តចុះមក ។ បទថា **អវីតរាគោ** (មិនទាន់ប្រាសចាកតម្រេក) បានដល់ អ្នកមានសេចក្ដីតម្រេកអស់ទៅមិនមាន ។ ដោយពាក្យនេះ ទ្រង់បដិសេធភាពជាព្រះអនាគាមី ។ បទថា **បញ្ចិន្ទ្រិយោ មុទូ** (ជាអ្នកមានឥន្ទ្រិយទាំង ៥... ទន់ខ្វី) បានដល់ ឥន្ទ្រិយក្នុងវិបស្សនា-ញាណ ៥ ប្រការ នៅទន់ខ្វី ។ ពិតណាស់ ឥន្ទ្រិយទាំងនោះរបស់ព្រះសោតាបន្ននោះ ប្រៀបជាមួយព្រះសកទាគាមីហើយ រាប់ថាទន់ខ្វី ។ បទថា **វិបស្សនា** បានដល់ ញាណជាគ្រឿងកំណត់សង្ខារ ។ បទថា **បុព្វេវ ឧបហញ្ញតិ** (ប្រទូស្ត... មុន) បានដល់ បៀតបៀនខ្លួនមុន ។ បទថា **អក្ខតោ**

*(មិនដឹករំលើងគុណរបស់ខ្លួន) បានដល់ មិនដឹករំលើង គឺ មិនចូលទៅទម្លាយ ដោយការដឹករំលើងគុណ ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ហើយ ។*

ចប់អដ្ឋកថា ធម្មិកសូត្រទី ១២

## ចប់ធម្មិកវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១២ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១២ សូត្រ

# ចប់បឋមបណ្ណាសកៈ

# ទុតិយបណ្ណាសកៈ

## មហាវគ្គវណ្ណនាទី ១

## អដ្ឋកថា សោណសូត្រទី ១

*(ត្រាស់ពិណខ្សែ ៣ ដល់ព្រះសោណៈ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សោណសូត្រទី ១ ដូចតទៅនេះ ៖*

[៥៥] *បទថា **សោណោ** (ព្រះសោណៈ) បានដល់ ព្រះសោណត្ថេរៈជាសុខុមាលជាតិ ។ បទថា **សីតវនេ** (ព្រៃឈ្មោះសីតវន) បានដល់ ក្នុងព្រៃខ្មោចដែលមានឈ្មោះយ៉ាងនេះ ។ ដំណាលមកថា ក្នុងព្រៃខ្មោចនោះ គេសាងទីចង្រ្កមទុក ៥០០ កន្លែង រៀបរយតាមលំដាប់ ។ ក្នុងទីចង្រ្កម ៥០០ កន្លែងនោះ ព្រះថេរៈជ្រើសរើសយកទីចង្រ្កម (មួយកន្លែង) ដែលជាទីសប្បាយសម្រាប់ខ្លួន ហើយបំពេញសមណធម៌ ។ កាលព្រះថេរៈនោះប្រារព្ធសេចក្តីព្យាយាមដើរចង្រ្កម បាតជើងក៏បែក ។ កាលលោកលុតជង្គង់ចង្រ្កម ទាំងជង្គង់ទាំងបាតដៃក៏បែកជាដំបៅ ។ ព្រះថេរៈប្រារព្ធសេចក្តី*

ព្យាយាមដូច្នោះ ក៏មិនអាចឃើញសូម្បីត្រឹមតែឱកាស ឬនិមិត្ត ។ ដើម្បីសំដែងដល់វិតក្កៈដែលកើតឡើងដល់ព្រះសោណៈនោះ ជាអ្នកលំបាកកាយដោយសេចក្ដីព្យាយាមហើយ អង្គុយ (សម្រាក) នៅលើថ្ម (ដែលតាំងនៅ) ក្នុងទីបំផុតក្នុងទីចង្ក្រម ព្រះសង្គីតិកាចារ្យ ទើបពោលពាក្យថា **អថខោ អាយស្មតោ (លំដាប់នោះ ព្រះសោណៈដ៏មានអាយុ)** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អារទ្ធវិរិយា (ជាអ្នកប្រារព្ធព្យាយាម)** បានដល់ ផ្គងសេចក្ដីព្យាយាមដ៏ខ្លាំងក្លា ។ បទថា **ន អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ (ចិត្តរបស់យើងរួចចាកអាសវៈ ព្រោះមិនប្រកាន់មាំមិនបាន)** សេចក្ដីថា ព្រះសោណៈបង្អោនចិត្តជឿថា ប្រសិនបើយើងជាឧគ្ឃដិតញ្ញូ វិបច្ចិតញ្ញូ ឬនេយ្យបុគ្គលសោត ចិត្តរបស់យើងនឹងគប្បីរួចផុតបានយ៉ាងពិតប្រាកដ តែយើងជាបទបរមបុគ្គលតែម្យ៉ាង ទើបចិត្តរបស់យើងមិនរួចផុត ដូច្នេះ ហើយគិតដល់ហេតុមានជាអាទិ៍ថា **ក៏ (ភោគទ្រព្យ) រមែងមាន** ។ បណ្ដាបទទាំងនោះ បទថា **ភោគា (ភោគទ្រព្យ)** ជាបឋមាវិភត្តិប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។

បទថា **បាតុរហោសិ** (ប្រាកដ) សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ជ្រាបវារៈចិត្តរបស់ព្រះថេរៈ ទ្រង់ត្រិះរិះថា ថ្ងៃនេះ សោណៈនេះអង្គុយនៅលើផែនថ្មដែលបំពេញសេចក្តីព្យាយាមក្នុងព្រៃសីតវន ទឹកគិតដល់វិតក្កៈរឿងនេះ តថាគតទឹងទៅ ហើយបញ្ឈប់វិតក្កៈដែលបៀតបៀនគេ ហើយប្រាប់កម្មដ្ឋានដែលឧបមាដោយពិណ ដូច្នេះ ហើយទ្រង់ប្រាកដចំពោះមុខ ។

បទថា **បញ្ញត្តេ អាសនេ** (លើអាសនៈដែលបានក្រាលថ្វាយ) សេចក្តីថា ភិក្ខុអ្នកបំពេញព្យាយាម ក្រាលអាសនៈតាមដែលរកបានទុក ដើម្បីជាទីប្រថាប់នៅរបស់ព្រះមានព្រះភាគស្តេចមកដើម្បីត្រាស់ទូន្មាន ដល់ទីកន្លែងនៅរបស់ខ្លួនមុន ហើយទើបបំពេញព្យាយាម កាលរកអាសនៈដទៃមិនបាន ក៏ក្រាលសូម្បីស្លឹកឈើចាស់ៗ ហើយក្រាលសង្ឃដីខាងលើ ។ សូម្បីព្រះថេរៈក្រាលអាសនៈមុនហើយ ទើបបានបំពេញសេចក្តីព្យាយាម ។ ព្រះសង្គីតិកាចារ្យសំដៅយកអាសនៈនោះ ទើបពោលថា **លើអាសនៈដែលបានក្រាលហើយ** ។

បទថា **តំ កឹ មញ្ញសិ** (អ្នកសម្គាល់សេចក្តីនោះ ដូចម្តេច) សេចក្តី

ថា ព្រះសាស្តាទ្រង់ត្រិះរិះថា ភិក្ខុនេះមិនមានសេចក្តីត្រូវការដោយកម្មដ្ឋាន ដ៏សេស ភិក្ខុនេះឈ្លាស ធ្លាប់ជំនាញមកហើយក្នុងសិល្បៈរបស់អ្នកប្រគុំតន្ត្រី គេនឹងកំណត់ឧបមា ក្នុងពេលតថាគតត្រាស់ទុកក្នុងវិស័យរបស់ខ្លួនបានលឿនរហ័ស ដូច្នេះ ដើម្បីនឹងត្រាស់ឧបមាដោយពិណ ព្រះអង្គទើបត្រាស់ពាក្យថា *អ្នកសម្គាល់សេចក្តីនោះដូចម្តេច* ជាដើម ។ ភាពជាអ្នកឈ្លាសក្នុងការដេញពិណ ឈ្មោះថា *វីណាយ តន្តិស្សរេ កុសលតា (ជាអ្នកឈ្លាសក្នុងសំឡេងពិណ)* ក៏ព្រះសោណៈនោះ ជាអ្នកឈ្លាសក្នុងការដេញពិណនោះ ។ ពិតណាស់ មាតាបិតារបស់ព្រះសោណៈនោះ គិតថា កូនប្រុសរបស់យើង កាលនឹងសិក្សាសិល្បៈយ៉ាងដទៃ ក៏នឹងលំបាកកាយ តែថា សិល្បៈដេញពិណនេះ កូនរបស់យើងអង្គុយលើទីដេក ក៏អាចរៀនបាន ទើបឲ្យរៀនចំពោះតែសិល្បៈរបស់អ្នកតន្ត្រីប៉ុណ្ណោះ ។ សិល្បៈរបស់អ្នកតន្ត្រី (គន្ធព្វ) មានជាអាទិ៍គឺ :

*សំឡេងទាំងនេះ គឺ មាន ៧ សំឡេង ពួកសំឡេងផ្សំ*

*៣ ពួក លំដាប់សំឡេង ២១ លំដាប់ ឋានសំឡេង ៤៩*

ឋាន ចាត់ជាក្រុមសំឡេង ។

សំឡេងទាំងអស់នោះឯង ព្រះសោណៈជំនាញមកហើយនោះឯង ។

បទថា **អច្ចាយតា (តឹងពេក)** បានដល់ (ពិណ) ដែលតឹងពេក គឺមានលំដាប់នៃសំឡេងរឹង (មិនពីរោះ) ។ បទថា **សរវតី (មានសំឡេងពីរោះ)** បានដល់ ដល់ព្រមដោយសំឡេង ។ បទថា **កម្មញ្ញា (គួរដល់ការប្រើ)** បានដល់ សមគួរដល់ការងារ គឺ ប្រើការបាន ។ បទថា **អតិសិថិលា (ធូរពេក)** បានដល់ កម្រិតសំឡេងខ្សោយ (ធូរ) ។ បទថា **សមេ គុណេ បតិដ្ឋិតា (តាំងនៅក្នុងកណ្តាល)** បានដល់ នៅក្នុងកម្រិតសំឡេងជាកណ្តាល ។ បទថា **អច្ចារទ្ធំ (ដែលប្រារព្ធតឹងពេក)** បានដល់ សេចក្តីព្យាយាមដែលតឹងពេក ។ បទថា **ឧទ្ធច្ចាយ សំវត្តតិ (រមែងប្រព្រឹត្តទៅដើម្បីសេចក្តីរាយមាយ)** បានដល់ រមែងប្រព្រឹត្តទៅដើម្បីភាពជាអ្នករាយមាយ ។ បទថា **អតិលីនំ (ដែលធូរពេក)** បានដល់ ដែលធូរហួសពេក ។ បទថា **កោសជ្ជាយ (ដើម្បីសេចក្តីខ្ជិលច្រអូស)** បានដល់ ដើម្បីភាពជាអ្នកខ្ជិលច្រអូស ។ បទថា **វីរិយសមតំ អធិដ្ឋាហិ (ចូរតាំងសេចក្តីព្យាយាម

ឲ្យល្មម) បានដល់ លោកចូរតាំងសមថៈដែលសម្បយុត្តដោយវិរិយៈទុកឲ្យ មុតមាំ សេចក្តីថា ចូរប្រកបវិរិយៈជាមួយសមថៈ ។ បទថា **ឥន្ទ្រិយានញ្ច សមតំ បដិវិជ្ឈ (ចូរតាំងឥន្ទ្រិយទាំងឡាយឲ្យស្មើគ្នា)** សេចក្តីថា អ្នកចូរ តាំងភាពស្មើគ្នា គឺ ភាវៈដែលស្មើគ្នានៃឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើម ទុកឲ្យមាំ ។

ក្នុងបទនោះ ភិក្ខុដែលប្រកបសទ្ធាជាមួយបញ្ញា ប្រកបបញ្ញាជាមួយ សទ្ធា ប្រកបវិរិយៈជាមួយសមាធិ និងប្រកបសមាធិជាមួយវិរិយៈ ឈ្មោះ ថា ជាអ្នកតម្កល់ភាវៈដែលស្មើគ្នានៃឥន្ទ្រិយទាំងឡាយទុក ។ ចំណែកសតិ រមែងត្រូវការក្នុងទីទាំងពួង សតិដែលកម្លាំងនោះឯង រមែងគួរស្មប្បីគ្រប់ កាល ។ ក៏វិធីប្រកបឥន្ទ្រិយទាំងនោះចូលគ្នា សម្តែងទុកជាក់ច្បាស់ហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **តត្ថ ច និមិត្តំ គណ្ហាហិ (និងចូរកាន់យកនិមិត្តក្នុងភាព ស្មើគ្នា)** សេចក្តីថា ក៏កាលមានភាវៈដែលស្មើគ្នា (នៃឥន្ទ្រិយទាំងឡាយ) នោះ និមិត្តណាគប្បីកើតឡើងដូចស្រមោលមុខក្នុងកញ្ចក់ អ្នកចូរកំណត់កាន់

យកនិមិត្តនោះ និងជាសមថនិមិត្តក្តី វិបស្សនានិមិត្តក្តី មគ្គនិមិត្តក្តី ផលនិមិត្តក្តី គឺ ចូរធ្វើឲ្យនិមិត្តនោះកើតឡើង ។ ព្រះសាស្តាត្រាស់កម្មដ្ឋានរួមរហូតអរហត្តដល់ព្រះសោណៈនោះ ដោយប្រការដូច្នេះ ។ បទថា **តត្ថ ច និមិត្តំ អគ្គហេសិ** (និងបានកាន់យកនិមិត្តក្នុងភាពស្មើគ្នានោះ) សេចក្តីថា ព្រះសោណៈបានកំណត់កាន់យកទាំងសមថនិមិត្ត និងវិបស្សនានិមិត្ត ។

បទថា **ឆដ្ឋានានិ** (ឋានៈ ៦ យ៉ាង) បានដល់ ហេតុ ៦ យ៉ាង ។ បទថា **អធិមុត្តោ ហោតិ** (រមែងជាអ្នកបង្អោនទៅ) បានដល់ ជាអ្នកចាក់ធ្លុះ ធ្វើឲ្យប្រច័ក្សហើយតាំងនៅ ។ បទទាំងអស់មានជាអាទិ៍ថា **នេក្ខម្មាធិមុត្តោ** (បង្អោនទៅកាន់នេក្ខម្មៈ) ព្រះសោណៈពោលទុកដោយអំណាចអរហត្តផលនោះឯង ។ ពិតណាស់ អរហត្តផលឈ្មោះថា **នេក្ខម្មៈ** ព្រោះចេញចាកកិលេសទាំងពួង ឈ្មោះថា **បវិវេកោ** (សេចក្តីស្ងាត់) ព្រោះស្ងាត់ចាកកិលេសទាំងអស់នោះឯង ឈ្មោះថា **អព្យាបជ្ឈំ** (ការមិនមានបៀតបៀន) ព្រោះមិនមានសេចក្តីបៀតបៀន ឈ្មោះថា **តណ្ហក្ខយោ** (ការអស់តណ្ហា) ព្រោះកើតឡើងក្នុងទីបំផុតនៃការអស់តណ្ហា ឈ្មោះថា **ឧបាទាន-**

ក្ខយោ (ការអស់ឧបាទាន) ព្រោះកើតឡើងក្នុងទីបំផុតនៃឧបាទាន ឈ្មោះថា **អសម្មោហោ** (ការមិនវង្វេង) ព្រោះមិនមានសេចក្តីវង្វេង ។ បទថា **កេវលំ សទ្ធាមត្តកំ** (គុណត្រឹមសទ្ធាតែម្យ៉ាង) បានដល់ គុណត្រឹមតែសទ្ធាសុទ្ធៗ ដែលវៀរចាកបដិវេធ គឺ មិនលាយដោយបញ្ញាជាគ្រឿងចាក់ធ្លុះ ។ បទថា **បតិចយំ** (ការបន្ថែមនូវកិច្ចដែលធ្វើហើយ) បានដល់ ការចម្រើនដោយការបំពេញរឿយៗ ។ បទថា **វិតរាគត្តា** (ព្រោះជាអ្នកប្រាសចាករាគៈ) បានដល់ ព្រោះរាគៈប្រាសទៅហើយដោយការចាក់ធ្លុះមគ្គនោះឯង ។ ភិក្ខុជាអ្នកចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ដល់អរហត្តផល ពោលគឺ នេក្ខម្មៈហើយតាំងនៅ ។ អធិប្បាយថា នៅដោយធម៌ជាគ្រឿងនៅ គឺ ផលសមាបត្តិ និងជាអ្នកមានចិត្តបង្អោនទៅក្នុងផលសមាបត្តិនោះឯង ។ សូម្បីក្នុងបទដ៏សេសក៏មានន័យដូចគ្នានេះឯង ។

បទថា **លាភសក្ការសិលោកំ** (លាភសក្ការៈ និងការសរសើរ) បានដល់ លាភ គឺ បច្ច័យ ៤ បច្ច័យទាំងនោះឯង ដែលបុគ្គលធ្វើសក្ការៈល្អហើយ និងការពោលសរសើរ ។ បទថា **និកាមយមានោ** (សេចក្តីសង្ឃឹម)

បានដល់ ត្រូវការ គឺ ប្រាថ្នា ។ បទថា **បវេកាធិមុត្តោ (ជាអ្នកបង្អោនទៅក្នុងសេចក្ដីស្ងប់ស្ងាត់)** សេចក្ដីថា ព្យាករណ៍អរហត្តផលយ៉ាងនេះថា យើងបង្អោនទៅក្នុងសេចក្ដីស្ងប់ស្ងាត់ ។ បទថា **សីលព្វតបរាមាសំ (ការស្ទាបអង្អែលសីល និងវត្ត)** បានដល់ ត្រឹមតែកាន់តាមសីល និងវត្ត ដែលខ្លួនបានជឿមកហើយ ។ បទថា **សារតោ បច្ចាគច្ឆន្តោ (ប្រកាន់ថា... ជាខ្លឹម)** បានដល់ យល់ថាជាសារៈ ។ បទថា **អព្យាបជ្ឈាធិមុត្តោ (ជាអ្នកបង្អោនទៅកាន់ការមិនបៀតបៀន)** បានដល់ ព្យាករណ៍ការមិនបៀតបៀនគ្នាថា ជាអរហត្តផល ។ គប្បីឃើញអត្ថក្នុងទីគ្រប់កន្លែងតាមន័យនេះ ។

ម្យ៉ាងទៀត ក្នុងផ្នែកនេះ អាចារ្យពួកខ្លះពោលថា ព្រះសោណៈពោលអរហត្តទុកដោយចំពោះ ក្នុងបទនេះថា **ជាអ្នកបង្អោនទៅកាន់នេក្ខម្មៈ** ពោលនិព្វានទុកក្នុង ៥ បទដ៏សេស ។ អាចារ្យដទៃទៀតពោលថា ព្រះសោណៈពោលទាំងអរហត្ត ទាំងនិព្វានទុកក្នុងបទទាំងនោះ គ្រប់ៗ បទទាំងអស់នោះឯង ។ បទថា **ភុសា (ល្អផ្ទើម)** បានដល់ មានកម្លាំង គឺ ដូចរូបដែលជាទិព្វ ។

*បទថា* ***នេវស្ស ចិត្តំ បរិយាទិយន្តិ*** *(រូបនោះមិនអាចគ្របសង្កត់ចិត្តរបស់លោកបាន) សេចក្តីថា រូបនោះ មិនអាចនឹងចាប់ចិត្តរបស់ព្រះខីណាស្រពនោះបានឡើយ ។ ពិតណាស់ កិលេសទាំងឡាយ ឈ្មោះថា រមែងចាប់ចិត្តដែលកំពុងកើតឡើង[១] ។ បទថា* ***អមិស្សកតំ*** *(ជាចិត្តមិនលាយដោយកិលេស) បានដល់ ក៏កិលេសទាំងឡាយ រមែងធ្វើចិត្តជាមួយអារម្មណ៍ឲ្យលាយគ្នា កាលមិនមានកិលេសទាំងនោះ ចិត្តទើបឈ្មោះថា មិនលាយដោយកិលេស ។ បទថា* ***ឋិតំ*** *(ជាចិត្តនឹងធឹង) បានដល់ តាំងមាំ ។ បទថា* ***អានេញ្ជប្បត្តំ*** *(ដល់នូវការមិនញាប់ញ័រ) បានដល់ ដល់នូវការមិនឃ្លេងឃ្លោង ។ បទថា* ***វយញ្ចស្សានុបស្សតិ*** *(លោកក៏ពិចារណាឃើញនូវការរលត់ទៅនៃចិត្តនោះ) បានដល់ ភិក្ខុនោះ រមែងឃើញទាំងការកើតឡើង ទាំងការរលត់ទៅរបស់ចិត្តនោះ ។ បទថា* ***ភូសា វាតវុដ្ឋិ*** *(ខ្យល់ភ្លៀងដ៏ខ្លាំងក្លា) បានដល់ គំនរខ្យល់ដ៏ពន្លឹក ។ បទថា* ***នេវ សង្កម្បេយ្យ*** *(មិន... ឲ្យឃ្លាត) បានដល់ មិនគប្បីនឹងឲ្យឃ្លាតបាន ។ បទថា*

---

(១) កិលេសទាំងឡាយដែលកំពុងកើតឡើង ឈ្មោះថា រមែងចាប់ចិត្តទុក ។

**ន សម្បកម្បេយ្យំ (មិន... ឲ្យកម្រើក)** បានដល់ មិនគប្បីធ្វើឲ្យកម្រើកបាន គ្រប់ចំណែក គឺ មិនអាចធ្វើឲ្យគុណកម្រើកបាន ។ បទថា **ន សម្បវេធេយ្យំ (មិន... ឲ្យញាប់ញ័របាន)** បានដល់ មិនអាចធ្វើឲ្យញាប់ញ័រ គឺ កក្រើកញាប់ញ័របាន ។

បទថា **នេក្ខម្មាធិមុត្តស្ស (ភិក្ខុមានចិត្តបង្អោនទៅកាន់នេក្ខម្មៈ)** បានដល់ អ្នកចាក់ធ្លុះអរហត្តផលហើយតាំងនៅ ។ សូម្បីក្នុងបទដ៏សេស ព្រះសោណៈពោលចំពោះព្រះអរហត្តដូចគ្នា ។ បទថា **ឧបាទានក្ខយស្ស ច (ជាអ្នកបង្អោនទៅកាន់ការអស់ឧបាទាន)** ជាឆដ្ឋីវិភត្តិ ប្រើក្នុងន័យនៃទុតិយាវិភត្តិ ។ បទថា **អសម្មោហញ្ច ចេតសោ (ជាអ្នកបង្អោនទៅកាន់ការមិនវង្វេងនៃចិត្ត)** បានដល់ បង្អោនទៅកាន់ការមិនវង្វេងនៃចិត្ត ។ បទថា **ទិស្វា អាយតនុប្បាទំ (ព្រោះឃើញការកើតឡើងនៃអាយតនៈទាំងឡាយ)** បានដល់ ឃើញការកើតឡើង នឹងការរលត់នៃអាយតនៈទាំងឡាយ ។ បទថា **សម្មា ចិត្តំ វិមុច្ចតិ (ចិត្ត... រមែងរួចផុតដោយល្អ)** សេចក្តីថា ចិត្តរមែងរួចផុត គឺ រមែងបង្អោនទៅក្នុងអារម្មណ៍ គឺ និព្វានដោយប្រពៃ គឺ

ដោយហេតុ ដោយន័យ បានដល់ ដោយអំណាចផលសមាបត្តិ ព្រោះការបដិបត្តិវិបស្សនានោះ ។ម្យ៉ាងទៀត ព្រះសោណៈពោលដល់បដិបទារបស់ព្រះខីណាស្រពដោយបទនេះ ។ ព្រោះថា ចិត្តរបស់ព្រះខីណាស្រពនោះរមែងរួចផុតដោយល្អចាកកិលេសទាំងអស់ ដោយអនុភាពអរិយមគ្គ ដែលលោកបានឃើញការកើតឡើងនៃអាយតនៈទាំងឡាយ ហើយសម្រេចដោយវិបស្សនានោះ ។ បទថា *តស្ស សម្មាវិមុត្តស្ស (បេ) ន វិជ្ជតិ (ការបន្ថែមកិច្ចដែលធ្វើហើយ និងកិច្ចដែលគួរធ្វើ រមែងមិនមានដល់ភិក្ខុដែលរួចផុតហើយដោយល្អ អ្នកមានចិត្តស្ងប់ហើយ)* ដោយប្រការដូច្នេះ ។ បណ្តាបទទាំងនោះ បទថា *សន្តចិត្តស្ស (អ្នកមានចិត្តស្ងប់ហើយ)* បានដល់ មានចិត្តរលត់ហើយ ។ បទដ៏សេសក្នុងសូត្រនេះ មានសេចក្តីងាយហើយ ។

ចប់អដ្ឋកថា សោណសូត្រទី ១

# អដ្ឋកថា ផគ្គុណសូត្រទី ២

## (ស្តេចទ្រង់ទតព្រះផគ្គុណអាពាធ)

គប្បីជ្រាបវិនិច្ឆ័យក្នុង ផគ្គុណសូត្រទី ២ ដូចតទៅនេះ ៖

[៥៦] បទថា *សមធោសិ* (នឹងក្រោក) បានដល់ សម្តែងអាការក្រោកឡើង ។ *បដិក្កមន្តិ* (រមែងបន្ទោបង់) បានដល់ រមែងធូរស្រាល ។ បទថា *នោ អភិក្កមន្តិ* (មិនកម្រើក) បានដល់ មិនចម្រើនឡើង ។ បទថា *សីសវេឋនំ ទទេយ្យ* (រុំក្បាល) បានដល់ ចងក្បាលហើយយកឈើមួល (ត្របែង) ។ បទថា *ឥន្ទ្រិយានិ វិប្បសីទឹសុ* (ឥន្ទ្រិយ... ផូរផង់ក្រៃលែង) បានដល់ ក្នុងសម័យជិតស្លាប់នោះ ឥន្ទ្រិយ ៦ ផូរផង់ក្រៃលែង ។ បទថា *អត្ថុបបរិក្ខាយ* (ក្នុងការពិចារណាអត្ថនៃធម៌) បានដល់ ដោយការពិចារណាដល់ប្រយោជន៍ និងមិនមែនប្រយោជន៍ គឺ ហេតុ និងមិនមានហេតុ ។ បទថា *អនុត្តរេ ឧបធិសង្ខយេ* (ក្នុងធម៌ដែលជាទីអស់ទៅនៃឧបធិកិលេសដែលរកធម៌ដទៃក្រៃលែងជាងគ្មាន) បានដល់ ក្នុងនិព្វាន ។ បទថា *អធិមុត្តំ ហោតិ* (នៅមិនទាន់រួចផុត) បានដល់ បង្អោនទៅក្នុងអរហត្តផល ។

ចប់អដ្ឋកថា ផគ្គុណសូត្រទី ២

# អដ្ឋកថា ឆឡាភិជាតិយសូត្រទី ៣

## (ទ្រង់បញ្ញត្តិអភិជាតិ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឆឡាភិជាតិយសូត្រទី ៣ ដូចតទៅនេះ ៖*

[៥៧] *បទថា* ***ឆឡាភិជាតិយោ*** *(អភិជាតិ ៦ ប្រការ) បានដល់ ជាតិ ៦ យ៉ាង ។ បទថា* ***តត្រិទំ*** *គឺ* ***តត្រាយំ*** *។ បទថា* ***លុទ្ទា*** *(ពួក ព្រាន) បានដល់ មនុស្សសាហាវ ។ បទថា* ***ភិក្ខូ កណ្ហាធិមុត្តិកា*** *(ពួកភិក្ខុដែលជឿក្នុងចំណែកខ្មៅ) បានដល់ ជនទាំងនេះ គឺ ពួកសមណៈ ។ បទថា* ***ឯកសាដកា*** *(ប្រើសំពត់តែមួយផ្ទាំង) បានដល់ អ្នកបិទបាំងខាងមុខដោយសំពត់កំណាត់ចាស់ ១ ផ្ទាំងប៉ុណ្ណោះ ។ បទថា* ***អកាមកស្ស ពិលំ ឱលគេយ្យុំ*** *(មនុស្សទាំងឡាយបង្គាប់... ដែលមិនត្រូវការឲ្យទទួលចំណែកសាច់) សេចក្តីថា កាលពួករទេះដើរផ្លូវទៅ កាលគោ (មួយក្បាល) ងាប់ហើយ មនុស្សទាំងឡាយក៏កាត់ចៀរសាច់គោនោះ ដើម្បីត្រូវការតម្លៃនិងបរិភោគបណ្តើរ ទើបបែងចែកឲ្យដល់បុរសម្នាក់ ដែលមិនត្រូវការសាច់គោ ហើយពោលថា លោកត្រូវបរិភោគចំណែកនេះ ហើយត្រូវឲ្យតម្លៃផងដូច្នេះ ហើយបង្គាប់ឲ្យទទួលចំណែកសាច់ ពោលគឺ ចំណែកនោះ គឺ ដាក់*

ទុកក្នុងដៃដោយពលការ (ប្រើកម្លាំង) ។

បទថា *អក្ខេត្តញ្ញុនា* (មិនស្គាល់ខេត្តបញ្ញត្តិ) បានដល់ ជាអ្នកមិនស្គាល់ទីតាំងនៃការបញ្ញត្តិអភិជាតិ ។ បទថា *តំ សុណាហិ* (អ្នកចូរស្តាប់បញ្ញត្តិនោះ) បានដល់ អ្នកចូរស្តាប់ការបញ្ញត្តិនោះរបស់តថាគត ។ បទថា *កណ្ហាភិជាតិកោ*[១] (អ្នកមានអភិជាតិខ្មៅ) បានដល់ អ្នកមានកំណើតខ្មៅ ។ បទថា *កណ្ហំ ធម្មំ អភិជាយតិ* (ប្រព្រឹត្តធម៌ខ្មៅ) បានដល់ កើត គឺ បង្កើតជាសភាពខ្មៅ ឬកើតក្នុងកំណើតខ្មៅ ។ បទថា *និព្វានំ អភិជាយតិ* (ដល់និព្វាន) បានដល់ លុះនិព្វាន ឬកើតក្នុងនិព្វានជាតិ ពោលគឺ អរិយភូមិ ។

ចប់អដ្ឋកថា ឆឡាភិជាតិយសូត្រទី ៣

---

(១) បិដក = កណ្ហាភិជាតិយោ ។

# អដ្ឋកថា អាសវសូត្រទី ៤

## (ធម៌ជាហេតុលះអាសវៈ)

គប្បីជ្រាបវិនិច្ឆ័យក្នុង អាសវសូត្រទី ៤ ដូចតទៅនេះ ៖

[៥៨] បទថា **សំវរា បហាតព្វា** (ត្រូវលះដោយការសង្រួម) បានដល់ (អាសវៈទាំងឡាយ) គប្បីលះបានដោយការសង្រួម ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ បទថា **ឥធ (ក្នុងធម្មវិន័យនេះ)** បានដល់ក្នុងសាសនានេះ ។ បទថា **បដិសំខា** (ពិចារណា) បានដល់ ពិចារណា គឺ ជ្រាប អធិប្បាយថា ពិចារណា ។ បទថា **យោនិសោ (ដោយឧបាយ)** បានដល់ ដោយឧបាយ គឺ ដោយរបៀប ។ មួយវិញទៀត ក្នុងសូត្រនេះ ការពិចារណាទោសក្នុងអសំវរៈ គប្បីជ្រាបថា ជាការពិចារណាដោយឧបាយ ។ ក៏ការពិចារណានោះ គប្បីជ្រាបតាមអាទិត្តបរិយាយសូត្រ មានជាអាទិ៍ថា "ម្នាលភិក្ខុទាំងឡាយ ចក្ខុន្ទ្រិយត្រូវរុកដោយដែកដ៏ក្តៅឆេះរន្ទាល ប្រសើរជាង តែការកាន់យកនូវនិមិត្តក្នុងរូបទាំងឡាយដែលគប្បីដឹងដោយចក្ខុ និងអនុព្យញ្ជនៈ មិនប្រសើរឡើយ" ។

បទថា **ចក្ខុន្ទ្រិយសំវរសំវុតោ វិហរតិ (ជាអ្នកសង្រួម ដោយការសង្រួមនូវចក្ខុន្ទ្រិយ)** នេះ មានអធិប្បាយដូចតទៅនេះ ឥន្ទ្រិយ គឺ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ។ ដែលឈ្មោះថា **ការសង្រួម** ព្រោះរាំង មានអធិប្បាយថា ព្រោះបិទបាំង ព្រោះរាំង ។ បទថា **ការសង្រួម** នោះ ជាឈ្មោះរបស់សតិ ។ ការសង្រួមក្នុងចក្ខុន្ទ្រិយ ឈ្មោះថា **ការសង្រួមចក្ខុន្ទ្រិយ** ក៏ការសង្រួមចក្ខុន្ទ្រិយនេះ សូម្បីកាលជវនចិត្តកើតឡើង ក៏ហៅថា ការសង្រួមចក្ខុន្ទ្រិយ ព្រោះហាមកិលេសទាំងឡាយមិនឲ្យកើតឡើងក្នុងទ្វារនោះ ។ បទថា **សំវុតោ (ជាអ្នកសង្រួម)** បានដល់ ជាអ្នកប្រកបដោយសំវរៈនោះ ។ ពិតហើយ ក្នុងវិភង្គថា ជាអ្នកសង្រួមក្នុងបាតិមោក្ខ ព្រះមានព្រះភាគត្រាស់ថា ជាអ្នកប្រកបហើយ... ជាអ្នកដល់ព្រមហើយដោយបាតិមោក្ខសំវរៈនេះ ។ ម្យ៉ាងទៀត ឈ្មោះថា **ជាអ្នកសង្រួម** ព្រោះអត្ថថា សង្រួមហើយ មានអធិប្បាយថា រាំងហើយ គឺ បិទហើយ ។ បទថា **ជាអ្នកសង្រួមដោយការសង្រួមចក្ខុន្ទ្រិយ** បានដល់ សង្រួម អធិប្បាយថា រាំង បិទដោយទ្វារ គឺ សតិ ពោលគឺ ចក្ខុន្ទ្រិយសំវរៈ ត្រង់ចក្ខុទ្វារ

ដូចបិទទ្វារត្រង់ទ្វារផ្ទះ ដូច្នោះ អធិប្បាយក្នុងបទនេះដូច្នេះ ប្រសើរជាង ។ ពិតហើយ អត្ថនេះឯង ប្រាកដក្នុងពាក្យទាំងនេះ គឺ អ្នកមិនសង្រួម ដល់ការមិនសង្រួមក្នុងចក្ខុន្ទ្រិយ អ្នកសង្រួម ដល់ការសង្រួមក្នុងចក្ខុន្ទ្រិយ ។

ក្នុងបទថា ***យញ្ហិស្ស***[១] (កាលបើអ្នក) ជាដើម មានអធិប្បាយថា កាលភិក្ខុនោះមិនសង្រួម គឺ មិនរាំង មិនបិទចក្ខុន្ទ្រិយណា ។ម្យ៉ាងទៀត ***យេ*** អក្សរ អាទេសជា ***យំ*** ក៏បាន មានន័យដូចគ្នានឹង ***យេ អស្ស*** ។ បទថា ***អាសវា វិឃាតបរិឡាហា (អាសវៈ និងសេចក្ដីក្ដៅក្រហាយ ដែលធ្វើឲ្យចង្អៀតចង្អល់)*** បានដល់ អាសវៈ ៤ យ៉ាង និងសេចក្ដីក្ដៅក្រហាយព្រោះកិលេស ឬសេចក្ដីក្ដៅក្រហាយព្រោះវិបាក ដែលធ្វើសេចក្ដីចង្អៀតចង្អល់ឲ្យ ។ អធិប្បាយថា កាលភិក្ខុត្រេកអរ គឺ ភ្លើតភ្លើនក្នុងឥដ្ឋារម្មណ៍ ដែលមកកាន់គន្លងចក្ខុទ្វារ ដោយអំណាចសេចក្ដីពេញចិត្តក្នុងកាម ***កាមាសវៈ*** រមែងកើតឡើង , កាលភិក្ខុត្រេកអរដោយការប្រាថ្នាភពថា យើងនឹងបានដល់ឥដ្ឋារម្មណ៍ដូច្នេះ សូម្បីក្នុងសុគតិភពដទៃ ***ភវាសវៈ*** រមែងកើតឡើង,

---

(១) បិដក = យំ ហិស្ស ។

កាលភិក្ខុប្រកាន់ថា សត្វ ឬថា របស់សត្វ **ទិដ្ឋាសវៈ** រមែងកើតឡើង , ការមិនដឹង ដែលកើតព្រមជាមួយអាសវៈនោះឯង ឈ្មោះថា **អវិជ្ជាសវៈ** អាសវៈ ៤ រមែងកើតឡើង ដូចពោលមកនេះឯង ។ កិលេសពួកដទៃដែលសម្បយុត្តជាមួយនឹងអាសវៈទាំងនោះ ដែលមានសេចក្ដីក្ដៅក្រហាយកើតពីសេចក្ដីចង្អៀតចង្អល់ ឬវិបាករបស់កិលេសទាំងនោះក្នុងអនាគត លោកពោលថា គប្បីកើតឡើងដល់ភិក្ខុអ្នកមិនសង្រួមចាកអាសវៈទាំងនោះ ។ បទថា **ឯវំស តេ** ជាបទថា **ឯវំ អស្ស តេ** មានអធិប្បាយថា មិនមានដោយឧបាយនេះ ទាំងមិនមានដោយឧបាយដទៃ ។

សូម្បីក្នុងបទថា **បដិសំខា យោនិសោ សោតិន្ទ្រិយសំវរសំវុតោ** (ពិចារណាដោយឧបាយហើយ ជាអ្នកសង្រួម ដោយការសង្រួមសោតិន្ទ្រិយ) ជាដើម ក៏មានន័យនេះនោះឯង ។ បទថា **ឥមេ វុច្ចន្តិ អាសវា សំវរា បហាតព្វា** (ទាំងនេះហៅថា អាសវៈដែលភិក្ខុត្រូវលះដោយការសង្រួម) បានដល់ អាសវៈ ២៤ យ៉ាង ដោយការចែកអាសវៈ ៤ យ៉ាង តាមទ្វារទាំង ៦ នេះ ព្រះមានព្រះភាគត្រាស់ថា គប្បីលះដោយការសង្រួម ។

បទណាដែលគប្បីពោលទុកក្នុងបទថា **បដិសំខា យោនិសោ ចីវរំ** (ពិចារណាដោយឧបាយហើយ "រមែងសេព" ចីវរ) ជាដើម បទទាំងអស់នោះ បានពោលទុកហើយនោះឯងក្នុងសីលកថា ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **យញ្ហិស្ស** (កាលភិក្ខុ) បានដល់ ក៏កាលភិក្ខុ (មិនសេព) ចីវរ ឬបច្ច័យណាមួយ ក្នុងបណ្ដាបច្ច័យមានបិណ្ឌបាតជាដើម ។ បទថា **អប្បដិសេវតោ** (មិនសេព) បានដល់ មិនសេពដោយឧបាយដ៏ប្រពៃយ៉ាងនេះ ។ ក្នុងទីនេះ កាលភិក្ខុប្រាថ្នាបច្ច័យ មានចីវរជាដើម ដែលនៅមិនទាន់បាន ឬត្រេកអរក្នុងបច្ច័យ មានចីវរជាដើមដែលបានហើយ គប្បីជ្រាបថា **កាមាសវៈ** កើតឡើង កាលភិក្ខុត្រេកអរដោយការប្រាថ្នាកពថា យើងនឹងបានបច្ច័យដូច្នេះក្នុងសុគតិភពសូម្បីដទៃ គប្បីជ្រាបថា **ភវាសវៈ** កើតឡើង ។ កាលភិក្ខុតាំងអត្តសញ្ញា (សេចក្ដីសំគាល់ថាជាតួខ្លួន) ថា យើងបាន យើងមិនបាន ឬថា ចីវរនេះជារបស់យើង គប្បីជ្រាបថា **ទិដ្ឋាសវៈ** កើតឡើង ។ ចំណែក **អវិជ្ជាសវៈ** គប្បីជ្រាបថា កើតព្រមជាមួយអាសវៈដទៃនោះឯង ការកើតឡើងរបស់អាសវៈ ៤ និងសេចក្ដីក្ដៅក្រហាយ ដែល

ធ្វើសេចក្តីចង្អៀតចង្អល់ឲ្យកើតឡើង គប្បីជ្រាបដូចការពណ៌នាមកនេះឯង ។ គប្បីជ្រាបអាសវៈ និងសេចក្តីក្តៅក្រហាយ ដែលធ្វើសេចក្តីចង្អៀតចង្អល់ឲ្យកើតឡើង សូម្បីដោយការធ្វើវេទនាថ្មីឲ្យកើតឡើង ។ បទថា **ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា បដិសេវនា បហាតព្វា (ម្នាលភិក្ខុទាំងឡាយ នេះហៅថាអាសវៈដែលភិក្ខុគប្បីលះដោយការសេព)** បានដល់ អាសវៈ ១៦ យ៉ាងនេះ ដោយចែកចេញជា ៤ ៗ ចំណែក ក្នុងមួយបច្ច័យ[១] ព្រះមានព្រះភាគត្រាស់ថា គប្បីលះដោយការពិចារណា និងសេព ពោលគឺ ញាណសំវរៈ ។

បទថា **បដិសំខា យោនិសោ ខមោ ហោតិ សីតស្ស (ពិចារណាដោយឧបាយហើយ រមែងជាអ្នកអត់ធន់ដល់ត្រជាក់)** សេចក្តីថា ភិក្ខុពិចារណាដោយឧបាយ គឺ ដោយត្រូវផ្លូវហើយ រមែងជាអ្នកអត់ធន់ដល់ត្រជាក់ គឺ រមែងគ្របសង្កត់ រមែងអត់ទ្រាំចំពោះត្រជាក់ បានដល់ មិនញាប់ញ័រ គឺ មិនលះបង់កម្មដ្ឋាន ព្រោះត្រជាក់សូម្បីត្រឹមតែតិចតួច ដូចជាមនុស្សលាមក ។ សូម្បីក្នុង **ក្តៅ** ជាដើម ក៏មានន័យនេះឯង ។ ក៏ក្នុងទីនេះ

---

(១) គឺ អាសវៈទាំង ៤ រមែងកើតក្នុងបច្ច័យទាំង ៤ មានចីវរប្បច្ច័យជាដើម ទើបបាន ១៦ ។

*ពាក្យពោលនេះឯង គប្បីជ្រាបថា* ***វចនបថោ***[១] ***(ពាក្យសំដី)*** *។ បទថា* ***ទុក្ខានំ (ជាទុក្ខ)*** *ជាដើម គប្បីជ្រាបថា វេទនា ជាទុក្ខ ព្រោះអត្ថថា ទ្រាំបានលំបាក* ***តេ្បិរិក្ខា*** *ដោយអត្ថថា ច្រើន* ***ខ្លាំង*** *ដោយអត្ថថា គ្រោតគ្រាត* ***ក្តៅក្រហាយ*** *ដោយអត្ថថា ឈឺចាប់* ***មិនជាទីត្រេកអរ*** *ព្រោះវៀរចាកសេចក្តីត្រេកអរ* ***មិនជាទីពេញចិត្ត*** *ព្រោះមិនធ្វើចិត្តឲ្យចម្រើន* ***អាចផ្តាច់ជីវិតបាន*** *ព្រោះអាចផ្តាច់ជីវិតបាន ។ បទថា* ***យញ្ហិស្ស (កាលបើភិក្ខុ)*** *បានដល់ (កាលភិក្ខុនោះ មិនអត់ធន់) ក្នុងអារម្មណ៍ណាមួយ គឺ សូម្បីធម៌ណាមួយ មានត្រជាក់ជាដើម ។ បទថា* ***អនធិវាសយតោ (មិនអត់ទ្រាំ)*** *បានដល់ មិនអត់ទ្រាំ គឺ មិនអត់ធន់ ។ចំណែកការកើតឡើងនៃអាសវៈក្នុងរឿងនេះ គប្បីជ្រាបដូចតទៅនេះ កាលភិក្ខុប្រសព្វនឹងត្រជាក់ ប្រាថ្នាក្តៅ កាមាសវៈរមែងកើតឡើង ក្នុងទីគ្រប់កន្លែងក៏ន័យនេះ ។ កាលភិក្ខុប្រាថ្នាភពថា ក្នុងសុគតិភពមិនមានត្រជាក់ ឬក្តៅ ភវាភវៈរមែងកើតឡើង ការប្រកាន់ថា យើងត្រជាក់ យើងក្តៅ ដូច្នេះ ជាទិដ្ឋាសវៈ (ចំណែក)*

---

(១) បិដក = វចនបថានំ ។

អវិជ្ជាសវៈ ប្រកបព្រមជាមួយអាសវៈ (ដែលបានពោលមក) នោះឯង ។ បទថា **ឥមេ វុច្ចន្តិ** (នេះហៅថា) អធិប្បាយថា អាសវៈទាំងនេះ មានចំនួនច្រើន ដោយចែកតែមួយយ៉ាងក្នុងត្រជាក់ជាដើម ចេញជា ៤ ព្រះមានព្រះភាគត្រាស់ថា គប្បីលះដោយការអត់ធន់ ពោលគឺ ខន្តិសំវរៈនេះ ។

បទថា **បដិសំខា យោនិសោ ចណ្ឌហត្ថឹ បរិវជ្ជេតិ** (ពិចារណាដោយឧបាយហើយ រមែងចៀសចេញពីដំរីកាច) សេចក្តីថា ភិក្ខុពិចារណាដោយឧបាយ គឺ ដោយត្រូវផ្លូវយ៉ាងនេះថា យើងមិនគួរឈរក្នុងទីជិតដំរីកាច ដោយគិតថា យើងជាសមណៈ ព្រោះថា នឹងមានសេចក្តីស្លាប់ខ្លះ សេចក្តីទុក្ខស្មើតែនឹងស្លាប់ខ្លះ ព្រោះហេតុមកពីការឈរក្នុងទីជិតនោះ ដូច្នេះ ហើយចៀសចេញ គឺ គេចចេញពីដំរីកាច ។ ក្នុងគ្រប់បទ ក៏មានន័យនេះ ។ បទថា **ចណ្ឌំ** (កាច) បានដល់ ឃោរឃៅ គឺ កាចសាហាវ ។ បទថា **ខាណុំ** (ដង្គត់) បានដល់ ដង្គត់ដើមឈើជាដើម ។ បទថា **កណ្ដកដ្ឋានំ** (ទីមានបន្លា) បានដល់ ទីដែលបន្លាគប្បីមុតបាន ។ បទថា **សោព្ភំ** (អន្លង់) បានដល់ ទីចន្លោះផ្លូវ (ឡើងចុះ) គ្រប់ជ្រុង ។ បទថា **បបាតំ**

(ជ្រោះ) បានដល់ ទីដែលដាច់ ៗ បទថា **ចណ្ឌនិកំ**[១] (រណ្ដៅទឹកស្អុយ) បានដល់ ទីដែលមានទឹកស្អុយ និងមន្ទិលគក់ជាដើម ៗ បទថា **ឱឡិគល្លំ** (បឡ្លាយទឹកស្អុយ) បានដល់ ទីដែលហូរទៅនូវកក់ជាដើមនោះឯង ៗ ទីនោះជ្រៅត្រឹមជង្គង់ ក៏ជាទីពេញទៅដោយរបស់មិនស្អាត ៗ ក៏ស្ថានទីទាំង ២ កន្លែងនេះ ជាស្ថានទីដែលមានមនុស្សកកកុញ ព្រោះដូច្នោះ ទើបត្រូវវៀរ ៗ ក្នុងបទថា **អនាសនេ** (ក្នុងទីមិនគួរអង្គុយ) នេះ មានអធិប្បាយថា ទីអង្គុយមិនសមគួរ ឈ្មោះថា **ទីមិនគួរអង្គុយ** ដែលមិនគួរអង្គុយនោះ ដោយន័យគប្បីជ្រាបថា បានដល់ ទីអង្គុយក្នុងទីកំបាំង ដែលជាហេតុនៃអនិយតសិក្ខាបទ ៗ សូម្បីក្នុងបទនេះថា **អគោចរេ** (ក្នុងទីមិនគួរត្រាច់ទៅ) មានសេចក្ដីថា ដែលត្រាច់ទៅក្នុងទីដែលមិនសមគួរ ឈ្មោះថា **ទីមិនគួរត្រាច់ទៅ** ៗ ទីមិនគួរត្រាច់ទៅនោះមាន ៥ យ៉ាង មានកន្លែងស្រីពេស្យាជាដើម ៗ បទថា **បាបកេ មិត្តេ** (បាបមិត្រ) បានដល់ មិត្រលាមក គឺ មិត្រដែលទ្រុស្តសីល បានដល់ មិត្រក្លែងក្លាយ គឺ អ្នកមិន

---

(១) បិដក = ចន្ទនិកំ ៗ

មែនជាមិត្រ ។ បទថា **បាបកេសុ** (ដែលជាបាប) បានដល់ ថោកទាប ។ បទថា **ឱកប្បេយ្យុំ** (គប្បីយល់ឃើញ) បានដល់ គប្បីជឿ គឺ គប្បីបង្អោនចិត្តជឿថា អ្នកមានអាយុរូបនេះ បានធ្វើ ឬមិនបានធ្វើហ្ន៎ ។ បទថា **យំ ហិស្ស** (បើភិក្ខុ) សេចក្តីថា បើភិក្ខុនោះ (មិនបន្ទោបង់) អន្តរាយយ៉ាងណាមួយ គឺ មានអន្តរាយណាមួយក្នុងបណ្តាអន្តរាយ មានដំរីជាដើម ។ ចំណែកការកើតឡើងនៃអាសវៈក្នុងទីនេះ គប្បីជ្រាបដូចតទៅនេះ កាលភិក្ខុប្រសព្វទុក្ខ មានដំរីជាដើមជាហេតុ ប្រាថ្នាសុខ កាមាសវៈរមែងកើតឡើង កាលភិក្ខុប្រាថ្នាភពថា ទុក្ខដូចនេះមិនមាននៅក្នុងសុគតិភព ភវាសវៈរមែងកើតឡើង ការប្រកាន់ថា ដំរីជាន់យើង សេះជាន់យើង ដូច្នេះ ជាទិដ្ឋាសវៈ (ចំណែក) អវិជ្ជាសវៈប្រកបព្រមជាមួយអាសវៈ (ដែលពោលមកហើយ) នេះឯង ។ បទថា **ឥមេ វុច្ចន្តិ** (ទាំងនេះហៅថា **អាសវៈ**) សេចក្តីថា អាសវៈទាំងនេះមានច្រើនយ៉ាង តែមួយក្នុងបណ្តាអន្តរាយ មានដំរីជាដើមដោយការចែកក្នុងមួយៗ ៤ យ៉ាង ព្រះមានព្រះភាគត្រាស់ថា គប្បីលះដោយការវៀរ ពោលគឺ សីលសំវរៈនេះ ។

បទថា **បដិសំខា យោនិសោ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ** (ពិចារណាដោយឧបាយហើយ រមែងមិនរក្សាទុក... នូវកាមវិតក្កៈដែលកើតឡើង) សេចក្តីថា ភិក្ខុពិចារណាឃើញទោសក្នុងកាមវិតក្កៈ ដោយឧបាយដោយន័យជាដើមថា វិតក្កៈនេះជាអកុសលសូម្បីព្រោះហេតុនេះ មានទោសសូម្បីព្រោះហេតុនេះ មានផលជាទុក្ខសូម្បីព្រោះហេតុនេះ ក៏វិតក្កៈនេះឯងរមែងប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនខ្លះ ដូច្នេះហើយ មិនកាន់យកកាមវិតក្កៈដែលកើតឡើងទុកក្នុងអារម្មណ៍នោះៗ អធិប្បាយថា លើកកាមវិតក្កៈឡើងកាន់ចិត្តហើយ មិនឲ្យស្ថិតនៅ ឬមិនឲ្យនៅក្នុងខាងក្នុង ។ សួរថា ភិក្ខុកាលមិនកាន់យក នឹងធ្វើដូចម្តេច ។ ឆ្លើយថា **បជហតិ** (រមែងលះបង់) ។ សួរថា រមែងលះបង់ដូចយកជាលជងទឹកចោលឬ ។ ឆ្លើយថា មិនមែនដោយពិត **រមែងបន្ទោបង់ (វិនោទេតិ)** គឺ បាក់ជោត នាំកាមវិតក្កៈនោះចេញ ។ សួរថា បាក់ដូចយកជន្ទួញបាក់គោពលិព័ទឬ ។ ឆ្លើយថា មិនមែន ការពិតគឺ **រមែងធ្វើឲ្យអស់ទៅ (ព្យន្តីករោតិ)** គឺ ធ្វើកាមវិតក្កៈនោះឲ្យមានទីបំផុតអស់ទៅ ទីបំផុតរបស់កាមវិតក្កៈនោះ ដោយហោចសូម្បីត្រឹម

កង្ខណៈ (របស់ចិត្ត) មិនឲ្យសល់ដោយប្រការណា នឹងធ្វើកាមវិតក្កៈនោះដោយប្រការនោះ ។ សួរថា ក៏ភិក្ខុនឹងធ្វើកាមវិតក្កៈនោះឲ្យជាយ៉ាងនោះបានដូចម្តេច ។ ឆ្លើយថា **(រមែងធ្វើឲ្យអស់ទៅ) អនភាវំ គមេតិ** គឺ ឲ្យដល់ការមិនមានតទៅ បានដល់ ត្រូវគ្របសង្កត់កាមវិតក្កៈដោយវិក្ខម្ភនប្បហាន ។ សូម្បីក្នុងវិតក្កៈ ២ យ៉ាងដ៏សេស ក៏មានន័យនេះឯង ។ បទថា **ឧប្បន្នុប្បន្នេ (ដែលកើតឡើងហើយកើតឡើងទៀត)** បានដល់ (វិតក្កៈ) ដែលកើតឡើងហើយ អធិប្បាយថា ត្រឹមតែកើតឡើងប៉ុណ្ណោះ ម្យ៉ាងទៀត អធិប្បាយថា បន្ទោបង់វិតក្កៈដែលកើតឡើងមួយគ្រាហើយ មិនឲ្យកើតឡើងក្នុងគ្រាទី ២ បានដល់ បន្ទោបង់វិតក្កៈដែលកើតឡើងហើយ ទាំង ៧ ដងនោះឯង ។ បទថា **បាបកេ អកុសលេ ធម្មេ (នូវធម៌ដែលជាបាបអកុសល)** បានដល់ វិតក្កៈទាំងឡាយ មានកាមវិតក្កៈជាដើមទាំងនោះឯង ឬវិតក្កៈធំទាំង ៩ ប្រភេទ ។ បណ្តាលវិតក្កៈទាំង ៩ ប្រភេទ វិតក្កៈ ៣ យ៉ាង ព្រះមានព្រះភាគត្រាស់ទុកហើយ (ចំណែក) វិតក្កៈ ៦ យ៉ាងដ៏សេសនេះ គឺ ញាតិវិតក្កៈ (ត្រិះរិះដល់ញាតិ) ជនបទវិតក្កៈ (ត្រិះរិះដល់ជនបទ)

អមរវិតក្កៈ (ត្រិះរិះដល់ទេវតា) វិតក្កៈដែលជាប់ដោយការអាណិតដល់អ្នកដទៃ វិតក្កៈដែលជាប់ដោយលាភសក្ការៈ និងពាក្យសរសើរ វិតក្កៈដែលជាប់ដោយការមិនមើលងាយ ។ បទថា **យញ្ញិស្ស (កាលភិក្ខុ)** បានដល់ (កាលភិក្ខុនោះមិនបន្ទោបង់) វិតក្កៈណាមួយក្នុងបណ្តាវិតក្កៈទាំងនេះ ។ ម្យ៉ាងទៀត ក្នុងទីនេះ កាមវិតក្កៈ ក៏គឺ កាមាសវៈនោះឯង វិតក្កៈដ៏សេសក្រៅពីកាមវិតក្កៈនោះ ចាត់ជាភវាសវៈ វិតក្កៈដែលសម្បយុត្តដោយភវាសវៈនោះ ចាត់ជាទិដ្ឋាសវៈ អវិជ្ជាក្នុងវិតក្កៈទាំងអស់ចាត់ជាអវិជ្ជាសវៈ គប្បីជ្រាបការកើតឡើងនៃអាសវៈដូចពណ៌នាមកនេះឯង ។ បទថា **ឥមេ វុច្ចន្តិ (ទាំងនេះហៅថា)** អធិប្បាយថា អាសវៈទាំងនេះ មានប្រការដូចពោលហើយ ដោយអំណាចកាមវិតក្កៈជាដើម ព្រះមានព្រះភាគត្រាស់ថា គប្បីលះដោយប្រការបន្ទោបង់ ពោលគឺ វីរិយៈដែលប្រកបដោយការពិចារណាឃើញទោសក្នុងវិតក្កៈនោះៗ ។

បទថា **បដិសំខា យោនិសោ សតិសម្ពោជ្ឈង្គំ ភាវេតិ (ពិចារណាដោយឧបាយហើយ រមែងចម្រើនសតិសម្ពោជ្ឈង្គៈ)** សេចក្តីថា ភិក្ខុពិចារណា

ឃើញទោសក្នុងការមិនមានការនា និងអានិសង្សក្នុងការនា ដោយឧបាយ គឺដោយគន្ធងហើយ ចម្រើនសតិសម្ពោជ្ឈង្គ: ។ ក្នុងគ្រប់បទក៏មានន័យនេះ ។ ក៏ការចម្រើនពោជ្ឈង្គ:ទាំងឡាយ បានអធិប្បាយទុកពិស្តារហើយក្នុងខាងដើមនោះឯង ។ បទថា **យញ្ហិស្ស** (កាលភិក្ខុ) បានដល់ កាលភិក្ខុនោះ (មិនចម្រើន) ពោជ្ឈង្គ:ប្រការណាមួយក្នុងបណ្តាពោជ្ឈង្គ:ទាំងនេះ ។ ក៏ក្នុងការកើតឡើងអាសវ: ក្នុងទីនេះ គប្បីជ្រាបដូចតទៅនេះថា អាសវ:ពួកណា មានកាមាសវ:ជាដើមគប្បីកើតឡើង ព្រោះមិនបានចម្រើនពោជ្ឈង្គ: ទាំងឡាយដែលសម្បយុត្តដោយអរិយមគ្គ អាសវ:ទាំងនោះ រមែងមិនមានដល់អ្នកដែលចម្រើន (ពោជ្ឈង្គ:) យ៉ាងនេះ ។ បទថា **ឥមេ វុច្ចន្តិ (នេះហៅថា)** អធិប្បាយថា អាសវ:ទាំងឡាយ មានកាមាសវ:ជាដើមនេះឯង ព្រះមានព្រះភាគត្រាស់ថា គប្បីលះបានដោយការចម្រើននូវពោជ្ឈង្គ: ដែលជាលោកុត្តរនេះ ។

ចប់អដ្ឋកថា អាសវសូត្រទី ៤

# អដ្ឋកថា ទារុកម្មិកសូត្រទី ៥

## (ត្រាស់ឲ្យទារុកម្មិកគហបតីថ្វាយទានសង្ឃ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទារុកម្មិកសូត្រទី ៥ ដូចតទៅនេះ ៖*

[៥៩] *បទថា* ***ទារុកម្មិកោ (ទារុកម្មិកៈ)*** *បានដល់ ឧបាសកមួយរូប មានអាជីពលក់អុស ។ បទថា* ***កាសិកចន្ទនំ (ចន្ទន៍ដែនកាសី)*** *បានដល់ ចន្ទន៍ដ៏ល្អិត ។ បទថា* ***អគ្គេន (ដោយហេតុ)*** *បានដល់ ដោយអង្គមិនមែនជាគុណ , ក្នុងធម៌ចំណែកល្អ បានដល់ ដោយអង្គដែលជាគុណ ។ បទថា* ***នេមន្តនិកោ (អ្នកទទួលនិមន្ត)*** *បានដល់ ជាអ្នកទទួលនិមន្ត ។ បទថា* ***សង្ឃេ ទានានិ ទស្សាមិ (នឹងឲ្យទានចំពោះសង្ឃ)*** *បានដល់ នឹងថ្វាយដល់ភិក្ខុសង្ឃ ។ ឧបាសកនោះ លុះក្រាបទូលយ៉ាងនោះហើយ ក៏ថ្វាយបង្គំព្រះសាស្តាហើយចៀសចេញទៅ ។ ក្នុងវេលាតមក ភិក្ខុដែលជាកុលូបកៈរបស់គេចំនួន ៥០០ រូប បានដល់ភាពជាគ្រហស្ថ (សឹក) ។ ទារុកម្មិកគហបតីនោះ កាលមនុស្សទាំងឡាយនិយាយថា ភិក្ខុដែលជាកុលូបកៈរបស់លោក សឹកអស់ហើយ ក៏ពោលថា យើងនឹងធ្វើអ្វីបានក្នុងរឿងនេះ*

ហើយមិនបានធ្វើឲ្យខុសប្រក្រតីកើតឡើងក្នុងចិត្តឡើយ ។ ព្រះសាស្តាទ្រង់សំដៅយកហេតុនេះ ទើបត្រាស់ថា កាលលោកឲ្យទានក្នុងសង្ឃហើយ ចិត្តនឹងជ្រះថ្លា ដូច្នេះ ។

ចប់អដ្ឋកថា ធារុកម្មិកសូត្រទី ៥

# អដ្ឋកថា ចិត្តហត្ថិសារីបុត្តសូត្រទី ៦

## (ហេតុឲ្យចិត្តហត្ថិសារីបុត្តលាសិក្ខា)

គប្បីជ្រាបវិនិច្ឆ័យក្នុង ចិត្តហត្ថិសារីបុត្តសូត្រទី ៦ ដូចតទៅនេះ ៖

[៦០] បទថា **អភិធម្មកថំ (អភិធម្មកថា)** បានដល់ កថាលាយដោយអភិធម្ម ។ បទថា **កថំ ឱបាតេតិ (និយាយស៊កឡើង)** សេចក្តីថា (ចិត្តហត្ថិសារីបុត្រ) ពោលពាក្យរបស់ខ្លួនកាត់ពាក្យរបស់ភិក្ខុទាំងនោះ ។ បទថា **ថេរានំ ភិក្ខូនំ (កាលបើពួកភិក្ខុជាថេរៈ)** ជាឆដ្ឋីវិភត្តិប្រើក្នុងអត្ថនៃតតិយាវិភត្តិ ។ មានន័យថា ជាមួយពួកភិក្ខុជាថេរៈ និងអធិប្បាយថា អភិធម្មកថារបស់ថេរៈទាំងឡាយណា សូម្បីព្រះចិត្តហត្ថិសារីបុត្តនេះក៏អាចពោលអភិធម្មកថានោះបាន ។ បទថា **ចេតោបរិយាយំ (វារៈចិត្ត)** បានដល់ វារៈនៃចិត្ត ។ បទថា **ឥធ (ក្នុងលោកនេះ)** គឺ ក្នុងលោកនេះ ។ បទថា **សោរតសោរតោ (ដូចជាស្ងប់ស្ងៀម)** គឺ ជាអ្នកស្ងប់ស្ងៀម ដូចបុគ្គលអ្នកស្ងប់ស្ងៀម អធិប្បាយថា ដូចបុគ្គលអ្នកប្រកបដោយសោរច្ចៈ (សេចក្តីស្ងប់ស្ងៀម) ។ បទថា **និវាតនិវាតោ (ដូចជាទន់ភ្លន់)** គឺ ជាអ្នក

បន្ទាបខ្លួន ដូចបុគ្គលអ្នកបន្ទាបខ្លួន អធិប្បាយថា ដូចបុគ្គលអ្នកប្រព្រឹត្តបន្ទាបខ្លួន ។ បទថា **ឧបសន្តូបសន្តោ** (ជាអ្នកស្រគត់ស្រគំ) គឺ ជាអ្នកស្ងប់រម្ងាប់ដូចបុគ្គលដែលស្ងប់រម្ងាប់ ។

បទថា **វិបកស្សតេវ សត្ថារា** (ចេញចាកពីព្រះសាស្តា) បានដល់ចៀសចេញអំពីសំណាក់ព្រះសាស្តា ។ បទថា **សំសដ្ឋស្ស** (ច្រឡូកច្រឡំ) បានដល់ ច្រឡូកច្រឡំដោយការច្រឡូកច្រឡំ ៥ យ៉ាង ។ បទថា **វិស្សដ្ឋស្ស** (បណ្តោយចិត្ត) បានដល់ មានចិត្តត្រូវបណ្តែតបណ្តោយហើយ ។ បទថា **បាកដស្ស** (មិនសង្រួមឥន្ទ្រិយ) បានដល់ មានឥន្ទ្រិយប្រាកដ (មិនបិទ) ។ បទថា **កិដ្ឋាទោ** (ដែលធ្លាប់ស៊ីសំណាប) បានដល់ ដែលទំពាស៊ីសំណាប ។ បទថា **អន្តរធាបេយ្យ** (គប្បីញុំាង "ធូលី" ឲ្យវិនាសទៅ) បានដល់ គប្បីឲ្យវិនាស ។ បទថា **គោបសូ** (គោ និងសត្វចិញ្ចឹម) បានដល់ គោ និងពពែ ។ បទថា **សិប្បិសម្ពុកំ** (ខ្យង និងគ្រំ) បានដល់ខ្យងផង គ្រំផង ។ បទថា **សក្ខរកថលំ** (គ្រួស អម្បែង) ដុំគ្រួសផងអម្បែងផង ។ បទថា **អភិទោសិកំ** (អាហារផ្អូម) បានដល់ របស់បរិភោគ

ផ្សំដោយស្មៅដែលមានទោសប្រាកដហើយ ។ បទថា **នច្ចាទេយ្យ (មិនគាប់ចិត្ត)** បានដល់ មិនពេញចិត្ត ។ បទទុតិយាវិភត្តិដែលថា **បុរិសំ កុត្តាវី (បុរសដែលបរិភោគ)** នោះណា ក្នុងសូត្រនោះ បទនោះគប្បីឃើញថា ប្រើក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។ បទថា **អមុញ្ញាវុសោ បុរិសំ (បុរសឯនោះ)** បានដល់ អ្នកមានអាយុ បុរសឯនោះ ។

បទថា **សព្វនិមិត្តានំ (និមិត្តទាំងពួង)** បានដល់ និមិត្តថា ទៀងទាំងពួង ។ បទថា **អនិមិត្តំ ចេតោសមាធឹ (ចេតោសមាធិដែលមិនមាននិមិត្ត)** បានដល់ សមាធិក្នុងវិបស្សនាដែលមានកម្លាំង ។ បទថា **ចីរិឡិកាសទ្ទោ (សំឡេងអឺងកង)** បានដល់ សំឡេងគគ្រឹកគគ្រេង ។ បទថា **សរិស្សតិ នេក្ខម្មស្ស (នឹងរឭកដល់ការចេញបួស)** បានដល់ នឹងរឭកដល់គុណនៃការបព្វជា ។ បទថា **អរហតំ អហោសិ (បានជា... ក្នុងចំនួនព្រះអរហន្តទាំងឡាយ)** បានដល់ បានជាព្រះអរហន្តមួយអង្គ ក្នុងចំណោមព្រះអរហន្តដែលជាសាវករបស់ព្រះមានព្រះភាគ ។

ពិតណាស់ ព្រះថេរៈនេះជាគ្រហស្ថ ៧ ដង បួស ៧ ដង ។ ព្រោះ

ហេតុអ្វី ។ បានឮថា ក្នុងសម័យព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា កស្សបៈ ។ លោកបានពោលសរសើរគុណក្នុងភាពជាគ្រហស្ថដល់ភិក្ខុមួយរូប ។ ព្រោះកម្មនោះឯង ទាំងដែលឧបនិស្ស័យនៃអរហត្តផលមានដោយពិតៗ លោកក៏ប្រព្រឹត្តទៅក្នុងភាពជាគ្រហស្ថ និងការបព្វជ្ជា (បួសហើយសឹក) ដល់ ៧ ដង បួសក្នុងលើកទី ៧ ទើបបានសម្រេចអរហត្តផលនោះឯង ។

ចប់អដ្ឋកថា ចិត្តហត្ថិសារីបុត្តសូត្រទី ៦

# អដ្ឋកថា បារាយនសូត្រទី ៧

## (ការព្យាករណ៍បញ្ហាក្នុងបារាយនវគ្គ)

គប្បីជ្រាបវិនិច្ឆ័យក្នុង បារាយនសូត្រទី ៧ ដូចតទៅនេះ ៖

[៦១] បទថា *បារាយនេ មេត្តេយ្យបញ្ហេ* (ក្នុងប្រស្នារបស់មេត្តេយ្យមាណពក្នុងបារាយនវគ្គ) បានដល់ ក្នុងបញ្ហារបស់មេត្តេយ្យមាណពដែលមកក្នុងបារាយនវគ្គ ។

បទថា *ឧភន្តេ វិទិត្វាន* (ដឹងចំណែកបំផុតទាំងពីរ) បានដល់ ដឹងទីបំផុត ២ យ៉ាង គឺ ២ ចំណែក ។ បទថា *មជ្ឈេ មន្តា ន លិប្បតិ*[១] *(ដោយប្រាជ្ញា មិនជាប់ក្នុងចំណែកកណ្តាល)* សេចក្តីថា បញ្ញា ហៅថា មន្តា (បុគ្គលណា) ដឹងទីបំផុតទាំងពីរដោយបញ្ញា ដែលហៅថា មន្តានោះ ហើយមិនជាប់នៅក្នុងចំណែកកណ្តាល គឺ មិនជាប់នៅត្រង់កណ្តាល ។ បទថា *សិព្វិនិមច្ចគា* (ឈានកន្លងគ្រឿងចាក់ស្រែះ) បានដល់ (បុគ្គលនោះ) បានកន្លងផុតតណ្ហា ដែលហៅថា ជាគ្រឿងចាក់ស្រែះបានហើយ ។

---

(១) បិដក = លិម្បតិ ។

បទថា ផស្សោ (ផស្សៈ) បានដល់ ព្រោះកើតឡើងដោយអំណាចផស្សៈ អត្តភាពនេះទើបមាន ។ បទថា ឯកោ អន្តោ (ជាចំណែកបំផុតទី ១) បានដល់ ផស្សៈនេះ ជាចំណែក ១ ។ បទថា ផស្សសមុទយោ (កើតឡើងព្រោះផស្សៈ) មានវិគ្រោះថា ផស្សៈ ជាដែនកើតនៃអត្តភាពនោះ ព្រោះហេតុនោះ អត្តភាពនោះទើបឈ្មោះថា មានផស្សៈជាដែនកើត គឺ អត្តភាពក្នុងអនាគតដែលកើតឡើង ព្រោះមានផស្សៈ គឺ កម្មដែលធ្វើទុកក្នុងអត្តភាពនេះជាបច្ច័យ ។ បទថា ទុតិយោ អន្តោ (ចំណែកបំផុតទី ២ ) បានដល់ ជាចំណែកទី ២ ។ បទថា ផស្សនិរោធោ (ការរលត់នៃផស្សៈ) បានដល់ និព្វាន ។ បទថា មជ្ឈេ (ជាចំណែកកណ្តាល) បានដល់ និព្វាន ឈ្មោះថា ជាចំណែកកណ្តាល ដោយអត្ថថា កាត់តណ្ហាជាគ្រឿងចាក់ស្រែះចេញ ហើយចែកធម៌ (ផស្សៈ និងការកើតឡើងព្រោះផស្សៈ) ចេញជា ២ ចំណែក ។ បទថា តណ្ហា ហិ នំ សិព្វតិ (ព្រោះថា តណ្ហារមែងចាក់ស្រែះនូវផស្សៈ និងការកើតឡើងព្រោះផស្សៈនោះ) សេចក្តីថា តណ្ហារមែងចាក់ស្រែះ គឺ ភ្ជាប់នូវផស្សៈ និងការកើតឡើងព្រោះផស្សៈ

ដែលរាប់ថា ជាអត្តភាពទាំងពីរនោះ ។ ព្រោះហេតុអ្វី ។ ព្រោះធ្វើភព នោះៗ ឯង ឲ្យកើតឡើង អធិប្បាយថា ប្រសិនបើតណ្ហាមិនគប្បីចាក់ស្រេះ (ផស្សៈ និងការកើតឡើងព្រោះផស្សៈ) សោត ភពនោះៗ ឯងក៏មិនគប្បី កើតឡើង ។ ក្នុងទីនេះ អ្នកប្រាជ្ញទាំងឡាយបានសំដែងការប្រៀបធៀបរវាង ចំណែកទីបំផុតនឹងចំណែកកណ្តាលទុក ។ ទីបំផុត (ខាងចុង) នៃឈើ ២ កំណាត់[១] ដែលបុគ្គលយកខ្សែចងត្រង់កណ្តាល ធ្វើឲ្យជាកំណាត់តែមួយ គេហៅថា កណ្តាល ។ កាលខ្សែដាច់ ឈើទាំងពីរកំណាត់ក៏នឹងធ្លាក់ទៅ ជាពីរចំណែក ក្នុងសេចក្តីនេះក៏ដូច្នោះ ចំណែកបំផុត ២ យ៉ាង មានប្រការ ដូចពោលហើយ ប្រៀបដូចឈើ ២ កំណាត់ តណ្ហាប្រៀបដូចជាខ្សែចង (ឈើ) កាលតណ្ហារលត់ ទីបំផុតទាំងពីរក៏រលត់ដែរ ប្រៀបដូចកាលខ្សែ ដាច់ ឈើទាំង ២ កំណាត់ក៏នឹងធ្លាក់ទៅជាពីរចំណែក ។

បទថា **ឯត្តាវតា** (ព្រោះហេតុប៉ុណ្ណោះ) អធិប្បាយថា ដោយហេតុ ត្រឹមតែប៉ុណ្ណោះ គឺ ដោយការដឹងទីបំផុតទាំងពីរហើយ មិនត្រូវតណ្ហាចាប់

(១) បិដកប្រែថា ប្រៀបធៀបដោយគ្រាប់ព្រួញ ...។ល។

ទុកត្រង់កណ្តាលនេះ ភិក្ខុទើបឈ្មោះថា ដឹងធម៌ដ៏ក្រៃលែង គឺ សច្ចៈ ៤ ដែលគួរដឹងក្រៃលែង ឈ្មោះថា កំណត់ដឹងសច្ចៈដែលជាលោកិយៈទាំងពីរ ដែលគួរកំណត់ដឹងដោយតីរណបរិញ្ញា និងបហានបរិញ្ញា ។ បទថា **ទិដ្ឋេវ ធម្មេ (ក្នុងបច្ចុប្បន្ននោះឯង)** បានដល់ ក្នុងអត្តភាពនេះឯង ។ បទថា **ទុក្ខស្សន្តករោ ហោតិ (ជាអ្នកធ្វើទីបំផុតនៃទុក្ខបាន)** បានដល់ ឈ្មោះថា រមែងជាអ្នកធ្វើទីបំផុតនៃវដ្តទុក្ខ គឺ ជាអ្នកធ្វើការកំណត់ការវិលវល់បាន ។

ក្នុងវារៈទី ២ មានអធិប្បាយដូចតទៅនេះ គប្បីជ្រាបឧបមាដោយអំណាចឈើ ៣ កំណាត់ ។ ពិតហើយ ឈើ ៣ កំណាត់ ដែលបុគ្គលយកខ្សែចងទុក កាលខ្សែដាច់ ឈើ ៣ កំណាត់ ក៏នឹងធ្លាក់ទៅក្នុងទី ៣ កន្លែង ក្នុងប្រការនេះក៏ដូច្នេះ គឺ ខន្ធដែលជាអតីត អនាគត និងបច្ចុប្បន្ន ប្រៀបដូចឈើ ៣ កំណាត់ , តណ្ហា ប្រៀបដូចខ្សែ ក៏តណ្ហានោះរមែងចាក់ស្រេះខន្ធដែលជាអតីតជាមួយខន្ធដែលជាបច្ចុប្បន្ន និងចាក់ស្រេះខន្ធដែលជាបច្ចុប្បន្នជាមួយខន្ធជាអនាគត កាលតណ្ហារលត់ ខន្ធដែលជាអតីត អនាគត និងបច្ចុប្បន្នក៏ជាការរលត់ដូចគ្នា ប្រៀបដូចកាលខ្សែដាច់ ឈើ

៣ កំណាត់ ក៏ធ្លាក់ទៅក្នុងទី ៣ កន្លែង ។

ក្នុងវារៈទី ៣ មានអធិប្បាយដូចតទៅនេះ បទថា **អទុក្ខមសុខា មជ្ឈេ (អទុក្ខមសុខវេទនាជាកណ្តាល)** សេចក្តីថា អទុក្ខមសុខវេទនា ឈ្មោះថា កណ្តាល ព្រោះតាំងនៅក្នុងរវាងវេទនា ២ យ៉ាង (សុខវេទនា និងទុក្ខ-វេទនា) ។ ព្រោះថា សុខ ឈ្មោះថានូវខាងក្នុងនៃទុក្ខ ឬថា ទុក្ខ ឈ្មោះថានៅខាងក្នុងនៃសុខ មិនមាន ។ បទថា **តណ្ហាសិព្វនី (តណ្ហាជាគ្រឿងចាក់ស្រែះ)** បានដល់ សេចក្តីក្តៅក្តៃន និងតម្រេកក្នុងវេទនាទាំងឡាយ ។ អធិប្បាយថា តណ្ហារមែងចូលទៅជំទាស់ក្នុងការលេតនៃវេទនា ព្រោះហេតុនោះ តណ្ហានោះទើបឈ្មោះថា ចាក់ស្រែះវេទនានោះទុក ។

ក្នុងវារៈទី ៤ មានអធិប្បាយដូចតទៅនេះ បទថា **វិញ្ញាណំ មជ្ឈេ (វិញ្ញាណជាចំណែកកណ្តាល)** សេចក្តីថា ទាំងបដិសន្ធិវិញ្ញាណ ទាំងវិញ្ញាណដ៏សេស ឈ្មោះថា ជាកណ្តាលនៃនាម និងរូប ព្រោះកើតឡើងជាបច្ច័យនៃនាម និងរូប ។

ក្នុងវារៈទី ៥ មានអធិប្បាយដូចតទៅនេះ បទថា **វិញ្ញាណំ មជ្ឈេ**

(វិញ្ញាណជាចំណែកកណ្តាល) សេចក្តីថា កម្មវិញ្ញាណ ឈ្មោះថាជាចំណែកកណ្តាល ។ មួយវិញទៀត វិញ្ញាណប្រភេទណាមួយ ក្នុងទីនេះ ឈ្មោះថាជាចំណែកកណ្តាល ព្រោះក្នុងបណ្តាលអាយតនៈខាងក្នុង (ចំពោះ) មនាយតនៈ (អាយតនៈ គឺ ចិត្ត) ទទួលយកកម្មទុក ។ មួយវិញទៀត ជវនវិញ្ញាណ ឈ្មោះថាជាចំណែកកណ្តាល ព្រោះមនោទ្វារាវជ្ជនៈ (ការបង្វែរនទីកក្នុងមនោទ្វារ) អាស្រ័យអាយតនៈខាងក្នុង ។

ក្នុងវារៈទី ៦ មានអធិប្បាយដូច្នេះ បទថា *សក្កាយោ* (*សក្កាយៈ*) បានដល់ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា *សក្កាយសមុទយោ* (*ហេតុកើតសក្កាយៈ*) បានដល់ សមុទយសច្ចៈ ។ បទថា *សក្កាយនិរោធោ* (*ការរលត់សក្កាយៈ*) បានដល់ និរោធសច្ចៈ ។ បទថា *បរិយាយេន* (*ដោយបរិយាយ*) គឺ ដោយហេតុនោះៗ ។ បទដ៏សេសគប្បីជ្រាបតាមន័យដែលពោលហើយក្នុងទីគ្រប់កន្លែងចុះ ។

ចប់អដ្ឋកថា ឆាភយនសូត្រទី ៧

# អដ្ឋកថា ឧទកសូត្រទី ៨

## (ទ្រង់កំណត់ដឹងចិត្តដោយចិត្តដើម្បីដឹងបុគ្គល)

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧទកសូត្រទី ៨ ដូចតទៅនេះ ៖

[៦២] បទថា **អញ្ញតរោ (ភិក្ខុ) មួយរូប** បានដល់ ភិក្ខុមួយរូបជាបក្ខពួករបស់ព្រះទេវទត្ត ។ បទថា **សមន្នាហរិត្វា (ទ្រង់កំណត់ដឹង)** បានដល់ ទ្រង់បង្អោនទឹក ។ ភិក្ខុនោះសួររឿងនេះ ក៏ដោយបំណងថា ព្រះមានព្រះភាគទ្រង់ជ្រាបហើយត្រាស់ ឬមិនទ្រង់ជ្រាប ត្រាស់ជាឯកង្សិកព្យាករណ៍ (ត្រាស់ដោយព្រះអង្គឯងតែម្យ៉ាង) ឬថា ត្រាស់ជាវិភជ្ជព្យាករណ៍ (ចំណែកត្រូវឆ្លើយ) ។ បទថា **អបាយិកោ (នឹងត្រូវកើតក្នុងអបាយ)** បានដល់ ជាអ្នកទៅកើតក្នុងអបាយ ។ **នេរយិកោ (ធ្លាក់នរក)** បានដល់ ទៅកាន់នរក ។ បទថា **កប្បដ្ឋោ (តាំងនៅអស់ ១ កប្ប)** បានដល់ នឹងតាំងនៅ (ក្នុងនរក) រហូតអស់កប្ប ព្រោះបានធ្វើកម្មដែលជាហេតុឲ្យតាំងនៅរហូតអស់កប្បទុក ។ បទថា **អតេកិច្ឆោ (កែខៃមិនបាន)** បានដល់ មិនអាចនឹងកែខៃបាន ។

បទថា **ទ្វេជ្ឈំ** (ចំណែកពីរ) បានដល់ ភាវៈជាពីរចំណែក ។ បទថា **វាលគ្គកោដិ និត្តុទ្ទនមត្តំ** (សូម្បីប្រមាណស្មើដោយរោមនៃចុងរោមទ្រាយ) បានដល់ នឹងសំដែងប្រមាណបានដោយចុងរោមទ្រាយ ឬត្រឹមតែយកចុងរោមទ្រាយចាក់ចុះ ។ បទថា **បុរិសិន្ទ្រិយញ្ញាណានិ** (ញាណជាគ្រឿងកំណត់ដឹងឥន្ទ្រិយរបស់បុរស) បានដល់ ញាណជាគ្រឿងដឹងនូវភាពចាស់ក្លា និងទន់ខ្សោយនៃឥន្ទ្រីយ៍របស់បុគ្គលទាំងឡាយ អធិប្បាយថា ញាណជាគ្រឿងបង្អោននឹកដល់ឥន្ទ្រីយ៍ទាំងឡាយចាស់ក្លា និងទន់ខ្សោយ ។ បទថា **វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មា** (កុសលធម៌ក្តី អកុសលធម៌ក្តី... មានហើយ) សេចក្តីថា តថាគតដឹងថា កុសលធម៌ (របស់បុគ្គលនេះ) មានប៉ុណ្ណេះ អកុសលធម៌មានប៉ុណ្ណេះ ។ បទថា **អន្តរហិតា** (វិនាសទៅ) បានដល់ សូម្បីការមើលមិនឃើញ ។ បទថា **សម្មុខីភូតា** (ប្រាកដឡើងចំពោះមុខ) បានដល់ កើតប្រាកដដោយអំណាចការផ្សាយឡើង ។ បទថា **កុសលមូលំ** (កុសលមូល) បានដល់ អធ្យាស្រ័យដែលជាកុសល ។ បទថា **កុសលា-កុសលំ** (កុសល និងអកុសល) កុសលសូម្បីយ៉ាងដទៃ នឹងកើតឡើងពី

អធ្យាស្រ័យដែលជាកុសល ។

បទថា *សារវន្តានិ* (កើតក្នុងសារទរដូវ) បានដល់ កាន់យកសារៈបាន គឺ មានសារៈដែលបុគ្គលកាន់យកបាន ឬកើតឡើងក្នុងខែសារទៈ ។ បទថា *សុខសយិតានិ* (រក្សាទុកល្អហើយ) បានដល់ រក្សាទុកដ៏សមគួរហើយ ។ បទថា *សុខេត្តេ* (ក្នុងស្រែល្អ) បានដល់ ក្នុងស្រែដែលសម្បូរដោយជីជាតិ ។ បទថា *និក្ខិត្តានិ* (ដែលបុគ្គលដាំ) បានដល់ ដែលព្រោះចុះ ។ បទថា *សមប្បជិកាតា* (ដែលស្រោចស្រពដៀងគ្នា) បានដល់ ដែលឃើញស្មើគ្នា ។ បទថា *អភិទោសអឌ្ឍរត្តំ* (ក្នុងវេលាកណ្ដាលយប់) បានដល់ ក្នុងវេលាជិតពាក់កណ្ដាលរាត្រី គឺ កាលពាក់កណ្ដាលយប់ប្រាកដចំពោះមុខ ។ បទថា *ភត្តកាលសមយេ* (ក្នុងវេលាសោយព្រះក្រយាហាររបស់រាជត្រកូល) បានដល់ ក្នុងសម័យ ពោលគឺ វេលាសោយព្រះក្រយាហាររបស់រាជត្រកូលទាំងឡាយ ។

សួរថា នរណាដែលព្រះមានព្រះភាគទ្រង់ជ្រាបយ៉ាងនេះថា *បរិហានធម្មោ* (អ្នកវិនាស... ជាធម្មតា) ។

ឆ្លើយថា ព្រះបាទអជាតសត្រូវ ព្រោះថា ព្រះបាទអាជាតសត្រូវនោះ អាស្រ័យបាបមិត្រ ទ្រង់វិនាសចាកមគ្គផល ។ ចំណែកបុគ្គលដទៃ មានព្រះបាទសុប្បពុទ្ធៈ និងសុនក្ខត្តៈជាដើម ព្រះមានព្រះភាគក៏ទ្រង់ជ្រាបដូចគ្នា ។

សួរថា នរណាដែលព្រះមានព្រះភាគទ្រង់ជ្រាបយ៉ាងនេះថា **អបរិហានធម្មោ (អ្នកមិនវិនាស... ជាធម្មតា)** ។

ឆ្លើយថា សុសិមបរិព្វាជក និងបុគ្គលដទៃដែល (មានឧបនិស្ស័យ) ដូច្នេះ ។

សួរថា នរណាដែលព្រះមានព្រះភាគទ្រង់ជ្រាបយ៉ាងនេះថា **បរិនិព្វាយិស្សតិ (នឹងបរិនិព្វាន)** ។

ឆ្លើយថា សន្តតិមហាមាត្យ និងបុគ្គលដទៃដែល (មានឧបនិស្ស័យ) ដូច្នេះ ។

ចប់អដ្ឋកថា ឧទកសុត្រទី ៨

# អដ្ឋកថា និព្វេធិកសូត្រទី ៩

## (ធម្មបរិយាយជាហេតុជម្រះកិលេស)

គប្បីជ្រាបវិនិច្ឆ័យក្នុង និព្វេធិកសូត្រទី ៩ ដូចតទៅនេះ ៖

[៦៣] បទថា **និព្វេធិកបរិយាយោ** (ជាផ្លូវនៃការជម្រះកិលេស) ដោយចំពោះ គឺ ទម្លាយកងលោភៈជាដើម ដែលមិនធ្លាប់បំផ្លាញ មិនធ្លាប់ត្រូវទម្លាយមកអំពីកាលមុន អធិប្បាយថា ហេតុនៃការទម្លុះទម្លាយ ។ ក្នុងបទថា **និទានសម្ភវោ** (ហេតុនាំឲ្យកើត) មានវិគ្រោះដូច្នេះ ឈ្មោះថា **និទាន** ព្រោះអត្ថថា បង្អោនឲ្យដល់កាម គឺ ប្រគល់ឲ្យ ដោយភាពជាហេតុឲ្យកើតឡើង ។ ធម៌ឈ្មោះថា **សម្ភវៈ** ព្រោះអត្ថថា ជាដែនកើត ។ សម្ភវៈ គឺ និទាន ឈ្មោះថា **និទានសម្ភវៈ** (ហេតុកើត) ។ បទថា **វេមត្តតា** (សេចក្តីផ្សេងគ្នា) បានដល់ ហេតុផ្សេងៗ គ្នា ។

បទថា **កាមគុណា** (កាមគុណ) ឈ្មោះថា កាម ដោយអត្ថថា ដឹកនាំឲ្យប្រាថ្នា ឈ្មោះថា គុណ ដោយអត្ថថា ចងទុក ។ ដូចក្នុងពាក្យជាដើមថា **អន្តគុណំ** ។ បទថា **ចក្ខុវិញ្ញេយ្យា** (គួរដឹងដោយភ្នែក) បានដល់

ដែលគប្បីឃើញបានដោយចក្ខុវិញ្ញាណ ។ បទថា **ឥដ្ឋា** (គួរប្រាថ្នា) បានដល់ នឹងប្រាថ្នាបាន ឬមិនបានក៏ដោយ អធិប្បាយថា ជាអារម្មណ៍ដែលល្អ ។ បទថា **កន្តា** (ជាទីត្រេកអរ) បានដល់ ជារបស់គួរប្រាថ្នា ។ បទថា **មនាបា** (ជាទីពេញចិត្ត) បានដល់ ជាទីចម្រើនចិត្ត ។ បទថា **បិយរូបា** (ជាទីស្រលាញ់) បានដល់ មានភាពគួរស្រឡាញ់ ។ បទថា **កាមូបសំហិតា** (ប្រកបដោយកាម) បានដល់ កាមដែលកើតឡើង ព្រោះធ្វើរូបឲ្យជាអារម្មណ៍ទាក់ទាញហើយ ។ បទថា **រជនីយា** (នាំឲ្យកើតតម្រេក) បានដល់ ជាហេតុនៃការកើតឡើងនូវរាគៈ ។ បទថា **នេតេ កាមា** (វត្ថុទាំងនេះមិនឈ្មោះថា កាម) បានដល់ រូបជាដើមទាំងនេះ បានឈ្មោះថា កាម ដោយអត្ថថា ប្រាថ្នា ក៏មិនមែន ។

បទថា **សង្កប្បរាគោ** (តម្រេកដែលកើតដោយអំណាចការត្រិះរិះ) បានដល់ រាគៈដែលកើតឡើងដោយអំណាចនៃសេចក្តីត្រិះរិះ ។ បទថា **កាមោ** (ឈ្មោះថាកាម) បានដល់ រាគៈដែលកើតឡើងហើយនេះ បុគ្គលបដិបត្តិដើម្បីលះកាម ចាំបាច់ត្រូវលះ ។ រូបជាដើម ឈ្មោះថា **កាម** ព្រោះ

អត្ថថា ជាហេតុប្រាថ្នា ។ បទថា **ចិត្រានិ** (ដ៏វិចិត្រ) បានដល់ អារម្មណ៍ដែលវិចិត្រល្អ ។

បទថា **ផស្សា** (ផស្សៈ) បានដល់ ផស្សៈដែលកើតឡើងព្រមគ្នា ។ បទថា **កាមយមានោ** (បុគ្គលប្រាថ្នាហើយ) បានដល់ អ្នកប្រាថ្នាកាម ។ បទថា **តជ្ជំ តជ្ជំ** (ដែលកើតពីសេចក្តីប្រាថ្នានោះៗ) បានដល់ដែលកើតឡើងពីកាមនោះៗ ។ បទថា **បុញ្ញភាគិយំ** (ជាចំណែកបុណ្យ) ជាដើម សេចក្តីថា អត្តភាពរបស់បុគ្គលដែលប្រាថ្នាកាមជាទិព្វ ហើយកើតក្នុងទេវលោក ព្រោះសុចរិតធម៌បរិបូណ៌ ឈ្មោះថា **ជាចំណែកបុណ្យ** អត្តភាពរបស់បុគ្គលកើតក្នុងអបាយ ព្រោះទុច្ចរិតកម្មបរិបូណ៌ ឈ្មោះថា **ចំណែកមិនមែនបុណ្យ** ។ បទថា **អយំ វុច្ចតិ ភិក្ខវេ កាមានំ វិបាកោ (នេះហៅថា វិបាកនៃកាម)** សេចក្តីថា អត្តភាពទាំងពីរយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ថា ជាវិបាករបស់កាម ព្រោះអាស្រ័យសេចក្តីប្រាថ្នាកាមកើតឡើង ។ បទថា **សោ ឥមំ និព្វេធិកំ (ដែលប្រព្រឹត្តទៅក្នុងចំណែកនៃការជម្រះកិលេស)** បានដល់ ភិក្ខុនោះរមែងដឹងចរិយាដ៏ប្រសើរនេះ ដែល

ជាគ្រឿងទំលុះទម្លាយឋានៈ ៣៦ យ៉ាង ។ បទថា **កាមនិរោធំ (ជាទីរលត់កាម)** បានដល់ ដែលបានឈ្មោះយ៉ាងនេះ ព្រោះកាមទាំងឡាយរលត់ ។ ព្រោះថា ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ហៅមគ្គ ពោលគឺ ព្រហ្មចរិយៈ នោះថា **ជាទីរលត់កាម** ។

បទថា **សាមិសា (ដែលលាយដោយអាមិស)** បានដល់ ដែលសម្បយុត្តដោយអាមិស គឺ កិលេស ។ គប្បីជ្រាបសេចក្តីដោយន័យនេះ ក្នុងគ្រប់ៗ ឋានៈ (ភាវៈ) ។ម្យ៉ាងទៀត បទថា **វោហារវេបក្កំ**[១] **(មានវោហារជាផល)** បានដល់ ឲ្យផលជាពាក្យនិយាយ អធិប្បាយថា វោហារ ពោលគឺ ពាក្យសំដី ឈ្មោះថា វិបាករបស់សញ្ញា ។ បទថា **នំ** ក្នុងបទថា **យថា យថា នំ** នេះ ត្រឹមតែជានិបាតប៉ុណ្ណោះ ។ ដូច្នោះ ទើបមានអធិប្បាយថា ព្រោះហេតុដែលបុគ្គលចាំបានយ៉ាងណាៗ រមែងនិយាយយ៉ាងនោះៗ ដោយគិតថា យើងចាំបានយ៉ាងនេះ ដូច្នោះទើបឈ្មោះថា **មានពាក្យនិយាយជាផល** ។ បទថា **អវិជ្ជា (អវិជ្ជា)** បានដល់ អវិជ្ជាដ៏ក្រាស់

---

(១) បិដក = វោហារវេបក្កាហំ ។

ដែលមិនដឹងក្នុងឋានៈទាំង ៨ ។ អាសវៈទាំងឡាយ ឈ្មោះថា **និរយគមនិយា** (ជាហេតុឲ្យទៅកាន់នរក) ព្រោះអត្ថថា ឲ្យសត្វទៅនរក អធិប្បាយថា ជាហេតុនៃការកើតក្នុងនរក ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

បទថា **ចេតនាហំ** កាត់បទជា **ចេតនំ អហំ** (តថាគតពោលចេតនាថាជាកម្ម) ។ ក្នុងបទថា **ចេតនាហំ** នេះ ព្រះមានព្រះភាគទ្រង់សំដៅយកចេតនា ដែលមានការចាត់ចែង (សម្បយុត្តធម៌) ដែលរួមដល់ធម៌គ្រប់យ៉ាង (កុសលធម៌ អកុសលធម៌) ។ បទថា **ចេតយិត្វា** (គិតហើយ) បានដល់ចេតនាដែលប្រព្រឹត្តទៅក្នុងទ្វារ ។ បទថា **មនសា** (ដោយចិត្ត) បានដល់ដោយចិត្តដែលសម្បយុត្តដោយចេតនា ។ បទថា **និរយវេទនិយំ** (ដែលឲ្យផលក្នុងនរក) បានដល់ ដែលឲ្យវិបាកក្នុងនរក ។ សូម្បីក្នុងពាក្យទាំងឡាយដ៏សេស ក៏មានន័យនេះឯង ។

បទថា **អធិមត្តំ** (ទុក្ខយ៉ាងខ្លាំង) បានដល់ ទុក្ខដ៏មានកម្លាំង ។ បទថា **ទន្ធវិរាគំ** (ទុក្ខក្រសាយ) បានដល់ ទុក្ខធ្ងន់ គឺ ទុក្ខដែលរសាយទៅមិនរហ័ស បានដល់ យូរៗ ទើបរសាយ ។ បទថា **ឱរត្តាឡ្ហី កន្ទតិ**

(គក់ទ្រូង កន្ទក់កន្ទេញ) បានដល់ មានមុខឱនចុះយំខ្សឹកខ្សួល ។ បទថា បរិយេដ្ឋឹ (ស្វែងរក) បានដល់ ការស្វែងរក ។ បទថា ឯកបទំ ទ្វិបទំ (ផ្លូវមួយ ឬផ្លូវពីរ) បានដល់ ដឹងត្រឹមតែផ្លូវមួយ ឬផ្លូវពីរ អធិប្បាយថា នរណាទីងដឹងប្រមាណ[១] ។ បទថា សម្មោហវេបក្កំ (មានសេចក្តីវង្វេងជាផល) បានដល់ ឲ្យផលជាសេចក្តីវង្វេង (វេងវោង) ។ អធិប្បាយថា ការវេងវោង ឈ្មោះថា ជាផលហូរចេញពីទុក្ខ ។ សូម្បីក្នុងបទទាំងពីរ ក៏មានន័យនេះឯង ។ ព្រោះថា សូម្បីការស្វែងរក ក៏ជាផលហូរចេញពីទុក្ខនោះ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ទុកទាំងចំណែកវដ្ដៈ និងចំណែកវិវដ្ដៈ ។

ចប់អដ្ឋកថា និព្វេធិកសូត្រទី ៩

---

(១) មន្តបទ១ ឬមន្តបទ២ អធិប្បាយថា នរណាដឹងដឹងមន្តខ្លះ ។

# អដ្ឋកថា ពលសូត្រទី ១០

## (កម្លាំងព្រះតថាគត ៦ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង ពលសូត្រទី ១០ ដូចតទៅនេះ ៖

[៦៤] បទថា **អាសភណ្ឋានំ (ឋានៈរបស់អ្នកអង់អាច)** បានដល់ឋានៈដ៏ប្រសើរបំផុត គឺ ឋានៈដែលមិនញាប់ញ័រ ។ បទថា **សីហនាទំ (សីហនាទ)** បានដល់ ការបន្លឺយ៉ាងក្លៀវក្លា គឺ បន្លឺក្នុងឋានៈជាប្រមុខ ។ បទថា **ព្រហ្មចក្កំ (ព្រហ្មចក្រ)** បានដល់ ចក្រ គឺ ញាណដ៏ប្រសើរ គឺបដិវេធញាណ និងញាណដ៏សេស ។ បទថា **ឋានញ្ច ឋានតោ (នូវឋានៈតាមឋានៈ)** បានដល់ នូវហេតុដោយភាពជាហេតុ ។ បទថា **យម្បិ** បានដល់ ដោយញាណណា ។ បទថា **ឥទម្បិ តថាគតស្ស (សូម្បី... នេះជាកម្លាំងរបស់ព្រះតថាគត)** បានដល់ ឋានាឋានញ្ញាណសូម្បីនេះ ឈ្មោះថាជាកម្លាំងរបស់ព្រះតថាគត ។ សូម្បីក្នុងបទទាំងពួង ក៏គប្បីជ្រាបសេចក្តីយ៉ាងនេះ ។

បទថា **កម្មសមាទានានំ (នៃកម្មសមាទាន)** បានដល់ កុសលកម្ម

និងអកុសលកម្មដែលបុគ្គលតាំងចិត្តធ្វើហើយ ។ មួយវិញទៀត កម្មនោះឯង ឈ្មោះថា កម្មសមាទាន ។ បទថា **ឋានសោ ហេតុសោ (ដោយបច្ច័យ ដោយហេតុ)** បានដល់ ទាំងដោយបច្ច័យ ទាំងដោយហេតុ ។ បណ្ដាបច្ច័យ និងហេតុទាំងពីរយ៉ាងនោះ **គតិ** (កំណើតមាននរកជាដើម) **ឧបធិ (អត្តភាព រាងកាយ) កាល** (វេលាដែលកម្មឲ្យផល) **បយោគៈ** (ការព្យាយាមប្រកប) ជាឋានៈរបស់វិបាក កម្មជាហេតុរបស់វិបាក ។ បទថា **ឈានវិមោក្ខស-មាធិសមាបត្តីនំ (នៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ)** បានដល់ ឈាន ៤ វិមោក្ខ ៨ សមាធិ ៣ អនុបុព្វសមាបត្តិ ៩ ។ បទថា **សង្កិលេសំ (សេចក្ដីសៅហ្មង)** បានដល់ ធម៌ដែលជាចំណែកនៃសេចក្ដីវិនាស ។ បទថា **វោទានំ (សេចក្ដីផូរផង់)** បានដល់ ធម៌ដែលជាចំណែកនៃគុណវិសេស ។ បទថា **វុដ្ឋានំ (ការចេញចាក)** បានដល់ ឈានដែលជំនាញ ដែលត្រាស់ទុកយ៉ាងនេះថា "សូម្បីសេចក្ដីផូរផង់ ក៏ឈ្មោះថា ការចេញចាក សូម្បីការចេញចាកសមាធិនោះៗ ក៏ឈ្មោះថា ការចេញចាក" ១ ភវង្គ និងផល-សមាបត្តិ ១ ។ ព្រោះថា ឈានដែលជំនាញថ្នាក់ទាបៗ ជាឫសគល់របស់

ឈានជាន់ខ្ពស់ៗ ឡើងទៅ ព្រោះដូច្នោះ ទើបត្រាស់ថា សូម្បីសេចក្ដីដូវផង់ ក៏ឈ្មោះថា ការចេញចាក ។ ចំណែកការចេញចាកឈានទាំងពួង រមែងមានដោយភវង្គ ។ ការចេញចាកនិរោធសមាបត្តិ រមែងមានបានដោយផលសមាបត្តិ ។ ព្រះពុទ្ធវចនៈថា "សូម្បីការចេញចាកសមាបត្តិនោះៗ ក៏ឈ្មោះថា ការចេញចាក" ទ្រង់ត្រាស់ទុកសំដៅយកការចេញនោះ ។

បទថា **អនេកវិហិតំ (ជាច្រើនប្រការ)** ជាដើម បានពណ៌នាទុកហើយក្នុងវិសុទ្ធិមគ្គ ។ **អាសវក្ខយញាណ** ក៏មានន័យដូចដែលធ្លាប់ពោលទុកហើយនោះឯង ។ អ្នកប្រាថ្នានឹងជ្រាបសេចក្ដីពិស្ដាររបស់ញាណទាំង ៣ ខាងដើម គប្បីមើលសេចក្ដីដែលពណ៌នាទុកក្នុងមហាសីហនាទសូត្រ ក្នុងអដ្ឋកថាមជ្ឈិមនិកាយចុះ ។ បទថា **សមាហិតស្ស (របស់បុគ្គលដែលមានចិត្តតាំងមាំ)** បានដល់ របស់អ្នកមានចិត្តមានអារម្មណ៍តែមួយ ។ បទថា **សមាធិ មគ្គោ (សមាធិជាផ្លូវត្រូវ)** បានដល់ សមាធិជាឧបាយដើម្បីសម្រេចឈានទាំងនេះ ។ ការមិនមានចិត្តមានអារម្មណ៍តែមួយ ឈ្មោះថា **អសមាធិ (ការមិនមានសមាធិ)** ។ ផ្លូវដែលខុស ឈ្មោះថា **កុម្មគ្គោ (ជាផ្លូវខុស)** ក្នុង

-២១៣- មហាវគ្គទី ១ អដ្ឋកថា ពលសូត្រទី ១០

*ព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់កម្លាំងញាណរបស់ព្រះតថាគត ។*

ចប់អដ្ឋកថា ពលសូត្រទី ១០

## ចប់មហាវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# ទេវតាវគ្គវណ្ណនាទី ២

## អដ្ឋកថា អនាគាមិសូត្រទី ១

*(បុគ្គលគួរ និងមិនគួរសម្រេចអនាគាមិផល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនាគាមិសូត្រទី ១ ដូចតទៅនេះ ៖*

[៦៥] *បទថា **អស្សទ្ធិយំ** (ភាពជាអ្នកមិនមានសទ្ធា) បានដល់ ភាពជាអ្នកមិនមានសទ្ធា ។ បទថា **ទុប្បញ្ញតំ** (ភាពជាអ្នកមានបញ្ញាទន់ខ្សោយ) បានដល់ ភាពជាអ្នកមិនមានប្រាជ្ញា ។*

ចប់អដ្ឋកថា អនាគាមិសូត្រទី ១

# អដ្ឋកថា អរហន្តសូត្រទី ២

*(បុគ្គលគួរ ឬមិនគួរសម្រេចព្រះអរហត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អរហន្តសូត្រទី ២ ដូចតទៅនេះ ៖*

[៦៦] *បទថា* **បមាទំ** *(សេចក្តីធ្វេសប្រហែស) បានដល់ ការនៅដោយប្រាសចាកសតិ ។*

ចប់អដ្ឋកថា អរហន្តសូត្រទី ២

# អដ្ឋកថា មិត្តសូត្រទី ៣

## *(គុណ និងទោសនៃការមានមិត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មិត្តសូត្រទី ៣ ដូចតទៅនេះ ៖*

[៦៧] *បទថា **អភិសមាចារិកំ** (អភិសមាចារិកវត្ត) បានដល់ ធម៌ដែលជាសមាចារ (មារយាទ) ខ្ពង់ខ្ពស់ គឺ សីល ដែលជាការបញ្ញត្តិ ដោយអំណាចនៃវត្ត ។ បទថា **សេក្ខធម្មំ** (សេក្ខធម៌) បានដល់ សីលដែលជាការបញ្ញត្តិដល់ព្រះសេក្ខៈ ។ បទថា **សីលានិ** (សីល) បានដល់ មហាសីល ៤ យ៉ាង ។*

ចប់អដ្ឋកថា មិត្តសូត្រទី ៣

# អដ្ឋកថា ឋានសូត្រទី ៤

## (ឋានៈដែលប្រព្រឹត្តទៅបាន និងមិនបាន)

គប្បីជ្រាបវិនិច្ឆ័យក្នុង ឋានសូត្រទី ៤ ដូចតទៅនេះ ៖

[៦៨] បទថា *សង្គណិការាមោ* (ពេញចិត្តប្រឡូកប្រឡល់ដោយពួក) បានដល់ រីករាយក្នុងការស្និទ្ធស្នាលដោយពួកគណៈ ។ បទថា *គណារាមោ* (រីករាយក្នុងគណៈ) ព្រោះអត្ថថា ត្រេកអរក្នុងគណៈ មានគណៈសិក្សាព្រះសូត្រជាដើម ឬក្នុងគណៈ ពោលគឺ បរិស័ទរបស់ខ្លួន ។ បទថា *បវិវេក* (ក្នុងវិវេក) បានដល់ កាយវិវេក ។ បទថា *ចិត្តស្ស និមិត្តំ* (និមិត្តនៃចិត្ត) បានដល់ និមិត្តរបស់សមាធិចិត្ត និងវិបស្សនាចិត្ត គឺអាការរបស់សមាធិ និងវិបស្សនា ។ បទថា *សម្មាទិដ្ឋឹ* (សម្មាទិដ្ឋិ) បានដល់ សមាទិដ្ឋិក្នុងវិបស្សនា ។ បទថា *សមាធឹ* (សមាធិ) បានដល់ មគ្គសមាធិ និងផលសមាធិ ។ បទថា *សញ្ញោជនានិ* (សញ្ញោជនៈ) បានដល់ សញ្ញោជនៈ ១០ យ៉ាង ។ បទថា *និព្វានំ* (និព្វាន) បានដល់ បរិនិព្វាន ដែលរកបច្ច័យមិនបាន ។

ចប់អដ្ឋកថា ឋានសូត្រទី ៤

# អដ្ឋកថា ទេវតាសូត្រទី ៥

*(ទេវតាក្រាបទូលធម៌ជាហេតុមិនឲ្យវិនាស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទេវតាសូត្រទី ៥ ដូចតទៅនេះ ៖*

[៦៩] *ភាវៈជាអ្នកប្រដៅងាយ ឈ្មោះថា សោវចស្សតា (ភាពជាអ្នកប្រដៅងាយ) ។ ភាពជាអ្នកមានមិត្រល្អ ឈ្មោះថា កល្យាណមិត្តតា (ភាពជាអ្នកមានមិត្រល្អ) ។ បទថា សត្ថុគារវោ (ជាអ្នកគោរពក្នុងព្រះសាស្ដា) បានដល់ ជាអ្នកប្រកបទៅដោយការគោរពក្នុងព្រះសាស្ដា ។ ក្នុងបទទាំងពួង ក៏មានន័យនេះ ។*

ចប់អដ្ឋកថា ទេវតាសូត្រទី ៥

# អដ្ឋកថា សតិសូត្រទី ៦

## (ឋានៈ និងអឋានៈចំពោះអ្នកមានសមាធិ)

គប្បីជ្រាបវិនិច្ឆ័យក្នុង សតិសូត្រទី ៦ ដូចតទៅនេះ ៖

[៧០] បទថា **ន សន្តេន** (មិនមាន“សមាធិ”ដែលស្ងប់) បានដល់ មិនស្ងប់ចាកកិលេសដែលជាសត្រូវទាំងឡាយ ។ បទថា **ន បណីតេន** (មិនមាន“សមាធិ”ដែលប្រណីត) បានដល់ មិនមែនដោយសមាធិ ដែលមិនក្តៅក្រហាយ ។ បទថា **ន បដិប្បស្សទ្ធិលទ្ធេន** (មិនមាន“សមាធិ”ដែលបានដោយសេចក្តីស្ងប់) បានដល់ ដែលមិនបាន គឺ ដែលមិនសម្រេចដោយការស្ងប់កិលេស ។ បទថា **ន ឯកោទិភាវាធិគតេន** (មិនមាន“សមាធិ”ដែលដល់ភាពជាអ្នកមានអារម្មណ៍តែមួយ) បានដល់ ដែលមិនចូលដល់ភាពជាអ្នកមានអារម្មណ៍តែមួយ ។

ចប់អដ្ឋកថា សតិសូត្រទី ៦

# អដ្ឋកថា សក្ខិសូត្រទី ៧

*(បុគ្គលគួរ និងមិនគួរជាសាក្សីក្នុងគុណវិសេស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សក្ខិសូត្រទី ៧ ដូចតទៅនេះ ៖*

[៧១] *បទថា* ***តត្រ តត្រ*** *(ក្នុងធម៌នោះៗ) បានដល់ ក្នុងគុណវិសេសនោះៗ ។ បទថា* ***សក្ខិភព្វតំ*** *(ជាអ្នកគួរជាសាក្សី) បានដល់ ភាពជាអ្នកប្រាកដប្រជា ។ បទថា* ***អាយតនេ*** *(កាលបើមានហេតុ) បានដល់ ក្នុងហេតុការណ៍ ។ ធម៌ទាំងឡាយ មានធម៌* ***ប្រព្រឹត្តក្នុងចំណែកនៃសេចក្ដីវិនាស*** *ជាដើម ខ្ញុំបានពណ៌នាទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា* ***អសក្កច្ចការី*** *(ជាអ្នកមិនធ្វើសេចក្ដីអើពើ) បានដល់ មិនធ្វើឲ្យល្អ គឺ មិនធ្វើដោយអើពើ ។ បទថា* ***អសប្បាយការី*** *(ជាអ្នកមិនធ្វើសេចក្ដីសប្បាយ) បានដល់ មិនធ្វើឲ្យជាទីសប្បាយ គឺ មិនធ្វើឲ្យជាធម៌មានឧបការៈ ។*

*ចប់អដ្ឋកថា សក្ខិសូត្រទី ៧*

# អដ្ឋកថា ពលសូត្រទី ៨

*(បុគ្គលមិនគួរសម្រេចការមានកម្លាំងក្នុងសមាធិ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពលសូត្រទី ៨ ដូចតទៅនេះ ៖*

[៧២] *បទថា* ***ពលតំ*** *(ការមានកម្លាំង) បានដល់ ភាពជាអ្នកមានកម្លាំង គឺ ភាពជាអ្នកមានរហ័សរហួន (ក្នុងសមាធិ) ។ បទថា* ***អសាតច្ចការី*** *(ជាអ្នកមិនឲ្យរឿយៗ) បានដល់ មិនធ្វើឲ្យជាប់តគ្នា ។ បទដ៏សេសមានន័យដូចដែលបានពោលហើយនោះឯង ។*

ចប់អដ្ឋកថា ពលសូត្រទី ៨

# អដ្ឋកថា បឋមឈានសូត្រទី ៩

## (បុគ្គលគួរ និងមិនគួរលុះបឋមឈាន)

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមឈានសូត្រទី ៩ ដូចតទៅនេះ ៖*

*[៧៣] បទថា **ន យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋោ ហោតិ** (រមែងជាទោស ដែលភិក្ខុមិនឃើញច្បាស់ដោយសម្មប្បញ្ញាតាមពិត) សេចក្ដីថា ទោសក្នុងវត្ថុកាម និងកិលេសកាម រមែងមិនមានទោសដល់ភិក្ខុឃើញច្បាស់ហើយដោយឈានបញ្ញា (បញ្ញាក្នុងលំដាប់ឈាន) តាមសេចក្ដីពិត ។*

ចប់អដ្ឋកថា បឋមឈានសូត្រទី ៩

# អដ្ឋកថា ទុតិយឈានសូត្រទី ១០

*(បុគ្គលគួរ និងមិនគួរល្មុះទុតិយឈាន)*

[៧៤] *ទុតិយឈានសូត្រទី ១០ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ទុតិយឈានសូត្រទី ១០

## ចប់ទេវតាវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# អរហន្តវគ្គវណ្ណនាទី ៣

## អដ្ឋកថា ទុក្ខសូត្រទី ១

*(ធម៌ធ្វើឲ្យជាទុក្ខ និងជាសុខ)*

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុក្ខសូត្រទី ៩ ដូចតទៅនេះ ៖

[៧៥] បទថា **សវិឃាតំ** (មានសេចក្តីចង្អៀតចង្អល់) បានដល់ ប្រកបដោយភាពចង្អៀតចង្អល់ គឺ មានឧបទ្ទវៈ ។ បទថា **សបរិឡាហំ** (ក្តៅក្រហាយ) បានដល់ មានសេចក្តីក្រវល់ក្រវាយ ដោយភាពក្រវល់ក្រវាយផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **បាដិកង្ខា** (គប្បីសង្ឃឹមបាន) បានដល់ គប្បីបាន គឺ បានពិតប្រាកដ ។

ចប់អដ្ឋកថា ទុក្ខសូត្រទី ១

# អដ្ឋកថា អរហត្តសូត្រទី ២

## (បុគ្គលគួរ និងមិនគួរលុះអរហត្តផល)

គប្បីជ្រាបវិនិច្ឆ័យក្នុង អរហត្តសូត្រទី ២ ដូចតទៅនេះ ៖

[៧៦] បទថា **មានំ (សេចក្តីប្រកាន់)** បានដល់ សេចក្តីប្រកាន់ (ខ្លួន) ដោយជាតិជាដើម ។ បទថា **ឱមានំ (ការប្រកាន់ខ្លួនថាថោកទាបជាងគេ)** បានដល់ សេចក្តីប្រកាន់ខ្លួនថា អញជាមនុស្សថោកទាបជាងគេ ។ បទថា **អតិមានំ (ការលើកតម្កើង)** បានដល់ សេចក្តីប្រកាន់ខ្លួនខ្ពង់ខ្ពស់ដ៏លើសលុប ។ បទថា **អធិមានំ (ការយល់ខុស)** បានដល់ ការប្រកាន់ថា បានសម្រេច (យ៉ាងនោះយ៉ាងនេះ) ។ បទថា **ថម្ភំ (រឹងត្អឹង)** បានដល់ ភាពជាអ្នករឹងត្អឹង ព្រោះសេចក្តីក្រោធ និងមានះ ។ បទថា **អតិនិបាតំ (ការមើលងាយខ្លួនឯងថាជាមនុស្សថោកទាប)** បានដល់ ការប្រកាន់នូវខ្លួនដែលថោកទាបថា យើងជាមនុស្សថោកទាប ។

ចប់អដ្ឋកថា អរហន្តសូត្រទី ២

# អដ្ឋកថា ឧត្តរិមនុស្សធម៌សូត្រទី ៣

## (បុគ្គលគួរ និងមិនគួរសម្រេចឧត្តរិមនុស្សធម្ម)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧត្តរិមនុស្សធម្មសូត្រទី ៣ ដូចតទៅនេះ ៖*

*[៧៧] បទថា **ឧត្តរិមនុស្សធម្មា** (ដ៏ក្រៃលែងជាងធម៌របស់មនុស្ស) បានដល់ ធម៌ដ៏ក្រៃលែងជាងធម៌របស់មនុស្ស ។ បទថា **អលមរិយញ្ញាណទស្សនវិសេសំ** (ញាណទស្សនៈដ៏វិសេស ដែលអាចធ្វើនូវភាពជាព្រះអរិយៈ) បានដល់ ញាណទស្សនវិសេស ដែលធ្វើមនុស្សឲ្យជាព្រះអរិយៈបាន អធិប្បាយថា បានដល់ មគ្គ ៤ ផល ៤ ។ បទថា **កុហនំ** (កុហក) បានដល់ រឿងកុហក ៣ យ៉ាង[១] ។ បទថា **លបនំ** (និយាយលើកដាក់) បានដល់ ការពោលលើកដាក់ ឬសង្កត់ ដោយភាពជាមនុស្សត្រូវការលាភ ។*

ចប់អដ្ឋកថា ឧត្តរិមនុស្សធម៌សូត្រទី ៣

(១) ខុ.មហានិ = ការកុហកដោយការសេពបច្ច័យ ១ , ការកុហកអាស្រ័យឥរិយបថ ១ , ការកុហកដោយការនិយាយលើកដាក់ ១ ។

# អដ្ឋកថា សុខសូត្រទី ៤

## (ធម៌ធ្វើឲ្យមានសេចក្ដីសុខ និងសោមនស្ស)

គប្បីជ្រាបវិនិច្ឆ័យក្នុង សុខសូត្រទី ៤ ដូចតទៅនេះ ៖

[៧៨] បទថា **យោនិ ចស្ស អារទ្ធា ហោតិ** *(និងរមែងជាអ្នកប្រារព្ធហេតុ)* បានដល់ និងហេតុរបស់លោកបរិបូណ៌ហើយ គឺ លោកផ្គងទុកហើយ ។ បទថា **ធម្មារាមោ** *(ជាអ្នកត្រេកអរក្នុងធម៌)* បានដល់ប្រសព្វសេចក្ដីត្រេកអរក្នុងធម៌ ។ ឈ្មោះថា **ភាវនារាមោ** *(ជាអ្នកត្រេកអរក្នុងភាវនា)* ព្រោះអត្ថថា ត្រេកអរក្នុងភាវនា ឬកាលភាវនាក៏ត្រេកអរ ។ បទថា **បហានារាមោ** *(ជាអ្នកត្រេកអរក្នុងលះ)* ព្រោះអត្ថថា ត្រេកអរក្នុងការលះ ឬកាលលះហើយក៏ត្រេកអរ ។ បទថា **បវិវេការាមោ** *(ជាអ្នកត្រេកអរក្នុងសេចក្ដីស្ងាត់)* ព្រោះអត្ថថា ត្រេកអរក្នុងការស្ងាត់ ៣ យ៉ាង ។ បទថា **អព្យាបជ្ឈារាមោ** *(ជាអ្នកត្រេកអរក្នុងការមិនព្យាបាទ)* ព្រោះអត្ថថា ត្រេកអរក្នុងការមិនបៀតបៀន គឺ ក្នុងការមិនមានទុក្ខ ។ បទថា **និប្បបញ្ចារាមោ** *(ជាអ្នកត្រេកអរក្នុងធម៌ដែលមិនយឺតយូរ)* ព្រោះអត្ថថា ត្រេកអរ

ក្នុងព្រះនិព្វាន ពោលគឺ ធម៌ដែលមិនមានកិលេសជាគ្រឿងយឹតយូរ ។

ចប់អដ្ឋកថា សុខសូត្រទី ៤

# អដ្ឋកថា អធិគមសូត្រទី ៥

## (បុគ្គលគួរ និងមិនគួរសម្រេចកុសលធម៌)

គប្បីជ្រាបវិនិច្ឆ័យក្នុង អធិគមសូត្រទី ៥ ដូចតទៅនេះ ៖

[៧៩] បទថា ន *អាយកុសលោ* (ជាអ្នកមិនឈ្លាសក្នុងហេតុនៃសេចក្តីចម្រើន) បានដល់ អ្នកមិនឈ្លាសក្នុងហេតុកើត (ទាំងកុសល និងអកុសល) ។ បទថា ន *អបាយកុសលោ* (ជាអ្នកមិនឈ្លាសក្នុងហេតុនៃសេចក្តីវិនាស) បានដល់ អ្នកមិនឈ្លាសក្នុងហេតុវលត់ (ទាំងកុសល និងអកុសល) ។ បទថា *ឆន្ទំ* (ឆន្ទៈ) បានដល់ សេចក្តីពេញចិត្ត គឺ ភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើ ។ បទថា ន *សារក្ខតិ* (មិនរក្សា) បានដល់ មិនថែរក្សា ។

ចប់អដ្ឋកថា អធិគមសូត្រទី ៥

# អដ្ឋកថា មហាវគ្គសូត្រទី ៦

## (អ្នកគួរសម្រេចភាពជាធំក្នុងធម៌)

គប្បីជ្រាបវិនិច្ឆ័យក្នុង មហាវគ្គសូត្រទី ៦ ដូចតទៅនេះ ៖

[៨០] បទថា *អាលោកពហុលោ (ជាអ្នកច្រើនដោយពន្លឺ)* បានដល់ ច្រើនទៅដោយពន្លឺនៃញាណ ។ បទថា *យោគពហុលោ (ជាអ្នកច្រើនដោយសេចក្ដីព្យាយាមជាគ្រឿងប្រកប)* បានដល់ ធ្វើសេចក្ដីព្យាយាមដ៏ច្រើន ។ បទថា *វេទពហុលោ (ជាអ្នកច្រើនទៅដោយសេចក្ដីរីករាយ)* បានដល់ ច្រើនទៅដោយបីតិ និងបាមោជ្ជៈ ។ បទថា *អសន្តុដ្ឋិពហុលោ (ជាអ្នកច្រើនទៅដោយសេចក្ដីមិនសន្ដោស)* បានដល់ អ្នកមិនសន្ដោសក្នុងកុសលធម៌ទាំងឡាយ ។ បទថា *អនិក្ខិត្តធុរោ (ជាអ្នកមិនលះធុរៈចោល)* បានដល់ អ្នកមិនដាក់ធុរៈ គឺ ផ្គងសេចក្ដីព្យាយាម ។ បទថា *ឧត្តរិញ្ច បតារេតិ (រមែងព្យាយាមក្រៃលែងឡើងទៅ)* បានដល់ ធ្វើសេចក្ដីព្យាយាមក្នុងពេលនេះឯងឲ្យក្រៃលែងឡើងៗ ។

ចប់អដ្ឋកថា មហាវគ្គសូត្រទី ៦

# អដ្ឋកថា បឋមនិរយសូត្រទី ៧

*(ធម៌ធ្វើឲ្យធ្លាក់នរក និងឡើងឋានសួគ៌)*

[៨១] *បឋមនិរយសូត្រទី ៧ ងាយយល់ហើយ ។*

ចប់អដ្ឋកថា បឋមនិរយសូត្រទី ៧

# អដ្ឋកថា ទុតិយនិរយសូត្រទី ៨

*(ធម៌ធ្វើឲ្យធ្លាក់នរក និងឡើងឋានសួគ៌)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយនិរយសូត្រទី ៨ ដូចតទៅនេះ ៖*

[៨២] *បទថា បគព្ភោ (ជាអ្នកឃ្នើសឃ្នង) បានដល់ ប្រកបដោយការឃ្នើសឃ្នងផ្លូវកាយជាដើម ។*

ចប់អដ្ឋកថា ទុតិយនិរយសូត្រទី ៨

# អដ្ឋកថា អគ្គធម្មសូត្រទី ៩

*(បុគ្គលគួរ និងមិនគួរសម្រេចធម៌ដ៏កំពូល)*

[៨៣] *អគ្គធម្មសូត្រទី ៩ ងាយហើយនោះឯង ។*

ចប់អដ្ឋកថា អគ្គធម្មសូត្រទី ៩

# អដ្ឋកថា រត្តិសូត្រទី ១០

*(បុគ្គលសង្ឃឹមបានសេចក្តីវិនាសក្នុងយប់ និងថ្ងៃដែលកន្លងមក)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង រត្តិសូត្រទី ១០ ដូចតទៅនេះ ៖*

[៨៤] *បទថា* ***វិឃាតវា*** *(មានសេចក្តីចង្អៀតចង្អល់) បានដល់ ជាអ្នកមានទុក្ខ ព្រោះទុក្ខកើតអំពីសេចក្តីលោភ ដែលអាស្រ័យសេចក្តីប្រាថ្នាច្រើនកើតឡើង ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ហើយ ។*

ចប់អដ្ឋកថា រត្តិសូត្រទី ១០

## ចប់អរហន្តវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# សីតិវគ្គវណ្ណនាទី ៤

## អដ្ឋកថា សីតិសូត្រទី ១

*(បុគ្គលគួរ និងមិនគួរធ្វើឲ្យច្បាស់នូវភាពជាអ្នកត្រជាក់)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីតិសូត្រទី ១ ដូចតទៅនេះ ៖*

[៨៥] *បទថា* ***សីតិភាវំ*** *(នូវភាពជាអ្នកត្រជាក់) បានដល់ ដល់នូវសេចក្តីត្រជាក់ ។ បទថា* ***យស្មឹ សមយេ ចិត្តំ និគ្គណ្ហិតព្វំ***[១] *(សម័យដែលគួរគ្របសង្កត់) ជាដើម មានអធិប្បាយដូចតទៅនេះ បណ្តាចិត្តគួរគ្របសង្កត់ទុកដោយសមាធិ ក្នុងវេលាដែលរាយមាយ ។ គួរផ្គងដោយសេចក្តីព្យាយាម ក្នុងវេលាដែលចិត្តធ្លាក់ទៅព្រោះកោសជ្ជៈ (ការខ្ជិលច្រអូស) ។ គួរឲ្យរីករាយដោយសមាធិ ក្នុងវេលាដែលចិត្តខ្វះភាពស្រស់ស្រាយ ។ គួរចូលទៅសម្លឹងដោយឧបេក្ខាសម្ពោជ្ឈង្គៈ ក្នុងវេលាដែលចិត្តប្រព្រឹត្តស្មើ ។*

ចប់អដ្ឋកថា សីតិសូត្រទី ១

---

(១) បិដក = យស្មឹ សមយេ ចិត្តំ និគ្គហេតព្វំ ។

# អដ្ឋកថា ភព្វសូត្រទី ២

## (បុគ្គលគួរ និងមិនគួរចូលដល់ធម៌)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភព្វសូត្រទី ២ ដូចតទៅនេះ ៖*

*[៨៦] បទថា **កម្មាវរណតាយ** (ដោយភាពជាអ្នកមានកម្មជាគ្រឿងរាំង) បានដល់ ព្រោះអនន្តរិយកម្មទាំង ៥ ។ បទថា **កិលេសាវរណតាយ** (ជាអ្នកមានកិលេសជាគ្រឿងរាំង) បានដល់ និយតមិច្ឆាទិដ្ឋិ ។ បទថា **វិបាកាវរណតាយ** (ជាអ្នកមានវិបាកជាគ្រឿងរាំង) បានដល់ ដោយបដិសន្ធិដែលជាអកុសលវិបាក ឬដោយអហេតុកបដិសន្ធិជាកុសលវិបាក (សន្តីរណៈដែលសហគតដោយឧបេក្ខាទាំងជាកុសល និងអកុសល) ។*

ចប់អដ្ឋកថា ភព្វសូត្រទី ២

# អដ្ឋកថា អាវរណតាសូត្រទី ៣

## (បុគ្គលគួរ និងមិនគួរចូលដល់ធម៌)

[៨៧] *សូត្រទី ៣ លោកមិនបានពណ៌នាទុក ។*

ចប់អដ្ឋកថា អាវរណាសូត្រទី ៣

# អដ្ឋកថា សុស្សូសាសូត្រទី ៤

## (អ្នកស្តាប់ដោយល្អគួរចូលដល់ធម៌)

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុស្សូសាសូត្រទី ៤ ដូចតទៅនេះ ៖*

[៨៨] *បទថា* **អនត្ថំ** *(វត្ថុដែលមិនជាប្រយោជន៍) បានដល់ វត្ថុដែលមិនចម្រើន ។ បទថា* **អត្ថំ វិញ្ចតិ** *(លះបង់វត្ថុដែលជាប្រយោជន៍) បានដល់ លះបង់ប្រយោជន៍ គឺ សេចក្តីចម្រើន ។ បទថា* **អននុលោមិកាយ** *(ដែលមិនសមគួរ) បានដល់ មិនធ្វើតាមពាក្យទូន្មាន ។*

ចប់អដ្ឋកថា សុស្សូសាសូត្រទី ៤

# អដ្ឋកថា បហាតព្វសូត្រទី ៥

*(ធម៌ដែលលះបង់ហើយធ្វើឲ្យលុះទិដ្ឋិសម្បទា)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បហាតព្វសូត្រទី ៥ ដូចតទៅនេះ ៖*

[៨៩] *បទថា ទិដ្ឋិសម្បទំ (ទិដ្ឋិសម្បទា) បានដល់ សោតាបត្តិមគ្គ ។*

ចប់អដ្ឋកថា បហាតព្វសូត្រទី ៥

# អដ្ឋកថា បហីនសូត្រទី ៦

*(ធម៌ដែលព្រះសោតាបន្នលះបានហើយ)*

[៩០] *សូត្រទី ៦ នេះ លោកមិនបានពណ៌នាទុកទេ ។*

ចប់អដ្ឋកថា បហីនសូត្រទី ៦

# អដ្ឋកថា ឧប្បាទេតព្វសូត្រទី ៧

*(ធម៌ដែលកើតឡើងដល់ព្រះសោតាបន្ន)*

[៩១] *សូត្រទី ៧ លោកមិនបានពណ៌នាទុកទេ ។*

ចប់អដ្ឋកថា ឧប្បាទេតព្វសូត្រទី ៧

# អដ្ឋកថា សត្តិសូត្រទី ៨

## (ឋានៈអ្នកគោរពព្រះសាស្តាជាដើម)

គប្បីជ្រាបវិនិច្ឆ័យក្នុង សត្តិសូត្រទី ៨ ដូចតទៅនេះ ៖

[៩២] បទថា *អនាគមនីយវត្ថុំ (រឿងដែលមិនគួរដល់)* បានដល់ហេតុដែលមិនគួរចូលដល់ ។ ក៏បទនេះ ជាឈ្មោះរបស់ពៀរ ៥ និងទិដ្ឋិ ៦២ ប្រការ ។ បទថា *អដ្ឋមំ ភវំ* (ភពទី ៨) បានដល់ បដិសន្ធិទី ៨ ក្នុងជាន់កាមាវចរ ។

ចប់អដ្ឋកថា សត្តិសូត្រទី ៨

# អដ្ឋកថា កពាសិសង្ខារសូត្រទី ៩

*(ឋានៈបុគ្គលមិនប្រកាន់សង្ខារអ្វីៗ ជាដើម)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កពាសិសង្ខារសូត្រទី ៩ ដូចតទៅនេះ ៖*

[៩៣] *បទថា* ***កោតុហលមង្គលេន*** *(ដោយមង្គលភ្ញាក់ផ្អើល) បាន ដល់ ដោយទិដ្ឋិមង្គល (ប្រកាន់វត្ថុដែលបានឃើញជាមង្គល) សុតមង្គល (ប្រកាន់វត្ថុដែលបានស្តាប់ជាមង្គល) មុតមង្គល (ប្រកាន់វត្ថុដែលបានជ្រាប ជាមង្គល) ។*

ចប់អដ្ឋកថា កពាសិសង្ខារសូត្រទី ៩

# អដ្ឋកថា មាតរិសូត្រទី ១០

## (ឋានៈបុគ្គលមិនគួរសម្លាប់មាតាជាដើម)

[៩៤] *អដ្ឋកថាសូត្រទី ១០ លោកមិនបានពណ៌នាទុកទេ ។*

ចប់អដ្ឋកថា មាតរិសូត្រទី ១០

# អដ្ឋកថា សយង្កតសូត្រទី ១១

*(សុខទុក្ខកើតឡើងព្រោះខ្លួនឯងធ្វើ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សយំកតសូត្រទី ១១ ដូចតទៅនេះ ៖*

[៩៥] *បទថា* ***សយំ កតំ*** *(ដែលខ្លួនឯងធ្វើហើយ) ជាដើម ព្រះមានព្រះភាគត្រាស់ហើយដោយអំណាចនៃអត្តទិដ្ឋិ (ការឃើញថាជាអត្តា) ។ បទថា* ***អធិច្ចសមុប្បន្នំ*** *(ដែលកើតឡើងឯង) បានដល់ ដែលកើតឡើងដោយរកហេតុមិនបាន ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយយល់ហើយ ។*

ចប់អដ្ឋកថា សយង្កតសូត្រទី ១១

## ចប់សីតិវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

# អានិសង្សវគ្គវណ្ណនាទី ៥

## អដ្ឋកថា ធាតុកាវសូត្រទី ១

*(សេចក្តីប្រាកដដែលរកបានលំបាក)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ធាតុកាវសូត្រទី ១ ដូចតទៅនេះ ៖*

[៩៦] *បទថា* ***អរិយាយតនេ*** *(ក្នុងប្រទេសជាទីនៅនៃព្រះអរិយៈ) បានដល់ ក្នុងមជ្ឈិមប្រទេស ។ បទថា* ***ឥន្ទ្រិយានំ*** *(ឥន្ទ្រិយ) បានដល់ ឥន្ទ្រិយដែលចិត្តជាគម្រប់ទី ៦ ។*

ចប់អដ្ឋកថា ធាតុកាវសូត្រទី ១

# អដ្ឋកថា អនិសង្សសូត្រទី ២

## *(អានិសង្សនៃសោតាបត្តិផល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានិសង្សសូត្រទី ២ ដូចតទៅនេះ ៖*

[៩៧] *បទថា **សទ្ធម្មនិយតោ** (ជាបុគ្គលតាំងមាំក្នុងព្រះសទ្ធម្ម) បានដល់ ជាអ្នកតាំងមាំក្នុងព្រះសទ្ធម្ម គឺ ពាក្យទូន្មាន ។ បទថា **អសាធារណេន** (មិនទូទៅ) បានដល់ (ប្រកបដោយញាណ) ដែលមិនទូទៅដល់បុថុជ្ជនទាំងឡាយ ។*

ចប់អដ្ឋកថា អានិសង្សសូត្រទី ២

## អដ្ឋកថា អនិច្ចសូត្រទី ៣

*(បុគ្គលឃើញសង្ខារជារបស់មិនទៀង)*

[៩៨] *ក្នុងសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា អនិច្ចសូត្រទី ៣

# អដ្ឋកថា ទុក្ខសូត្រទី ៤

## (បុគ្គលឃើញសង្ខារជាទុក្ខ)

[៩៩] ក្នុងសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្ដីទេ ។

ចប់អដ្ឋកថា ទុក្ខសូត្រទី ៤

# អដ្ឋកថា អនត្តសូត្រទី ៩

(បុគ្គលឃើញសង្ខារជារបស់អនត្តា)

[១០០] ក្នុងសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្ដីទេ ។

ចប់អដ្ឋកថា អនត្តសូត្រទី ៩

# អដ្ឋកថា និព្វានសូត្រទី ៦

*(បុគ្គលឃើញនិព្វានជាសុខ)*

*[១០១] ក្នុងសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា និព្វានសូត្រទី ៦

# អដ្ឋកថា បឋមអនោទិសសូត្រទី ៧

## (ការធ្វើមិនឲ្យមានខេត្តក្នុងសង្ខារទាំងពួង)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអនោទិសសូត្រទី ៧ ដូចតទៅនេះ ៖

[១០២] បទថា *អនោធឹ ករិត្វា* (ធ្វើមិនឲ្យមានខេត្តដែនកម្ចាត់) បានដល់ មិនធ្វើឲ្យមានខេត្ត គឺ ខេត្តយ៉ាងនេះថា សង្ខារមានប្រមាណប៉ុណ្ណេះឯងមិនទៀង ក្រៅអំពីនេះទៅ មិនមែនមិនទៀង (គឺទៀង) ។ បទថា *អនវត្ថិតតោ* (ដោយភាពជារបស់មិនខ្ជាប់ខ្ជួន) បានដល់ វៀរចាកឋានៈ (ហេតុដែលប្រព្រឹត្តទៅបាន) ដោយភាពជារបស់ខ្ជាប់ខ្ជួន អធិប្បាយថា នឹងប្រាកដជាសភាវធម៌ដែលបែកធ្លាយនោះឯង ។ បទថា *សព្វលោកេ* (ក្នុងលោកទាំងពួង) បានដល់ ក្នុងលោកទាំងអស់ បានដល់ ក្នុងលោកធាតុទាំង ៣ ។ បទថា *សាមញ្ញេន* (ដោយដែលធ្វើនូវភាពជាសមណៈ) បានដល់ ដោយភាពជាសមណៈ អធិប្បាយថា ដោយអរិយមគ្គ ។

ចប់អដ្ឋកថា បឋមអនោទិសសូត្រទី ៧

# អដ្ឋកថា ទុតិយអនោទិសសូត្រទី ៨

## *(ការធ្វើមិនឲ្យមានខេត្តក្នុងសង្ខារទាំងពួង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអនោទិសសូត្រទី ៨ ដូចតទៅនេះ ៖*

[១០៣] *បទថា* *មេត្តាវតាយ (ប្រកបដោយមេត្តា) បានដល់ ព្រោះការបដិបត្តិប្រកបដោយមេត្តា ។ ព្រោះថា ព្រះសេក្ខបុគ្គល ៧ ពួក រមែងបដិបត្តិព្រះតថាគត ដោយការទំនុកបម្រុងប្រកបទៅដោយមេត្តា ។ សូម្បីព្រះខីណាស្រព ក៏ជាអ្នកបដិបត្តិព្រះសាស្តា (ដូចគ្នា) ។*

ចប់អដ្ឋកថា ទុតិយអនោទិសសូត្រទី ៨

# អដ្ឋកថា តតិយអនោទិសសូត្រទី ៩

## *(ការធ្វើមិនឲ្យមានខេត្តក្នុងសង្ខារទាំងពួង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយអនោទិសសូត្រទី ៩ ដូចតទៅនេះ ៖*

[១០៤] *បទថា* ***អតម្មយោ*** *(ជាអ្នកមិនមានតណ្ហា និងទិដ្ឋិ) បានដល់ ជាអ្នកវៀរចាកតណ្ហា និងទិដ្ឋិ ដែលព្រះមានព្រះភាគត្រាស់ហៅថា តម្មយៈ ។ បទថា* ***អហំការា*** *(ទិដ្ឋិ... ដែលជាហេតុឲ្យធ្វើការប្រកាន់ខ្លួនថាយើង) បានដល់ ទិដ្ឋិ គឺ អហំការ (ការឃើញថាជាយើង) ។ បទថា* ***មមំការា*** *(តណ្ហាដែលជាហេតុឲ្យធ្វើការប្រកាន់ថាជារបស់យើង) បានដល់ តណ្ហា គឺ មមំការ (ការប្រកាន់ថារបស់អញ) ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា តតិយអនោទិសសូត្រទី ៩

# អដ្ឋកថា ភវសូត្រទី ១០

*(តែភព និងតែសិក្ខា)*

[១០៥] *ក្នុងសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា ភវសូត្រទី ១០

# អដ្ឋកថា តណ្ហាសូត្រទី ១១

*(តណ្ហា និងមានះ)*

[១០៦] *ក្នុងសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា តណ្ហាសូត្រទី ១១

## ចប់អានិសង្សវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៥ សូត្រ

## ចប់ទុតិយបណ្ណាសកៈ

# វគ្គមិនរួមចូលក្នុងបណ្ណាសកៈ

## តិកវគ្គវណ្ណនាទី ១

## អដ្ឋកថា រាគសូត្រទី ១

*(ធម៌ដែលគួរលះ មានរាគៈជាដើម)*

គប្បីជ្រាបវិនិច្ឆ័យក្នុង រាគសូត្រទី ១ ដូចតទៅនេះ ៖

[១០៧] បទថា **អសុភៈ** បានដល់ អសុភកម្មដ្ឋាន ។ បទថា **មេត្តា** បានដល់ មេត្តាកម្មដ្ឋាន ។ បទថា **បញ្ញា** បានដល់ មគ្គបញ្ញាព្រមដោយវិបស្សនា ។

ចប់អដ្ឋកថា រាគសូត្រទី ១

# អដ្ឋកថា ទុច្ចរិតសូត្រទី ២

*(ទុច្ចរិត និងសុចរិត)*

[១០៨] *ក្នុងសូត្រនេះ លោកមិនបានពណ៌នាទុកទេ ។*

ចប់អដ្ឋកថា ទុច្ចរិតសូត្រទី ២

# អដ្ឋកថា វិតក្កសូត្រទី ៣

*(អកុសលវិតក្ក និងកុសលវិតក្ក)*

[១០៩] *ក្នុងសូត្រនេះ លោកមិនបានពណ៌នាទុកទេ ។*

ចប់អដ្ឋកថា វិតក្កសូត្រទី ៣

# អដ្ឋកថា សញ្ញាសូត្រទី ៤

*(អកុសលសញ្ញា និងកុសលសញ្ញា)*

[១១០] *ក្នុងសូត្រនេះ លោកមិនបានពណ៌នាទុកទេ ។*

ចប់អដ្ឋកថា វិតក្កសូត្រទី ៣

# អដ្ឋកថា ធាតុសូត្រទី ៥

## (ធាតុដែលគួរលះ និងគួរចម្រើន)

[១១១] ក្នុងសូត្រនេះ លោកមិនបានពណ៌នាទុកទេ ។

ចប់អដ្ឋកថា ធាតុសូត្រទី ៥

# អដ្ឋកថា អស្សាទសូត្រទី ៦

## (ធម៌ដែលគួរលះ មានអស្សាទទិដ្ឋិជាដើម)

គប្បីជ្រាបវិនិច្ឆ័យក្នុង អស្សាទសូត្រទី ៦ ដូចតទៅនេះ ៖

[១១២] បទថា **អស្សាទទិដ្ឋិ** បានដល់ សស្សតទិដ្ឋិ ។ បទថា **អត្តានុទិដ្ឋិ** បានដល់ សក្កាយទិដ្ឋិ មានវត្ថុ ២០ ដែលប្រព្រឹត្តទៅតាមអត្តា ។ បទថា **មិច្ឆាទិដ្ឋិ** បានដល់ ទិដ្ឋិ ៦២ យ៉ាង ។ បទថា **សម្មាទិដ្ឋិ** បានដល់ សម្មាទិដ្ឋិក្នុងអរិយមគ្គ ។ម្យ៉ាងទៀត ទិដ្ឋិទាំងឡាយមានជាអាទិ៍ថា ទានដែលឲ្យហើយ មិនមានផល ឈ្មោះថា **មិច្ឆាទិដ្ឋិ** ។ កម្មស្សកតាញាណ ឈ្មោះថា **សម្មាទិដ្ឋិ** ។

ចប់អដ្ឋកថា អស្សាទសូត្រទី ៦

# អដ្ឋកថា អរតិសូត្រទី ៧

## *(ធម៌ដែលគួរលះ មានអរតិជាដើម)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អរតិសូត្រទី ៧ ដូចតទៅនេះ ៖*

[១១៣] *បទថា អធម្មចរិយា (ការមិនប្រព្រឹត្តធម៌) បានដល់ អកុសលកម្មបថ ១០ ។*

ចប់អដ្ឋកថា អរតិសូត្រទី ៧

# អដ្ឋកថា តុដ្ឋិសូត្រទី ៨

*(ធាតុដែលគួរបម្រើន មានការសន្តោសជាដើម)*

[១១៤] *ក្នុងសូត្រនេះ លោកមិនបានពណ៌នាទុកទេ ។*

ចប់អដ្ឋកថា តុដ្ឋិសូត្រទី ៨

# អដ្ឋកថា ទោវចស្សតាសូត្រទី ៩

*(ធាតុដែលគួរលះ មានការប្រដៅក្រជាដើម)*

[១១៥] *ក្នុងសូត្រនេះ លោកមិនបានពណ៌នាទុកទេ ។*

ចប់អដ្ឋកថា ទោវចស្សតាសូត្រទី ៩

# អដ្ឋកថា ឧទ្ធច្ចសូត្រទី ១០

*(ធាតុដែលគួរលះ មានឧទ្ធច្ចៈជាដើម)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧទ្ធច្ចសូត្រទី ១០ ដូចតទៅនេះ ៖*

[១១៦] *បទថា* ***អសំវរោ*** *(ការមិនសង្រួម) បានដល់ ភាពជាអ្នកមានការរក្សាមិនបាននូវ (ឥន្ទ្រិយទាំងឡាយ) ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា ឧទ្ធច្ចសូត្រទី ១០

## ចប់តិកវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៤ សូត្រ

# អដ្ឋកថា ដែលមិនរួមចូលក្នុងវគ្គ

គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១១៧-១៣០] បទថា *តបុស្សោ (តបុស្សៈ)* បានដល់ ឧបាសកអ្នកបញ្ចេញវាចាដល់ព្រះរតនត្រ័យ ២ ។ បទថា **តថាគតេ និដ្ឋង្គតោ** *(ជាអ្នកអស់សង្ស័យក្នុងព្រះតថាគត)* បានដល់ ជាអ្នកមានចិត្តតាំងមាំល្អហើយ គឺ លះសេចក្តីសង្ស័យបានហើយក្នុងព្រះពុទ្ធគុណ ។ ពិត្តុឈ្មោះថា **អមតទ្ទសោ** *(ឃើញអមតធម៌)* ព្រោះអត្ថថា បានឃើញអមតធម៌ ។ បទថា **អរិយេន** *(អរិយៈ)* បានដល់ លោកុត្តរសីលដែលមិនមានទោស ។ បទថា **ញាណេន** *(ញាណ)* បានដល់ ដោយបច្ចវេក្ខណញ្ញាណ ។ បទថា **វិមុត្តិយា** *(វិមុត្តិ)* បានដល់ ផលវិមុត្តិរបស់ព្រះសេក្ខៈ ។

បទថា **តវកណ្ណិកោ** *(តវកណ្ណិកៈ)* បានដល់ គហបតីដែលមានឈ្មោះយ៉ាងនេះ ។ បាលីថា **តបកណ្ណិកៈ** ដូច្នេះក៏មាន ។ បទថា **ភគស្ស** *(ភគៈ)* បានដល់ ភគៈដែលសម្បយុត្តដោយកាមគុណ ៥ ។ បទដ៏សេសក្នុងទីទាំងពួង មានសេចក្តីងាយយល់ហើយ ។

ចប់អដ្ឋកថា ដែលមិនរួមចូលក្នុងវគ្គ

ចប់អដ្ឋកថា

អង្គុត្តរនិកាយ ឆក្កនិបាត

ឈ្មោះ

មនោរថបូរណី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្រ្តាលី | $ 500 AUS |
| -ភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |